# អដ្ឋកថា ព្រះសុត្តន្តបិដក

## ជាតកដ្ឋកថា

## ចតុត្ថភាគ ចត្តាឡីសនិបាត

## ភាគ ៦០

ពុទ្ធសករាជ ២៥៦៦

# អដ្ឋកថា ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយ

## ជាតកដ្ឋកថា

## ចតុត្ថភាគ ចត្តាឡីសនិបាត

# លេខ ៦០

ពុទ្ធសករាជ ២៥៦៦

អធិប្បាយ

ចត្តាឡីសនិបាត

# អដ្ឋកថា ខុទ្ទកនិកាយ

# ជាតកដ្ឋកថា

# ភាគ ៦០

## ចតុត្ថភាគ

សរុបក្នុងនិបាតនេះ មាន ១និបាត

១. ចត្តាឡីសនិបាត មាន ១០ អដ្ឋកថា

សរុប ១០ អដ្ឋកថា

# ស្រៈនិងស្រៀយ

## *Signes et accents.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | \| | ា | ិ | ី | ុ | ូ | េ | ោ |
| ឡូប Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | \| | า | ิ | ี | ุ | ู | เ | โ |
| លាវ Laotien | \| | າ | ິ | ີ | ຸ | ູ | ເ | ເາ |
| លង្កៈ Cinghalais | \| | ා | ි | ී | ු, ු | ූ, ූ | ෙ | ො |
| ភូមា Birman | \| | ာ | ိ | ီ | ု | ူ | ေ | ော |

# ស្រៈពេញតួ

# Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| ឡាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

## *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡាំង Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡូប Romain | ṭ | ṭh | ḍ | ḍh | ṇ |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| សង្ហ Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| [illegible] Sanscrit | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| សង្ក Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប្ប | ផ្ផ | ព្ព | ភ្ភ | ម្ម |
| រ៉ូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ບ | ຜ | ພ | ຠ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ្យ | ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ | ំ | ។ |
| រ៉ូម Romain | y | r | l | v | s | h | ḷ | ṃ | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ មានអង្គ ៩ គឺ ៖*

***សុត្ត:** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។*

***គេយ្យៈ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណៈ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះ ពោលដល់ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តកៈ** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្លៈ** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី*

រីករាយ និងសាកសួរជាបន្តៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទឹកដីផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រតិបត្តិ ។

ព្រះមានព្រះភាគទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឈ្លាសក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្ដាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលពួកខ្លះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីលនិងទិដ្ឋិផ្សេងៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយព្រមទាំងអត្ថ និងព្យញ្ជនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងមានឧស្សាហៈដ៏ខ្លាំងក្លា បានអធិ-ប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក ចំពោះសេចក្ដីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់ក្នុងគម្ពីរព្រះពុទ្ធសាសនាខាងក្រោយមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកពោល អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួនឱ្យខ្ពង់ខ្ពស់ទុកជាមួយអត្តនោមតិ គឺ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលជាគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះប្រកបដោយការយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់ជាមួយព្រះត្រៃបិដកពុទ្ធសាសនិកជនល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់ ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ ។ លុះព្រះពុទ្ធសាសនាកន្លងបាន ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១. ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២. ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣. ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន មិនមែនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤. ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥. ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦. ការបដិបត្តិដែលឧបជ្ឈាយ៍-អាចារ្យ ធ្លាប់ប្រព្រឹត្តមកខុសត្រូវយ៉ាងណាប្រព្រឹត្តតាម គួរ ។

៧. ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨. ភិក្ខុផឹកស្រាខ្សោយៗ គួរ ។

៩. ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០. ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា **កាកណ្ឌកៈ** បានស្ដាប់វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរសរបស់ព្រះបាទសុសុនាគៈធ្វើជាសម្ងាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោមភិក្ខុ ១.២០០.០០០ អង្គ គឺ (ដប់ពីរសែន) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកព្រះសីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ តិះដៀលហើយ ទើបស្វែងរកពួកគណៈ លុះបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា **មហាសង្ឃិកៈ** និង**ឯកព្យោហារិកៈ** ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យ ២ ពួកដទៃទៀត គឺ **បញ្ញត្តិវាទៈ** និង**ពហុលិយៈ** ដែលមានឈ្មោះម្យ៉ាងទៀតថា **ពហុស្សុតិកៈ** ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀត ឈ្មោះថា **ចេតិយវាទ** កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះៗ ឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈ ដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា ៦ ត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកអំពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តចរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១

សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំនោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញអំពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកអំពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមទាំងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទ និងនិកាយអាចរិយវាទ ៦ ដែលបែកចេញមកអំពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយនោះ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយដែលពោលមកហើយនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញអំពីគ្នា, ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។




*ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ៗ*

*(ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ)*

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា របស់គម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈ អារាធនាឲ្យព្រះពុទ្ធឃោសៈតែងគម្ពីរនេះ ជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ ។ កើតក្នុងត្រកូលព្រាហ្មណ៍ នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេងៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិ-បញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតអស់ទាំងសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថា ជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានសេចក្ដីសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទា ក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដនាមថា **ព្រះពុទ្ធឃោសៈ** ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្តនាតំបន់ពុទ្ធគយានោះ លោកបានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថាឈ្មោះ **អដ្ឋសាលិនី** ដែលជាអដ្ឋកថាគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺអដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបានឃើញអដ្ឋកថា ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែលង្កាទ្វីបនៅមានព្រោះព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចព្រះអគ្គសាវក) ជាដើម បានរចនាទុក និងតមក ព្រះមហិន្ទត្ថេរបានត្រួតពិនិត្យហើយ រចនាទុកជាភាសាសីហឡៈ

សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិ-សោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរ ដែលបាននិមន្តជួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅ រហូតដល់កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រិយ៍លង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា (សិរិនិវាស) ខ្វះ (សិរិកុថៈ) ខ្វះ (សិរិកូដ្ឋៈ) ខ្វះ ក្នុងពុទ្ធសករាជ (៩៥២-៩៧៤) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់នូវអដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគដោយពិត ទើបបានសូមការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនាអដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថា ឲ្យលោករចនាសិនទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈ បានរចនាបករណ៍ឈ្មោះវិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កា

ទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក ។ តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀត គម្រប់ ៣ ដង បន្ទាប់មក ក៏បានប្រគេនគម្ពីរដែលបានរចនាទាំងពីរលើកនោះវិញ វេលានោះទើបបានគម្ពីរវិសុទ្ធិមគ្គជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយ ក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារ បានឃើញសេចក្ដីអស្ចារ្យ ក៏នាំគ្នាត្រេកអរកោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជាព្រះមេត្តេយ្យពោធិសត្វដោយពិត នឹងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះមហានាមក្សត្រិយ៍នៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណនៃមហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ មកជាអដ្ឋកថាព្រះ

ត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១. មហាអដ្ឋកថា

២. បច្ចរីយអដ្ឋកថា

៣. កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈ ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទឹក) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១. **សមន្តប្បាសាទិកា** អដ្ឋកថាព្រះវិន័យបិដក

២. **កង្ខាវិតរណី ឬមាតិកដ្ឋកថា** អដ្ឋកថាព្រះបាតិមោក្ខ

៣. **សុមង្គលវិលាសនី** អដ្ឋកថាទីឃនិកាយ

៤. **បបញ្ចសូទនី** អដ្ឋកថាមជ្ឈិមនិកាយ

៥. **សារត្ថប្បកាសិនី** អដ្ឋកថាសំយុត្តនិកាយ

៦. **មនោរថបូរណី** អដ្ឋកថាអង្គុត្តរនិកាយ

៧. **បរមត្ថជោតិកា** អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨. **ធម្មបទដ្ឋកថា** អដ្ឋកថាធម្មបទ

៩. **ជាតកដ្ឋកថា** អដ្ឋកថាជាតក

១០. **អដ្ឋសាលិនី** អដ្ឋកថាធម្មសង្គណីបករណ៍

១១. **សម្មោហវិនោទនី** អដ្ឋកថាវិភង្គបករណ៍

១២. **បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី** ជាព្រះអដ្ឋកថាព្រះអភិធម្ម ទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣. **វិសុទ្ធិមគ្គ** បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤. **ញាណោទ័យ** តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥. **បរិត្តដ្ឋកថា** អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេងៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅបានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យដ៏សំខាន់ក្រៃលែងរបស់លោកយើងនេះ ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្លាត ហ៊ីន

ឧបាសក ឆាក់ ម៉ៅ

ឧបាសក ធុំ ធួន

ឧបាសក ហុក សីវហ្វាត

ឧបាសក ជឹម ជំនិត

ឧបាសក កើត និត្យ

ឧបាសក សន ម៉ារតី

ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម វ៉ៃយ៉ា

ឧបាសក សុក្រ ហ៊ិត

ឧបាសក សោម រតនៈ

ឧបាសក សំ ឆាយ

ឧបាសក ម៉ៅ ផុន

ឧបាសក ជា ស៊ីថាន

ឧបាសិកា ថាប់ លៀម

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៊ុត សេដាដួង

ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ឧបាសក ហាយ ចំរើន

ឧបាសក ជឹម ជំនិត

ឧបាសក សង ម៉ារឌី

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ-

ឧទ្ទិសថ្វាយ និងគោរពជូន:

-ព្រះមហាវរក្សត្រិយ៍ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រិយ៍នៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុជាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះរឿង ទំព័រ

## ចត្តាឡីសនិបាត


១-អដ្ឋកថា តេសកុណជាតក ១

២-អដ្ឋកថា សរភង្គជាតក ៨១

៣-អដ្ឋកថា អលម្ពុសាជាតក ១៨៦

៤-អដ្ឋកថា សង្ខបាលជាតក ២៣៣

៥-អដ្ឋកថា ចុល្លសុតសោមជាតក ៣០២

# ចត្តាឡីសនិបាត

# បរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ

# ជាតកដ្ឋកថា

## អដ្ឋកថា តេសកុណជាតកទី ១

(រឿងបក្សីតបបញ្ហាព្រះរាជា)

*ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានត្រាស់ព្រះធម្មទេសនានេះ ដោយទំនងជាថ្វាយព្រះឱវាទព្រះបាទបសេនទិកោសល មានពាក្យផ្តើមថា **វេស្សន្តរំ តំ បុច្ឆាមិ** “យើងសូមសួរអ្នកជាវេស្សន្តរ” ដូច្នេះ ។*

*សេចក្តីពិស្តារថា ព្រះសាស្តាត្រាស់នឹងព្រះរាជានោះ ដែលស្តេចយាងមកដើម្បីស្តាប់ធម៌ព្រះធម្មទេសនា ទ្រង់ត្រាស់ថា “មហាបពិត្រ ធម្មតាព្រះរាជាគួរគ្រងរាជ្យដោយធម៌ ព្រោះសម័យណា*

ព្រះរាជាទ្រង់មិនតាំងនៅក្នុងធម៌ សម័យនោះសូម្បីអ្នករាជការទាំងឡាយ ក៏ជាអ្នកមិនតាំងនៅក្នុងធម៌” ដូច្នេះហើយ ទ្រង់ទើបឱវាទដោយន័យនៃព្រះសូត្រដែលមកក្នុងចតុក្កនិបាត និងត្រាស់ពណ៌នាទោស និងអានិសង្សនៃការលុះក្នុងអំណាចអគតិ ទ្រង់សម្តែងទោសក្នុងកាមទាំងឡាយឲ្យពិស្តារ ដោយន័យជាដើមថា កាមទាំងឡាយប្រៀបដូចជាការយល់សប្តិ ហើយត្រាស់ថា

មហាបពិត្រ ការឃ្លាតចាកអំពីម្រឹត្យុ រមែងមិនមានដល់សត្វទាំងនេះឡើយ ការទទួលសំណូកក៏មិនមាន ការតយុទ្ធក៏មិនមាន ជ័យជំនះក៏មិនមាន សត្វទាំងមូលសុទ្ធតែមានសេចក្តីស្លាប់ជាខាងមុខ ។

កាលសត្វទាំងនោះទៅកាន់បរលោក វៀរកល្យាណធម៌ដែលខ្លួនធ្វើទុកហើយ ឈ្មោះថា ទីពឹងដទៃមិនមានឡើយ ចាំបាច់ត្រូវលះបង់វត្ថុដែលប្រាកដជាតិចតួចទាំងនេះទៅដោយពិត ដូច្នេះ មិនគួរ

នឹងអាស្រ័យយសធ្វើនូវសេចក្តីប្រមាទ គប្បីពេញចិត្តក្នុងភាពជាអ្នកមិនប្រមាទសោយរាជ្យដោយធម៌តែម្យ៉ាង សូម្បីកាលព្រះពុទ្ធទ្រង់មិនទាន់បានឧប្បត្តិ បុរាណក្សត្រទាំងឡាយក៏តាំងនៅក្នុងឱវាទរបស់បណ្ឌិត សោយរាជ្យដោយធម៌ ស្តេចទៅកើតក្នុងសួគ៌គ្រប់អង្គ" ព្រះបាទកោសលទ្រង់ទូលអារាធនាហើយ ទើបទ្រង់នាំអតីតនិទានមកត្រាស់សម្តែង ដូចតទៅនេះ ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងព្រះនគរពារាណសី មិនមានព្រះឱរស សូម្បីទ្រង់ប្រាថ្នាហើយក៏មិនបានព្រះឱរស ឬព្រះធីតា ។ ថ្ងៃមួយ ស្តេចយាងប្រពាសព្រះរាជឧទ្យានជាមួយរាជបរិវារដ៏ច្រើន ទ្រង់ក្រសាលក្នុងព្រះរាជ-ឧទ្យានអស់មួយថ្ងៃ ក្រាលទីផ្ទំក្រោមដើមមង្គលសាលព្រឹក្ស ផ្ទំលក់មួយស្របក់ តើនអំពីផ្ទំហើយទ្រង់ទតព្រះនេត្រមើលដើមសាលៈឃើញសម្បុកបក្សីនៅលើដើមឈើនោះ ។ លុះទតព្រះនេត្រឃើញ

ហើយ ក៏កើតសេចក្តីស្នេហា ទើបត្រាស់ហៅមហាតលិកម្នាក់មក ត្រាស់ថា "អ្នកឡើងដើមឈើនេះ ចូរមើលឲ្យដឹងថា ក្នុងសម្បុក បក្សីនោះមានអ្វីនៅ ឬមិនមាន" ។ មហាតលិកឡើងទៅ ឃើញ ពងបក្សីនៅក្នុងសម្បុកនោះ ៣ ពង ទើបក្រាបទូលថ្វាយ ។ ព្រះ រាជាត្រាស់ថា "បើដូច្នោះ អ្នកកុំដកដង្ហើមលើពងទាំងនោះ" ដូច្នេះ ហើយត្រាស់តទៅទៀតថា "អ្នកចូរដាក់សំឡីក្នុងប្រអប់ ដាក់ពង បក្សីទាំងនោះទុកក្នុងប្រអប់ហើយសឹមចុះមក" គ្រាត្រាស់បង្គាប់ឲ្យ មហាតលិកចុះមកហើយ ទ្រង់ទទួលប្រអប់ដោយព្រះហត្ថ ត្រាស់ សួរពួកអាមាត្យថា "នេះជាពងសត្វអ្វី" អាមាត្យទាំងឡាយនាំគ្នា ក្រាបទូលថា "ខ្ញុំព្រះអង្គមិនជ្រាបទេ ពួកព្រានគង់នឹងដឹងព្រះអង្គ" ព្រះរាជាទើបត្រាស់ឲ្យពួកព្រានចូលគាល់ ហើយត្រាស់សួរ ។ ពួក ព្រានក្រាបទូលថា "ព្រះតេជះតម្កល់លើត្បូង ពងបក្សីទាំងនេះ ១ ជាពងសត្វមៀម ១ ទៀតជាពងសត្វសារិកា ១ ជាពងសត្វសេក"

ត្រាស់សួរថា "ពងសត្វទាំងបីនៅរួមសម្បុកតែមួយជាមួយគ្នាបាន ឬ?" ក្រាបទូលថា "បានព្រះអង្គ កាលមិនមានអន្តរាយ ពងបក្សី ដែលមេក្រាបល្អហើយ រមែងមិនវិនាស" ព្រះរាជាទ្រង់ពេញព្រះទ័យ ព្រះតម្រិះថា "បក្សីទាំងនេះនឹងជាកូនរបស់យើង" ប្រោសឲ្យអាមាត្យបីនាក់ទទួលពងបក្សីទុកម្នាក់មួយ ត្រាស់បង្គាប់ថា "បក្សីទាំងនេះនឹងជាកូនរបស់យើង ពួកអ្នកចូរផ្គត់ផ្គង់ឲ្យល្អ វេលាកូនបក្សីកើតមក ចូរប្រាប់យើង" ។

អាមាត្យទាំងបីនាក់ រក្សាពងបក្សីទាំងនោះដោយល្អ ។ ក្នុងចំនួនពងសត្វទាំងនោះ ពងសត្វមៀមញាស់មុន ។ អាមាត្យទើបហៅព្រានម្នាក់មកសួរថា "អ្នកដឹងទេសត្វនេះញី ឬឈ្មោល?" កាលព្រាននោះពិចារណាហើយ ប្រាប់ថា "ឈ្មោល" ទើបចូលទៅគាល់ព្រះរាជាក្រាបទូលថា មហាបពិត្រ ឱរសរបស់ព្រះអង្គកើតហើយព្រះអង្គ" ។ ព្រះរាជាទ្រង់សប្បាយព្រះទ័យ ព្រះរាជទានទ្រព្យដល់

អាមាត្យនោះដ៏ច្រើន ត្រាស់បង្គាប់ថា "អ្នកចូរផ្គត់ផ្គង់កូនយើងឲ្យល្អ ចូរតាំងឈ្មោះថា "*វេស្សន្តរ*" អាមាត្យនោះបានធ្វើតាមព្រះបរមរាជឱង្ការ ។ កន្លងមក ២-៣ ថ្ងៃទៀត ពងសត្វសារិកាក៏ញាស់ ។ អាមាត្យទើបឲ្យព្រានពិនិត្យមើល ដឹងថា "ជាញី" ទើបទៅកាន់រាជសម្នាក់ក្រាបទូលថា "មហាបពិត្រ រាជធីតារបស់ព្រះអង្គកើតហើយព្រះអង្គ" ព្រះរាជាទ្រង់ពេញព្រះទ័យ ព្រះរាជទានទ្រព្យដល់អាមាត្យម្នាក់នោះដ៏ច្រើន ហើយត្រាស់ថា "អ្នកចូរផ្គត់ផ្គង់ធីតារបស់យើងឲ្យល្អ និងចូរតាំងឈ្មោះថា "*កុណ្ឌលិនី*" ។ សូម្បីអាមាត្យនោះក៏ធ្វើតាមព្រះរាជតម្រាស់ ។ កន្លងមក ២-៣ ថ្ងៃទៀត ពងសត្វសេកក៏ញាស់ សូម្បីអាមាត្យនោះក៏ឲ្យព្រានពិនិត្យមើល កាលគេប្រាប់ថា "ជាសត្វឈ្មោល" ទើបទៅកាន់រាជសម្នាក់ ក្រាបទូលថា "មហាបពិត្រ ឱរសរបស់ព្រះអង្គកើតហើយ ព្រះអង្គ" ។ ព្រះរាជាទ្រង់ពេញព្រះទ័យ ព្រះរាជទានទ្រព្យដល់អាមាត្យនោះជាច្រើន ហើយ

ត្រាស់ប្រាប់ទៅថា អ្នកចូរចាត់ចែងធ្វើនូវមង្គលដល់កូនរបស់យើង ដោយបរិវារជាច្រើន ហើយតាំងឈ្មោះគេថា "ជម្ពុកៈ" ។ អាមាត្យនោះក៏ធ្វើតាមព្រះរាជតម្រាស់ ។ សូម្បីបក្សីទាំង ៣ ក៏ចម្រើនធំធាត់ក្នុងផ្ទះរបស់អាមាត្យទាំង ៣ នាក់ដោយការរក្សាស្មើនឹងរាជ-កុមារ ។

ព្រះរាជាតែងត្រាស់ហៅថា "បុត្តរបស់យើង ធីតារបស់យើង" ដូច្នេះរឿយៗ ។ គ្រានោះ ពួកអាមាត្យរបស់ព្រះអង្គនាំគ្នាញញឹមដាក់គ្នាថា "អ្នកទាំងឡាយ ចូរមើលការធ្វើរបស់ព្រះរាជា ព្រះអង្គយាងត្រាស់ហៅសត្វតិរច្ឆានទាំងបីថា បុត្តរបស់យើង ធីតារបស់យើង" ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបទ្រង់ព្រះតម្រិះថា "អាមាត្យពួកនេះនៅមិនដឹងដល់សេចក្តីសម្បូរដោយបញ្ញានៃកូនទាំងបីរបស់យើង យើងនឹងធ្វើឲ្យប្រាកដដល់ពួកគេ" ។ ទើបត្រាស់ប្រើអាមាត្យម្នាក់ទៅរកវេស្សន្តរ ឲ្យប្រាប់ថា "ព្រះបិតារបស់អ្នកប្រាថ្នានឹងត្រាស់

សួរបញ្ហា ស្តេចនឹងយាងមកសួរបានក្នុងកាលណា?" អាមាត្យទៅសំពះវេស្សន្តរហើយ ប្រាប់ព្រះតម្រាស់ឲ្យជ្រាប ។ វេស្សន្តរទើបអញ្ជើញអាមាត្យដែលចិញ្ចឹមខ្លួនមកសួរថា "គេប្រាប់ថា ព្រះរាជ-បិតារបស់ខ្ញុំប្រាថ្នាត្រាស់សួរបញ្ហានឹងខ្ញុំ កាលព្រះអង្គស្តេចមកទីនេះ គួរយើងធ្វើសក្ការៈ នឹងឲ្យព្រះអង្គស្តេចមកក្នុងកាលណាហ្ន៎ពុក?" អាមាត្យតបថា "អំពីនេះទៅ ៧ ថ្ងៃទើបយាងស្តេចមក" ។ វេស្សន្តរបានស្តាប់ដូច្នោះ ទើបបញ្ជូនដំណឹងឲ្យក្រាបទូលថា "ព្រះរាជបិតាសូមស្តេចយាងមកក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះទៅបាន" ។ អាមាត្យនោះត្រឡប់មកទូលថ្វាយព្រះរាជា ។ ដល់ថ្ងៃទី ៧ ព្រះរាជាត្រាស់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ហើយស្តេចយាងទៅកាន់ទីនៅរបស់បុត្ត វេស្សន្តរក៏ប្រាប់ឲ្យធ្វើមហាសក្ការៈចំពោះព្រះរាជាដោយហោចសូម្បីទាសៈ និងកម្មករក៏ឲ្យធ្វើសក្ការៈផង ។ ព្រះរាជាសោយក្នុងផ្ទះរបស់បក្សីវេស្សន្តរ ទ្រង់បានទទួលការប្រណិប័តន៍

សមនឹងព្រះកិត្តិយស ហើយស្តេចក៏ត្រឡប់ទៅកាន់ព្រះរាជនិវេ-សន៍ ត្រាស់ឲ្យធ្វើមហាមណ្ឌបត្រង់ព្រះលានហ្លួង ឲ្យត្រាច់វាយស្គរប្រកាសក្នុងព្រះនគរហើយប្រថាប់អង្គុយក្នុងមណ្ឌបដែលតាក់តែងហើយ ហែហមទៅដោយមហាជន ទ្រង់បញ្ជូនព្រះរាជសាសន៍ទៅកាន់សម្នាក់របស់អាមាត្យថា "ចូរនាំវេស្សន្តរមកចុះ" អាមាត្យឲ្យវេស្សន្តរទុំលើតាំងមាសនាំមកថ្វាយ ។ វេស្សន្តរបក្សីទុំលើព្រះភ្លៅព្រះរាជបិតា លេងជាមួយព្រះរាជបិតា ហើយហើរទៅទុំលើតាំងមាសនោះដូចដើម ។

លំដាប់នោះ ព្រះរាជាកាលនឹងត្រាស់សួររាជធម៌នឹងវេស្សន្តរក្នុងកណ្តាលមហាជន ទើបត្រាស់បឋមគាថាថា

[៩៦៧] វេស្សន្តរន្តំ បុច្ឆាមិ សកុណ ភទ្ទមត្ថុ តេ
រជ្ជំ ការេតុកាមេន កឹសុ កិច្ចំ កតំ វរំ ។

យើងសូមសួរអ្នកវេស្សន្តរ បក្សីអើយ សូមសេចក្តីចម្រើន

ចូរមានដល់អ្នក កិច្ចអ្វីដែលបុគ្គលអ្នកបំណាំងគ្រប់គ្រងរាជ្យ-

សម្បត្តិធ្វើហើយ ជាកិច្ចប្រសើរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះ ដូចតទៅនេះ ។ ព្រះរាជា

ទ្រង់សាកសួរវេស្សន្តរនោះថា **បក្សីអើយ** ។

បទថា **កឹសុ** “អ្វី” សេចក្តីថា ន័យថា ព្រះរាជានោះត្រាស់

សួរវេស្សន្តរៈនោះយ៉ាងនេះថា “កិច្ចអ្វីដែលអ្នកប្រាថ្នាគ្រងរាជ្យធ្វើ

ហើយជារបស់ល្អ គឺ ខ្ពង់ខ្ពស់ បាអើយ អ្នកចូរប្រាប់រាជធម៌ទាំង

មូលដល់អញចុះ” ។

វេស្សន្តរបក្សីបានស្តាប់ព្រះរាជតម្រាស់ហើយ នៅមិនទាន់

ទូលដោះស្រាយបញ្ហាទេ កាលនឹងទូលដាស់តឿនព្រះរាជាក្នុងរឿង

សេចក្តីប្រមាទមុន ទើបពោលគាថាទីពីរថា

[៥៦៨] ចិរស្សំ វត មំ តាតោ កំសោ ពារាណសិគ្គហោ

បមត្តោ អប្បមត្តំ មំ បិតា បុត្តំ អចោទយិ ។

យូរណាស់ហើយហ្ន៎ ព្រះបាទកសិរាជព្រះរាជបិតារបស់យើង ទ្រង់សង្គ្រោះអ្នកក្រុងពារាណសី ជាអ្នកប្រមាទ បានត្រាស់សួរយើងជាបុត្តដែលរកសេចក្តីប្រមាទមិនបាន ។

បណ្តាបទទាំងនោះ បទថា **តាតោ** "ព្រះរាជបិតា" បានដល់ព្រះរាជបិតា ។ បទថា **កំសោ** "ព្រះបាទកសិរាជ" នេះ ជាឈ្មោះរបស់ព្រះរាជាព្រះអង្គនោះ ។ បទថា **ពារាណសិគ្គហោ** "ដែលទ្រង់សង្គ្រោះអ្នកក្រុងពារាណសី" សេចក្តីថា ទ្រង់ប្រព្រឹត្តសង្គ្រោះអ្នកក្រុងពារាណសីដោយសង្គហវត្ថុ ៤ ប្រការ ។ បទថា **បមត្តោ** "ជាអ្នកប្រមាទ" សេចក្តីថា ស្តេចនៅក្នុងសម្នាក់របស់បណ្ឌិតបែបនេះ ឈ្មោះថា ជាអ្នកប្រមាទហើយ ព្រោះមិនបានត្រាស់សួរបញ្ហា ។ បទថា **អប្បមត្តំ** "ដែលរកប្រយោជន៍មិនបាន" សេចក្តីថា ទំនុកបម្រុងចិញ្ចឹមយើងអ្នកឈ្មោះថា មិនប្រមាទហើយ ព្រោះប្រកបដោយគុណមានសីលជាដើម ។ បទថា **បិតា** "ព្រះរាជបិតា" បានដល់ ព្រះ

រាជបិតាទ្រង់ជាអ្នកចិញ្ចឹម ។ បទថា **អចោទយិ** “ត្រាស់សួរ” គឺ វេស្សន្តរបក្សពោលថា “ព្រះរាជបិតាត្រូវពួកអាមាត្យឡកឡើយថា ព្រះរាជាត្រាស់ហៅសត្វតិរច្ឆានថាជាបុត្ត ទ្រង់ដល់សេចក្តីប្រមាទហើយ ទ្រង់សួរ គឺ ត្រាស់សួរបញ្ហាក្នុងថ្ងៃនេះអស់កាលយូរមកហើយ” ។

វេស្សន្តរទូលសួរដោយគាថាយ៉ាងនេះហើយ ទូលថា “ព្រះតេជះ ព្រះជនកមហារាជ ដែលឈ្មោះថា ព្រះរាជាគួរតាំងនៅក្នុងធម៌ ៣ ប្រការ សោយរាជ្យសម្បត្តិដោយធម៌” កាលនឹងសម្តែងរាជធម៌ ទើបពោលគាថាថា

[៥៦៩] បឋមេនេវ វិតថំ កោធំ ហាសំ និវារយេ

តតោ កិច្ចានិ ការេយ្យ តំ វតំ អាហុ ខត្តិយ ។

បពិត្រព្រះបរមក្សត្រ ជម្មតាព្រះរាជាគួរហាមមុសាវាទ

សេចក្តីក្រោធ និងសភាពឡេះឡោះអំពីមុននោះឯង តពីនោះ

គប្បីត្រាស់ឲ្យធ្វើរាជកិច្ចទាំងឡាយ ពាក្យដែលខ្ញុំព្រះអង្គពោល មកនោះ អ្នកប្រាជ្ញទាំងឡាយពោលថាជាព្រះរាជប្រពៃណី ។

យំ ត្វំ តាត តបេ កម្មំ បុព្វេ កតមសំសយំ
រត្តោ ទុដ្ឋោ ច យំ កយិរា ន តំ កយិរា តតោ បុន ។

បពិត្រព្រះបិតា កាលមុនព្រះអង្គទ្រង់ពេញព្រះទ័យ និង ខ្ញីមរអើមហើយទ្រង់គប្បីធ្វើកម្មណា កម្មនោះដែលព្រះអង្គ ទ្រង់ធ្វើហើយ គប្បីញុំាងព្រះអង្គឲ្យក្តៅក្រហាយដោយឥតសង្ស័យ ដូច្នោះ ព្រះអង្គមិនគួរធ្វើកម្មនោះទៀតឡើយ ។

ខត្តិយស្ស បមត្តស្ស រដ្ឋស្មឹ រដ្ឋវឌ្ឍន
សព្វេ ភោគា វិនស្សន្តិ រញ្ញោ តំ វុច្ចតេ អឃំ ។

បពិត្រព្រះអង្គអ្នកទ្រទ្រង់នូវរដ្ឋ កាលក្សត្រប្រមាទហើយ ភោគសម្បត្តិគ្រប់យ៉ាងក្នុងដែនរមែងវិនាស ប្រការនោះអ្នក ប្រាជ្ញពោលថា ជាសេចក្តីទុក្ខរបស់ព្រះរាជា ។

សិរី ច តាត លក្ខី ច បុច្ឆិតា ឯតទព្រវុំ

ឧដ្ឋានេ វីរិយេ បោសេ រមាមហំ អនុសូយកេ ។

បពិត្រព្រះបិតា ទេពធីតាឈ្មោះសិរី និងឈ្មោះអលក្ខី ត្រូវសុចិបរិវារសេដ្ឋីសួរ បានតបថា ខ្ញុំរមែងត្រេកអរក្នុងបុរស អ្នកមានសេចក្ដីព្យាយាម និងមិនមានឥស្សា ។

ឧសូយកេ ទុហទយេ បុរិសេ កម្មទុស្សកេ

កាឡកណ្ណី មហារាជ រមតិ ចក្កភញ្ជនី ។

បពិត្រមហារាជ អលក្ខីទេពធីតាដែលជាកាឡកណ្ណី អ្នកទម្លាយនូវកុសលចក្រ រមែងត្រេកក្នុងបុរសអ្នកឥស្សា អ្នកមានចិត្តអាក្រក់ ទម្លាយនូវកុសលធម៌ ។

សោ ត្វំ សព្វេសុ សុហទយោ សព្វេសំ រក្ខិតោ ភវ

អលក្ខី នុទ មហារាជ លក្ខ្យា ភវ និវេសនំ ។

បពិត្រមហារាជ ព្រះអង្គចូរទ្រង់ជាអ្នកមានព្រះទ័យល្អដល់

មនុស្សទាំងពួង ទ្រង់ចូរការពាររក្សាមនុស្សទាំងឡាយ ប្រោស ទ្រង់បណ្តេញនាងទេពធីតាដែលអប្បជោគចេញទៅ សូមព្រះ រាជនិវេសន៍ចូរជាទីនៅនៃទេពធីតាអ្នកមានជោគប៉ុណ្ណោះ ។

សលក្ខី ធីតិសម្បន្នោ បុរិសោ ហិ មហគ្គតោ

អមិត្តានំ កាសិបតិ មូលំ អគ្គញ្ច ឆិន្ទតិ ។

បពិត្រព្រះអង្គជាធំលើជននៃដែនកាសី បុរសអ្នកមានបញ្ញា សម្បូរទៅដោយសេចក្តីព្យាយាម មានអធ្យាស្រ័យធំទូលាយ រមែងកាត់គល់ និងចុងរបស់សត្រូវទាំងឡាយបាន ។

សក្កោបិ ហិ ភូតបតិ ឧដ្ឋានេ នប្បមជ្ជតិ

សកល្យាណេ ធិតឹ កត្វា ឧដ្ឋានេ កុរុតេ មនោ ។

បពិត្រព្រះអង្គជាធំលើប្រជាជន ការពិត សូម្បីស្តេចសក្កៈ ក៏ទ្រង់មិនប្រមាទក្នុងសេចក្តីព្យាយាម ស្តេចទ្រង់ធ្វើសេចក្តី ព្យាយាមក្នុងកល្យាណធម៌ តាំងព្រះទ័យមាំក្នុងសេចក្តីប្រឹង

ប្រែងព្យាយាម ។

គន្ធព្វា បិតរោ ទេវា សាជីវា ហោន្តិ តាទិនោ

ឧដ្ឋហតោ អប្បមជ្ជតោ អនុតិដ្ឋន្តិ ទេវតា ។

គន្ធព្វ ព្រហ្ម ទេវតាទាំងឡាយជាអ្នកអាស្រ័យព្រះរាជាដូច្នោះ កាលព្រះរាជាទ្រង់ឧស្សាហៈ ទ្រង់មិនប្រមាទ ទេវតាទាំងឡាយរមែងឃុំគ្រងការពារ ។

សោ អប្បមត្តោ អក្កុទ្ធោ តាត កិច្ចានិ ការយ

វាយមស្សុ សកិច្ចេសុ នាលសោ វិន្ទតេ សុខំ ។

បពិត្រព្រះបិតា ព្រះអង្គចូរទ្រង់ជាអ្នកមិនប្រមាទ ទ្រង់មិនព្រះពិរោធ ហើយត្រាស់បង្គាប់ឲ្យធ្វើរាជកិច្ចទាំងឡាយ ចូរទ្រង់ព្យាយាមក្នុងកិច្ចទាំងឡាយ ព្រោះបុគ្គលមិនខ្ជិលច្រអូសរមែងជួបនឹងសេចក្ដីសុខ ។

តត្ថេវ តេ វត្តបទា ឯសាវ អនុសាសនី

អលំ មិត្តេ សុខាបេតុំ    អមិត្តានំ ទុខាយ ច ។

សេចក្តីដែលខ្ញុំព្រះអង្គពោលដោះស្រាយហើយ ក្នុងបញ្ហារបស់ព្រះអង្គនោះ ជាវត្ថុបទ ប្រការនេះជាអនុសាសនី អាចញុំាងបុគ្គលដែលជាមិត្តឲ្យដល់នូវសេចក្តីសុខ និងញុំាងបុគ្គលដែលជាសត្រូវឲ្យដល់នូវសេចក្តីទុក្ខបាន ។

បណ្តាបទទាំងនោះ បទថា **បឋមេនេវ វិតថំ** “មុសាវាទ... មុននោះឯង” សេចក្តីថា បពិត្រស្តេចពុក ធម្មតាព្រះរាជាគួរហាមមុសាវាទជាខាងដើមមុន ។ អធិប្បាយថា ផែនដីរបស់ព្រះរាជាអ្នកត្រាស់មុសាវាទរមែងមិនចម្រើនលូតលាស់ ។ វត្ថុត្រឹមតែរតនៈ ៧ រមែងចូលទៅនៅខាងក្រោមស្ថានទីធ្វើនូវសេចក្តីចម្រើនលូតលាស់ដល់ផែនដី តពីនោះ ក្នុងអាហារ ក្នុងទឹកដោះ ទឹកឃ្មុំ ទឹកអំពៅជាដើម ឬក្នុងឱសថទាំងឡាយ រមែងរកឱជាមិនបាន មហាជនបរិភោគអាហារដែលមិនមានរសេ រមែងកើតជម្ងឺច្រើន ប្រាក់ចំណូល

ទាំងផ្លូវគោកផ្លូវទឹករមែងមិនកើតឡើងក្នុងដែន ។ កាលចំណូលមិនកើត ព្រះរាជាក៏ត្រូវដល់នូវសេចក្ដីលំបាក ។ ព្រះអង្គរមែងមិនអាចសង្រ្គោះសេវកាមាត្យបាន ។ ពួកសេវកាមាត្យកាលមិនបានទទួលនូវការសង្រ្គោះ ខ្វះក៏នឹងមិនសម្លឹងមើលព្រះរាជាដោយចិត្តគោរពកោតក្រែង ។ បពិត្រស្ដេចពុក ដែលឈ្មោះថា មុសាវាទនេះ ខូចសេចក្ដីចម្រើនយ៉ាងនេះ ដូច្នោះ ទើបមិនគួរពោលមុសាវាទនោះសូម្បីព្រោះហេតុនៃជីវិត ។ តែគួរកំណត់កាន់យកសុភាសិតដែលថា "សច្ចៈប្រសើរជាងរសទាំងឡាយ" ដូច្នេះប៉ុណ្ណោះ ។ មួយទៀត ដែលឈ្មោះថា មុសាវាទ ជាគ្រឿងកម្ចាត់នូវគុណមានវិបត្តិជាទីបំផុត ធ្វើ (ខ្លួន) ឲ្យទៅអវិចីក្នុងវារចិត្តទីពីរ ។ មួយទៀតក្នុងសេចក្ដីនេះ គួរសម្ដែងចេតិយជាតក មានជាអាទិថា "ធម៌ដែលបុគ្គលធ្វើឲ្យវិនាសហើយនោះឯងរមែងកម្ចាត់គេ" ។

បទថា កោធំ "សេចក្ដីក្រោធ" សេចក្ដីថា បពិត្រស្ដេចពុក

ធម្មតាព្រះរាជាគួរហាមសូម្បីសេចក្តីក្រោធ ដែលមានសេចក្តីថ្នាំង ថ្នាក់ជាលក្ខណៈជាមុន បពិត្រស្តេចពុក ព្រោះថា សេចក្តីក្រោធ របស់បុគ្គលពួកដទៃ រមែងមិនដល់ទីបំផុតដោយរហ័ស តែរបស់ ព្រះរាជារមែងដល់រហ័ស ធម្មតាព្រះរាជាទាំងឡាយទ្រង់មានវាចាជា អាវុធ ទ្រង់ពិរោធហើយរមែងញុំាងអ្នកដទៃឲ្យវិនាសបាន សូម្បី ដោយអាការត្រឹមតែទ្រង់ធ្មៀងព្រះនេត្រ ព្រោះដូច្នោះ ព្រះរាជាកុំ មានសេចក្តីក្រោធលើសជនដទៃៗ គួរសម្បូរដោយខន្តីគុណ មេ-ត្តាគុណ និងសេចក្តីអាណិតអាសូរ សម្លឹងមើលពលរដ្ឋដូចឱរស ជាទីស្រឡាញ់របស់ខ្លួន ។ បពិត្រព្រះបិតា ក៏ព្រះរាជាទ្រង់ច្រើន ដោយសេចក្តីក្រោធ រមែងមិនអាចរក្សានូវព្រះកិត្តិយសដែលកើត ឡើងបានឡើយ ។ មួយទៀត ដើម្បីសម្តែងខ្លឹមសារនេះ គួរសម្តែង ខន្តិវាទីជាតក និងចុល្លធម្មបាលជាតក ។ ពិតហើយ ក្នុងចុល្លធម្ម-បាលជាតក ព្រះបាទមហាបតាបនរាជត្រាស់ឲ្យផ្តាច់ព្រះជន្មព្រះរា-

ជនិរស កាលព្រះទេវីបែកព្រះទ័យអស់ព្រះជន្មជីពព្រោះសោកដល់ព្រះឱរសហើយ សូម្បីព្រះអង្គក៏សោកក្នុងព្រះទេវី ទ្រង់បែកព្រះទ័យសុគតទៅដូចគ្នា ។ គ្រានោះ អាមាត្យទាំងឡាយត្រូវថ្វាយព្រះភ្លើងត្រង់ព្រះមេរុតែមួយចំពោះព្រះសព ៣ ព្រះអង្គ ។ ព្រោះដូច្នោះព្រះរាជាគួរវៀរចាកមុសាវាទជាដំបូង លំដាប់ទីពីរគួរវៀរចាកនូវសេចក្ដីក្រោធ ។

បទថា ហាសំ "សភាពឡេះឡោះ" បានដល់ ការសប្បាយរីករាយ ។ មួយទៀត បាឋៈក៏ដូច្នោះដូចគ្នា ។ អធិប្បាយថា ព្រះរាជាគួរហាមភាពជាអ្នកលេងសើចក្នុងរាជកិច្ចផ្សេងៗ ដោយព្រះហឫទ័យឡេះឡោះ គឺ ហាមសេចក្ដីសប្បាយរីករាយចេញ បពិត្រព្រះរាជបិតា ធម្មតាព្រះរាជាមិនគួរជាបុគ្គលលេងសើច មិនគួរនឹងជឿអ្នកដទៃ ត្រូវចាត់ការរាជកិច្ចគ្រប់យ៉ាងដោយប្រាកដប្រជាដោយព្រះអង្គឯងប៉ុណ្ណោះ ។ ព្រះរាជាមានព្រះទ័យសប្បាយហើយ កាល

ទ្រង់ធ្វើរាជកិច្ចដោយមិនពិចារណា រមែងញុំាងព្រះឥស្សរិយយស ដែលបានហើយឲ្យវិនាស ។ មួយទៀត សេចក្តីក្នុងអធិការនេះ គួរសម្តែងរឿងព្រះបាទទណ្ឌកីរាជក្នុងសរភង្គជាតក ទ្រង់ជឿនូវពាក្យរបស់បុរោហិត ហើយធ្វើខុសក្នុងកីសវច្ឆតាបស ធ្វើឲ្យវិនាសរដ្ឋ-មណ្ឌលទៅកើតក្នុងកុកកុលនរក គួរសម្តែងរឿងព្រះបាទមេជ្ឈរាជក្នុងមាតង្គជាតក ទ្រង់ជឿពាក្យរបស់ពួកព្រាហ្មណ៍ បានធ្វើខុសក្នុងមាតង្គតាបស ហើយក៏វិនាសទៅព្រមជាមួយរដ្ឋមណ្ឌល ទៅកើតក្នុងនរក និងគួរសម្តែងរឿងដែលត្រកូលវាសុទេព ជឿពាក្យរបស់រាជទារកបងប្អូន ១០ នាក់ដែលវង្វេង ធ្វើខុសក្នុងកណ្ហទីបាយ-នតាបស ដល់នូវសេចក្តីវិនាសទៅ ក្នុងឃដបណ្ឌិតជាតក ។

បទថា *តតោ កិច្ចានិការយេ* “*តពីនោះ គប្បីត្រាស់ឲ្យធ្វើរាជកិច្ចទាំងឡាយ*” សេចក្តីថា បពិត្រព្រះរាជបិតា ព្រះរាជាវៀរមុសាវាទជាលំដាប់ដំបូង សេចក្តីក្រោធជាលំដាប់ទីពីរ សេចក្តីក្លើត

ភ្ញើនមិនមែនជាធម៌ ជាលំដាប់ទីបី តអំពីនោះ ទើបគួរត្រាស់ឲ្យធ្វើរាជកិច្ចដែលគួរធ្វើដល់អ្នកដែនជាខាងក្រោយ ។ បទថា **តំ វត្តំ អាហុ ខត្តិយ** "បពិត្រព្រះបរមក្សត្រ... ពាក្យដែលខ្ញុំព្រះអង្គពោលមកនោះ អ្នកប្រាជ្ញទាំងឡាយពោលថា ជាព្រះរាជប្រវេណី" ន័យថា បពិត្រព្រះខត្តិយមហារាជ ពាក្យណាដែលខ្ញុំម្ចាស់ទូលហើយ បុរាណកបណ្ឌិតពោលពាក្យនោះថា "ជាព្រះរាជប្រវេណីរបស់ព្រះរាជា" ។ បទថា **ន តំ កយិរា** "មិនគួរទ្រង់ធ្វើកម្មនោះ" សេចក្តីថា បពិត្រព្រះរាជបិតា កម្មណាដែលជាគ្រឿងធ្វើសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដោយអំណាចនៃកិលេសមានរាគៈជាដើម ដែលព្រះអង្គធ្វើទុកហើយ ព្រះអង្គមិនគួរធ្វើឡើយ គឺ ទ្រង់កុំធ្វើកម្មនោះទៀត ក្នុងកម្មដែលព្រះអង្គបានធ្វើទុកក្នុងកាលមុននោះ ។

បទថា **វុច្ចតេ** "ពោល" សេចក្តីថា បទនោះលោកពោលថា ជាសេចក្តីទុក្ខរបស់ព្រះរាជា ។ បុរាណកបណ្ឌិតទាំងឡាយពោល

*ទុកយ៉ាងនេះ ។ បទថា **សិរី ច** “សិរី” សេចក្ដីថា វេស្សន្ដរនាំហេតុការណ៍ដែលប្រព្រឹត្តទៅក្នុងក្រុងពារាណសីក្នុងអតីតកាលមកសម្ដែងដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **អព្រវុំ** “បានឆ្លើយ” សេចក្ដីថា សិរិទេពត្រូវសុចិបរិវារសេដ្ឋីសួរហើយទើបប្រាប់ ។ បទថា **ឧដ្ឋានេ វិរិយេ** “អ្នកមានសេចក្ដីព្យាយាម” សេចក្ដីថា សិរិ-ទេពពោលថា “បុគ្គលណាតាំងមាំនៅក្នុងសេចក្ដីប្រឹងប្រែង និងក្នុងសេចក្ដីព្យាយាម ទាំងឃើញសម្បត្តិរបស់អ្នកដទៃហើយមិនប្ញស្យាខ្ញុំរីករាយក្នុងបុគ្គលនោះ” ។ វេស្សន្ដរបកស្រាយពោលដល់សិរិទេពជាមុនយ៉ាងនេះ ។ បទថា **ឧសុយ្យកេ** “អ្នកប្ញស្យា” សេចក្ដីថា បពិត្រព្រះរាជបិតា ចំណែកអលក្ខីទេព ត្រូវសួរហើយបានពោលថា “ខ្ញុំត្រេកអរក្នុងបុគ្គលដែលប្ញស្យាសម្បត្តិអ្នកដទៃ” ។*

*បទថា **ទូហទយេ**[១] “អ្នកមានចិត្តអាក្រក់” បានដល់ មនុស្សមានចិត្តថោកទាប ។ បទថា **កម្មទូសកោ**[២] “អ្នកទម្លាយកុសលកម្ម”*

---

*បិដក. ១. ទុហទយេ, ២. កម្មទុស្សកេ ។*

បានដល់ បុគ្គលដែលប្រទូសរ៉ាយកល្យាណកម្ម អលក្ខីទេពពោល ថា "បុគ្គលណាប្រទូសរ៉ាយ មិនព្យាយាម មិនធ្វើនូវកល្យាណកម្ម ខ្ញុំត្រេកអរក្នុងបុគ្គលនោះៗ" ។ បពិត្រមហារាជ កាឡកណ្ណីអ្នកកាច់ បំបាក់នូវកុសលចក្រ មានការរស់នៅក្នុងប្រទេសដ៏សមគួរជាដើម រមែងត្រេកអរយ៉ាងនេះ ។ បទថា ***សុហទយោ*** ***"ទ្រង់ជាអ្នកមាន ព្រះទ័យល្អ"*** សេចក្ដីថា សូមព្រះអង្គចូរមានព្រះទ័យស្អាត គឺ មាន ព្រះទ័យគិតប្រយោជន៍ដ៏ធំ ។ បទថា ***នុទ*** ***"ប្រោសទ្រង់បណ្ដេញ"*** បានដល់ ចូរដេកចេញ ។ បទថា ***និវេសនំ*** ***"ចូរជាទីនៅ"*** សេចក្ដី ថា តែចូរយកបុញ្ញាធិការជាទីនៅទីពំនាក់ចុះ ។

បទថា ***សលក្ខី ធិតិសម្បន្នោ***[១] ***"អ្នកមានបញ្ញា សម្បូរដោយ សេចក្ដីព្យាយាម"*** សេចក្ដីថា បពិត្រមហារាជជាធំក្នុងដែនកាសី បុរសអ្នកសម្បូរដោយបញ្ញា និងសេចក្ដីព្យាយាមនោះ ។ បទថា

---

បិដក. ១. ធីតិសម្បន្នោ ។

មហគ្គតោ "មានអធ្យាស្រ័យធំទូលាយ" សេចក្តីថា វេស្សន្តរបក្សី ពោលថា "បុរសអ្នកមានអធ្យាស្រ័យធំទូលាយ កាលចាប់ចោរអ្នកឧបត្ថម្ភចោរ ក៏ឈ្មោះថា ចាប់ចោរដែលជាឫសគល់របស់អមិត្រ រមែងកាត់ចុងរបស់ពួកអមិត្របាន" ។

បទថា សក្កោ "ស្តេចសក្កៈ" បានដល់ ព្រះឥន្ទ ។ វេស្ស-ន្តរបក្សីហៅព្រះរាជាថា ភូតបតិ អ្នកជាធំនៃមហាជន ។ បទថា ឧដ្ឋានេ "ក្នុងសេចក្តីព្យាយាម" បានដល់ អ្នកមានការប្រឹងប្រែងព្យាយាម ។ បទថា នប្បមជ្ជតិ "ទ្រង់មិនប្រមាទ" សេចក្តីថា ធ្វើកិច្ចទាំងពួង ។

បទថា ស កល្យាណេ⁽¹⁾ "ព្រះរាជា... ក្នុងកល្យាណធម៌" គឺ ព្រះរាជាអង្គនោះយកព្រះទ័យទុកដាក់ក្នុងសេចក្តីប្រឹងប្រែង និងសេចក្តីព្យាយាមមិនធ្វើបាបកម្ម ធ្វើសេចក្តីព្យាយាមក្នុងកល្យាណ-

---

បិដក. ១. សកល្យាណេ ។

កម្ម គឺ បុញ្ញកម្មតែម្យ៉ាង មិនប្រមាទ ធ្វើទុកក្នុងចិត្តក្នុងសេចក្តីព្យាយាម ។ មួយទៀត ដើម្បីសម្តែងការៈនៃការធ្វើសេចក្តីព្យា-យាមក្នុងកល្យាណកម្មរបស់ស្តេចសក្កៈនោះ គួរសម្តែងរឿងមានជាដើមថា ការដែលស្តេចសក្កៈនោះមកកាន់កបិដ្ឋារាម ព្រមជាមួយទេវតាក្នុងទេវលោកទាំងពីរ ហើយសួរបញ្ហាស្តាប់ធម៌ក្នុងសរភង្គ-ជាតក និងសភាពនៃពាក្យទូន្មានរៀវចុះ ដែលសក្កទេវរាជញ៉ាំងមហាជនឲ្យត្រេកអរហើយ បណ្តាលឲ្យប្រព្រឹត្តទៅដោយអានុភាពរបស់ព្រះអង្គ ក្នុងមហាកណ្ហជាតក ។

បទថា **គន្ធព្វា** "គន្ធព្វ" សេចក្តីថា បានឮថា ទេវតាដែលមានកំណើត ៤ កើតក្រោមស្តេចចាតុម្មហារាជ ឈ្មោះថា គន្ធព្វ ព្រោះទេវតាទាំងនោះមានកំណើត ៤ ។ បទថា **បិតរោ** "ព្រហ្ម" បានដល់ ស្តេចមហាព្រហ្ម ។ បទថា **ទេវា** "ទេវតា" បានដល់ ទេវតាជាន់ឆកាមាវចរដោយអំណាចនៃឧប្បត្តិទេព ។ បទថា **តាទិនោ**

"ដូច្នោះ" សេចក្ដីថា លោកទាំងនោះខ្វះមានអាជីព មានជីវិតស្មើប្រព្រឹត្តទៅបាន កាលព្រះរាជាទ្រង់ត្រេកអរក្នុងកុសលដូច្នោះ ។ ព្រោះព្រះរាជាដូច្នោះ កាលទ្រង់ធ្វើបុណ្យមានទានជាដើម ទ្រង់រមែងឧទ្ទិសចំណែកបុណ្យដល់ទេវតាទាំងឡាយ ។ ទេវតាទាំងនោះទទួលអនុមោទនាចំណែកបុណ្យនោះហើយ ក៏ចម្រើនដោយទិព្វយស ។ បទថា **អនុតិដ្ឋន្តិ** "រមែងឃុំគ្រង" សេចក្ដីថា កាលព្រះរាជាទ្រង់ធ្វើនូវសេចក្ដីព្យាយាម ដល់នូវសេចក្ដីមិនប្រមាទ ទេវតាទាំងឡាយរមែងនាំគ្នាការពាររក្សា តាមទៅចាត់ចែងរក្សាដោយធម៌ ។

បទថា **សោ** "ព្រះអង្គ" បានដល់ ព្រះអង្គនោះ ។ បទថា **វាយមស្សុ ច**[1] "ចូរទ្រង់ព្យាយាម" សេចក្ដីថា កាលព្រះអង្គទ្រង់ធ្វើរដ្ឋកិច្ចនោះ ប្រោសធ្វើសេចក្ដីព្យាយាមក្នុងរដ្ឋកិច្ចនោះៗ ដោយអំណាចការប្រៀបផ្ទឹម ការស្ទាបស្ទង់ ការធ្វើឲ្យប្រចក្សចុះ ។

---

បិដក. ១. វាយាមស្សុ ។

បទថា **តត្ថេវ តេ វត្តបទា** "សេចក្តីដែលខ្ញុំព្រះអង្គពោល ដោះស្រាយហើយក្នុងបញ្ហារបស់ព្រះអង្គ នោះជាវត្តបទ" សេចក្តីថា បពិត្រព្រះរាជបិតា ព្រះអង្គត្រាស់សួរបញ្ហាណានឹងខ្ញុំព្រះអង្គថា "កិច្ចណាដែលបុគ្គលបំណងនឹងគ្រប់គ្រងសម្បត្តិធ្វើហើយ ជាកិច្ចប្រសើរ" ក្នុងបញ្ហារបស់ព្រះអង្គនោះឯង ខ្ញុំព្រះអង្គបានទូលពាក្យជាដើមថា "គួរហាមមុសាវាទជាមុន" ដូច្នេះហើយ ប្រការទាំងនោះជាវត្តបទ ជាវត្តកោដ្ឋាសៈ ព្រះអង្គប្រោសទ្រង់ប្រព្រឹត្តក្នុងវត្តបទនោះ តាមប្រការដែលខ្ញុំព្រះអង្គបានទូលហើយ ។ បទថា **ឯសា**[១] "**ប្រការនេះ**" សេចក្តីថា ប្រការនេះខ្ញុំព្រះអង្គទូលហើយ នេះឯងជាអនុសាសនីសម្រាប់ព្រះអង្គ ។ បទថា **អលំ** "**អាច**" សេចក្តីថា ព្រោះថា កាលព្រះរាជាទ្រង់ប្រព្រឹត្តយ៉ាងនេះ រមែងអង់អាចអាចដើម្បីញុំាងមូលមិត្តឲ្យមានសេចក្តីសុខ និងបង្កទុក្ខដល់មូល-

---

បិដក. ១. ឯសាវ ។

អមិត្តបាន ។

កាលវេស្សន្តរបក្សី សួរដល់សេចក្តីប្រមាទរបស់ព្រះរាជា ដោយគាថាមួយបទ ហើយពោលធម៌ដោយ ១១ គាថាយ៉ាងនេះ មហាជនក៏កើតសេចក្តីអស្ចារ្យឡើងថា “វេស្សន្តរបក្សីឆ្លើយបញ្ហា ដោយលីលានៃព្រះសម្ពុទ្ធ” ដូច្នេះហើយ បាននាំគ្នាសាធុការព្រមគ្នា ១០០ ដង ។ ព្រះរាជាទ្រង់សោមនស្ស ត្រាស់ហៅពួកអាមាត្យមក ត្រាស់បង្គាប់ថា “អាមាត្យដ៏ចម្រើនទាំងឡាយ ព្រោះវេស្សន្តរបុត្តរបស់យើងពោលឆ្លើយបញ្ហាស្រេចហើយយ៉ាងនេះ យើងគួរនឹងចាត់ការដូចម្តេច?” ពួកអាមាត្យក្រាបទូលថា “គួរចាត់ការដោយប្រគល់តំណែងមហាសេនាឲ្យ ព្រះអង្គ” ទើបត្រាស់ថា “បើដូច្នោះ យើងនឹងឲ្យតំណែងមហាសេនាដល់វេស្សន្តរនោះ” ហើយទ្រង់ស្ថាបនាវេស្សន្តរទុកក្នុងឋានន្តរសក្តិ ។ ចាប់តាំងអំពីនោះមក វេស្សន្តរនោះក៏តាំងនៅក្នុងតំណែងជាមហាសេនា ស្នងរាជកិច្ចរបស់ព្រះរាជបិតា

ដោយប្រការដូច្នេះ ។

ចប់វេស្សន្តរបញ្ហា

កន្លងទៅ ២-៣ ថ្ងៃទៀត ព្រះរាជាបញ្ជូនទូតទៅកាន់សម្នាក់កណ្ឌលិនី ដោយទំនងដើមនោះឯង ហើយស្ដេចទៅកាន់កាន់ទីនោះក្នុងថ្ងៃទី ៧ ស្ដេចត្រឡប់មកប្រថាប់ត្រង់កណ្ដាលនៃមណ្ឌបនោះ ត្រាស់ឲ្យនាំកុណ្ឌលិនីមក កាលនឹងត្រាស់សួររាជធម៌នឹងនាងបក្សីដែលទំនៅលើតាំងមាស ទើបត្រាស់គាថាថា

[៥៧០] សក្ខិ តុវំ កុណ្ឌលិនិ មញ្ញសិ ខត្តពន្ធុនី
រជ្ជំ ការេតុកាមេន កឹសុ កិច្ចំ កតំ វរំ ។

ម្នាលកុណ្ឌលិនី ខ្លួននាងជាផៅពង្សរបស់បក្សីមានបណ្ដាស័ក្តិ នាងអាចដែរឬ នាងនឹងយល់បានឬ កិច្ចអ្វីហ្ន៎ ដែលបុគ្គលបំណងគ្រប់គ្រងសម្បត្តិធ្វើហើយ ជាកិច្ចប្រសើរ ។

បណ្ដាបទទាំងនោះ បទថា សក្ខិ “អាច” សេចក្ដីថា ព្រះរាជាត្រាស់សួរថា “នាងនឹងអាចដោះស្រាយបញ្ហាដែលបិតាសួរបានឬ?” ព្រះរាជាទ្រង់សួរដោយឈ្មោះ ដែលមកដោយគេទរបស់នាង

បក្សីនោះថា “នែនាងកុណ្ឌលិនី បានឮថា ក្រោយត្រចៀកទាំងពីររបស់នាងបក្សីនោះ មានស្នាមពីរកន្លែងសណ្ឋានដូចត្រចៀក ព្រោះហេតុនោះ ព្រះរាជាទើបប្រោសឲ្យតាំងឈ្មោះថា “កុណ្ឌលិនី” ។ បទថា **មញ្ញសិ “នឹងយល់បាន”** សេចក្តីថា ព្រះរាជាត្រាស់សួរថា “នាងនឹងដោះស្រាយសេចក្តីនៃបញ្ហាដែលពុកសួរបានឬ?” ព្រះរាជាទ្រង់សួរនាងបក្សីនោះយ៉ាងនេះថា “នែនាងអ្នកមានផៅពង្សនៃបក្សីដែលមានបណ្តាសក្តិ” ដូច្នេះ ព្រោះជាប្អូនស្រីរបស់មហាសេនាអ្នកមានបណ្តាសក្តិ ។ ហេតុអ្វី ព្រះរាជាមិនត្រាស់សួរវេស្សន្តរ បែរជាត្រាស់សួរកុណ្ឌលិនីវិញ? ព្រោះនាងបក្សីនេះជាឥត្ថីភេទ ព្រះរាជាទ្រង់ព្រះតម្រិះថា “ធម្មតាស្ត្រីមានបញ្ញាតិចតួច បើនាងបក្សីនេះអាចក៏នឹងសួរ បើមិនអាច ក៏មិនសួរ” ទើបបានត្រាស់សួរដូច្នេះ ដោយទ្រង់សាកល្បងមើល ហើយត្រាស់សួរបញ្ហាដូច្នោះដូចគ្នា ។

កាលព្រះរាជាត្រាស់សួររាជធម៌យ៉ាងនេះហើយ នាងកុណ្ឌ-

លិនីទើបទូលថា "បពិត្រព្រះបិតា ប្រហែលព្រះបិតាចង់សាកល្បង ខ្ញុំម្ចាស់ ដោយមានព្រះទ័យថា ដែលឈ្មោះថា ស្ត្រីហើយ នឹងដោះស្រាយដូចម្ដេចបាន ខ្ញុំម្ចាស់នឹងពោលនូវរាជធម៌ទាំងអស់ថ្វាយព្រះបិតារួមគ្នាក្នុងពីរបទតែម្ដង" ដូច្នេះហើយទើបពោលគាថាថា

[៥៧១] ទ្វេវ តាត បទកានិ យត្ថ សព្វំ បតិដ្ឋិតំ

អលទ្ធស្ស ច យោ លាភោ លទ្ធស្ស ចានុរក្ខនា ។

បពិត្រព្រះបិតា ប្រយោជន៍តាំងមាំនៅក្នុងហេតុ ២ ប្រការប៉ុណ្ណោះ គឺ ការបានលាភដែលមិនទាន់បាន ១ ការតាមរក្សាលាភដែលបានហើយ ១ ។

អមច្ចេ តាត ជានាហិ ធីរេ អត្ថស្ស កោវិទេ

អនក្ខាកិតវេ តាត អសោណ្ឌេ អវិនាសកេ ។

បពិត្រព្រះបិតា ព្រះអង្គចូរទ្រង់ដឹងនូវអាមាត្យទាំងឡាយជាអ្នកប្រាជ្ញឈ្លាសក្នុងប្រយោជន៍ មិនលេងល្បែង មិនបិទ

បាំង ជាអ្នកមិនលេងសុរា មិនធ្វើឲ្យវិនាស ។

យោ ច តាត រក្ខេយ្យ ធនំ យញ្ចេវ តេ សិយា
សូតោវ រថំ សង្គណ្ហេ សោ តេ កិច្ចានិ ការយេ ។

បពិត្រព្រះបិតា ឯអាមាត្យណារក្សាព្រះរាជទ្រព្យរបស់ព្រះអង្គឲ្យគង់វង់បាន ដូចនាយសារថីរក្សារថបាន ព្រះអង្គគួរទ្រង់ប្រើអាមាត្យនោះ ឲ្យធ្វើរាជកិច្ចទាំងឡាយរបស់ព្រះអង្គចុះ ។

សុសង្គហីតន្តជនោ សយំ វិត្តំ អវេក្ខិយ
និធិញ្ច ឥណទានញ្ច ន ករេ បរបត្តិយា ។

ព្រះរាជាគប្បីសង្គ្រោះជនខាងក្នុងដោយល្អ ត្រួតត្រាព្រះរាជទ្រព្យដោយព្រះអង្គឯង មិនគួរបោត់ការរាជទ្រព្យ និងកូនបំណុលដោយទ្រង់ទុកព្រះទ័យក្នុងអ្នកដទៃឡើយ ។

សយំ អាយំ វយំ ជញ្ញា សយំ ជញ្ញា កតាកតំ

និគណ្ហេ និគ្គហារហំ បគ្គណ្ហេ បគ្គហារហំ ។

ព្រះរាជាគួរជ្រាបការចំណូល និងចំណាយដោយព្រះអង្គឯង គួរទ្រង់ជ្រាបកិច្ចដែលធ្វើហើយ និងមិនទាន់បានធ្វើដោយព្រះអង្គឯង គួរសង្កត់សង្កិនបុគ្គលដែលគួរសង្កត់សង្កិន គួរលើកសរសើរបុគ្គលដែលគួរលើកសរសើរ ។

សយំ ជានបទំ អត្ថំ អនុសាស រថេសភ
មា តេ អធម្មិកា យុត្តា ធនំ រដ្ឋញ្ច នាសយុំ ។

បពិត្រព្រះអង្គទ្រង់ជាកំពូលនៃទ័ព ព្រះអង្គទ្រង់ចូរទូន្មានហេតុផលដល់អ្នកជនបទដោយព្រះអង្គឯង រាជបុរសអ្នកទារកាស៊ីអាករ ដែលមិនប្រកបដោយធម៌ កុំញុំាងព្រះរាជទ្រព្យនិងរដ្ឋសីមារបស់ព្រះអង្គឲ្យវិនាសឡើយ ។

មា ច វេគេន កិច្ចានិ ការេសិ[1] ការយេសិ វា

---

១.ម. ករោសិ ។

វេគសា ហិ កតំ កម្មំ  មន្ទោ បច្ឆានុតប្បតិ ។

ម្យ៉ាងទៀត ព្រះអង្គទ្រង់កុំធ្វើដោយព្រះអង្គឯង ឬទ្រង់កុំប្រើអ្នកដទៃធ្វើរាជកិច្ចទាំងឡាយដោយប្រញាប់ ព្រោះថា ការងារដែលធ្វើទៅដោយប្រញាប់មិនល្អឡើយ បុគ្គលល្ងង់រមែងក្តៅក្រហាយជាខាងក្រោយ ។

មា តេ អធិសរេ មុញ្ច  សុពាឡ្ហមធិកោបិតំ

កោធសា ហិ ពហូ ផីតា  កុលា អកុលតំ គតា ។

ព្រះអង្គទ្រង់កុំកន្ទ្រកុសលឡើយ ទ្រង់កុំបណ្តោយព្រះទ័យឲ្យក្រោធពេក ព្រោះថា ត្រកូលដែលស្តុកស្តម្ភដ៏ច្រើនបានដល់នូវភាពមិនមែនជាត្រកូលក៏ព្រោះសេចក្តីក្រោធ ។

មា តាត ឯស្សរោម្ហីតិ  អនត្ថាយ  បតារយិ

ឥត្ថីនំ  បុរិសានញ្ច  មា តេ អាសិ ទុក្ខុទ្រយោ ។

បពិត្រព្រះបិតា ព្រះអង្គទ្រង់កុំគិតថា យើងជាធំ ហើយ

ញុំាងមហាជនឲ្យធ្លាក់ចុះដើម្បីសេចក្ដីវិនាស កម្រែ គឺ សេចក្ដីទុក្ខកុំកើតមានដល់ស្រ្តី និងបុរសរបស់ព្រះអង្គឡើយ ។

អបេតលោមហំសស្ស រញ្ញោ កាមានុសារិនោ
សព្វេ ភោគា វិនស្សន្តិ រញ្ញោ តំ វុច្ចតេ អឃំ ។

ភោគសម្បត្តិទាំងពួងរបស់ព្រះរាជា ដែលប្រាសចាកការព្រឺរោម ស្វែងរកតែកាមារម្មណ៍ រមែងវិនាសអស់ ប្រការនោះអ្នកប្រាជ្ញទាំងឡាយពោលថា ជាសេចក្ដីទុក្ខរបស់ព្រះរាជា ។

តត្ថេវ តេ វត្តបទា ឯសាវ អនុសាសនី
ទក្ខស្សុទានិ បុញ្ញករោ អសោណ្ឌោ អវិនាសកោ
សីលវស្សុ មហារាជ ទុស្សីលោ វិនិបាតិកោ ។

សេចក្ដីដែលខ្ញុំម្ចាស់ក្រាបទូលក្នុងបញ្ហារបស់ព្រះអង្គនោះជាវត្តបទ នេះឯងជាអនុសាសនី បពិត្រមហារាជ ឥឡូវនេះសូមព្រះអង្គទ្រង់គប្បីខ្មីឃ្មាតបំពេញបុណ្យ កុំជាអ្នកលេង ទ្រង់

*កុំជុតបំផ្លាញទ្រព្យ ចូរមានសីល ព្រោះថា បុគ្គលទ្រុស្តសីល រមែងធ្លាក់ចុះ ។*

*បណ្តាបទទាំងនោះ បទថា* **បទកានិ** *ជាពាក្យបញ្ជាក់ដល់ហេតុ ។ បទថា* **យត្ថ** *“ណា” សេចក្តីថា សុខដែលជាប្រយោជន៍ដ៏ទូលាយដែលជាផលកើតហើយទាំងអស់ តាំងនៅក្នុងបទទាំងពីរណា ។ បទថា* **អលទ្ធស្ស** *“ដែលមិនទាន់បាន” សេចក្តីថា ការបានលាភដែលនៅមិនទាន់បានអំពីមុន ១ ការតាមរក្សាលាភដែលបានហើយ ១ ។ អធិប្បាយថា បពិត្រព្រះបិតា ដែលឈ្មោះថា ការញុំាងលាភដែលមិនទាន់កើតឲ្យកើតឡើងក៏ជាភារៈ ចំណែកការតាមរក្សាលាភដែលកើតឡើងហើយក៏ជាភារៈដូចគ្នា ព្រោះថា បុគ្គលខ្លះសូម្បីញុំាងយសឲ្យកើតឡើងហើយ ស្រវឹងក្នុងយស កើតការប្រមាទ ធ្វើសេចក្តីអាក្រក់មានបាណាតិបាតជាដើម ជាមហាចោរដើរប្លន់ដែន ប្រសិនបើព្រះរាជាត្រាស់បង្គាប់ឲ្យចាប់មកបាន ត្រូវ*

ដាក់ព្រះអាជ្ញាឲ្យដល់សេចក្ដីវិនាសធំ ។

ម្យ៉ាងទៀត បុគ្គលខ្លះស្រវឹងក្នុងកាមគុណ មានរូបដែលកើតហើយជាដើម បំផ្លាញទ្រព្យសម្បត្តិដោយមិនត្រូវទំនង កាលអស់ទ្រព្យ ក៏ត្រូវជាបុគ្គលកំព្រា ស្លៀកដណ្ដប់សំពត់សំបកឈើ កាន់អំបែងដើរសូមទាន ឬន័យម្យ៉ាងទៀត បព្វជិតញ៉ាំងលាភសក្ការៈឲ្យកើតដោយអំណាចនៃគន្ថធុរៈជាដើម ហើយស្រវឹងវិលមកដើម្បីសេចក្ដីវិនាស អន្តខ្លះសូម្បីចម្រើនបឋមជ្ឈានជាដើមឲ្យកើត ក៏ជាប់នៅក្នុងអារម្មណ៍នោះ ព្រោះជាអ្នកមានសតិវង្វេងរមែងវិនាសចាកឈាន រក្សាយស ឬរក្សាការបានឈានជាដើម ដែលកើតឡើងហើយជារបស់លំបាកយ៉ាងក្រៃលែង មួយទៀត ដើម្បីនឹងសម្ដែងសេចក្ដីនោះ គួរសម្ដែងរឿងព្រះទេវទត្ត និងគួរសម្ដែងរឿងមុទុលក្ខណ-ជាតក លោមសកស្សបជាតក ហារិតជាតក និងសង្កប្បជាតក ។

ចំណែកបុគ្គលខ្លះញ៉ាំងលាភសក្ការៈឲ្យកើតឡើងហើយ តាំង

នៅក្នុងសេចក្ដីមិនប្រមាទ ធ្វើកម្មដែលស្អាត ។ យសរបស់បុគ្គល នោះរមែងចម្រើន ដូចព្រះចន្ទក្នុងថ្ងៃពេញដូច្នោះ បពិត្រមហារាជ ព្រោះដូច្នោះ ព្រះអង្គកុំប្រមាទ តាំងនៅក្នុងបយោគសម្បត្តិ គ្រង រាជ្យដោយធម៌ តាមរក្សាព្រះកិត្តិយសរបស់ព្រះអង្គដែលកើតឡើង ហើយចុះ ។

បទថា ជានាហិ "ទ្រង់ចូរដឹង" សេចក្ដីថា ដើម្បីធ្វើការងារ ជានាយឃ្លាំងជាដើម ព្រះអង្គទ្រង់ចូរពិចារណា ។ បទថា ***អន-ក្ខាកិតវេ "មិនបិទបាំងលេងល្បែងភ្នាល់"*** សេចក្ដីថា ទ្រង់ប្រោស ត្រួតមើលពួកអាមាត្យដែលជាបុគ្គលមិនលេងល្បែង មិនជាបុគ្គល កោង គឺ មិនមែនអ្នកលេងល្បែងភ្នាល់ និងមិនមែនជាអ្នកកុហក ។ បទថា ***អសោណ្ឌេ "មិនជាអ្នកលេងសុរា"*** សេចក្ដីថា ជាបុគ្គល វៀរចាកភាពជាអ្នកលេងនំ អ្នកលេងស្រា អ្នកលេងគ្រឿងក្រអូប និងផ្កាកម្រង ។ បទថា ***អវិនាសកេ "មិនធ្វើឲ្យវិនាស"*** សេចក្ដីថា

មិនមែនជាអ្នកញ៉ាំងធនសារ និងធញ្ញាហារជាដើម ដែលជារាជ-ទ្រព្យរបស់ព្រះអង្គឲ្យវិនាស ។

បទថា **យោ** "បុគ្គលណា" បានដល់ អមាត្យណា ។ បទថា **យញ្ចេវ** "ណា" សេចក្តីថា អាមាត្យណាគប្បីរក្សារាជទ្រព្យដែលមាននៅក្នុងព្រះរាជវាំងរបស់ព្រះអង្គបាន ។ បទថា **សូតោវ** "ដូចនាយសារថី" សេចក្តីថា ដូចសារថីបរនូវរថ អធិប្បាយថា នាយសារថីកាលកាន់ខ្សែសេះដើម្បីហាមផ្លូវដែលមិនរាបស្មើ គប្បីទាញខ្សែឈប់យ៉ាងណា អាមាត្យណាដូច្នោះ អាចដើម្បីនឹងរក្សាព្រះអង្គព្រមទាំងភោគសម្បត្តិបាន អាមាត្យនោះឈ្មោះថា ជាអាមាត្យរបស់ព្រះអង្គ ។ ព្រះអង្គគួរកាន់យកអាមាត្យដូច្នោះទុក ត្រាស់បង្គាប់ឲ្យធ្វើរាជកិច្ចដូចជានាទីជានាយឃ្លាំងជាដើម ។

បទថា **សុសង្គហីតន្តជនោ** "សង្គ្រោះជនជាខាងក្នុង" ន័យថា បពិត្រព្រះបិតា ព្រោះថា អន្តោជន និងបរិជនដែលប្រើប្រាស់

ក្នុងរាជសម្នាក់របស់ព្រះរាជាណា មិនបានទទួលការសង្គ្រោះដោយទានជាដើម ព្រះរាជទ្រព្យដូចជាមាសប្រាក់ជាដើម ក្នុងព្រះរាជដ្ឋានរបស់ព្រះរាជានោះ រមែងវិនាសដោយអំណាចនៃមនុស្សដែលមិនបានទទួលការសង្គ្រោះទាំងនោះ ពួកខ្លះក៏នាំគ្នាទៅខាងក្រៅ ព្រោះហេតុនោះ ព្រះអង្គទ្រង់ប្រោសសង្គ្រោះអន្តោជនដោយល្អ គួរត្រួតត្រាព្រះរាជទ្រព្យរបស់ព្រះអង្គដោយអង្គឯងឲ្យដឹងថា "ទ្រព្យរបស់យើងមានចំនួនប៉ុណ្ណេះ" និងមិនគួរចាត់ការសូម្បីកិច្ចទាំងពីរយ៉ាងថា "យើងកប់កំណាប់ទ្រព្យទុកក្នុងទីឯណោះ យើងនឹងបុលបំណុលដល់មនុស្សឯណោះ" ។

បទថា **បរបត្តិយា** "ដោយទ្រង់ទុកដាក់ព្រះទ័យក្នុងជនដទៃ" សេចក្តីថា នាងបក្សីកុណ្ឌលិនីក្រាបទូលថា "ព្រះអង្គទ្រង់កុំបានធ្វើសូម្បីដោយការទុកចិត្តអ្នកដទៃ គួរចាត់ការរាជកិច្ចទាំងអស់ដែលប្រច័ក្សដល់ព្រះអង្គប៉ុណ្ណោះ" ។

បទថា **អាយំ វយំ** **"ចំណូលចំណាយ"** សេចក្ដីថា ព្រះអង្គគួរជ្រាបនូវចំណូលដែលកើតអំពីផ្លូវនោះ និងគួរជ្រាបនូវចំណាយដែលគួរព្រះរាជទានដល់បុគ្គលផ្សេងៗ ដោយព្រះអង្គឯង ។ បទថា **កតាកតំ "កិច្ចដែលធ្វើហើយ និងមិនទាន់បានធ្វើ"** សេចក្ដីថា ក្នុងសង្គ្រាម ក្នុងនវកម្ម ឬក្នុងរាជកិច្ចដទៃៗ ព្រះអង្គគប្បីជ្រាបចំពោះរាជការនេះដោយព្រះអង្គឯងថា "កិច្ចនេះយើងត្រូវធ្វើដោយចំណែករាជទ្រព្យនេះ កិច្ចនេះមិនត្រូវធ្វើដោយចំណែករាជទ្រព្យនេះ" ទ្រង់កុំទុកព្រះទ័យក្នុងអ្នកដទៃ ។ បទថា **និគ្គណ្ហេ "បុគ្គលដែលគួរសង្កត់សង្កិន"** សេចក្ដីថា បពិត្រព្រះបិតា ធម្មតាព្រះរាជាត្រូវពិចារណាជម្រះដល់បុគ្គលអ្នកកាត់ទី.តជាដើម ដែលជាជនគួរសង្កត់សង្កិនដែលគេនាំមកសម្ដែង គួរត្រួតមើលចំពោះច្បាប់ដែលព្រះរាជាមុនៗកំណត់ទុក សឹមទ្រង់ដាក់ព្រះរាជអាជ្ញាតាមសមគួរដល់ទោស ។ បទថា **បគ្គណ្ហេ "បុគ្គលដែលគួរសរសើរ"** សេចក្ដីថា មយ៉ាងទៀត

បុគ្គលណាជាអ្នកគួរសរសើរ និងជាបុគ្គលកម្ចាត់កម្លាំងរបស់បរ-បក្ខដែលនរណាៗ កម្ចាត់មិនបានក្តី និងជាបុគ្គលលួងលោមកម្លាំងខ្លួនដែលបែកបាក់ក្តី ជាបុគ្គលនាំនូវរាជសម្បត្តិដែលមិនទាន់បានមកថ្វាយក្តី បុគ្គលដែលធ្វើរាជសម្បត្តិដែលបានមកហើយឲ្យជាថាវរៈក្តី ឬថា បុគ្គលណាជួយព្រះជន្មបាន ព្រះរាជាទ្រង់គប្បីសរសើរបុគ្គលដូច្នេះ ដែលជាបុគ្គលគួរសរសើរហើយ គួរត្រាស់បង្គាប់ឲ្យធ្វើនូវសក្ការៈសម្មានៈដ៏ធំ ហេតុដូច្នោះ សូម្បីជនដទៃៗ ក៏នឹងថ្វាយជីវិតធ្វើនូវកិច្ចដែលគួរធ្វើក្នុងរាជកិច្ចរបស់ព្រះរាជានោះ ។

បទថា **ជានបទំ** **"អ្នកជនបទ"** សេចក្តីថា ព្រះអង្គចូរទ្រង់អនុសាសន៍ប្រៀនប្រដៅអត្ថ និងធម៌ដល់អ្នកជនបទដោយព្រះអង្គឯង ដោយកតិកាច្បាស់លាស់ដល់ព្រះអង្គនោះឯង ។ បទថា **អ-ធម្មិកាយុត្តា**[1] **"អ្នកមិនប្រកបដោយធម៌"** សេចក្តីថា ក្អាក់ងារខ្ញុំ

---

បិដក. ១. អធម្មិកា យុត្តា ។

រាជការដែលមិនតាំងនៅក្នុងធម៌ ទទួលសំណូកក្នុងទីនោះៗ ហើយត្រឡប់ពាក្យពិភាក្សា កុំញុំាងព្រះរាជទ្រព្យ និងដែនរបស់ព្រះអង្គឲ្យវិនាសឡើយ ព្រោះហេតុនេះ ព្រះអង្គកុំប្រមាទ ចូរអនុសាសន៍ទូន្មានដោយព្រះអង្គឯងតែម្យ៉ាង ។

បទថា *វេគេន* *"ដោយប្រញាប់"* សេចក្តីថា ព្រះអង្គទ្រង់មិនទាន់បានសាកសួរ មិនទាន់បានពិចារណា ទ្រង់កុំធ្វើ ឬត្រាស់ឲ្យធ្វើដោយរួសរាន់ ។ បទថា *វេគសា* *"ដោយរួសរាន់"* សេចក្តីថា ព្រោះកម្មដែលមិនបានពិចារណា ធ្វើទៅដោយរួសរាន់ដោយអំណាចឆន្ទាគតិជាដើម មិនល្អមិនស្អាតឡើយ ។ ព្រោះហេតុអ្វី? ព្រោះហេតុថា បុគ្គលល្ងង់ធ្វើកម្មដូច្នោះ ក្រោយមករមែងក្តៅក្រហាយក្នុងលោកនេះ ដោយអំណាចវិប្បដិសារៈ និងកាលសោយទុក្ខក្នុងអបាយ រមែងក្តៅក្រហាយក្នុងលោកខាងមុខ ។ ក៏ខនេះ បណ្ឌិតគប្បីសម្តែងរឿងកុរុជាតក ដែលមានខ្លឹមសារថា "យើងបានឮថា

ព្រះបាទកុរុរាជទ្រង់ធ្វើខុសចំពោះឥសីទាំងឡាយ” ។

បទថា មា តេ អធិសរេ មុច្ច សុពាឡ្ហមធិកោបិតំ “ព្រះអង្គទ្រង់កុំកន្ទងកុសលឡើយ ទ្រង់កុំបណ្ដោយព្រះទ័យឲ្យក្រោធខ្លាំង” សេចក្ដីថា បពិត្រព្រះបិតា ព្រះអង្គទ្រង់កុំបណ្ដោយព្រះទ័យឲ្យខឹងក្រោធខ្លាំងទៅក្នុងអកុសលកម្មរបស់អ្នកដទៃ ដែលកន្ទងនូវកុសល គឺ កុំឲ្យតាំងនៅបាន ។ លោកអធិប្បាយទុកថា បពិត្រព្រះបិតា កាលណាពួករាជបុរសក្រាបទូលសម្ដែងចោរចំពោះព្រះអង្គ ដែលស្ថិតនៅត្រង់ទីវិនិច្ឆ័យថា ជននេះសម្លាប់មនុស្ស ឬថា ជននេះកាត់នូវទី.ត ក្នុងកាលនោះ ប្រោសកុំបណ្ដោយព្រះទ័យ សូម្បីទ្រង់ខឹងក្រោធខ្លាំង ដោយពាក្យរបស់អ្នកដទៃដែលទ្រង់ព្រះពិរោធ ដែលទ្រង់មិនទាន់បានពិចារណាហើយ កុំដាក់ព្រះអាជ្ញា ។ ព្រោះហេតុអ្វី? ព្រោះថា គេចាប់មនុស្សដែលមិនមែនចោរ ថាជាចោរនាំមកក៏បាន ដូច្នោះ ទ្រង់កុំពិរោធប្រោសស្ដាប់ពាក្យរបស់អ្នកដែលត្រូវ

ហេតុក៏ និងចម្លើយទាំងពីរចំណែក ទ្រង់ជម្រះដោយល្អ ដឹងថា គេជាចោរប្រាកដដោយព្រះអង្គឯង ទើបទ្រង់ធ្វើវត្ថុដែលគួរធ្វើ ដោយអំណាចនៃអាជ្ញាដែលកំណត់ទុកតាមព្រះរាជប្រពៃណី ក៏សូម្បីកើតសេចក្តីក្រោធឡើងហើយ ព្រះរាជាមិនបានធ្វើព្រះទ័យឲ្យត្រជាក់ជាមុន មិនគួរធ្វើការវិនិច្ឆ័យឡើយ ។ លុះកាលណាព្រះទ័យត្រជាក់រលត់ក្តៅ ទន់ភ្លន់ ក្នុងកាលនោះទើបគួរធ្វើការវិនិច្ឆ័យ ព្រោះកាលចិត្តក្រោតក្រោធ ហេតុផលរមែងមិនប្រាកដ ដូចកាលទឹកនៅកម្រើកស្រមោលមុខក៏មិនប្រាកដដូច្នោះ ។ បទថា **កោធសា ហិ** "**ព្រោះសេចក្តីក្រោធ**" សេចក្តីថា បពិត្រព្រះបិតា រាជត្រកូលទាំងឡាយដែលស្តុកស្តម្ភដ៏ច្រើន នឹងដល់នូវការមិនមានត្រកូល គឺ ដល់នូវសេចក្តីមហាវិនាសនោះឯង ក៏ព្រោះសេចក្តីក្រោធ ព្រោះហេតុនោះដើម្បីសម្តែងសេចក្តីនេះ គួរពោលដល់ខន្តិវាទីជាតក រឿងព្រះបាទនាឡិកីរាជ និងរឿងស្តេចអរជុនៈដែលមានកម្រងផ្កា ១.០០០ ជា

ដើម ។

បទថា **បតារយិ** *"ឲ្យធ្លាក់ចុះ"* សេចក្តីថា បពិត្រព្រះបិតា ព្រះអង្គទ្រង់កុំញ៉ាំងមហាជនឲ្យវង្វេង ធ្លាក់ចុះកាន់កាយទុច្ចរិតជាដើម ដើម្បីសេចក្តីវិនាសដោយទ្រង់គិតថា យើងជាធំលើផែនដី បុគ្គលកាន់យកនូវទុច្ចរិតដែលជាសេចក្តីវិនាសប្រព្រឹត្តទៅយ៉ាងណា ព្រះអង្គទ្រង់កុំបានធ្វើយ៉ាងនោះ ។ បទថា **មា តេ អាសិ** *"កុំមាន... របស់ព្រះអង្គឡើយ"* សេចក្តីថា បពិត្រព្រះបិតា ក្នុងដែនរបស់ព្រះអង្គ កម្រែ គឺ សេចក្តីទុក្ខកុំបានមានដល់បុរសស្ត្រីឡើយ មិនថាជាមនុស្ស ឬសត្វតិរច្ឆានក៏ដោយ ។ អធិប្បាយថា "ប្រជាជនក្នុងដែនរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ នាំគ្នាធ្វើកាយទុច្ចរិតជាដើម រមែងកើតក្នុងនរកយ៉ាងណា ចំពោះអ្នកដែនរបស់ព្រះអង្គ កុំបានមានដូច្នោះឡើយ គឺ សេចក្តីទុក្ខដូច្នោះនឹងមិនមានដល់អ្នកដែនរបស់ព្រះអង្គដោយវិធីណា ទ្រង់ធ្វើដោយវិធីនោះចុះ" ។

បទថា **អបេតលោមហំសស្ស** “**អ្នកប្រាសចាកការព្រឺរោម**” សេចក្តីថា អ្នកប្រាសចាកភ័យ ព្រោះភ័យមានការតិះដៀលខ្លួនជាដើម ។ ដោយបទនេះ នាងកុណ្ឌលិនីសម្តែងថា “បពិត្រព្រះបិតា ព្រះរាជាអង្គណាទ្រង់ធ្វើសេចក្តីសង្ស័យក្នុងអារម្មណ៍អ្វីហើយ ទ្រង់រលឹកដល់តែសេចក្តីប្រាថ្នារបស់ព្រះអង្គតែម្យ៉ាង ទ្រង់ប្រាថ្នាវត្ថុណាក៏ធ្វើវត្ថុនោះដោយអំណាចឆន្ទៈសេចក្តីពេញចិត្ត ដូចជាបុគ្គលខ្វាក់ភ្នែកលះបង់ឈើច្រត់ និងដូចជាដំរីកាចមិនមានកង្វេរ ភោគសម្បត្តិទាំងអស់របស់ព្រះរាជានោះ ដែលប្រាសចាកភ័យដូចជាការតិះដៀលជាដើម រមែងវិនាសទៅ ការវិនាសនៃភោគៈនោះ លោកពោលថាជាទុក្ខរបស់ព្រះរាជាអង្គនោះ” ។ បទថា **តត្ថេវ** “**ក្នុងបញ្ហា... នោះ**” សេចក្តីដែលក្រាបទូលមកនោះជាវត្ថុបទ គប្បីប្រកបដោយន័យមុននោះចុះ ។

បទថា **ទក្ខស្សុទានិ** “**ឥឡូវនេះ សូមព្រះអង្គទ្រង់ព្យាយាម**”

សេចក្តីថា បពិត្រព្រះបិតា ព្រះអង្គទ្រង់ស្តាប់អនុសាសនីនេះហើយ ឥឡូវនេះ គប្បីជាអ្នកព្យាយាម កុំខ្ជិល ទ្រង់សាងបុណ្យកុសល ហេតុបំពេញបុណ្យកុសល កុំជាអ្នកលេងសុរា ហេតុរក្សាដោយសុរាជាដើម កុំញុំាងព្រះអង្គឲ្យវិនាស ហេតុដែលមិនជាប្រយោជន៍បច្ចុប្បន្ន និងសម្បរាយិកកពឲ្យវិនាស ។ បទថា **សីលវស្សុ** “ទ្រទ្រង់នូវសីល” សេចក្តីថា ព្រះអង្គចូរជាអ្នកមានសីល សម្បូរដោយអាចារមារយាទ តាំងនៅក្នុងទសពិធរាជធម៌សោយរាជ្យសម្បត្តិ ។ បទថា **ទុស្សី លោ វិនិបាតកោ** “**បុគ្គលទ្រុស្តសីលរមែងធ្លាក់ចុះ**” សេចក្តីថា បពិត្រព្រះបិតា ព្រោះបុគ្គលទ្រុស្តសីល កាលញុំាងខ្លួនឲ្យធ្លាក់ទៅក្នុងនរក រមែងជាអ្នកឈ្មោះថា ធ្វើខ្លួនឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ។

សូម្បីនាងកុណ្ឌលិនី ក៏សម្តែងធម៌ដោយគាថា ១១ គាថា ដោយប្រការដូច្នេះ ។ ព្រះរាជាទ្រង់ពេញព្រះទ័យ ទ្រង់ត្រាស់ហៅ

អាមាត្យមកសួរថា "ម្នាលអាមាត្យដ៏ចម្រើនទាំងឡាយ យើងគួរធ្វើកិច្ចណាដល់កុណ្ឌលិនីរាជធីតារបស់យើង ដែលបានពោលធម៌ហើយយ៉ាងនេះ" ។

ពួកអាមាត្យក្រាបទូលថា "គួរប្រគល់តំណែងនាយឃ្លាំងឲ្យព្រះអង្គ" ត្រាស់ថា "បើដូច្នោះ យើងនឹងប្រគល់មុខនាទីតំណែងជានាយឃ្លាំងដល់ធីតារបស់យើង" ហើយទ្រង់តែងតាំងនាងកុណ្ឌលិនីទុកក្នុងឋានន្តរសក្តិ ។ ចាប់តាំងអំពីនោះមក នាងកុណ្ឌលិនីក៏តាំងនៅក្នុងតំណែងនាយឃ្លាំង បានធ្វើការស្នងរាជកិច្ចរបស់ព្រះបិតា ។

## ចប់កុណ្ឌលិនីបញ្ហា

កន្លងមកទៀត ២-៣ ថ្ងៃ ព្រះរាជាបញ្ជូនទូតទៅកាន់សម្នាក់របស់ជម្ពុកបណ្ឌិតដោយវិធីដើម ហើយស្ដេចទៅក្នុងសម្នាក់របស់បក្សីជម្ពុកបណ្ឌិតនោះ ក្នុងថ្ងៃទី ៧ ទ្រង់សោយសម្បត្តិហើយស្ដេចត្រឡប់មក ប្រថាប់នៅត្រង់កណ្ដាលមណ្ឌបនោះឯង ។ គ្រានោះអាមាត្យអញ្ជើញជម្ពុកបណ្ឌិត ទំលើតាំងមាស ហើយយកសីសៈទូលតាំងមាសមកគាល់ព្រះរាជា ។ ជម្ពុកបណ្ឌិតទំលើភ្លៅរបស់ព្រះរាជបិតាលេងហើយ ក៏ទំត្រង់តាំងមាសដូចដើម ។

លំដាប់នោះ កាលព្រះរាជាទ្រង់ត្រាស់សួរបញ្ហានឹងជម្ពុកបណ្ឌិត ទើបត្រាស់គាថាថា

[៥៧២] អបុច្ឆិម្ហា កោសិយគោត្តំ កុណ្ឌលិនឹ តថេវ ច

ជម្ពុក ត្វំ ទានិ វទេហិ ពលានំ ពលមុត្តមំ ។

ម្នាលជម្ពុកៈ បិតាបានសួរបញ្ហានឹងកោសិយគោត្ត និងកុណ្ឌលិនីមកជាមួយគ្នាហើយ ជម្ពុកៈកូនសម្លាញ់ គ្រានេះ

កូនចូរប្រាប់កម្លាំងដ៏ខ្ពង់ខ្ពស់ជាងកម្លាំងទាំងឡាយចុះ ។

ព្រះគាថានោះ មានអត្ថាធិប្បាយដូច្នេះ "នែជម្ពុកៈកូន បិតាបានសួររាជធម៌នឹងវេស្សន្តរៈជាកោសិយគោត្រ ដែលជាបងប្រុស និងនាងកុណ្ឌលិនីជាបងស្រីរបស់កូនហើយ ទាំងពីរនាក់ក៏ឆ្លើយតាមកម្លាំងបញ្ញារៀងៗខ្លួន មួយទៀត បិតាសួរបងប្រុស និងបងស្រីរបស់កូនយ៉ាងណា ជម្ពុកៈកូនសម្លាញ់ ឥឡូវនេះបិតានឹងសួរកូនដូច្នោះដូចគ្នា កូនចូរប្រាប់រាជធម៌នោះ ដោយកម្លាំងដ៏ខ្ពង់ខ្ពស់ជាងកម្លាំងទាំងឡាយផងចុះ ។

ព្រះរាជា កាលត្រាស់សួរបញ្ហានឹងព្រះមហាសត្វយ៉ាងនេះ មិនបានត្រាស់សួរតាមទំនងដែលត្រាស់សួរបក្សីដទៃៗ ឡើយ ទ្រង់ត្រាស់សួរឲ្យវិសេសឡើងទៅ ។ លំដាប់នោះ ជម្ពុកបណ្ឌិតទូលថា "បពិត្រមហារាជ បើដូច្នោះ សូមព្រះអង្គផ្ទៀងព្រះសោតស្តាប់ចុះ ខ្ញុំព្រះអង្គនឹងពោលបញ្ហាទាំងពួងថ្វាយចំពោះព្រះអង្គ" ដូច្នេះ

ដែលហាក់ដូចជាប្រាប់ថន់ទ្រព្យ ១.០០០ ដល់ហ្វូនជនដែលលាត
ដៃចាំទទួលដូច្នោះ ផ្តើមសម្តែងធម៌ជាគាថាថា

[៥៧៣] ពលំ បញ្ចវិធំ លោកេ បុរិសស្មឹ មហគ្គតេ
តត្ថ ពាហុពលំ នាម ចរិមំ វុច្ចតេ ពលំ
ភោគពលញ្ច ទីឃាវុ ទុតិយំ វុច្ចតេ ពលំ ។

កម្លាំងក្នុងបុរសអ្នកមានអធ្យាស្រ័យធំក្នុងលោកនេះ មាន
៥ ប្រការ ក្នុងកម្លាំង ៥ ប្រការនោះ កម្លាំងដៃ បណ្ឌិតពោល
ថាជាកម្លាំងចុងក្រោយ បពិត្រព្រះអង្គដ៏ចម្រើន កម្លាំងភោគ-
ទ្រព្យ បណ្ឌិតពោលថា ជាកម្លាំងទីពីរ ។

អមច្ចពលញ្ច ទីឃាវុ តតិយំ វុច្ចតេ ពលំ
អភិជច្ចពលញ្ចេវ តំ ចតុត្ថំ អសំសយំ
យានិ ចេតានិ សព្វានិ អធិគ្គណ្ហាតិ បណ្ឌិតោ ។

បពិត្រព្រះអង្គដ៏ចម្រើន កម្លាំងអាមាត្យ បណ្ឌិតពោលថា

ជាកម្លាំងទី ៣ កម្លាំង គឺ ការមានជាតិដ៏ធំ ជាកម្លាំងទី ៤

ដោយពិត បណ្ឌិតរមែងកាន់យកកម្លាំងទាំងអស់នេះបាន ។

តំ ពលានំ ពលំ សេដ្ឋំ    អគ្គំ បញ្ញាពលំ ពលំ

បញ្ញាពលេនុបត្ថម្ភោ    អត្ថំ វិន្ទតិ បណ្ឌិតោ ។

កម្លាំងបញ្ញា បណ្ឌិតពោលថា ជាកម្លាំងដ៏ប្រសើរលើស

កម្លាំងទាំងឡាយ ព្រោះថា បណ្ឌិតដែលកម្លាំងបញ្ញាឧបត្ថម្ភ

ហើយ រមែងបាននូវប្រយោជន៍ ។

អបិ ចេ លភតិ មន្ទោ    ផីតំ    ធរណិមុត្តមំ

អកាមស្ស បសយ្ហំ វា    អញ្ញោ តំ បដិបជ្ជតិ ។

បើបុគ្គលមានបញ្ញាថោកទាប សូម្បីតែផែនដីដ៏ឧត្តម សម្បូរ

កាលគេមិនបំណងនឹងឲ្យអ្នកដទៃ ដែលដល់ព្រមដោយបញ្ញា

ក៏ញាំញីដណ្តើមយកផែនដីនោះបាន ។

អភិជាតោបិ ចេ ហោតិ    រជ្ជំ លទ្ធាន ខត្តិយោ

ទុប្បញ្ញោ ហិ កាសិបតិ សព្វេនបិ ន ជីវតិ ។

បពិត្រព្រះអង្គជាធំលើជនអ្នកដែនកាសី បើបុគ្គលសូម្បីជាអ្នកមានជាតិខ្ពង់ខ្ពស់ បានរាជ្យសម្បត្តិជាក្សត្រហើយ តែមានបញ្ញាថោកទាប នឹងតាំងព្រះជន្មនៅដោយរាជ្យសម្បត្តិគ្រប់យ៉ាងមិនបាន ។

បញ្ញា សុតវិនិច្ឆិនី បញ្ញា (កិត្តិ) សិលោកវឌ្ឍនី

បញ្ញាសហិតោ នរោ ឥធ (អបិ) ទុក្ខេ សុខានិ វិន្ទតិ ។

បញ្ញាជាគ្រឿងវិនិច្ឆ័យរឿងដែលបានស្តាប់ បញ្ញាជាគ្រឿងញុំាងកិត្តិយស និងលាភសក្ការៈឲ្យចម្រើន បុគ្គលក្នុងលោកនេះ ប្រកបដោយបញ្ញាហើយ សូម្បីកាលទុក្ខកើតឡើង ក៏រមែងបានទទួលសេចក្តីសុខ ។

បញ្ញញ្ច ខោ អសុស្សូសំ ន កោចិ អធិគច្ឆតិ

ពហុស្សុតំ អនាគម្ម ធម្មដ្ឋំ អវិនិព្ភុជំ ។

ក៏បុគ្គលខ្លះមិនតាំងចិត្តដោយល្អ មិនអាស្រ័យអ្នកជាពហូ-សូតដែលតាំងនៅក្នុងធម៌ មិនពិចារណាហេតុផល រមែងមិនបាននូវបញ្ញា ។

យោ ច ធម្មវិភង្គញ្ញូ កាលុដ្ឋាយី អតន្ទិតោ
អនុដ្ឋហតិ កាលេន កម្មផលំ តស្ស ឥជ្ឈតិ ។

មួយទៀត បុគ្គលណាដឹងនូវចំណែកធម៌ ក្រោកឡើងក្នុងវេលាព្រឹក មិនខ្ជិលច្រអូស រមែងព្យាយាមតាមកាល ផលនៃការងាររបស់បុគ្គលនោះរមែងសម្រេច ។

អនាយតនសីលស្ស អនាយតនសេវិនោ
ន និព្វិន្ទិយការិស្ស សម្មទត្ថោ វិបច្ចតិ ។

ប្រយោជន៍របស់បុគ្គលអ្នកមិនបង្កើតសីល ដែលគប់រកបុគ្គលអ្នកមិនបង្កើតសីល អ្នកមានប្រក្រតីនឿយណាយក្នុងការងារ រមែងបានផលមិនល្អ ។

អជ្ឈត្តញ្ច បយុត្តស្ស តថាយតនសេវិនោ
អនិព្វិន្ទិយការិស្ស សម្មទត្ថោ វិបច្ចតិ ។

ចំណែកប្រយោជន៍របស់បុគ្គលអ្នកប្រកបធម៌ដែលជាខាងក្នុង អ្នកគប់រកបុគ្គលដែលបង្កើតសីលនោះ មានប្រក្រតីមិននឿយណាយក្នុងការងារ រមែងសម្រេចផលដោយល្អ ។

យោគប្បយោគសង្ខាតំ សម្ភតស្សានុរក្ខនំ
តានិ ត្វំ តាត សេវស្សុ មា អកម្មាយ រន្ធយិ
អកម្មុនា ហិ ទុម្មេធោ នឡាគារំវ សីទតិ ។

បពិត្រព្រះបិតា សូមព្រះអង្គទ្រង់ស្វែងរកនូវបញ្ញា គឺការតាមប្រកបសេចក្ដីព្យាយាមក្នុងហេតុដែលគួរប្រកប និងការស្វែងរកការអនុរក្សទ្រព្យដែលទ្រង់រួបរួមទុកទាំងពីរយ៉ាងនោះចុះ ទ្រង់កុំបានទម្លាយទ្រព្យដោយហេតុមិនសមគួរ ព្រោះបុគ្គលមានបញ្ញាថោកទាប រមែងលិចចុះដោយការធ្វើដែលមិន

សមគួរ ដូចផ្ទះបបុសដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **មហគ្គតេ** “អ្នកមានអធ្យាស្រ័យធំ” សេចក្តីថា បពិត្រមហារាជ កម្លាំងក្នុងបុរសអ្នកមានអធ្យាស្រ័យធំក្នុងសត្វលោកមាន ៥ យ៉ាង ។ បទថា **ពាហុពលំ** “កម្លាំងដៃ” បានដល់ កម្លាំងកាយ ។ បទថា **ចរិមំ** “កម្លាំងចុងក្រោយ” ន័យថា កម្លាំងកាយនោះ សូម្បីជារបស់ធំក៏ជាកម្លាំងចុងក្រោយនោះឯង ព្រោះហេតុអ្វី ព្រោះជាកម្លាំងរបស់អន្ធពាល អធិប្បាយថា ប្រសិនបើកម្លាំងកាយឈ្មោះថាធំពិត កម្លាំងនាងចាបក៏រមែងតូចជាងកម្លាំងរបស់ដំរី ។ តែកម្លាំងរបស់ដំរីជាបច្ច័យនៃសេចក្តីស្លាប់ ព្រោះជាកម្លាំងអន្ធពាល ។ នាងចាបក៏ញ៉ាំងដំរីឲ្យដល់នូវការអស់ជីវិតបាន ព្រោះវាជាសត្វឈ្លាសក្នុងការដឹង ។ តែក្នុងសេចក្តីនេះ កិច្ចដោយកម្លាំងក្នុងទីគ្រប់កន្លែងមិនមានឡើយ ។ គួរនាំព្រះសូត្រថា “ពិតហើយ កម្លាំងរមែងមានទុកដើម្បីសម្លាប់បុគ្គលល្ងង់” ជាដើមមក

*សម្តែង ។*

*បទថា **ភោគពលំ "កម្លាំងភោគទ្រព្យ"** សេចក្តីថា កម្លាំងដែលកើតអំពីគ្រឿងឧបភោគដូចជាមាសប្រាក់ជាដើមទាំងអស់ ក៏ឈ្មោះថា កម្លាំង គឺ ភោគសម្បត្តិ កម្លាំងភោគសម្បត្តិនោះធំជាងកម្លាំងកាយ ដោយអំណាចជាគ្រឿងឧបត្ថម្ភ ។ បទថា **អមច្ចពលំ "កម្លាំងអាមាត្យ"** សេចក្តីថា ការមានជំរំអាមាត្យដែលមានមន្តមិនទម្លាយ មានសភាពក្លៀវក្លា មានចិត្តល្អ កម្លាំង គឺ អាមាត្យនោះជាកម្លាំងធំជាងកម្លាំងពីរយ៉ាងខាងដើម ព្រោះអាមាត្យជាអ្នកក្លៀវ-ក្លាក្នុងសង្គ្រាម ។ បទថា **អភិជច្ចពលំ "កម្លាំង គឺ ការមានជាតិជាធំ"** សេចក្តីថា ការដល់ព្រមនៃជាតិដោយអំណាចនៃត្រកូលក្សត្រឈានកន្ទងនូវត្រកូលទាំងបី កម្លាំង គឺ ភាពជាអ្នកមានជាតិខ្ពង់ខ្ពស់នោះធំជាងកម្លាំងក្រៅអំពីនេះ ព្រោះថា ជនអ្នកដល់ព្រមដោយជាតិប៉ុណ្ណោះរមែងបរិសុទ្ធ ជនក្រៅអំពីនេះរកបរិសុទ្ធមិនបាន ។*

បទថា **យានិ ចេតានិ** *"ទាំងអស់"* សេចក្តីថា បណ្ឌិតរមែងកាន់យក គឺ រមែងគ្របសង្កត់កម្លាំងសូម្បីទាំង ៤ យ៉ាងនេះ បានដោយអានុភាពនៃកម្លាំងណា កម្លាំងនោះបានដល់កម្លាំងបញ្ញា លោកពោលថា ជារបស់ប្រសើរ ថាជាកំពូលនៃកម្លាំងទាំងពួង ព្រោះហេតុអ្វី? ព្រោះបណ្ឌិតដែលកម្លាំងប្រភេទនោះឧបត្ថម្ភ រមែងបាននូវប្រយោជន៍ គឺ រមែងដល់នូវការចម្រើន ។ ដើម្បីនឹងញ៉ាំងសេចក្តីនោះឲ្យជាក់ច្បាស់ គួរសម្តែងបុណ្ណកទីជាតក ដែលថា "ក៏ជនទាំងឡាយពោលដល់ទន្លេដែលពេញច្រាំងថា ដែលសត្វណាគប្បីផឹកបាន" ដូច្នេះជាដើម និងគប្បីសម្តែងសិរិកាឡកណ្ណប្បញ្ហា បញ្ចបណ្ឌិតបញ្ហា សត្តុភស្តជាតក សម្ភវជាតក និងសរភង្គជាតក ជាដើម ។

បទថា **មន្ទោ** *"មានបញ្ញាថោកទាប"* បានដល់ បុគ្គលមានបញ្ញាថោកទាប គឺ បុគ្គលល្ងង់ ។ បទថា **ផីតំ** *"សម្បូរ"* សេចក្តី

ថា បពិត្រព្រះបិតា បុគ្គលអ្នកមានបញ្ញាថោកទាប សូម្បីបានទូវធរណីដ៏ឧត្តម សម្បូរទៅដោយរតនៈ ៧ ប្រការសោត កាលមិនប្រាថ្នាលះបង់ ឯបុគ្គលដទៃអ្នកសម្បូរដោយបញ្ញា នឹងធ្វើការញាំញីហើយគ្រប់គ្រងធរណីនោះបាន ព្រោះបុគ្គលមានបញ្ញាថោកទាបរមែងមិនអាចនឹងរក្សាយសដែលបានហើយ ឬថា មិនអាចដើម្បីនឹងបានរាជ្យសម្បត្តិដែលជាមត៌ករបស់ត្រកូល ឬដែលមកដល់ហើយដោយប្រពៃណីដែលស្តុកស្តម្ភសម្បូរបាន ។ ដើម្បីអធិប្បាយសេចក្តីនោះឲ្យជាក់ច្បាស់ បណ្ឌិតគប្បីសម្តែងបាទញ្ជលិជាតក ដែលថា "បាទញ្ជលីរាជកុមារ រមែងរុងរោចន៍កន្លងយើងទាំងឡាយ ដោយបញ្ញាដោយពិត" ដូច្នេះជាដើម ។

បទថា **លទ្ធាន** **"បាន"** សេចក្តីថា បុគ្គលអាស្រ័យជាតិ-សម្បត្តិហើយ សូម្បីនឹងបានរាជ្យសម្បត្តិហើយ សូម្បីនឹងបានរាជ្យ-សម្បត្តិដែលជារបស់ត្រកូល ។ បទថា **សព្វេនបិ** **"គ្រប់យ៉ាង"**

សេចក្តីថា បុគ្គលមានបញ្ញាថោកទាបរមែងនៅដោយរាជ្យសម្បត្តិទាំងអស់មិនបាន គឺ រមែងជាអ្នកដល់នូវសេចក្តីលំបាក ព្រោះភាពជាអ្នកមិនឈ្លាសក្នុងឧបាយ ។ ព្រះមហាសត្វពោលទោសរបស់ជនមិនមែនជាបណ្ឌិតដោយឋានៈប៉ុណ្ណេះដូច្នេះហើយ ឥឡូវនេះ កាលនឹងសរសើរបញ្ញា ទើបពោលពាក្យមានជាអាទិថា **បញ្ញា** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុតំ** **“រឿងដែលបានស្ដាប់”** បានដល់ ការរៀនដោយការស្ដាប់ ។ ពិតណាស់ បញ្ញានោះឯងរមែងវិនិច្ឆ័យវត្ថុដែលបានឮបានស្ដាប់នោះ ។ បទថា **កិត្តិសិលោកវឌ្ឍនី**[១] **“ជាគ្រឿងញ៉ាំងកិត្តិយស និងលាភសក្ការៈឲ្យចម្រើន”** បានដល់ ជាគ្រឿងចម្រើននៃកិត្តិយសកេរ្តិ៍ឈ្មោះ និងលាភសក្ការៈ ។ បុគ្គលអ្នកប្រកបដោយបញ្ញាសូម្បីកាលទុក្ខកើតឡើង រមែងជាអ្នកផុតភ័យត្រឡប់បានសេចក្តីសុខ ព្រោះជាអ្នកឈ្លាសក្នុងឧបាយ ។

---

បិដក. ១. (កិត្តិ) សិលោកវឌ្ឍនី ។

ដើម្បីនឹងសម្ដែងសេចក្ដីនោះ គួរសម្ដែងជាតក (វានរិន្ទជាតក និង សុំសុមារជាតក) ដែលជាគាថាមានខ្លឹមសារជាដើមថា

"ស្ដេចពានរ ធម៌ ៤ ប្រការទាំងនេះ គឺ សច្ចៈ ធម្មៈ ធិតិ និងចាគៈរបស់បុគ្គលណា ដូចមានក្នុងលោក បុគ្គលនោះរមែងរួចពីសត្រូវទៅបាន" និងថា "យើងមិនត្រូវការផ្លែស្វាយ ព្រីង និងខ្នុរទាំងនេះ" ។

បទថា អសុស្សូសំ "មិនតាំងចិត្តស្ដាប់ដោយល្អ" សេចក្ដីថា មិនចូលទៅជិត មិនស្ដាប់បុគ្គលជាបណ្ឌិត ។ បទថា ពហុស្សុតំ អនាគម្ម "មិនអាស្រ័យអ្នកជាពហូសូត" សេចក្ដីថា មិនជឿស្ដាប់ពាក្យរបស់គេ ។ បទថា ធម្មដ្ឋំ "ដែលតាំងនៅក្នុងធម៌" សេចក្ដីថា បពិត្រព្រះបិតា នរណាៗ មិនគិត គឺ មិនពិចារណាថា "ជាប្រយោជន៍ ឬមិន មានហេតុផល ឬមិនមាន" រមែងមិនបាននូវបញ្ញា ។

បទថា **ធម្មវិភង្គញ្ញូ** “ដឹងនូវចំណែកធម៌” សេចក្តីថា ជាអ្នកឈ្លាសក្នុងកុសលកម្មបថ ១០ ។ បទថា **កាលុដ្ឋាយី** “ក្រោកឡើងក្នុងវេលាព្រឹក” សេចក្តីថា ធ្វើសេចក្តីព្យាយាមក្នុងវេលាដែលគួរធ្វើសេចក្តីព្យាយាម ។ បទថា **អនុដ្ឋហតិ** “រមែងប្រឹងប្រែង” គឺរមែងធ្វើនូវកិច្ចនោះៗ ក្នុងកាលនោះៗ ។ បទថា **តស្ស** “របស់បុគ្គលនោះ” សេចក្តីថា ផលនៃកម្មរបស់បុគ្គលនោះរមែងសម្រេច គឺ រមែងសម្រេចផល ។

បទថា **អនាយតនសីលស្ស** “ដែលមិនមែនបង្កើតនៃសីល” សេចក្តីថា កម្ម គឺ ភាពជាអ្នកទ្រុស្តសីល មិនមែនបង្កើតនៃលាភយស និងសេចក្តីសុខ លោកហៅថា កម្មមិនមែនបង្កើត កាលបុគ្គលអ្នកមានប្រក្រតីយ៉ាងនោះ គឺ បុគ្គលអ្នកប្រកបដោយកម្ម គឺ ភាពជាអ្នកទ្រុស្តសីលនោះ ស្វែងរកហើយនូវបុគ្គលទ្រុស្តសីលដែលជាអ្នកមិនមែនបង្កើតតែម្យ៉ាង ក្នុងកាលធ្វើកុសលកម្ម ។ បទថា និ-

*ព្វិន្ទិយការិស្ស "អ្នកមានប្រក្រតីនឿយណាយក្នុងការងារ" សេចក្តីថា អ្នកនឿយណាយ គឺ ធុញទ្រាន់ក្នុងការងារ ។ អធិប្បាយថា បពិត្រព្រះបិតា ប្រយោជន៍នៃការងាររបស់បុគ្គលបែបនេះ រមែងមិនមានផល គឺ មិនសម្រេចដោយល្អ បានដល់ មិននាំទៅកាន់ឆកាមាវចរសួគ៌ ដែលជាកំពូលនៃត្រកូលទាំងឡាយ ។*

*បទថា **អជ្ឈត្តញ្ច** "ជាខាងក្នុង" សេចក្តីថា កាលបុគ្គលប្រកបនូវនិយកជ្ឈត្តធម៌របស់ខ្លួន ដោយអំណាចនៃការបំពេញភាពជារបស់មិនទៀងជាដើម ។ បទថា **តថាយតនសេវិនោ** "អ្នកគប់រកបុគ្គលដែលបង្កើតនៃសីលនោះ" សេចក្តីថា គប់រកអ្នកមានសីលជាប្រក្រតីនោះតែម្យ៉ាង ។ បទថា **វិបច្ចតិ** "រមែងសម្រេចផល" សេចក្តីថា ប្រយោជន៍របស់គេរមែងសម្រេចដោយល្អ គឺ រមែងឲ្យនូវយសដ៏ធំ ។*

*បទថា **យោគប្បយោគសង្ខាតំ** "គឺការតាមប្រកបនូវសេចក្តី*

ព្យាយាម" បានដល់ បញ្ញាជាចំណែកនៃការប្រកបក្នុងហេតុការណ៍ដែលសមគួរប្រកប ព្រោះសេចក្ដីព្យាយាម ។ បទថា **សម្ភតស្ស** "ដែលទ្រង់រួបរួមទុក" សេចក្ដីថា ចូរសេពការតាមរក្សាទ្រព្យដែលធ្វើការរួបរួមទុក ។ បទថា **តានិ ត្វំ** "សូមព្រះអង្គ... នោះ" គឺ បពិត្រព្រះបិតា សូមព្រះអង្គចូរបដិបត្តិតាមរក្សាទ្រព្យដែលបានរួបរួមទុក ប្រោសបដិបត្តិតាមពាក្យទូន្មានខាងដើមនេះ និងហេតុផលទាំងអស់ដូចដែលខ្ញុំព្រះអង្គបានទូលហើយ ចូរធ្វើឱវាទដែលទូលមកហើយទុកក្នុងព្រះហឫទ័យ ហើយទ្រង់រក្សាព្រះរាជទ្រព្យ ក្នុងព្រះឃ្លាំងរបស់ព្រះអង្គចុះ ។ បទថា **មា អកម្មាយ រន្ធយិ** "ទ្រង់កុំបានទម្លាយទ្រព្យដោយហេតុដែលមិនគួរ" សេចក្ដីថា ព្រះអង្គទ្រង់កុំទម្លាយដោយផ្លូវដែលមិនសមគួរ មិនមានហេតុផល គឺ កុំបំផ្លាញព្រះរាជទ្រព្យនោះ បានដល់ ទ្រង់កុំញ៉ាំងព្រះរាជទ្រព្យនោះឲ្យវិនាស ។ ព្រោះហេតុអ្វី? ព្រោះការធ្វើមិនសមគួរ ។ បទថា

អកម្មុនា “ដោយការធ្វើមិនសមគួរ” សេចក្តីថា ព្រោះធ្វើកម្មដែលមិនសមគួរ បុគ្គលអ្នកមានបញ្ញាថោកទាបបំផ្លាញទ្រព្យខ្លួនវិនាស ហើយក្រោយមកក៏ត្រូវទុក្ខលំបាក ។ បទថា **នឡាគារំវ សីទតិ “រមែងលិចចុះ... ដូចផ្ទះដើមបបុសដូច្នោះ”** មានសេចក្តីថា ផ្ទះដើមបបុសដែលចាស់គ្រាំគ្រាតាំងនៅមិនបាន រមែងរលំដួលតាំងអំពីក្រោមយ៉ាងណា បុគ្គលមានបញ្ញាថោកទាបបំផ្លាញទ្រព្យឲ្យវិនាសដោយមិនមានហេតុផល រមែងកើតក្នុងអបាយក៏ដូច្នោះ ។

ព្រះមហាសត្វបានពណ៌នាកម្លាំង ៥ យ៉ាង ដោយឋានៈមានប្រមាណប៉ុណ្ណេះហើយ លើកកម្លាំង គឺ បញ្ញាឡើងពោល ដូចជាបុគ្គលនាំមណ្ឌលនៃព្រះចន្ទទៅ កាលនឹងថ្វាយឱវាទដល់ព្រះរាជាដោយគាថាទាំង ១០ ក្នុងពេលនេះ ទើបពោលគាថាថា

[៥៧៤] ធម្មញ្ចរ មហារាជ មាតាបិតូសុ ខត្តិយ
ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងព្រះរាជមាតាព្រះរាជបិតា គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ បុត្តទារេសុ ខត្តិយ

ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងព្រះរាជឱរស និងព្រះអគ្គមហេសី គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ មិត្តាមច្ចេសុ ខត្តិយ

ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងមិត្ត និងអាមាត្យ គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ វាហនេសុ ពលេសុ ច

ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងរាជពាហនៈ និងពលនិកាយ គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ គាមេសុ និគមេសុ ច

ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងអ្នកស្រុក និងអ្នកនិគម គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ រដ្ឋេសុ ជនបទេសុ ច

ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌

ក្នុងអ្នកដែន និងអ្នកជនបទ គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោក
នេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ សមណេ ព្រាហ្មណេសុ ច
ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌
ក្នុងសមណៈ និងព្រាហ្មណ៍ទាំងឡាយ គ្រាទ្រង់ប្រព្រឹត្តធម៌
ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ មិគបក្ខីសុ ខត្តិយ
ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌
ក្នុងពួកម្រឹគ និងសត្វបក្សី គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះ
ហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ ធម្មោ ចិណ្ណោ សុខាវហោ

ឥធ ធម្មញ្ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ ព្រោះធម៌ដែលបុគ្គលប្រព្រឹត្តហើយ រមែងនាំសេចក្ដីសុខមកឲ្យ គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្ដេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ ឥន្ទា ទេវា សព្រហ្មកា

សុចិណ្ណេន ទិវំ បត្តា មា ធម្មំ រាជ បាមទោ[1] ។

បពិត្រព្រះខត្តិយមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ ព្រោះថា ព្រះឥន្ទ ពួកទេវតាព្រមទាំងព្រហ្មដល់នូវទិព្វស្ថានបាន ដោយធម៌ដែលខ្លួនប្រព្រឹត្តហើយ បពិត្រព្រះតេជះ សូមព្រះអង្គទ្រង់កុំប្រមាទក្នុងធម៌ឡើយ ។

ក្នុងគាថាទាំង ១០ នោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១

---

១.ម. បមាទោ ។

មុន ៗ បទថា **ឥធ ធម្មំ** ប្រព្រឹត្តធម៌ក្នុងលោកនេះ” សេចក្ដីថា សូមព្រះអង្គទ្រង់ចូរប្រព្រឹត្តមាតាបិតុបដ្ឋានធម៌ ។ ព្រះមហាសត្វពោលថា “ព្រះអង្គប្រោសស្ដេចក្រោកឡើងអំពីព្រឹក ហើយចាត់ចែងទឹកខ្ពុរមាត់ និងឈើស្ទន់ជាដើម ធ្វើការរក្សាសរីរៈកិច្ចគ្រប់យ៉ាងឲ្យបរិបូណ៌ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងមាតាបិតា ។

បទថា **បុត្តទារេសុ** “ក្នុងព្រះរាជឱរស និងព្រះអគ្គមហេសី” សេចក្ដីថា បិតាហាមបុត្តធីតាចាកអំពើអាក្រក់មុននឹងឲ្យតាំងនៅក្នុងកម្មជាការងារ ឲ្យសិក្សាសិល្បៈវិជ្ជាក្នុងវេលាចម្រើនវ័យ ចាត់ចែងអាវាហមង្គល និងវិវាហមង្គលដោយត្រកូល និងវ័យដែលគួរដល់គ្នា ប្រគល់ទ្រព្យឲ្យក្នុងសម័យ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងបុត្តធីតា ស្វាមីលើកតម្កើងរាប់អានភរិយា មិនប្រព្រឹត្តក្បត់ចិត្ត ប្រគល់ភាពជាធំឲ្យ ឲ្យគ្រឿងប្រដាប់ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងភរិយា ។

បទថា **មិត្តាមច្ចេសុ** “ក្នុងមិត្ត និងអាមាត្យ” សេចក្ដីថា ព្រះ

រាជាសង្គ្រោះមិត្ត និងអាមាត្យដោយសង្គហវត្ថុ ៤ ប្រការ មិនក្លែងពោលឲ្យឃ្លាតចាកសេចក្តីពិត ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងមិត្ត និងអាមាត្យទាំងនោះ ។

បទថា *វាហនេសុ ពលេសុ ច* “ក្នុងរាជពាហនៈ និងក្នុងពលនិកាយ” សេចក្តីថា ព្រះរាជាព្រះរាជទានវត្ថុដែលគួរព្រះរាជ-ទានដល់ពាហនៈ ដូចជាដំរី សេះជាដើម និងដល់ពលនិកាយ មិនធ្វើការបង្ខំប្រើដំរីសេះជាដើមក្នុងការងារក្នុងវេលាចាស់ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងរាជពាហនៈ និងពលនិកាយនោះ ។

បទថា *គាមេសុ និគមេសុ ច* “ក្នុងអ្នកស្រុក និងអ្នកនិគម” សេចក្តីថា ព្រះរាជាកាលមិនបៀតបៀនអ្នកស្រុក និងអ្នកនិគមដោយអាជ្ញា និងសួយសារអាករ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងអ្នកស្រុក និងអ្នកនិគម ។

បទថា *រដ្ឋេសុ ជនបទេសុ ច* “ក្នុងអ្នកដែន និងអ្នកជនបទ”

សេចក្តីថា ព្រះរាជាបៀតបៀនអ្នកដែន និងអ្នកជនបទឲ្យលំបាក ដោយប្រើហេតុ មិនចូលទៅតាំងទុកនូវចិត្តឲ្យទូលាយ ឈ្មោះថា មិនប្រព្រឹត្តធម៌ក្នុងអ្នកដែន និងអ្នកជនបទនោះ បើមិនបៀតបៀន ហើយផ្សាយមេត្តាទៅដោយចិត្តទូលាយ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុង អ្នកដែន និងអ្នកជនបទនោះឯង ។

បទថា សមណេ ព្រាហ្មណេសុ ច "ក្នុងសមណៈ និងព្រាហ្មណ៍ទាំងឡាយ" សេចក្តីថា ព្រះរាជាកាលព្រះរាជទានចតុប្បច្ច័យ ដល់សមណព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងសមណៈ និងព្រាហ្មណ៍ ។

បទថា មិគបក្ខេសុ ច[១] "ក្នុងពួកម្រឹគ និងសត្វបក្សី" គឺ ព្រះរាជាកាលព្រះរាជទានអភ័យដល់សត្វជើងបួន និងបក្សីទាំងពួង ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងម្រឹគជាតិ និងពួកបក្សីនោះឯង ។

---

បិដក. ១. មិគបក្ខីសុ ខត្តិយ ។

បទថា **ធម្មោ សុចិណ្ណោ** “ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ” សេចក្តីថា ធម៌ដែលប្រព្រឹត្តស្មើ ដែលព្រះរាជាប្រព្រឹត្តហើយ គឺនិសម្មចរិយធម៌ដែលព្រះរាជាទ្រង់ប្រព្រឹត្តហើយ ។ បទថា **សុខាវហោ** “នាំសេចក្តីសុខមកឲ្យ” សេចក្តីថា រមែងនាំមកនូវសេចក្តីសុខក្នុងកុសលសម្បត្តិ ៣ និងឆកាមាវចរសួគ៌ ។

បទថា **សុចិណ្ណេន** “ដែលខ្លួនប្រព្រឹត្តល្អហើយ” សេចក្តីថា ព្រោះកាយសុចរិតជាដើម ដែលព្រះអង្គទ្រង់ប្រព្រឹត្តល្អហើយក្នុងលោកនេះ ។ បទថា **ទិវំ បត្តា** “ដល់ទិព្វស្ថាន” សេចក្តីថា ព្រះឥន្ទ្រ ពួកទេវតាព្រមទាំងព្រហ្ម ទៅកាន់ទិព្វស្ថាន ពោលគឺ ទេវលោកនិងព្រហ្មលោក បានដល់ កើតជាអ្នកបាននូវទិព្វសម្បត្តិក្នុងទិព្វស្ថាននោះ ។ បទថា **មា ធម្មំ រាជា បមាទោ**[១] “សូមព្រះអង្គទ្រង់កុំប្រមាទក្នុងធម៌ឡើយ” សេចក្តីថា បពិត្រមហារាជ ព្រោះ

---

បិដក. ១. បាមទោ ។

ដូច្នោះ ព្រះអង្គសូម្បីនឹងត្រូវបង់ព្រះជន្ម ក៏ទ្រង់កុំប្រមាទក្នុងធម៌ ។

ព្រះមហាសត្វពោលគាថាសម្ដែងធម្មចរិយា ១០ យ៉ាងដូច្នេះហើយ កាលនឹងប្រទានឱវាទឲ្យក្រៃលែងឡើង ទើបពោលគាថាចុងក្រោយថា

តត្ថេវ តេ វត្តបទា ឯសាវ អនុសាសនី
សប្បញ្ញសេវិ កល្យាណី សមត្តំ សាម តំ វិទូតិ ។

ប្រការដែលខ្ញុំព្រះអង្គក្រាបទូលហើយក្នុងបញ្ហារបស់ព្រះអង្គនោះ ជាវត្តបទ ប្រការនេះឯងជាអនុសាសនី សូមព្រះអង្គទ្រង់គប់រកសមាគមជាមួយអ្នកមានបញ្ញា ចូរជាអ្នកមានកល្យាណធម៌ ព្រះអង្គទ្រង់ជ្រាបនូវប្រការនោះដោយព្រះអង្គឯងហើយ ទ្រង់ចូរបដិបត្តិឲ្យគ្រប់ចំណែកចុះ ។

បណ្ដាបទទាំងនោះ បទថា តត្ថេវ តេ វត្តបទា "ក្នុងបញ្ហារបស់ព្រះអង្គនោះ ជាវត្តបទ" នេះ គប្បីប្រកបដោយន័យមុននោះ

ចុះ ។ បទថា សប្បញ្ញសេវិ កល្យាណី សមត្តំ សាម តំ វិទូ "សូមព្រះអង្គទ្រង់គប់រកសមាគមជាមួយអ្នកមានបញ្ញា ចូរជាអ្នកមានកល្យាណធម៌ ព្រះអង្គទ្រង់ជ្រាបសេចក្តីនោះដោយព្រះអង្គឯងហើយ ចូរទ្រង់បដិបត្តិឲ្យគ្រប់សព្វចុះ" សេចក្តីថា បពិត្រព្រះតេជះព្រះអង្គ ប្រោសគប់រកបុគ្គលដែលមានបញ្ញាជានិច្ចកាល ចូរប្រកបដោយគុណដ៏ស្អាត ទ្រង់ដឹងច្បាស់ដោយសព្វគ្រប់បរិបូណ៌ដោយព្រះអង្គឯង គឺ ទ្រង់ជ្រាបច្បាស់ ដោយប្រច័ក្សដោយព្រះអង្គឯងហើយ ប្រោសបដិបត្តិឱវាទដែលខ្ញុំព្រះអង្គក្រាបទូលហើយចុះ ។

ព្រះមហាសត្វសម្តែងធម៌ដោយពុទ្ធលីលាដូច្នេះ ប្រៀបដូចជាទេវតាដ៏វិសេសញ៉ាំងទឹកក្នុងអាកាសឲ្យធ្លាក់ចុះមកដូច្នេះ ។ ឯមហាជនបានធ្វើមហាសក្ការៈ ហើយឲ្យសាធុការ ១.០០០ ដង ។ ព្រះរាជាទ្រង់ពេញព្រះទ័យ ហៅអាមាត្យមកត្រាស់សួរថា "ម្នាលអាមាត្យដ៏ចម្រើនទាំងឡាយ ជម្ពុកបណ្ឌិតអ្នកមានចំពុះស្មើដោយ

ផ្លែជម្ពូទ្វីដែលជាបុត្ររបស់យើង បានពោលហើយយ៉ាងនេះ យើង គួរធ្វើការតបស្នងដោយវត្ថុណា?" អាមាត្យទាំងឡាយក្រាបទូលថា "បពិត្រព្រះតេជះ គួរធ្វើការតបស្នងដោយតំណែងសេនាបតី ព្រះអង្គ" ។ ព្រះរាជាត្រាស់ថា "បើដូច្នោះ យើងនឹងព្រះរាជទានតំណែងសេនាបតីដល់ជម្ពុកៈនោះ" ហើយទ្រង់តែងតាំងជម្ពុកពោធិសត្វទុកក្នុងឋានន្តរសក្តិ ។ ចាប់តាំងអំពីនោះមក ជម្ពុកពោធិសត្វ តាំងនៅក្នុងតំណែងសេនាបតី បានធ្វើការស្នងរាជកិច្ចរបស់ព្រះបិតា ។ សក្ការៈដ៏ច្រើនបានមានដល់បក្សីទាំងបី ។ សូម្បីបក្សីទាំងបី ក៏នាំគ្នាអនុសាសន៍ទូន្មានអត្ថ និងធម៌ថ្វាយចំពោះព្រះរាជា ។ ព្រះរាជាទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ ទ្រង់បំពេញបុណ្យកុសលមានទានជាដើម ហើយទៅកាន់សួគ៌ ។ អាមាត្យទាំងឡាយនាំគ្នាចាត់ការថ្វាយព្រះភ្លើងព្រះបរមសពរបស់ព្រះរាជា ហើយប្រាប់ដល់បក្សីទាំងបីថា "បពិត្រជម្ពុកៈ ព្រះរាជាទ្រង់បានធ្វើរាជពិន័យកម្ម

ឲ្យលើកស្វេតច្ឆត្រដល់លោក” ។ ព្រះមហាសត្វតបថា “យើងមិនត្រូវការដោយរាជ្យសម្បត្តិទេ លោកទាំងឡាយចូរជាអ្នកមិនប្រមាទគ្រប់គ្រងចុះ” ហើយញុំាងមហាជនឲ្យតាំងនៅក្នុងសីល ណែនាំថា “ពួកលោកគប្បីញុំាងការវិនិច្ឆ័យធម៌ឲ្យប្រព្រឹត្តយ៉ាងនេះ” ហើយឲ្យចារឹកគោលការវិនិច្ឆ័យធម៌ចុះក្នុងក្រាំងមាស ហើយត្រឡប់ទៅកាន់ព្រៃ ។ ឱវាទរបស់ព្រះមហាសត្វប្រព្រឹត្តអស់ ៤០.០០០ ឆ្នាំ ។ ព្រះសាស្ដាទ្រង់សម្ដែងព្រះធម្មទេសនានេះ ដោយទំនងឲ្យឱវាទដល់ព្រះរាជា ហើយទ្រង់ប្រជុំជាតកថា “ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ, នាងកុណ្ឌលិនីក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណាថេរី, វេស្សន្តរបក្សីក្នុងកាលនោះ បានមកជាសារីបុត្ត ឯជម្ពុកៈក្នុងកាលនោះ គឺ **តថាគត** នេះឯង ។

ចប់អដ្ឋកថា តេសកុណជាតកទី ១

# អដ្ឋកថា សរភង្គជាតកទី ២

## (រឿងសរភង្គតាបសឆ្លើយបញ្ហា)

ព្រះសាស្ដាកាលស្ដេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធការបរិនិព្វានរបស់ព្រះមហាមោគ្គល្លាន ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អលង្កតា កុណ្ឌលិនោ សុវត្ថា** "លោកទាំងឡាយប្រដាប់ហើយ មានកុណ្ឌល ស្លៀកដណ្ដប់ល្អស្អាត" ។

បានឮថា ព្រះសារីបុត្តក្រាបទូលព្រះតថាគតដែលទ្រង់ប្រថាប់នៅក្នុងវិហារជេតពន ទ្រង់អនុញ្ញាតហើយ ក៏និមន្តទៅបរិនិព្វាននៅឯបន្ទប់ដែលខ្លួនកើតក្នុងនាឡន្ទាគ្រាម ។ ព្រះសាស្ដាទ្រង់បានស្ដាប់ថា "ព្រះសារីបុត្តបរិនិព្វានហើយ" ទើបស្ដេចយាងទៅក្រុងរាជគ្រឹះប្រថាប់នៅក្នុងវិហារវេឡុវ័ន គ្រានោះ ព្រះមហាមោគ្គល្លាននៅឯកាឡសិលាប្រទេស ជិតភ្នំឥសីគិលិ ។ ព្រះមហាមោគ្គល្លាននោះ

ត្រាច់ទៅកាន់ទេវលោកខ្លះ ឧស្សទនរកខ្លះ ដោយភាពជាអ្នកដល់ព្រមដោយឫទ្ធិ លោកឃើញឥស្សរិយយសធំរបស់ពុទ្ធសាវកក្នុងទេវលោក ឃើញទុក្ខដ៏ធំរបស់តិត្ថិយសាវកក្នុងឧស្សទនរក ហើយត្រឡប់មកកាន់មនុស្សលោក ប្រាប់ដល់មនុស្សលោកទាំងឡាយថា "ឧបាសកឯណោះ និងឧបាសិកាឯណោះបានសោយមហាសម្បត្តិក្នុងទេវលោកឈ្មោះឯណោះ សាវករបស់តិរ្ថិយឯណោះ និងឯណោះកើតក្នុងនរកជាដើមក្នុងអបាយឈ្មោះឯណោះ" ។ មនុស្សទាំងឡាយនាំគ្នាជ្រះថ្លាក្នុងព្រះសាសនា លះបង់ពួកតិត្ថិយ លាភសក្ការៈដ៏ធំបានកើតឡើងដល់សាវកព្រះពុទ្ធ ។ លាភសក្ការៈរបស់ពួកតិរ្ថិយក៏សាបសូន្យចុះ ។ ពួកតិត្ថិយទាំងនោះទើបនាំគ្នាចងអាឃាតក្នុងព្រះថេរៈ ក៏ប្រឹក្សាគ្នាថា "បើព្រះថេរៈនៅមានជីវិត ឧបដ្ឋាករបស់ពួកយើងក៏បែកខ្ញែក ទាំងលាភសក្ការៈក៏វិនាស ពួកយើងនឹងសម្លាប់ព្រះថេរៈឲ្យស្លាប់" ។ ពួកតិត្ថិយទាំងឡាយទើបជួលចោរឈ្មោះថា

សមណកុត្តៈ ជាប្រាក់ ១.០០០ កហាបណៈឲ្យសម្លាប់ព្រះថេរៈ ។ ចោរសមណកុត្តៈគិតថា “យើងនឹងសម្លាប់ព្រះថេរៈឲ្យស្លាប់” ទើបទៅកាន់ល្អាងកាឡសិលាព្រមជាមួយពួកចោរដ៏ច្រើន ។ ព្រះថេរៈចោរសមណកុត្តៈកំពុងដើរមក ទើបហោះគេចចេញដោយឫទ្ធិ ។ ថ្ងៃនោះ ចោរឃើញព្រះថេរៈហោះទៅទើបត្រឡប់ បានមកជាប់ៗ គ្នារាល់ៗ ថ្ងៃ អស់ ៦ ថ្ងៃ ។ ចំណែកព្រះថេរៈក៏គេចទៅដោយឫទ្ធិដូចទម្លាប់ ។ តែក្នុងថ្ងៃទី ៧ អបរាបរវេទនីយកម្មដែលព្រះថេរៈធ្វើទុកក្នុងកាលមុនបានឱកាស ។ បានឮថា ក្នុងជាតិមុនព្រះថេរៈជឿពាក្យរបស់ភរិយាបំណងនឹងសម្លាប់មាតាបិតាឲ្យស្លាប់ ទើបបរយាននាំមាតាបិតាទៅកាន់ព្រៃ ធ្វើអាការដូចជាចោរហើយវាយមាតាបិតា ។ មាតាបិតាមើលមិនឃើញអ្វី ព្រោះចក្ខុពិការ ចាំបុត្តរបស់ខ្លួនមិនបាន ដោយសម្គាល់ថា “នោះជាចោរ” ក៏បរិទេវនាការដើម្បីប្រយោជន៍ដល់បុត្តតែម្យ៉ាងថា “កូនអើយ ឲ្យពួកចោរនោះសម្លាប់

ពុកម៉ែចុះ កូនចូរគេចយករួចខ្លួនទៅ” បុត្តគិតថា “មាតាបិតារបស់យើងទាំងពីរនេះ សូម្បីត្រូវយើងវាយ ក៏នៅយំដើម្បីប្រយោជន៍ដល់យើងតែម្នាក់ យើងធ្វើកម្មដែលមិនសមគួរឡើយ” ។ លំដាប់នោះ គេទើបបោះមាតាបិតាសម្តែងអាការដូចពួកចោរហើយគេចទៅ ត្រឡប់មកច្របាច់ដៃជើងរបស់លោកទាំងពីរនិយាយថា “ពុកម៉ែកុំខ្លាច ពួកចោររត់អស់ហើយ” ហើយនាំត្រឡប់មកកាន់ផ្ទះរបស់ខ្លួនវិញ ។

កម្មនោះមិនបានឱកាសរហូតអស់វេលាត្រឹមនេះ តាំងនៅដូចដុំភ្លើងត្រូវផេះបិទបាំង ហើយជ្រៀតចូលក្នុងសរីរៈដែលមិនមានទីបំផុត ។ ក៏កម្មនេះបានឱកាសក្នុងវេលាណារមែងឲ្យផលក្នុងវេលានោះ ប្រៀបដូចសុនខដែលព្រានជួបម្រឹគហើយក៏លែងឲ្យដេញខាំម្រឹគ ក្នុងវេលាដេញទាន់ក្នុងវេលាណាក៏ខាំក្នុងវេលានោះដូច្នោះ ។ ដែលឈ្មោះថា អ្នកដែលរួចចាកកម្មនោះមិនមានឡើយ ។ ព្រះថេរៈ

ដឹងថា កម្មដែលខ្លួនធ្វើទុកនឹងតាមទាន់ ទើបមិនបានគេច ។ ព្រោះ ផលរបស់កម្មនោះ ព្រះថេរៈទើបមិនអាចហោះទៅក្នុងអាកាសបាន ឫទ្ធិរបស់ព្រះថេរៈសូម្បីអាចទូន្មាននន្ទោបនន្ទនាគរាជ និងអាចញ៉ាំង វេជ្ជយន្តប្រាសាទឲ្យញាប់ញ័របាន ក៏ដល់នូវការវិនាសកម្លាំងព្រោះ កម្លាំងនៃកម្ម ។ ចោរចាប់ព្រះថេរៈបាន វាយរហូតឆ្អឹងរបស់ព្រះ ថេរៈមានចំណែកប៉ុនៗ កំណាត់គ្រាប់អង្ករ ដូចបុកឲ្យជាម្សៅដូច្នោះ ហើយបោះទៅក្នុងគុម្ពោតឈើមួយកន្លែង ដោយសម្គាល់ថាស្លាប់ ហើយ ព្រមដោយពួកចោរនាំគ្នាគេចទៅ ។ រីឯព្រះថេរៈត្រឡប់ បានសតិក៏គិតថា "យើងនឹងថ្វាយបង្គំលាព្រះសាស្តាសិន ទើបនឹង បរិនិព្វាន" ហើយទើបប្រមូលអត្តភាពដោយកម្លាំងឈាន ហោះទៅ កាន់សម្នាក់ព្រះសាស្តាតាមផ្លូវអាកាស ថ្វាយបង្គំព្រះសាស្តាហើយ ទូលថា "បពិត្រព្រះអង្គដ៏ចម្រើន អាយុសង្ខាររបស់ខ្ញុំព្រះអង្គតាំង នៅមិនបានទេ ខ្ញុំព្រះអង្គនឹងបរិនិព្វាន" ។ ព្រះសាស្តាទ្រង់ត្រាស់ថា

“មោគ្គល្លាន អ្នកនឹងបរិនិព្វានឬ?” ទូលតបថា “ព្រះករុណាព្រះអង្គ” ត្រាស់សួរថា “អ្នកនឹងបរិនិព្វានក្នុងទីណា?” បានទូលតបថា “ត្រង់ផែនថ្មក្នុងល្អាងកាឡសិលា ព្រះអង្គ” ត្រាស់ថា “មោគ្គល្លាន បើដូច្នោះអ្នកចូរពោលធម៌ដល់តថាគតជាមុន ហើយសឹមទៅ ព្រោះគ្រានេះ ការបានឃើញសាវកដូចជាអ្នកមិនមានទៀតឡើយ” ។ ព្រះមហាមោគ្គល្លានទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើតាមព្រះពុទ្ធតម្រាស់” ថ្វាយបង្គំព្រះសាស្តាហើយ ហោះឡើងទៅក្នុងអាកាសកម្ពស់មួយជួរដើមត្នោត សម្តែងឫទ្ធិមានប្រការផ្សេងៗដូចព្រះសារីបុត្តក្នុងវេលាបរិនិព្វាន ពោលនូវធម្មកថាថ្វាយបង្គំព្រះសាស្តា ហើយបរិនិព្វានត្រង់កាឡសិលាប្រទេស ។

ក្នុងរំពេចនោះឯង ក្នុងទេវលោកទាំង ៦ ជាន់កើតកោលាហល ដូចគ្នាថា “ដំណឹងថា អាចារ្យរបស់ពួកយើងបរិនិព្វានហើយ” ខ្លះក៏កាន់គ្រឿងក្រអូប មាលា ធូប គ្រឿងអប់ និងលម្អិតខ្លឹមចន្ទន៍

ដែលជាទិព្វ ទាំងឧសច្រើនប្រភេទមក (ប្រជុំគ្នាហើយ) ។ (សាង) ចិត្តកាធារធ្វើដោយចន្ទន៍ក្រហមកម្ពស់ ៩៩ ហត្ថ ។ ព្រះសាស្តាប្រថាប់នៅក្នុងទីជិតៗ សពព្រះថេរៈ ត្រាស់ឲ្យចាត់ការដាក់សពរបស់ព្រះថេរៈ ។ ជុំវិញព្រៃស្មសាន ភ្លៀងផ្កាឈើក៏ធ្លាក់ចុះមកក្នុងទីប្រមាណ ១ យោជន៍ ។ មានមនុស្សនៅចន្លោះទេវតា ទេវតានៅចន្លោះមនុស្ស ។ តអំពីទេវតាដោយលំដាប់ ជាពួកយក្ស តអំពីពួកយក្សក៏ពួកគន្ធព្វ តអំពីពួកគន្ធព្វជាពួកនាគ តអំពីពួកនាគជាពួកគ្រុឌ តអំពីពួកគ្រុឌជាពួកកិន្នរី តអំពីពួកកិន្នរីក៏ជាពួកកិន្នរៈ តអំពីពួកកិន្នរក៏ជាឆត្រ តអំពីឆត្រជាសុវណ្ណចាមរ តអំពីសុវណ្ណ-ចាមរ ជាទង់ជ័យ តអំពីទង់ជ័យជាទង់ផ្កាំងសំពត់ អ្នកដែលមកប្រជុំគ្រប់កន្លែងខ្លះក៏លេងសាធុកីឡា (ការលេងដើម្បីបូជា) រហូតអស់ ៧ ថ្ងៃ ។ ព្រះសាស្តាត្រាស់បង្គាប់ឲ្យរក្សាធាតុរបស់ព្រះថេរៈធ្វើចេតិយបញ្ចុះទុកត្រង់ខ្លោងទ្វារព្រះវិហារវេឡុវន ។

កាលនោះ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា “អាវុសោទាំងឡាយ ព្រះសារីបុត្ត មិនបានទទួលការលើកតម្កើងយ៉ាងធំក្នុងសម្នាក់របស់ព្រះពុទ្ធ ព្រោះមិនបានបរិនិព្វាននៅក្នុងទីជិតព្រះសាស្តា ព្រះមហាមោគ្គល្លានបានទទួលកិត្តិយសដ៏ធំក្រៃលែង ព្រោះបរិនិព្វានក្នុងទីជិតព្រះសាស្តា” ។ ព្រះសាស្តាស្តេចយាងមកត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកអ្នកប្រជុំសន្ទនាគ្នាក្នុងរឿងអ្វី?” កាលភិក្ខុទាំងនោះក្រាបទូលថ្វាយហើយ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ព្រះមោគ្គល្លានមិនមែនបានសម្មានៈអំពីសម្នាក់តថាគតតែក្នុងជាតិនេះក៏ទេ សូម្បីក្នុងជាតិមុន លោកក៏បានទទួលហើយដូចគ្នា” ហើយទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះ ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងព្រះនគរពារាណសី ព្រះពោធិសត្វបានបដិសន្ធិក្នុងគភ៌របស់នាងព្រាហ្មណីជាភរិយារបស់បុរោហិត បានដប់ខែក៏សម្រាលចាកគភ៌

មាតាក្នុងវេលាជិតភ្លឺ ។ ខណៈនោះ អាវុធទាំងឡាយក្នុងព្រះនគរពារាណសីមានអាណាខេត្តប្រមាណ ១២ យោជន៍ក៏ភ្លឺរន្ទាលឡើង ។ ក្នុងខណៈដែលបុត្តសម្រាល បុរោហិតចេញមកខាងក្រៅសម្លឹងមើលទៅអាកាស ឃើញនិមិត្តជាគ្រឿងប្រកបនក្ខត្តឫក្ស ក៏ដឹងថា កុមារនេះ ជាអ្នកប្រសើរលើសនាយខ្មាន់ធ្នូទាំងឡាយក្នុងជម្ពូទ្វីប ព្រោះជាអ្នកកើតដោយនក្ខត្តឫក្សនេះ ទើបទៅកាន់រាជត្រកូលអំពីព្រឹកក្រាបទូលព្រះរាជាសួរដល់ការផ្ទំជាសុខ ។ កាលព្រះរាជាត្រាស់ថា "លោកអាចារ្យ សេចក្តីសុខនឹងមានអំពីណា ក្នុងថ្ងៃនេះ អាវុធក្នុងព្រះរាជវាំងទាំងអស់ឆេះអស់ហើយ" ទើបក្រាបទូលថា "បពិត្រមហារាជ ព្រះអង្គកុំស្លុតព្រះទ័យ មិនមែនតែអាវុធឆេះក្នុងព្រះរាជ-វាំងទេ សូម្បីក្នុងព្រះនគរទាំងមូលក៏ឆេះដូចគ្នាដែរ ដែលមានដូច្នេះព្រោះថ្ងៃនេះ កុមារកើតក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ" ព្រះរាជាត្រាស់ថា "លោកអាចារ្យ កុមារដែលកើតហើយយ៉ាងនេះ នឹងជាយ៉ាងណា?"

បុរោហិតក្រាបទូលថា "បពិត្រមហារាជ មិនមានអ្វីទេព្រះអង្គ តែថា កុមារនោះនឹងបានជាកំពូលនៃនាយខ្មាន់ធ្នូក្នុងជម្ពូទ្វីបទាំងមូល" ព្រះរាជាត្រាស់ថា "ល្អហើយលោកអាចារ្យ បើដូច្នោះលោកចូរផ្គត់ផ្គង់កុមារនោះ ហើយលើកឲ្យយើងក្នុងវេលាដែលគេចម្រើនវ័យ" ដូច្នេះហើយ ទើបត្រាស់ឲ្យព្រះរាជទានទ្រព្យ ១.០០០ កហាបណៈ ជាតម្លៃទឹកដោះជាមុន ។ បុរោហិតនោះទទួលទ្រព្យទៅផ្ទះប្រគល់ឲ្យនាងព្រាហ្មណី ក្នុងថ្ងៃតាំងឈ្មោះកូនប្រុស ក៏បានតាំងនាមឲ្យថា "**ជោតិបាលៈ**" ព្រោះក្នុងខណៈដែលប្រសូត អាវុធក៏ឆេះទូទៅ ។

ជោតិបាលកុមារចម្រើនវ័យហើយមានបរិវារដ៏ច្រើន ក្នុងគ្រាអាយុគ្រប់ ១៦ ឆ្នាំ ជាអ្នកមានរូបរាងស្រស់ស្អាត ។ បិតារបស់ជោតិបាលកុមារសម្លឹងមើលសរីរសម្បត្តិ ទើបប្រគល់នូវទ្រព្យឲ្យ ១.០០០ កហាបណៈ ប្រាប់ថា "កូនអើយ កូនចូរទៅក្រុងតក្កសិលា រៀនសិល្បសាស្ត្រក្នុងសម្នាក់អាចារ្យទិសាបាមោក្ខចុះ" ជោតិបាលកុមារ

ទទួលពាក្យហើយ កាន់យកទ្រព្យជាចំណែកអាចារ្យ សំពះមាតាបិតាលាទៅកាន់ក្រុងតក្កសិលានោះ ប្រគល់ទ្រព្យឲ្យអាចារ្យ ១.០០០ កហាបណៈហើយ ផ្តើមរៀនសិល្បវិជ្ជា រៀនសម្រេចត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ ។ លំដាប់នោះ អាចារ្យក៏ត្រេកអរ ទើបឲ្យព្រះខាន់កែវ ធ្នូស្នែងពពែ បំពង់ធ្នូ ដែលជារបស់តវង្សខ្លួន និងអាវក្រោះ និងក្បាំងមុខរបស់ខ្លួន ហើយប្រគល់មាណពទាំង ៥០០ នាក់ ដល់ជោតិបាលកុមារនោះថា "ជោតិបាលកូន អាចារ្យចាស់ហើយ ឥឡូវនេះអ្នកចូរជួយទូន្មានមាណពទាំងនេះផងចុះ" ព្រះមហាសត្វទទួលគ្រឿងឧបករណ៍គ្រប់យ៉ាងហើយ ក្រាបលាអាចារ្យធ្វើដំណើរត្រឡប់មកកាន់នគរពារាណសីសួរសុខទុក្ខមាតាបិតា ។

លំដាប់នោះ បុរោហិតជាបិតាទើបសួរជោតិបាលកុមារដែលសំពះហើយឈរថា "កូនសម្លាញ់ កូនរៀនសិល្បវិជ្ជាចប់ហើយឬ?" គេតបថា "បាទលោកពុក" បុរោហិតស្តាប់ពាក្យឆ្លើយហើយក៏ទៅ

កាន់រាជត្រកូល ក្រាបទូលថា "មហាបពិត្រ បុត្តរបស់ខ្ញុំព្រះអង្គរៀនសិល្បវិជ្ជាត្រឡប់មកវិញហើយ គេនឹងធ្វើអ្វី ព្រះអង្គ?" ព្រះរាជាត្រាស់ថា "លោកអាចារ្យ គេចូរមករក្សាយើងចុះ" ។ ទូលថា "បពិត្រមហារាជ ព្រះអង្គទ្រង់ប្រោសរលឹកដល់បៀវត្សសម្រាប់បុត្តរបស់ខ្ញុំព្រះអង្គផង" ត្រាស់ថា "គេនឹងបានបៀវត្សមួយថ្ងៃ ១.០០០ កហាបណៈ បុរោហិតទទួលព្រះតម្រាស់ហើយ ទើបទៅផ្ទះឲ្យហៅកុមារមកប្រាប់ថា "កូនសម្លាញ់ កូនចូររក្សាព្រះរាជាចុះ" ចាប់តាំងអំពីនោះមក ជោតិបាលកុមារក៏រក្សាព្រះរាជាបានទ្រព្យមួយថ្ងៃ ១.០០០ កហាបណៈរាល់ៗ ថ្ងៃ ខ្ញុំរាជបាទមូលិកាទាំងឡាយនាំគ្នាលើកទោសថា "ពួកយើងមិនឃើញការងារដែលជោតិបាលធ្វើ តែគេបានទទួលបៀវត្សមួយថ្ងៃ ១.០០០ កហាបណៈរាល់ៗ ថ្ងៃ ពួកយើងចង់ឃើញសិល្បៈរបស់គេ" ព្រះរាជាស្តាប់ពាក្យរបស់ពួកជនទាំងនោះ ទើបត្រាស់ប្រាប់បុរោហិត ។ បុរោហិតក៏ទទួលស្នងព្រះរាជតម្រាស់ថា

“មហាបពិត្រ ល្អហើយព្រះអង្គ” ហើយប្រាប់ដល់បុត្តរបស់ខ្លួន ជោតិបាលកុមារនិយាយថា “ល្អហើយលោកពុក ក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះទៅ ខ្ញុំនឹងសម្តែងសិល្បៈ មួយ៉ាងទៀត សូមព្រះរាជាប្រោសត្រាស់ឲ្យនាយខ្មាន់ធ្នូក្នុងដែនរបស់ព្រះអង្គមកប្រជុំគ្នា” បុរោហិតបានស្តាប់ដូច្នោះ ទើបទៅក្រាបទូលសេចក្តីនោះចំពោះព្រះរាជា ។ ព្រះរាជាទ្រង់ឲ្យវាយស្គរប្រកាសទូទាំងព្រះនគរ ហើយមានព្រះរាជឱង្ការឲ្យនាយខ្មាន់ធ្នូមកប្រជុំគ្នា ។ នាយខ្មាន់ធ្នូចំនួន ៦០.០០០ នាក់មកប្រជុំព្រមគ្នា ។ ព្រះរាជាទ្រង់ជ្រាបថា ពួកនាយខ្មាន់ធ្នូមកប្រជុំព្រមគ្នាហើយ ទើបត្រាស់ឲ្យវាយស្គរដើរប្រកាសថា “អ្នកព្រះនគរទាំងឡាយចូរទៅមើលសិល្បៈរបស់ជោតិបាលកុមារ” ហើយឲ្យត្រៀមព្រះលានហ្លួង ហែហមទៅដោយមហាជនប្រថាប់គង់បល្ល័ង្កដ៏ប្រសើរ ទ្រង់បញ្ជូនរាជបុរសឲ្យទៅអញ្ជើញជោតិបាលកុមារថា “ជោតិបាលកុមារ ចូរមកចុះ” ។ ជោតិបាលកុមារទើបសីកកូនសរ

ក្នុងបំពង់ព្រួញ ពាក់គ្រោះ និងសំពត់ជួតក្បាល ដែលអាចារ្យឲ្យ ក្នុងចន្លោះសំពត់ដណ្ដប់ ឲ្យមនុស្សកាន់ព្រះខាន់ ហើយដើរមកកាន់សម្នាក់ព្រះរាជាដោយជើងតាមធម្មតា បានឈរត្រង់ទីសមគួរមួយ កន្លែង ។ ពួកនាយខ្មាន់ធ្នូធ្វើការកំណត់គ្នាថា "គេថា ជោតិបាល-កុមារនឹងមកដើម្បីសម្ដែងសិល្បៈ គឺ ធ្នូ តែមិនកាន់ធ្នូមក គង់នឹង ប្រាថ្នាយកធ្នូអំពីដៃរបស់ពួកយើង" ពួកយើងកុំឲ្យធ្នូដល់គេ" ព្រះរាជាត្រាស់ហៅជោតិបាលកុមារមកត្រាស់ថា "កូនចូរសម្ដែងសិល្បៈចុះ" ជោតិបាលទើបឲ្យបាំងរាំងននទាញសំពត់សាដកចេញ ពាក់គ្រោះស្បែកខ្លា ហើយចងសំពត់ជួតក្បាល ទាញខ្សែមានពណ៌ដូចកែវប្រពាឡត្រង់ធ្នូស្នែងពពែឡើង ចងបំពង់ធ្នូក្រោយខ្នង សៀតព្រះខាន់ទុកខាងមុខ ចាប់កូនសរគ្រវីដែលមានចុងដូចពេជ្រ វែករាំងននចេញមក ស្រដៀងនឹងនាគកុមារដែលប្រដាប់តាក់តែងហើយ ជ្រែកផែនដីចេញមកដូច្នោះ ដើរទៅសម្ដែងនូវការគោរពចំពោះព្រះ

រាជា ឈរហើយ ។ មហាជនឃើញកុមារនោះហើយ ខ្ទរក៏ស្រែក ហ៊ោ បន្ទឺសំឡេងទះដៃអឺងកង ។ ព្រះរាជាត្រាស់ថា "ជោតិបាល កូនចូរសម្តែងសិល្បៈចុះ" ជោតិបាលកុមារទូលថា "បពិត្រមហារាជ បណ្តានាយខ្មាន់ធ្នូរបស់ព្រះអង្គ ព្រះអង្គប្រោសបង្គាប់ឲ្យមក ៤ នាក់ គឺ អ្នកដែលបាញ់លឿនដូចផ្លេកបន្ទោរ អ្នកដែលបាញ់សូម្បីរោមទ្រាយមិនខុស អ្នកដែលបាញ់តាមសំឡេងដែលបានឮ និងអ្នកដែលបាញ់តម្រង់កូនសរដែលបាញ់មក" ព្រះរាជាក៏ទ្រង់ប្រោសឲ្យហៅមក ។

ព្រះមហាសត្វចាត់ចែងធ្វើមណ្ឌបខាងក្នុងទីកំណត់បួនជ្រុង ក្នុងព្រះលានហ្លួង ឲ្យនាយខ្មាន់ធ្នូទាំង ៤ នាក់ឈរនៅជ្រុងទាំង ៤ ហើយ ឲ្យកូនសរ ៣០.០០០ កូន ដល់នាយខ្មាន់ធ្នូម្នាក់ៗ ឲ្យអ្នកបញ្ជូនកូនធ្នូឈរក្នុងទីជិតៗ នាយខ្មាន់ធ្នូម្នាក់មួយៗ ហើយខ្លួនឯងកាន់យកកូនធ្នូមានចុងដូចពេជ្រ ឈរនៅត្រង់កណ្តាលមណ្ឌប ក្រាប

ទូលព្រះរាជាថា "បពិត្រមហារាជ នាយខ្មាន់ធ្នូទាំង ៤ នាក់នេះ ចូរបាញ់កូនធ្នូមកខ្ញុំព្រះអង្គព្រមគ្នាចុះ ខ្ញុំព្រះអង្គនឹងហាមកូនធ្នូដែលពួកគេបាញ់មក" ព្រះរាជាទ្រង់ត្រាស់បង្គាប់ថា "ពួកអ្នកចូរធ្វើតាមនោះចុះ" ពួកនាយខ្មាន់ធ្នូទើបក្រាបទូលថា "បពិត្រមហារាជ ពួកខ្ញុំព្រះអង្គជានាយខ្មាន់ធ្នូបាញ់លឿនដូចផ្លេកបន្ទោរ បាញ់សូម្បីរោមទ្រាយក៏មិនខុស បាញ់តាមសំឡេងដែលបានឮ និងបាញ់ទៅតាមកូនសរដែលបាញ់មក ជោតិបាលជាក្មេងកំលោះ ពួកខ្ញុំព្រះអង្គនឹងបាញ់មិនបានទេ" ព្រះមហាសត្វទើបពោលថា "បើពួកលោកអាចក៏អញ្ជើញបាញ់ខ្ញុំបាន" នាយខ្មាន់ធ្នូទាំងនោះទទួលថា "ល្អហើយ" ទើបបាញ់កូនធ្នូទៅព្រមគ្នា ព្រះមហាសត្វយកកូនសរគ្រវាសកូនសរទាំងនោះឲ្យធ្លាក់ចុះតម្រៀបគ្នា ដូចជាវង់ស៊ុមព្រះពោធិព្រឹក្ស ផ្លែសរទៅតាមផ្លែសរ តួសរទៅតាមតួសរ កន្ទុយកូនសរទៅតាមកន្ទុយកូនសរ មិនឲ្យកន្ទង់នូវគ្នានិងគ្នា បានជាដូចបន្ទប់នៃកូនសរ ហេតុ

កូនសររបស់នាយខ្មាន់ធ្នូទាំងនោះអស់ ។ ព្រះមហាសត្វដឹងថា កូនសររបស់ពួកនាយខ្មាន់ធ្នូអស់ហើយ មិនបានញ៉ាំងបន្ទប់កូនសរទាំងឡាយឲ្យខូចឡើយ បានលោតឡើងទៅឈរគាល់ជិតព្រះរាជា ។ មហាជននាំគ្នាបន្ទឺសំឡេងស្រែកហ៊ោ ទះដៃអបអរ ធ្វើនូវមហាកោលាហលបោះសំពត់ និងគ្រឿងអាភរណៈឡើងទៅ ។ រហូតមានទ្រព្យរាប់បាន ១៨ កោដិ ជាគំនរធំយ៉ាងនេះ ។ លំដាប់នោះ ព្រះរាជាទើបត្រាស់សួរជោតិបាលកុមារថា "បាជោតិបាល នេះឈ្មោះសិល្បៈអ្វី?" ក្រាបទូលថា "បពិត្រមហារាជ ឈ្មោះ **សរបដិពាហនៈ** (គ្រឿងហាមកូនសរ) ព្រះអង្គ" ត្រាស់សួរថា "អ្នកដទៃៗ ដឹងដូច្នេះដែរឬ?" ទូលថា "បពិត្រមហារាជ វៀរខ្ញុំព្រះអង្គចេញហើយ អ្នកដទៃៗ ដឹងដូច្នេះមិនមានឡើយ ព្រះអង្គ" ត្រាស់ថា "បាជោតិបាល អ្នកចូរសម្តែងសិល្បៈដទៃខ្លះចុះ" ក្រាបទូលថា "បពិត្រមហារាជ បើនាយខ្មាន់ធ្នូទាំង ៤ នាក់ ឈរនៅត្រង់ជ្រុងទាំងបួន មិនអាចនឹង

បាញ់ខ្ញុំព្រះអង្គបានសោត តែខ្ញុំព្រះអង្គនឹងបាញ់អ្នកទាំងនេះដែលឈរនៅត្រង់ជ្រុងទាំង ៤ ដោយកូនសរតែមួយប៉ុណ្ណោះ” ពួកនាយខ្មាន់ធ្នូមិនអាចនឹងឈរនៅបានឡើយ” ។

ព្រះមហាសត្វទើបឲ្យដាំដើមចេកទុកត្រង់ជ្រុងទាំងបួន ហើយចងអំបោះក្រហមត្រង់តួកូនសរ បាញ់សំដៅទៅដើមចេកមួយដើម កូនសរទម្លុះដើមចេកទីមួយ ធ្លុះទៅដល់ដើមចេកទីពីរ ទីបី ទីបួន ហើយទម្លុះដល់ដើមចេកដំបូងដែលធ្លុះហើយ ចេញមកតាំងនៅក្នុងដៃដូចដើម ។ ដើមចេកទាំងឡាយដែលអំបោះដោតហើយក៏តាំងនៅបាន ។ មហាជនក៏បន្លឺសំឡេងគឹកកងរាប់ដោយ ១.០០០ ដង ។ ព្រះរាជាត្រាស់សួរថា “នេះឈ្មោះសិល្បៈអ្វីបា?” ព្រះមហាសត្វទូលតបថា “មហាតេជះ ឈ្មោះ **ចក្កវិទ្ធៈ** (សិល្បៈទម្លុះចក្រ) ព្រះអង្គ” ព្រះរាជាត្រាស់ថា “អ្នកចូរសម្តែងសិល្បៈសូម្បីយ៉ាងដទៃចុះបា” ព្រះមហាសត្វទើបសម្តែងសិល្បៈឈ្មោះ **សរលដ្ឋិ** (គឺសិល្បៈឈើ

ប្រត់សម្រេចដោយកូនសរ) ឈ្មោះ **សររជ្ជុ** (សិល្បៈរូបខ្សែសម្រេចដោយកូនសរ) ឈ្មោះ **សរវេណិ** (សិល្បៈបួនសក់ដោយកូនសរ) ឈ្មោះ **សរបាសាទៈ** (សិល្បៈរូបប្រាសាទកូនសរ) ឈ្មោះ **សរ-មណ្ឌបៈ** (សិល្បៈរូបមណ្ឌបកូនសរ) ឈ្មោះ **សរសោបាណៈ** (គឺសិល្បៈរូបជណ្ដើរកូនសរ) ឈ្មោះ **សរមណ្ឌលៈ** (សិល្បៈរូបគូទឹកសម្រេចដោយកូនសរ) ឈ្មោះ **សរវនៈ** (គឺសិល្បៈរូបព្រៃសម្រេចដោយកូនសរ) ឈ្មោះ **សរបោក្ខរណី** (សិល្បៈរូបស្រះបោក្ខរណីសម្រេចដោយកូនសរ) ឈ្មោះ **សរបទុម** (គឺសិល្បៈរូបផ្កាឈូកសម្រេចដោយកូនសរ) ញាំងសិល្បៈឈ្មោះ **សរបុប្ផៈ** (រូបផ្កាឈើសម្រេចដោយកូនសរឲ្យរីក) ញាំងសិល្បៈឈ្មោះ **សរវស្សៈ** (គឺរូបភ្លៀងសម្រេចដោយកូនសរឲ្យធ្លាក់) ។ លុះព្រះមហាសត្វបានសម្ដែងសិល្បៈ ១២ យ៉ាងនេះ ដែលមិនទូទៅដល់ជនដទៃយ៉ាងនេះហើយ ក៏បំបែកជំរំធំ ៧ ជង់ ដែលមិនទូទៅដល់ជនដទៃ ។

ព្រះមហាសត្វបាញ់បន្ទះឈើសង្កែកម្រាស់ ៨ ធ្នាប់, បាញ់បន្ទះឈើធ្នង់កម្រាស់ ៤ ធ្នាប់, បាញ់បន្ទះមាសកម្រាស់ ២ ធ្នាប់, បាញ់បន្ទះដែកកម្រាស់ ១ ធ្នាប់, បាញ់បន្ទះក្តារ ១០០ ផងឲ្យជាប់គ្នាតែមួយ ហើយបាញ់កូនសរទៅខាងមុខរទេះដែលផ្ទុកស្មឹកឈើ រទេះផ្ទុកខ្សាច់ និងរទេះផ្ទុកបន្ទះក្តារ ឲ្យធ្លុះចេញខាងក្រោយ, បាញ់កូនសរអំពីខាងក្រោយ ឲ្យធ្លុះចេញខាងមុខ បាញ់កូនសរទៅក្នុងទឹកចម្ងាយទី ៤ ឧសភៈ លើគោក ៨ ឧសភៈ បាញ់រោមទ្រាយក្នុងទី ១ ឧសភៈដោយសញ្ញាផ្លេត្រប់ ។ កាលជោតិបាលកុមារសម្តែងសិល្បៈមានប្រមាណប៉ុណ្ណេះហើយ ព្រះអាទិត្យក៏អស្តង្គតទៅ ។ លំដាប់នោះ ព្រះរាជាត្រាស់ឲ្យកំណត់តំណែងជាសេនាបតីដល់គេ ត្រាស់ថា “ម្នាលជោតិបាល ថ្ងៃនេះល្ងមហើយ ថ្ងៃស្អែកអ្នកនឹងបានទទួលសក្ការៈ គឺ តំណែងសេនាបតី អ្នកចូរទៅកាត់សក់កោរពុកមាត់ពុកចង្កា ងូតទឹកហើយមកចុះ” ដូច្នេះហើយ បានព្រះរាជទាន

ទ្រព្យ ១០០.០០០ កហាបណៈដើម្បីជាតម្លៃបៀវត្ស ក្នុងថ្ងៃនោះ ។

ព្រះមហាសត្វគិតថា "យើងមិនមានសេចក្តីត្រូវការដោយទ្រព្យចំនួននេះ" ទើបលះទ្រព្យចំនួន ១៨ កោដិដល់ពួកម្ចាស់របស់ ហើយទៅងូតទឹកជាមួយនឹងបរិវារដ៏ច្រើន ឲ្យជាងកាត់សក់កោរពុកមាត់ ងូតទឹកប្រដាប់ដោយសព្វាលង្ការ ហើយចូលទៅកាន់ផ្ទះដោយសិរីដែលរកអ្វីប្រៀបពុំបាន បរិភោគភោជនមានរសដ៏ប្រណីតផ្សេងៗស្រេចហើយ ឡើងកាន់ទីដេកដ៏មានសិរី ដេកអស់ពីរយាម ភ្ញាក់ក្នុងវេលាបច្ឆិមយាម ក្រោកឡើងអង្គុយពត់ភ្នែនលើទីដេក ពិចារណាខាងដើម ត្រង់កណ្តាល និងខាងចុងនៃសិល្បៈរបស់ខ្លួន រំពឹងថា "ការញុំាំងអ្នកដទៃឲ្យស្លាប់រមែងប្រាកដក្នុងចំណែកខាងដើមនៃសិល្បៈរបស់យើង ការបរិភោគប្រើប្រាស់ដោយអំណាចនៃកិលេសប្រាកដក្នុងចំណែកកណ្តាល ការបដិសន្ធិក្នុងនរកប្រាកដក្នុងទីខាងចុង ក៏បាណាតិបាត និងសេចក្តីប្រមាទ ព្រោះស្រវឹងក្នុងការបរិភោគ

ប្រើប្រាស់ដោយអំណាចកិលេស រមែងឲ្យបដិសន្ធិក្នុងនរក ព្រះរាជាទ្រង់ព្រះរាជទានតំណែងសេនាបតីដ៏ធំដល់យើង យើងក៏ជាអ្នកមានឥស្សរិយយសធំ ភរិយា និងបុត្តធីតាក៏នឹងមានច្រើន វត្ថុដែលជាទីតាំងនៃកិលេសដែលដល់នូវភាពធំទូលាយហើយ ជារបស់លះបានលំបាក គួរយើងចេញទៅកាន់ព្រៃតែម្នាក់ឯង ហើយបួសជាឥសីក្នុងកាលឥឡូវនេះ” ទើបក្រោកឡើងអំពីទីដេកដ៏ធំ មិនឲ្យអ្នកណាដឹង ចុះចាកប្រាសាទចេញតាមផ្លូវអគ្គទ្វារ ចូលកាន់ព្រៃម្នាក់ឯង ដើរសំដៅទៅកាន់ព្រៃខិតធំប្រមាណ ៣ យោជន៍ ជិតមាត់ស្ទឹងគោធាវរី ។ សក្កទេវរាជជ្រាបថា “ជោតិបាលកុមារនោះចេញហើយ” ទើបត្រាស់ហៅវិស្សុកម្មទេវបុត្តមកត្រាស់ថា “នែបា ជោតិបាលកុមារចេញអភិនេស្រ្កមណ៍ នឹងមានសមាគមធំ អ្នកចូរទៅនិម្មិតអាស្រមត្រង់កបិដ្ឋវ័នជិតមាត់ស្ទឹងគោធាវរី និងត្រៀមបរិក្ខាររបស់បព្វជិតទុកឲ្យស្រេច” វិស្សុកម្មទេវបុត្តបានធ្វើតាមទេវបញ្ជាគ្រប់ប្រការ ។

ព្រះមហាសត្វទៅដល់ទីនោះហើយ ឃើញផ្លូវមានស្នាមជើងដើរបានមនុស្សតែម្នាក់ គិតថា នឹងមានទីអាស្រ័យរបស់ពួកបព្វជិត ទើបដើរទៅកាន់កបិដ្ឋវ័នតាមផ្លូវនោះ ក៏មិនឃើញមាននរណា ក៏ចូលទៅកាន់បណ្ណសាលា ឃើញបរិក្ខាររបស់ពួកបព្វជិត គិតថាប្រហែលសក្កទេវរាជទ្រង់ជ្រាបថា យើងចេញអភិនេស្រ្កមណ៍ទើប លាតសំពត់សាដកដែលមានពណ៌ក្រហមស្លៀកដណ្តប់ ធ្វើស្បែកខ្លាធំឆៀងស្មាម្ខាង បួងសក់ លើកសំព្រែកដាក់លើស្មាម្ខាង កាន់ឈើច្រត់មនុស្សចាស់ ចេញចាកបណ្ណសាលាឡើងកាន់ទីចង្រ្កមចង្រ្កមទៅមកៗ អស់វារៈតិចតួច ញុំាងព្រៃឲ្យស្រស់ល្អដោយសិរី គឺ បព្វជ្ជា ធ្វើកសិណបរិកម្ម តាំងពីការដែលបួសហើយ ក្នុងថ្ងៃទី ៧ ក៏ញុំាងសមាបត្តិ ៨ អភិញ្ញា ៥ ឲ្យកើតឡើង ជាអ្នកមានផ្លែឈើមើមឈើក្នុងព្រៃជាអាហារដោយឧច្ឆាចរិយវត្ត (វត្ត គឺ ការត្រាច់សន្សំស្បៀងដើម្បីចិញ្ចឹមជីវិត) នៅតែម្នាក់ឯងប៉ុណ្ណោះ ។

មាតាបិតា មិត្តសម្លាញ់ជាដើម សូម្បីពួកញាតិរបស់ជោតិបាល-កុមារនោះ កាលមិនបានឃើញជោតិបាលកុមារ ក៏នាំគ្នាយំរៀបរាប់ត្រាច់ដើររក ។

លំដាប់នោះ ព្រានព្រៃម្នាក់ចូលទៅកាន់ព្រៃក៏ជួបព្រះមហាសត្វ អង្គុយនៅក្នុងអាស្រមបទត្រង់កបិដ្ឋវ័ន ចាំព្រះមហាសត្វបានក៏ធ្វើបដិសណ្ឋារៈនឹងព្រះមហាសត្វ ហើយត្រឡប់ទៅកាន់ព្រះនគរប្រាប់មាតាបិតារបស់លោកឲ្យជ្រាប ។ ព្រះរាជាត្រាស់ថា “មកចុះយើងនឹងទៅសួរសុខទុក្ខជោតិបាលតាបសនោះ” ហើយនាំមាតា-បិតារបស់លោក ហែហមដោយមហាជន ស្តេចយាងដល់មាត់ស្ទឹងគោធាវរី តាមផ្លូវដែលព្រានប្រាប់ ។ ព្រះពោធិសត្វមកកាន់មាត់ស្ទឹង អង្គុយលើអាកាសសម្តែងធម៌ អញ្ជើញជនទាំងអស់ចូលទៅកាន់អាស្រមអង្គុយលើអាកាសនោះឯង ប្រកាសទោសក្នុងកាមទាំងឡាយ ហើយសម្តែងធម៌ដល់ជនទាំងនោះ សូម្បីក្នុងទីនោះ ជនទាំង

អស់តាំងអំពីព្រះរាជាទៅក៏នាំគ្នាបួសទាំងអស់ ។ ព្រះពោធិសត្វមានពួកឥសីជាបរិវារនៅក្នុងទីនោះឯង តមកដំណឹងដែលតាបសស្នាក់នៅត្រង់ទីនោះ បានផ្សព្វផ្សាយទូទៅក្នុងជម្ពូទ្វីប ។ ព្រះរាជាអង្គដទៃៗ ព្រមទាំងអ្នកដែនក៏នាំគ្នាមកបួសក្នុងសម្នាក់របស់ព្រះមហាសត្វនោះ ។ រាប់បានជាមហាសមាគមដ៏ធំក្រៃលែង ។ បរិស័ទមួយសែន មិនមែនតិចបានមានហើយដោយលំដាប់ ។ បុគ្គលណាត្រិះរិះក្នុងកាមវិតក្កៈ ព្យាបាទវិតក្កៈ ឬវិហិង្សាវិតក្កៈ ព្រះមហាសត្វក៏ទៅក្នុងទីនោះ អង្គុយលើអាកាសសម្តែងធម៌ ប្រាប់កសិណបរិកម្មដល់បុគ្គលនោះ បរិស័ទទាំងឡាយតាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វហើយញុំាងសមាបត្តិ ៨ ឲ្យកើតឡើង សម្រេចក្នុងឈាន ។ ព្រះមហាសត្វក៏មានអន្តេវាសិកដែលជាធំ ៧ នាក់ គឺ **សាលិស្សរៈ ១ មេណ្ឌិស្សរៈ ១ បព្វតៈ ១ កាលទេវលៈ ១ កីសវច្ឆៈ ១ អនុសិស្សៈ ១ នារទៈ ១** ក្នុងវេលាតមក អាស្រមក្នុងកបិដ្ឋវ័ន ក៏

ពេញបរិបូណ៌ ឱកាសទីនៅរបស់ពួកឥសីមិនគ្រប់គ្រាន់ ។

លំដាប់នោះ ព្រះមហាសត្វទើបហៅសាលិស្សរៈមក ប្រាប់ថា "ម្នាលសាលិស្សរៈ អាស្រមនេះមិនល្មមដល់ពួកឥសី លោកចូរនាំពួកឥសីនេះ ចូលទៅអាស្រ័យលម្ពចូលកនិគមក្នុងដែនរបស់ព្រះបាទមេជ្ឈរាជអាស្រ័យនៅចុះ" ។ សាលិស្សរតាបស ទទួលពាក្យរបស់ព្រះមហាសត្វថា "សាធុ" ហើយនាំពួកឥសីប្រមាណពាន់សេស ទៅនៅក្នុងលម្ពចូលកនិគមនោះ ។ កាលមនុស្សទាំងឡាយនាំគ្នាបួសហើយ អាស្រមក៏ពេញទៀត ។ ព្រះមហាសត្វទើបហៅមេណ្ឌិស្សរតាបសមកប្រាប់ថា "ម្នាលមេណ្ឌិស្សរៈ ស្ទឹងឈ្មោះសាតោទកានទី នៅចន្លោះដែនសុរដ្ឋជនបទមានហើយ លោកចូរនាំពួកឥសីនេះទៅកាន់មាត់ស្ទឹងសាតោទកានទីនោះចុះ" ដោយឧបាយនោះឯង ព្រះពោធិសត្វហៅបព្វតតាបសមកក្នុងវារៈទី ៣ បញ្ជូនទៅថា "ម្នាលបព្វតៈ ភ្នំឈ្មោះអញ្ជនបព៌តមាននៅក្នុងព្រៃធំ លោក

ចូរចូលទៅអាស្រ័យអញ្ជនបព៌តនោះចុះ” ក្នុងវារៈទី ៤ ព្រះពោធិ-សត្វហៅកាឡទេវលតាបសមកថា “ម្នាលកាឡទេវលៈ ក្នុងដែនអវន្តី ក្នុងទក្ខិណាជនបទ មានភ្នំឈ្មោះឃនសេលបព៌ត លោកចូរអាស្រ័យឃនសេលបព៌តនោះចុះ” ។ អាស្រមក្នុងកបិដ្ឋវ័នក៏ពេញបរិបូណ៌ទៀត ។ ក្នុងស្ថានទី ៥ កន្លែងក៏មានពួកឥសីចំនួនដោយសែនសេស ចំណែកកីសវច្ឆតាបសក៏លាព្រះមហាសត្វ ចូលទៅអាស្រ័យលោកសេនាបតី គឺ នៅក្នុងព្រះរាជឧទ្យានក្នុងកុម្ភវតីនគរ ដែនរបស់ព្រះបាទទណ្ឌកីរាជ ។ នារទតាបសទៅនៅទីវាលនៃភ្នំអញ្ជនគិរី ក្នុងមជ្ឈិមប្រទេស ចំណែកអនុសិស្សតាបសក៏នៅក្នុងសម្នាក់របស់ព្រះមហាសត្វនោះឯង ។

កាលនោះ ព្រះបាទទណ្ឌកីរាជទ្រង់ដកស្រីពេស្យាម្នាក់ដែលបានសក្ការៈពីតំណែង ។ នាងត្រាច់ទៅតាមធម្មតារបស់ខ្លួន ដើរទៅកាន់ព្រះរាជឧទ្យានបានឃើញកីសវច្ឆតាបស គិតថា “តាបសនេះ

គន់ជាមនុស្សក្រាឡកណ្ដី យើងនឹងលោស់ខ្លួនចង្រៃ (បាបគ្រោះ) ដាក់លើសរីរៈរបស់តាបសនេះ ងូតទឹកហើយទើបទៅ” ដូច្នេះហើយ ទើបទំពាឈើស្ទន់ ហើយខាកស្ដោះស្ទេស្នំដុំៗ ដាក់លើសរីរៈរបស់តាបសនោះ មុនដំបូងស្ដោះដាក់ចន្លោះជដា ហើយបោះឈើស្ទន់ទៅសីសៈរបស់កីសវច្ឆតាបសនោះទៀត ខ្លួនឯងជ្រងសក់ហើយក៏គេចចេញទៅ ។ តមកព្រះរាជាទ្រង់រលឹកដល់នាង ហើយក៏ចាត់ស្ដាបនានាងទុកក្នុងតំណែងដើម ។ នាងជាមនុស្សវង្វេង បានធ្វើការសម្គាល់ថា “ព្រោះយើងរំដោះគ្រោះចង្រៃដាក់លើសរីរៈរបស់មនុស្សក្រាឡកណ្ដី ព្រះរាជាទើបទ្រង់ស្ដាបនាយើងទុកក្នុងតំណែងដើម យើងទើបបាននូវយសនេះវិញ” ។ តមកមិនយូរប៉ុន្មាន ព្រះរាជាទ្រង់ក៏ដកបុរោហិតចេញពីឋានន្តរសក្តិ ។ បុរោហិតនោះទើបទៅកាន់សម្នាក់របស់នាងគណិកានោះ សួរថា “ព្រោះហេតុអ្វី នាងទើបបានតំណែងវិញហ្ន៎?” លំដាប់នោះ ស្រីគណិកាទើបប្រាប់ថា

“ព្រោះខ្ញុំរំដោះគ្រោះលើសរីរៈរបស់មនុស្សកាឡកណ្ណី ក្នុងព្រះរាជឧទ្យាន” បុរោហិតទើបទៅរំដោះគ្រោះដាក់លើសរីរៈរបស់កីសវច្ឆតាបសយ៉ាងនោះដូចគ្នា ។ ព្រះរាជាទ្រង់ក៏ស្ដាប់នាសូម្បីបុរោហិតនោះទុកក្នុងឋានន្តរសក្តិវិញ ។

ក្នុងវេលាតមក ដាយព្រះរាជាណាខេត្តរបស់ព្រះបាទទណ្ឌកីនោះកើតចលាចល ស្ដេចហែហមទៅដោយអង្គសេនា ស្ដេចចេញដើម្បីយុទ្ធនាការ លំដាប់នោះបុរោហិតដែលវង្វេង បានទូលសួរព្រះរាជាថា “បពិត្រមហារាជ ព្រះអង្គទ្រង់ប្រាថ្នាជ័យជំនះ ឬបរាជ័យ” កាលព្រះរាជាត្រាស់តបថា “ប្រាថ្នាជ័យជំនះ” ទើបក្រាបទូលថា “បើដូច្នោះ មនុស្សកាឡកណ្ណីនៅក្នុងព្រះរាជឧទ្យាន ព្រះអង្គទ្រង់ចូររំដោះគ្រោះ ដាក់លើសរីរៈរបស់មនុស្សកាឡកណ្ណីនោះហើយ ស្ដេចយាងទៅចុះ” ព្រះរាជាជឿពាក្យបុរោហិតនោះ ត្រាស់ថា “អ្នកណាទៅជាមួយយើង ចូរនាំគ្នាទៅរំដោះគ្រោះត្រង់សរីរៈរបស់មនុស្ស

កាឡកណ្ណីក្នុងព្រះរាជឧទ្យាន” ហើយស្តេចចូលទៅកាន់ព្រះរាជ-ឧទ្យាន ទ្រង់ទំពាឈើស្ងួន់ ហើយព្រះអង្គទ្រង់ស្តោះទឹកមាត់ និងបោះឈើស្ងួន់ដាក់លើត្រង់ចន្ទោះជដារបស់កីសវច្ឆតាបសនោះមុនគេ ហើយទ្រង់ជ្រលក់ដៃក្នុងទឹកមកជ្រងសក់ ។ សូម្បីពលនិកាយរបស់ព្រះអង្គក៏ធ្វើដូច្នោះ ។ ក្នុងកាលព្រះរាជាស្តេចចេញទៅហើយ សេនាបតីមកជួបតាបស កាន់យកឈើស្ងួន់ទាំងអស់ចេញ ឲ្យស្រង់ទឹកយ៉ាងល្អ ហើយសួរថា “លោកម្ចាស់ អ្វីនឹងមានដល់ព្រះរាជា?” កីសវច្ឆតាបសតបថា “ចម្រើនពរ ការគិតប្រទូសមិនមានក្នុងចិត្តអាត្មា តែទេវតាមេឃដីក្រោធ រាប់តាំងអំពីនេះទៅ ៧ ថ្ងៃ នឹងធ្វើដែនដីទាំងអស់ឲ្យខ្ទេចខ្ទី លោកចូរគេចទៅនៅទីដទៃដោយរហ័សចុះ” សេនាបតីនោះភ័យតក់ស្លុត ទើបទៅក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះបាទទណ្ឌកីទ្រង់ស្តាប់ពាក្យសេនាបតីហើយទ្រង់មិនជឿ សេនាបតីនោះទើបត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន នាំបុត្តភរិយា

រត់ទៅនៅដែនដទៃ សរភង្គតាបសជាសាស្តាចារ្យដឹងហេតុនោះ ក៏បញ្ជូនតាបសកំលោះ ២ រូប ឲ្យយកមញ្ចសីវិកាហាមកិសវច្ចតាបស មកតាមផ្លូវអាកាស ។ ព្រះរាជាទ្រង់ច្បាំងចាប់ចោរបានហើយស្តេចក៏ត្រឡប់មកកាន់ព្រះនគរ ។ កាលព្រះរាជាស្តេចមកហើយទេវតាទាំងឡាយទើបបណ្តាលភ្លៀងឲ្យធ្លាក់ចុះមកមុន កាលសពគ្រប់ប្រភេទត្រូវអន្ទង់ទឹកភ្លៀងបន្សាត់នាំទៅហើយ ភ្លៀងខ្សាច់សុទ្ធក៏ធ្លាក់ចុះមក ភ្លៀងផ្កាឈើទិព្វក៏ធ្លាក់ចុះលើគំនរភ្លៀងខ្សាច់ ភ្លៀងមាសកៈធ្លាក់មកលើគំនរភ្លៀងផ្កាឈើ ភ្លៀងកហាបណៈធ្លាក់មកលើគំនរមាសកៈ ភ្លៀងទិព្វាភរណ៍ធ្លាក់មកលើគំនរភ្លៀងកហាបណៈ ។ មនុស្សទាំងឡាយក៏សោមនស្ស នាំគ្នារើសមាសប្រាក់ និងគ្រឿងអាភរណ៍ ។ លំដាប់នោះ ភ្លៀងអាវុធដ៏ក្លៀវក្លាមានប្រការផ្សេងៗធ្លាក់ចុះលើសរីរៈរបស់មនុស្សទាំងនោះ ។ មនុស្សទាំងនោះដាច់ជាកំណាត់តូចធំ ។ លំដាប់នោះ ផេះភ្លើងប្រាសចាកអណ្តាតដ៏ធំ

ក៏ធ្លាក់ចុះលើមនុស្សទាំងនោះ ។ កំពូលបពិតដ៏ធំឆេះភ្លើងរមៀល កិនលើមនុស្សទាំងនោះ ភ្លៀងខ្សាច់គ្រាប់ល្អិតដែលញ៉ាំងទីប្រមាណ ៦០ យោជន៍ បានញ៉ាំងទីឲ្យមិនមែនជារង្គមណ្ឌលដោយអាការយ៉ាងនេះ ។ ភាពជាដែនដីនោះក៏វិនាសទៅយ៉ាងនេះ បានផ្សព្វផ្សាយទូទៅពេញជម្ពូទ្វីប ។

គ្រានោះ ព្រះរាជា ៣ ព្រះអង្គ គឺ ព្រះបាទកាលិង្គៈ ១ ព្រះបាទអដ្ឋកៈ ១ ព្រះបាទភិមរថៈ ១ ដែលជាធំក្នុងដែនជាប់តគ្នានឹងដែននោះ ទ្រង់គិតគ្នា "បានឮថា ក្នុងកាលមុនព្រះបាទកាលាពុកាសិរាជ ក្នុងព្រះនគរពារាណសីប្រព្រឹត្តខុសក្នុងខន្តិវាទីតាបស ក៏ត្រូវផែនដីស្រូប ព្រះបាទនាលិកីរាជឲ្យស្ុនខខាំស៊ីតាបស និងព្រះបាទអជ្ជុនៈដែលទ្រទ្រង់នូវកម្លាំងដៃដល់ពាន់ ប្រព្រឹត្តខុសក្នុងអង្គីរសតាបស ក៏ត្រូវផែនដីស្រូបដូចគ្នា បានឮថា ក្នុងគ្រានេះព្រះបាទទណ្ឌកីរាជធ្វើខុសក្នុងកីសវច្ឆតាបស ក៏ដល់នូវសេចក្តីវិនាសព្រម

ទាំងដែនដី ពួកយើងមិនដឹងទីកើតរបស់ព្រះរាជាទាំង ៤ នេះ វៀរ សរភង្គសាស្តាចេញហើយ អ្នកដទៃឈ្មោះថា អាចនឹងប្រាប់រឿង នោះដល់យើងមិនមាន ពួកយើងនឹងចូលទៅសួរនូវបញ្ហាទាំងនោះ ក្សត្រទាំង ៣ ព្រះអង្គនោះព្រមទាំងរាជបរិវារដ៏ច្រើន ស្តេចចេញ ទៅដើម្បីនឹងសួរបញ្ហា ។ តែព្រះរាជាទាំង ៣ អង្គនោះទ្រង់មិន បានជ្រាបថា "សូម្បីព្រះរាជាអង្គឯណោះ ក៏ស្តេចចេញហើយទេ" អង្គខ្លះទ្រង់សម្គាល់ថា យើងទៅតែម្នាក់ឯងប៉ុណ្ណោះ ព្រមទាំងសមា-គមនៃក្សត្រទាំងនោះ" ដែលមានមិនឆ្ងាយអំពីស្ទឹងគោធាវរី ។ ព្រះ រាជាទាំងនោះស្តេចចុះចាកអំពីរថហើយ ស្តេចឡើងរថមួយជាមួយ គ្នាទៅ ទាំងព្រះអង្គក៏ទៅដល់មាត់ស្ទឹងគោធាវរី ។ ខណៈនោះសក្ក-ទេវរាជប្រថាប់អង្គុយលើព្រះទែនបណ្ឌុកម្ពលសិលាសនៈ ទ្រង់គិត បញ្ហា ៧ ប្រការ ហើយទ្រង់រំពឹងថា "វៀរសរភង្គសាស្តាចេញហើយ ជនដទៃក្នុងមនុស្សលោក ព្រមទាំងទេវលោក ដែលឈ្មោះថាអាច

នឹងដោះស្រាយបញ្ហានេះមិនមាន យើងនឹងសួរបញ្ហាទាំងនេះជាមួយសរភង្គសាស្តានោះ សូម្បីព្រះរាជាទាំង ៣ អង្គក៏មកដល់មាត់ស្ទឹងគោធាវរី ដើម្បីនឹងសួរបញ្ហាជាមួយសរភង្គសាស្តា យើងក៏នឹងសួរសូម្បីបញ្ហារបស់ព្រះរាជាទាំងនោះ” ពួកទេវតាក្នុងទេវលោកទាំងពីរ ហែហមហើយស្តេចក៏ចុះចាកទេវលោក ។ ក្នុងថ្ងៃនោះ កីសវច្ឆតាបសក៏បានធ្វើកាលកិរិយា ។ ឥសីច្រើនពាន់ក្នុងទីទាំង ៤ ក៏ទៅក្នុងទីនោះដូចគ្នា ដើម្បីធ្វើការតម្កល់សពរបស់កីសវច្ឆតាបសនោះ ហើយធ្វើមណ្ឌបទុក និងពួកឥសីពាន់សេសក្នុងទីទាំង ៥ នាំគ្នាធ្វើចិត្តកាធារដោយឈើចន្ទន៍ ដើម្បីតាំងសរីរៈរបស់កីសវច្ឆតាបស ហើយនាំគ្នាជួយដុតសរីរៈសព ភ្លៀងផ្កាកុមុទទិព្វធ្លាក់ចុះក្នុងស្ថានទីប្រមាណកន្លះយោជន៍ជុំវិញស្មសាន ។ ព្រះមហាសត្វឲ្យបាត់ការរើសសរីរធាតុរបស់កីសវច្ឆតាបស ហើយចូលទៅកាន់អាស្រមហែហមទៅដោយពួកឥសីទាំងនោះ ។ ក្នុងវេលាព្រះរាជា

ទាំងនោះមកដល់ប្រាំងទទី សំឡេងនៃកងទ័ពធំ សំឡេងនៃពាហនៈ និងសំឡេងនៃតន្ត្រីបានប្រាកដហើយ ព្រះមហាសត្វបានស្តាប់សំឡេងនោះ ទើបហៅអនុសិស្សតាបសមកប្រាប់ថា “លោកចូរទៅមើលមុនចុះ នោះជាសំឡេងអ្វី?” អនុសិស្សតាបសទើបកាន់ក្អមដាក់ទឹកទៅកាន់ទីនោះ ជួបព្រះរាជាទាំង ៣ ព្រះអង្គ ទើបពោលគាថាទី ១ ដោយជាពាក្យសួរថា

[៩៧៥] អលង្កតា កុណ្ឌលិនោ សុវត្ថា
វេឡុរិយមុត្តាថរុខគ្គពន្ធា
រថេសភា តិដ្ឋថ កេ នុ តុម្ហេ
កថំ វោ ជានន្តិ មនុស្សលោកេ ។

លោកទាំងឡាយប្រដាប់ហើយ ពាក់កុណ្ឌល ស្លៀកដណ្តប់សំពត់ល្អស្អាត សៀតព្រះខាន់មានស្រោមប្រដាប់ដោយកែវពិទូរ្យ និងកែវមុក្តា ជាកំពូលនៃពលឈរហើយ ជានរណាហ្ន៎

ជនទាំងឡាយក្នុងមនុស្សលោក នឹងស្គាល់លោកទាំងឡាយ ដូចម្ដេច?

បណ្ដាបទទាំងនោះ បទថា វេឡុរិយមុត្តាថរុក្ខគ្គពន្ធា “សៀត ព្រះខាន់មានស្រោមប្រដាប់ដោយកែវពិទូរ្យ និងកែវមុក្តា” សេចក្ដី ថា ប្រកបទៅដោយព្រះខាន់កែវ មានស្រោមប្រដាប់ទៅដោយកែវ ពិទូរ្យ និងរំយោលកែវមុក្តា ។ បទថា តិដ្ឋថ “ឈរហើយ” ន័យ ថា លោកទាំងឡាយឈរហើយនៅក្នុងរថមួយជាមួយគ្នា ។ បទថា កេ នុ “ជានរណាហ្ន៎” សេចក្ដីថា ពួកលោក គឺ នរណា មនុស្ស ក្នុងលោកស្គាល់ពួកលោកបានដូចម្ដេច?

ក្សត្រទាំងឡាយស្ដាប់ពាក្យរបស់តាបសហើយ ស្ដេចយាង ចុះចាករថថ្វាយនមស្ការហើយប្រថាប់ឈរ ។ ក្នុងក្សត្រទាំង ៣ អង្គ ព្រះបាទអដ្ឋករាជ កាលនឹងទ្រង់សន្ទនាជាមួយអនុសិស្សតាបស ទើបត្រាស់គាថាទី ២ ថា

[៥៧៦] អហមដ្ឋកោ ភីមរថោ បនាយំ
កាលិង្គរាជា បន ឧគ្គតោយំ
សុសញ្ញតានំ ឥសីនំ ទស្សនាយ
ឥធាគតា បុច្ឆិតាយេម្ហ បញ្ហេ ។

ខ្ញុំជាក្សត្រឈ្មោះអដ្ឋកៈ អង្គនេះគឺ ព្រះបាទភីមរថៈ ចំណែកអង្គនេះគឺ ព្រះបាទកាលិង្គរាជ មានព្រះតេជះល្បីល្បាញ ខ្ញុំទាំងបីមកក្នុងទីនេះ ដើម្បីសួរសុខទុក្ខឥសីទាំងឡាយអ្នកសង្រួមដោយល្អ និងដើម្បីសូមសួរបញ្ហា ។

បណ្ដាបទទាំងនោះ បទថា ឧគ្គតោ[១] "ល្បីល្បាញ" ន័យថា ជាអ្នកប្រាកដខ្ពរខ្ពាយទៅដូចព្រះចន្ទ និងព្រះអាទិត្យ ។ បទថា សុសញ្ញតានំ ឥសីនំ "ឥសីទាំងឡាយអ្នកសង្រួមដោយល្អ" សេចក្ដីថា (ព្រះបាទអដ្ឋករាជត្រាស់ថា) លោកម្ចាស់ ពួកខ្ញុំមកនឹងដើម្បីលេងកីឡាក្នុងព្រៃក៏មិនមែន ដែលពិត ពួកខ្ញុំមកក្នុងទីនេះក៏

ដើម្បីសួរសុខទុក្ខពួកឥសីជាអ្នកមានសីលសង្រួមល្អហើយ ដោយកាយជាដើម ។ បទថា **បុច្ឆិតាយេម្ហ បញ្ហេ**[១] "ខ្ញុំ... ដើម្បីនឹងសួរបញ្ហា" សេចក្តីថា ជាអ្នកមកហើយដើម្បីសាកសួរបញ្ហានឹងសរភង្គតាបសជាសាស្តា បណ្ឌិតគួរជ្រាបថា យ អក្សរ ធ្វើការភ្ជាប់នឹងព្យញ្ជនៈ ។

លំដាប់នោះ តាបសទើបបានទូលព្រះរាជាទាំងនោះថា "សូមថ្វាយព្រះពរព្រះមហារាជ ល្អហើយ ព្រះអង្គទាំងបីទ្រង់យាងមកស្ថានទីដែលគួរមកដោយពិត បើដូច្នោះ សូមស្រង់ទឹកហើយស្តេចយាងទៅកាន់អាស្រម ទ្រង់សំពះពួកឥសី ហើយត្រាស់សួរបញ្ហានឹងតាបសជាសាស្តាចុះ" លុះធ្វើបដិសណ្ឋារៈជាមួយព្រះរាជាទាំងនោះហើយ ទើបលើកក្អមទឹកឡើង ជូតតំណក់ទឹកបណ្តើរក្រឡេកមើលទៅអាកាសបណ្តើរ ឃើញសក្កទេវរាជហែហមដោយពួកទេវតាស្តេចទ្រង់លើ.គជ័រឯរាវ័ណដ៏ប្រសើរស្តេចកំពុងមក កាលនឹងសន្ទនា

---

បិដក. ១. បញ្ហេ ។

ជាមួយសក្កទេវរាជ ទើបពោលគាថាទី ៣ ថា

[៥៧៧] វេហាសយំ តិដ្ឋសិ អន្តលិក្ខេ

បថទ្ធុនោ បណ្ណរសេវ ចន្ទោ

បុច្ឆាមិ តំ យក្ខ មហានុភាវ

កថន្តំ ជានន្តិ មនុស្សលោកេ ។

លោកហោះតាមអាកាសវេហា ដូចជាព្រះចន្ទរសាត់នៅកណ្តាលផ្ទៃមេឃក្នុងថ្ងៃ ១៥ កើតដូច្នោះ ម្នាលទេវតា អាត្មាសូមសួរលោកអ្នកមាននូវអានុភាពច្រើន ជនទាំងឡាយក្នុងមនុស្សលោកនឹងស្គាល់លោកបានយ៉ាងណា? ។

បណ្តាបទទាំងនោះ បទថា វេហាសយំ "វេហា" សេចក្តីថា លោកហោះនៅក្នុងកណ្តាលវេហា គឺ ក្នុងអាកាស ។ បទថា បថទ្ធុនោ "អណ្តែត" សេចក្តីថា ដូចព្រះចន្ទដែលទៅកាន់ផ្លូវឆ្ងាយ គឺតាំងនៅក្នុងកណ្តាលផ្ទៃមេឃដែលជាដែនឆ្ងាយ ដូច្នោះ ។

សក្កទេវរាជបានស្តាប់ដូច្នោះ ទើបត្រាស់គាថាទី ៤ ថា

[៥៧៨] យមាហុ ទេវេសុ សុជម្បតីតិ
មឃវាតិ តំ អាហុ មនុស្សលោកេ
ស ទេវរាជា ឥធមជ្ជ បត្តោ
សុសញ្ញតានំ ឥសីនំ ទស្សនាយ ។

ក្នុងទេវលោកគេហៅខ្ញុំថា សុជម្បតី ក្នុងមនុស្សលោក គេហៅខ្ញុំថា ស្តេចមឃវា ខ្ញុំនេះគឺ ស្តេចទេវរាជ ថ្ងៃនេះមក ដល់ទីនេះ ដើម្បីសូមសួរសុខទុក្ខឥសីទាំងឡាយអ្នកសង្រួម ហើយដោយល្អ ។

បណ្តាបទទាំងនោះ បទថា ស ទេវរាជា "ខ្ញុំនោះ គឺ ស្តេចទេវរាជ" សក្កទេវរាជត្រាស់ថា "ខ្ញុំនេះ គឺ សក្កទេវរាជ" ។ បទថា ឥទមជ្ជ[១] បត្តោ "ថ្ងៃនេះមកដល់ទីនេះ" សេចក្តីថា មកកាន់

បិដក. ១. ឥធមជ្ជ ។

ស្ថានទីនេះ ក្នុងវេលានេះ ។ បទថា **ទស្សនាយ** “ដើម្បីសួរសុខទុក្ខ” សេចក្តីថា សក្កទេវរាជត្រាស់ថា “ដើម្បីនឹងសួរសុខទុក្ខ ក្រាបនមស្ការ និងដើម្បីសួរបញ្ហាជាមួយសរភង្គតាបសជាសាស្តាផង” ។

លំដាប់នោះ អនុសិស្សតាបសទើបទូលសក្កទេវរាជនោះថា “ប្រពៃហើយ ព្រះមហារាជ ព្រះអង្គស្តេចទ្រង់មកខាងក្រោយចុះ” ដូច្នេះហើយ ទើបកាន់ក្អមទឹកចូលទៅកាន់អាស្រម រក្សាក្អមទឹកហើយ ក្រាបប្រាប់រឿងដែលព្រះរាជា ៣ ព្រះអង្គ និងសក្កទេវរាជស្តេចមកដើម្បីនឹងត្រាស់សួរបញ្ហាចំពោះព្រះមហាសត្វ ព្រះមហា-សត្វនោះហែហមដោយពួកឥសី អង្គុយត្រង់រោងដ៏ធំ ។ ព្រះរាជាទាំង ៣ ព្រះអង្គស្តេចមកសំពះពួកឥសី ហើយប្រថាប់គង់ក្នុងទីដ៏សមគួរ ។ ចំណែកសក្កទេវរាជស្តេចក៏មក ហើយចូលទៅរកពួកឥសី ប្រថាប់ឈរផ្គងអញ្ជលី កាលទ្រង់សរសើរពួកឥសី ទើបថ្វាយនមស្ការ ត្រាស់គាថាទី ៥ ថា

[៥៧៩] *ទូរេ សុតា នោ ឥសយោ សមាគតា*

*មហិទ្ធិកា ឥទ្ធិគុណូបបន្នា*

*វន្ទាមិ តេ អយិរេ បសន្នចិត្តោ*

*យេ ជីវលោកេត្ថ មនុស្សសេដ្ឋា ។*

ឥសីទាំងឡាយរបស់ខ្ញុំ អ្នកមានឫទ្ធិច្រើន ចូលដល់នូវឥទ្ធិគុណ មកប្រជុំព្រមគ្នាហើយប្រាកដក្នុងទីឆ្ងាយ ខ្ញុំមានចិត្តជ្រះថ្លា សូមសំពះលោកម្ចាស់ទាំងឡាយដ៏ប្រសើរជាងមនុស្សក្នុងជីវលោកនេះ ។

បណ្តាបទទាំងនោះ បទថា *ទូរេ សុតា នោ* “របស់ខ្ញុំ... ប្រាកដក្នុងទីឆ្ងាយ” សេចក្តីថា កាលស្តេចទេវរាជ ទ្រង់នឹងសម្តែងសេចក្តីរាប់អាន ទើបត្រាស់យ៉ាងនេះថា “បពិត្រលោកដ៏ចម្រើនលោកទាំងឡាយដែលពួកខ្ញុំអ្នកស្ថិតនៅទេវលោកជាដែនឆ្ងាយ បានឮបានស្តាប់ហើយ” មានពាក្យអធិប្បាយថា “ឥសីទាំងឡាយរបស់

ពួកយើងមកប្រជុំគ្នានៅត្រង់ទីនេះ ពួកខ្ញុំបានឮហើយក្នុងទីឆ្ងាយ គឺប្រាកដទៅរហូតដល់ព្រហ្មលោក” ។ បទថា **មហិទ្ធិកា “អ្នកមានឫទ្ធិច្រើន”** បានដល់ មានអានុភាពច្រើន ។ បទថា **ឥទ្ធិគុណូបបន្នា “ចូលដល់នូវឥទ្ធិគុណ”** សេចក្តីថា ប្រកបទៅដោយឥទ្ធិគុណ ៥ យ៉ាង ។ បទថា **អយិរេ “លោកម្ចាស់”** បានដល់ ក្នុងលោកម្ចាស់ ។ បទថា **យេ “ណា”** សេចក្តីថា ខ្ញុំសូមសំពះពួកលោកដែលជាអ្នកប្រសើរបំផុត ក្នុងពួកមនុស្សក្នុងជីវលោកនេះ ។

សក្កទេវរាជត្រាស់សរសើរពួកឥសីយ៉ាងនេះហើយ កាលនឹងទ្រង់ចៀសវាងនូវទោសក្នុងការអង្គុយ ៦ យ៉ាង ទើបប្រថាប់អង្គុយក្នុងទីដ៏សមគួរ ។ លំដាប់នោះ អនុសិស្សតាបសឃើញស្តេចសក្កទេវរាជប្រថាប់អង្គុយត្រង់ក្រោមខ្យល់នៃពួកឥសី ទើបពោលគាថាទី ៦ ថា

[៥៨០] គន្ធោ ឥសីនំ ចិរទក្ខិតានំ

កាយា ចុតោ គច្ឆតិ មាលុតេន

ឥតោ បដិក្កម្ម សហស្សនេត្ត

គន្ធោ ឥសីនំ អសុចិ ទេវរាជ ។

ក្លិននៃឥសីទាំងឡាយអ្នកបួសយូរ រមែងចេញចាកកាយ ផ្សាយទៅតាមខ្យល់បាន ស្តេចសហស្សនេត្រ សូមមហាបពិត្រ ថយអំពីទីនេះ ស្តេចទេវរាជ ក្លិនឥសីទាំងឡាយមិនស្អាត ។

បណ្តាបទទាំងនោះ បទថា ចិរទក្ខិតានំ "អ្នកបួសយូរ" គឺ របស់អ្នកបួសអស់កាលយូរ ។ បទថា បដិក្កម្ម "ថយចេញទៅ" សេចក្តីថា សូមព្រះអង្គប្រោសស្តេចចេញទៅ គឺ ប្រោសថយចេញទៅ ។ បទថា សហស្សនេត្ត "ស្តេចសហស្សនេត្រ" នេះ ជាអាលបនៈ ។ ពិតហើយ ស្តេចសក្កៈក៏មួយអង្គនោះឯង (តែ) ទ្រង់ឃើញអត្ថដែលអាមាត្យ ១.០០០ នាក់គិតហើយ ដូច្នោះទើបហៅថា ស្តេចសហស្សនេត្រ ។ មា៉្យងទៀត ឈ្មោះថា ស្តេចសហស្សនេត្រ

ព្រោះជាអ្នកអាចធ្វេងផុតវិស័យនៃការឃើញរបស់ពួកទេវតាអ្នកមានព្រះនេត្រ ១.០០០ ដួង ។ បទថា **អសុចិ** “**មិនស្អាត**” សេចក្តីថា ឈ្មោះថាមានក្លិនស្អុយ ព្រោះប្រកបហើយដោយញើស ក្អែល និងមន្ទិលជាដើម មួយទៀត លោកទាំងឡាយជាអ្នកត្រូវការសេចក្តីស្អាត ហេតុនោះ ក្លិននេះរមែងនឹងបៀតបៀនលោកទាំងឡាយ ។

សក្កទេវរាជទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់គាថាតទៅថា

[៥៨១] គន្ធោ ឥសីនំ ចិរទក្ខិតានំ
កាយា ចុតោ គច្ឆតុ មាលុតេន
វិចិត្របុប្ផំ សុរភឹវ មាលំ
គន្ធញ្ច ឯតំ បដិកង្ខាម ភន្តេ
ន ហេត្ថ ទេវា បដិកូលសញ្ញិនោ ។

ក្លិនឥសីទាំងឡាយអ្នកបួសយូរ ចូរចេញចាកកាយផ្សាយទៅតាមខ្យល់ចុះ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំទាំងឡាយ

រមែងប្រាថ្នាក្លិននោះ ដូចជាកួនបុប្ផជាតិដ៏វិចិត្រមានក្លិនក្រអូប ព្រោះថា ទេវតាទាំងឡាយមិនបានសម្គាល់ក្នុងក្លិននេះថា ជាបដិកូលឡើយ ។

បណ្ដាបទទាំងនោះ បទថា **គច្ឆតុ "ផ្សាយទៅ"** សេចក្ដីថា ក្លិនរបស់ឥសីទាំងឡាយចូរប្រព្រឹត្តទៅតាមសម្រួលចុះ ។ អធិប្បាយថា ចូរប៉ះខ្ទប់នឹងច្រមុះរបស់ពួកខ្ញុំចុះ ។ បទថា **បដិកង្ខាម "រមែងប្រាថ្នា"** សេចក្ដីថា ពួកខ្ញុំត្រូវការ គឺ ប្រាថ្នា ។ បទថា **ឯត្ថ "ក្នុងក្លិននោះ"** សេចក្ដីថា ទេវតាទាំងឡាយមិនបានសម្គាល់ក្នុងក្លិននេះថា គួរខ្ពើមឡើយ ព្រោះពួកទេវតាទាំងឡាយនាំគ្នារង្កៀសក្នុងជនអ្នកទ្រុស្តសីលតែម្យ៉ាង មិនរង្កៀសក្នុងអ្នកមានសីលទេ ។

ក៏គ្រាស្ដេចសក្កទេវរាជពោលយ៉ាងនេះហើយ ទើបត្រាស់ថា "បពិត្រអនុសិស្សតាបសដ៏ចម្រើន ខ្ញុំមកដោយឧស្សាហ៍ធំដើម្បីសួរបញ្ហា លោកចូរធ្វើឱកាសដល់ខ្ញុំផងចុះ" ។ អនុសិស្សតាបសបាន

ស្តាប់ព្រះតម្រាស់របស់ស្តេចសក្កៈហើយ ទើបក្រោកពោលគាថា ២ គាថាថា

[៥៨២] បុរិន្ទទោ ភូតបតី យសស្សី
ទេវានមិន្ទោ មឃវា សុជម្បតិ
ស ទេវរាជា អសុរ (គណ) ប្បមទ្ទនោ
ឱកាសមាកង្ខតិ បញ្ហ បុច្ឆិតុំ ។
កោ នេវិមេសុំ ឥធ បណ្ឌិតានំ
បញ្ហេ បុដ្ឋោ និបុណេ ព្យាករិស្សតិ
តិណ្ណញ្ច រញ្ញំ មនុជាធិបានំ
ទេវានមិន្ទស្ស ច វាសវស្ស ។

ស្តេចមឃវាន សុជម្បតីទេវរាជ អន្តបុរិន្ទទៈដែលជាធំនៃភូត មានព្រះយស ជាធំជាងពួកទេវតា ទ្រង់ញាំញីពួកអាសុរ ទ្រង់រង់ចាំឱកាសដើម្បីត្រាស់សួរបញ្ហា ។

បណ្ដាឥសីជាបណ្ឌិតទាំងនេះ នៅត្រង់ទីនេះ នរណាហ្ន៎ ត្រូវសួរហើយ នឹងព្យាករបញ្ហាដែលសុខុមរបស់ព្រះរាជាទាំង ៣ ព្រះអង្គអ្នកជាធំក្នុងពួកមនុស្ស និងរបស់ស្ដេចវាសវៈអ្នកជាធំលើពួកទេវតាបាន ។

បណ្ដាបទទាំងនោះ បទថា **បុរិន្ទទោ** **“អង្គបុរិន្ទទៈ”** ជាដើម ជាគុណនាមរបស់សក្កទេវរាជនោះឯង ពិតហើយ ព្រោះស្ដេចសក្កៈនោះឲ្យទានមុន ទើបឈ្មោះថា **អង្គបុរិន្ទទៈ** ព្រោះជាធំក្នុងពួកភូតនិកាយ ទើបឈ្មោះថា **ភូបតិ** **“អ្នកជាធំនៃភូត”** ព្រោះដល់ព្រមដោយបរិវារ ទើបឈ្មោះថា **យសស្សី** **“មានព្រះយស”** ព្រោះជាឥស្សរធំ ទើបឈ្មោះថា **ទេវានមិន្ទោ** **“ជាធំជាងពួកទេវតា”** ព្រោះទ្រង់ធ្វើវត្តបទ ៧ ប្រការដោយល្អ ទើបឈ្មោះ **សក្កៈ**, ឈ្មោះ **មឃវា** **“មឃវាន”** ដោយអំណាចនាមក្នុងជាតិមុន ព្រោះជាស្វាមីរបស់នាងសុជាតាអសុរកញ្ញា ទើបឈ្មោះ **សុជម្បតី** ព្រោះញុាំង

ចិត្តរបស់ពួកទេវតាឲ្យត្រេកអរ ទើបឈ្មោះ **ទេវរាជ** ។ បទថា **កោនេវ** កាត់បទជា **កោ នុ ឯវ** ប្រែថា ក៏នរណាហ្ន៎ ។ បទថា **និបុណេ** "ដ៏សុខុម" បានដល់ បញ្ហាដ៏ល្អិតសុខុម ។ បទថា **រញ្ញោ** "របស់ព្រះរាជា" បានដល់ របស់ព្រះរាជាទាំងឡាយ ។ អធិប្បាយថា អនុសិស្សតាបសពោលថា "បណ្ដាឥសីអ្នកជាបណ្ឌិតទាំងនេះ នរណានឹងយល់ព្រះទ័យរបស់ព្រះរាជាទាំងបួនព្រះអង្គនេះ ហើយពោលដោះស្រាយបញ្ហារបស់ព្រះរាជាទាំងនោះចុះ" ។

ពួកឥសីបានឮដូច្នោះ ទើបពោលថា "អនុសិស្សៈអ្នកនិទុក្ខ លោកឈរនិយាយនៅលើផែនដីដូចមិនឃើញផែនដី វៀរសរភង្គជាសាស្ដាចេញហើយ អ្នកដទៃណាហ្ន៎ដែលអាចដើម្បីដោះស្រាយបញ្ហារបស់ព្រះរាជាទាំងនោះបាន" ទើបពោលគាថាថា

[៥៨៣] *អយំ ឥសិ សរភង្គោ តបស្សី*

*យតោ ជាតោ វិរតោ មេថុនស្មា*

*អាចេរបុត្តោ សុវិនីតរូបោ*

*សោ តេសំ បញ្ហានិ វិយាករិស្សតិ ។*

*សរភង្គឥសីអ្នកមានតបៈនេះ វៀរចាកមេថុនធម្មតាំងអំពីកើតមក ជាបុត្តរបស់បុរោហិតាចារ្យ បានទទួលហ្វឹកហាត់មកយ៉ាងល្អ លោកនឹងព្យាករណ៍បញ្ហារបស់ព្រះរាជាទាំងនោះបាន ។*

បណ្ដាបទទាំងនោះ បទថា **សរភង្គោ** **“សរភង្គឥសី”** ន័យថា ឥសីអ្នកបាញ់ធ្នូហើយ សម្ដែងសិល្បៈដូចជាសរបាការសិល្បៈជាដើមក្នុងអាកាស ហើយធ្វើឲ្យបែកទៅ ដូចញាំងកូនសរទាំងនោះឲ្យធ្លាក់ទៅដោយកូនសរមួយទៀតដូច្នោះ ទើបឈ្មោះថា សរភង្គៈ ។ បទថា **មេថុនស្មា** **“មេថុនធម្ម”** សេចក្ដីថា វៀរចាកមេថុនធម្ម ។ បានឮថា លោកមិនធ្លាប់បានសេពមេថុនធម្មបានមកបួសហើយ ។ បទថា **អាចរិយបុត្តោ**[១] **“ជាបុត្តរបស់បុរោហិតាចារ្យ”** សេចក្ដីថា

---

បិដក. ១. អាចេរបុត្តោ ។

លោកជាបុត្តរបស់បុរោហិតដែលជាអាចារ្យរបស់ព្រះរាជា ។

លុះពួកឥសីពោលយ៉ាងនេះហើយ ទើបប្រាប់អនុសិស្សតាបស ថា "បពិត្រលោកអ្នកនិរទុក្ខ លោកនោះឯងចូរសំពះលោកជាសាស្តា សូមឲ្យឱកាសដើម្បីនឹងដោះស្រាយដែលស្តេចសក្កទេវរាជសួរតាម ពាក្យរបស់ពួកឥសី" អនុសិស្សតាបសទទួលពាក្យហើយ ក៏សំពះ តាបសជាសាស្តា កាលនឹងសូមឱកាស ទើបពោលគាថាតទៅថា

[៥៨៤] កោណ្ឌញ្ញ បញ្ហានិ វិយាករោហិ
យាចន្តិ តំ ឥសយោ សាធុរូបា
កោណ្ឌញ្ញ ឯសោ មនុជេសុ ធម្មោ
យំ វុឌ្ឍមាគច្ឆតិ ឯស ភារោ ។

បពិត្រលោកកោណ្ឌញ្ញៈ សូមលោកបានប្រោសព្យាករណ៍ បញ្ហា ឥសីទាំងឡាយអ្នកញ៉ាំងប្រយោជន៍ឲ្យសម្រេច នាំគ្នា សូមអង្វរលោក បពិត្រលោកកោណ្ឌញ្ញៈ ភារៈនេះរមែងមក

ដល់លោកដ៏ចម្រើនដោយបញ្ញា ប្រការនេះជាធម្មតាក្នុងពួកមនុស្ស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះ ដូចតទៅនេះ អនុសិស្ស-តាបសហៅសរភង្គតាបសថា កោណ្ឌញ្ញៈដោយគោត្រ ។ បទថា ធម្មោ "ធម្មតា" បានដល់ សភាវធម៌ ។ បទថា យំ វុឌ្ឍំ "ចម្រើនដោយបញ្ញា" សេចក្ដីថា អនុសិស្សតាបសពោលថា "ឈ្មោះថាភារៈ គឺ ការវិសជ្ជនាបញ្ហានេះ រមែងមកដល់បុរសអ្នកមានបញ្ញាដែលចម្រើន នោះជាសភាវធម៌ក្នុងពួកមនុស្ស ព្រោះដូច្នោះ សូមលោកប្រោសដោះស្រាយបញ្ហារបស់ស្ដេចសក្កៈធ្វើឲ្យប្រាកដ ដូចជាញ៉ាំងព្រះចន្ទ និងព្រះអាទិត្យឲ្យតាំងឡើង ១.០០០ ដួងដូច្នោះ ។

លំដាប់នោះ ព្រះមហាបុរសកាលនឹងធ្វើឱកាស ទើបពោលគាថាជាលំដាប់តទៅថា

[៤៨៥] កតាវកាសា បុច្ឆន្តុ ភោន្តោ

យង្កិញ្ចិ បញ្ហំ មនសាភិបត្ថិតំ
អហំ ហិ តំ តំ វោ វិយាករិស្សំ
ញត្វា សយំ លោកមិមំ បរញ្ច ។

មហាបពិត្រដ៏ចម្រើនទាំងឡាយ អាត្មាភាពឲ្យឱកាសហើយ សូមត្រាស់សួរបញ្ហាណាមួយ តាមព្រះហឫទ័យប្រាថ្នាចុះ ក៏អាត្មាភាពដឹងលោកនេះ និងលោកខាងមុខដោយខ្លួនឯងហើយ នឹងព្យាករណ៍បញ្ហានោះៗ ដល់មហាបពិត្រទាំងឡាយ ។

*បណ្តាបទទាំងនោះ បទថា យំ កិញ្ចិ "ណាមួយ" សេចក្តីថា ព្រះសរភង្គតាបសប្រាថ្នានូវសព្វញ្ញុបវារណាថា "មហាបពិត្រដ៏ចម្រើនទាំងឡាយ សូមត្រាស់សួរបញ្ហាតាមចិត្តពួកលោកប្រាថ្នា ឬសូម្បីរបស់មនុស្សលោកព្រមទាំងទេវលោកនឹងយើងចុះ ព្រោះយើងធ្វើឲ្យច្បាស់នូវលោកនេះ និងលោកខាងមុខដោយបញ្ញាខ្លួនឯងហើយ នឹងដោះស្រាយបញ្ហាទាំងអស់នោះដែលអាស្រ័យលោក*

នេះ ឬលោកខាងមុខដល់លោកទាំងឡាយដោយអស់ជើង ។

កាលសរភង្គតាបសធ្វើឱកាសយ៉ាងនេះហើយ សក្កទេវរាជ ទើបត្រាស់បញ្ហាដែលព្រះអង្គត្រៀមមក ។

ទ្រង់កាលនឹងប្រកាសសេចក្ដីនោះ ព្រះសាស្ដាទើបត្រាស់ព្រះគាថាថា

[៥៨៦] តតោ ច មឃវា សក្កោ អត្ថទស្សី បុរិន្ទទោ
អបុច្ឆិ បឋមំ បញ្ហំ យញ្ចាសិ អភិបត្ថិតំ ។

លំដាប់នោះ ស្ដេចមឃវា សក្កទេវរាជ បុរិន្ទទៈ ទ្រង់ឃើញប្រយោជន៍ បានត្រាស់សួរបញ្ហាជាបឋមដូចដែលព្រះទ័យប្រាថ្នាថា

កឹសូ វធិត្វា ន កទាចិ សោចតិ
កិស្សប្បហានំ ឥសយោ វណ្ណយន្តិ
កស្សីធ វុត្តំ ផរុសំ ខមេថ

អក្ខាហិ មេ កោណ្ឌញ្ញ ឯតមត្ថំ ។

បុគ្គលសម្លាប់អ្វី ទើបនឹងមិនសោកក្នុងកាលណាៗ ឥសីទាំងឡាយរមែងសរសើរការលះអ្វី បុគ្គលគប្បីអត់ទ្រាំពាក្យគ្រោតគ្រាតដែលនរណាៗ ក្នុងលោកនេះពោលហើយ បពិត្រលោកកោណ្ឌញ្ញៈ សូមលោកប្រោសប្រាប់សេចក្តីប្រការនេះដល់ញោមចុះ ។

បណ្តាបទទាំងនោះ បទថា យញ្ចាសិ "បញ្ហាដែលជា" ន័យថា ក្នុងបញ្ហានោះ វត្ថុណាជាប្រការដែលទ្រង់ប្រាថ្នាដោយចិត្ត សក្កទេវរាជក៏ត្រាស់សួរវត្ថុនោះ ។ បទថា ឯតំ "ប្រការនោះ" សេចក្តីថា សក្កទេវរាជត្រាស់ថា "លោកប្រោសប្រាប់សេចក្តីដែលខ្ញុំសួរហើយដល់ខ្ញុំចុះ" សក្កទេវរាជត្រាស់សួរបញ្ហា ៣ ប្រការដោយព្រះគាថាតែមួយគាថា ។

តអំពីនោះ ព្រះមហាសត្វកាលនឹងព្យាករណ៍ទើបពោលគាថា

ថា

[៤៨៧] កោធំ វធិត្វា ន កទាចិ សោចតិ
មក្ខប្បហានំ ឥសយោ វណ្ណយន្តិ
សព្វេសំ វុត្តំ ផរុសំ ខមេថ
ឯតំ ខន្តឹ ឧត្តមមាហុ សន្តោ ។

បុគ្គលសម្លាប់សេចក្តីក្រោធបានហើយ ទើបនឹងមិនសោកក្នុងកាលណាៗ ឥសីទាំងឡាយរមែងសរសើរការលះសេចក្តីលុបគុណ បុគ្គលគួរអត់ទ្រាំពាក្យអាក្រក់ដែលជនទាំងឡាយពោល សប្បុរសទាំងឡាយពោលសេចក្តីអត់ធន់នេះថាឧត្តម ។

បណ្តាបទទាំងនោះ បទថា កោធំ វធិត្វា "សម្លាប់សេចក្តីក្រោធ បានហើយ" សេចក្តីថា បុគ្គលសម្លាប់សេចក្តីក្រោធបានហើយ ។ ពិតហើយ កាលមនុស្សយើងសោក រមែងសោកព្រោះចិត្តជាបដិឃៈតែម្យ៉ាង ព្រោះមិនមានសេចក្តីក្រោធ សេចក្តីសោក

នឹងមានអំពីណា ។ ព្រោះហេតុនោះ សរភង្គតាបសទើបពោលថា "នឹងមិនសោកក្នុងកាលណាៗ" ។ បទថា **មក្ខប្បហានំ "ការលះបង់សេចក្តីលុបគុណ"** សេចក្តីថា ឥសីទាំងឡាយសរសើរការលះបង់នូវសេចក្តីលុបគុណ មានការលុបគុណដែលបុគ្គលដទៃធ្វើហើយដល់ខ្លួនជាលក្ខណៈ ពោលគឺ ភាពជាបុគ្គលអកតញ្ញូ ។ បទថា **សព្វេសំ "ជនទាំងពួង"** សេចក្តីថា បុគ្គលគួរអត់ធន់ក្នុងពាក្យអាក្រក់សូម្បីរបស់បុគ្គលគ្រប់ប្រភេទ ទាំងបុគ្គលថ្នាក់ទាប ថ្នាក់កណ្តាល និងថ្នាក់ខ្ពស់ ។ បទថា **សន្តោ "សប្បុរសទាំងឡាយ"** សេចក្តីថា បុរាណកបណ្ឌិតទាំងឡាយពោលទុកយ៉ាងនេះ ។

សក្កទេវរាជត្រាស់សួរជាគាថាថា

[៥៨៨] **សក្កា ឧភិន្នំ វចនំ តិតិក្ខិតុំ**

**សទិសស្ស វា សេដ្ឋតរស្ស វាបិ**

**កថំ នុ ហីនស្ស វចោ ខមេថ**

អក្ខាហិ មេ កោណ្ឌញ្ញ ឯតមត្ថំ ។

បុគ្គលអាចនឹងអត់ធន់ក្នុងពាក្យរបស់ទាំងពីរជំពូកបាន គឺ បុគ្គលដែលស្មើគ្នា ១ បុគ្គលដែលប្រសើរជាងខ្លួន ១ នឹងអត់ធន់ក្នុងពាក្យរបស់បុគ្គលទាបជាងខ្លួនយ៉ាងណាហ្ន៎ បពិត្រកោណ្ឌញ្ញៈ សូមលោកប្រោសប្រាប់នូវសេចក្ដីនេះដល់ញោមចុះ ។

សរភង្គតាបសទូលតបជាគាថាថា

[៥៨៩] កយា ហិ សេដ្ឋស្ស វចោ ខមេថ

សារម្ភហេតុ បន សាទិសស្ស

យោ ចីធ ហីនស្ស វចោ ខមេថ

ឯតំ ខន្តឹ ឧត្តមមាហុ សន្តោ ។

បុគ្គលគប្បីអត់ធន់ក្នុងពាក្យរបស់អ្នកប្រសើរជាងបាន ក៏ព្រោះការខ្លាច គប្បីអត់ធន់ក្នុងពាក្យរបស់បុគ្គលស្មើគ្នាបាន

ព្រោះការប្រណាំងប្រជែងជាហេតុ ចំណែកជនណាក្នុងលោកនេះ គប្បីអត់ធន់ក្នុងពាក្យរបស់អ្នកទាបជាងខ្លួនបាន សប្បុរសទាំងឡាយពោលសេចក្ដីអត់ធន់នោះថា ឧត្តម ។

គាថាពីរគាថា មានសេចក្ដីដូចពោលមកហើយយ៉ាងនេះ គួរជ្រាបថា ទាក់ទងគ្នាដោយការសួរ និងការឆ្លើយ ។

បណ្ដាបទទាំងនោះ បទថា **អក្ខាហិ មេ** "សូមលោកប្រោសប្រាប់... ដល់ញោមចុះ" សេចក្ដីថា សក្កទេវរាជកាលនឹងត្រាស់សួរ ទើបត្រាស់យ៉ាងនេះថា "បពិត្រលោកជាកោណ្ឌញ្ញៈគោត្រដ៏ចម្រើន បញ្ហាពីរប្រការលោកដោះស្រាយល្អហើយ តែនៅមិនទាន់ចូលចិត្តរបស់ខ្ញុំមួយប្រការទៀត គឺ បុគ្គលយើងអាចនឹងអត់ធន់ក្នុងពាក្យរបស់បុគ្គលដែលទាបជាងខ្លួនបានយ៉ាងណា សូមលោកប្រាប់សេចក្ដីនោះដល់ខ្ញុំ" ។ បទថា **ឯតំ ខន្តិំ** "**សេចក្ដីអត់ធន់នោះ**" សេចក្ដីថា ការអត់ធន់ក្នុងពាក្យរបស់ជនដែលទាបជាងដោយជាតិ

និងគោត្រជាដើមណា បុរាណកបណ្ឌិតទាំងឡាយ ពោលការអត់ធន់នោះថា ឧត្តម ។ ចំណែកការអត់ធន់ក្នុងពាក្យរបស់អ្នកខ្ពស់ជាងដោយជាតិជាដើម ព្រោះខ្លាច ការអត់ធន់ក្នុងពាក្យរបស់អ្នកស្មើគ្នា ព្រោះឃើញទោសក្នុងការប្រណាំងប្រជែង ដែលមានការធ្វើឲ្យក្រែលែងជាងជាលក្ខណៈនេះ មិនឈ្មោះថា អធិវាសខន្តិទេ ។

កាលព្រះមហាសត្វពោលយ៉ាងនេះហើយ សក្កទេវរាជទើបត្រាស់នឹងព្រះមហាសត្វថា "បពិត្រឥសីដ៏ចម្រើន ជាដំបូងលោកពោលថា បុគ្គលយើងគួរអត់ធន់ក្នុងពាក្យអាក្រក់របស់បុគ្គលគ្រប់ជំពូក បុរាណកបណ្ឌិតពោលសេចក្ដីអត់ធន់នោះថា ឧត្តម តែក៏ត្រឡប់ជាពោលថា បុគ្គលណាក្នុងលោកនេះ អត់ធន់ក្នុងពាក្យជនដែលទាបជាងបាន លោកពោលសេចក្ដីអត់ធន់របស់បុគ្គលនោះថាឧត្តម ពាក្យរបស់លោកដែលពោលខាងក្រោយ មិនសមគ្នាជាមួយពាក្យដែលពោលក្នុងគ្រាដំបូង" ។ លំដាប់នោះ ព្រះមហាសត្វទើប

ពោលនឹងសក្កទេវរាជថា "បពិត្រសក្កៈ ពាក្យក្រោយអាត្មាពោល ដោយអំណាចនៃបុគ្គលអ្នកដឹងថា "អ្នកនេះជាជនថោកទាប" ហើយ អត់ធន់ក្នុងពាក្យរបស់គេបាន ក៏ព្រោះសត្វទាំងឡាយជាអ្នកប្រសើរ ជាដើម នរណាៗ មិនអាចនឹងដឹងបានត្រឹមតែឃើញរូបរាង ដូច្នោះ ទើបពោលពាក្យជំបូង" កាលនឹងប្រកាសសេចក្តីដែលសត្វទាំងឡាយ ជាអ្នកប្រសើរជាដើម ជាការដឹងបានលំបាក ដោយអាការត្រឹមតែ ឃើញរូបរាង វៀរតែការនៅរួមគ្នារបស់សត្វទាំងឡាយ ទើបពោល គាថាថា

[៥៩០] កថំ វិជញ្ញា ចតុមដ្ឋរូបំ
សេដ្ឋំ សរិក្ខំ អថវាបិ ហីនំ
វិរូបរូបេន ចរន្តិ សន្តោ
តស្មា ហិ សព្វេស វចោ ខមេថ ។

ដូចម្តេចទើបនឹងស្គាល់បុគ្គលប្រសើរជាង បុគ្គលដែលស្មើ

គ្នា ឬបុគ្គលដែលថោកទាបជាង ដែលមានសភាពនៃឥរិយា-
បថ ៤ បិទបាំង ព្រោះថា សប្បុរសទាំងឡាយរមែងត្រាច់
ទៅដោយសភាវៈដែលគួរខ្ពើម ព្រោះហេតុនោះឯង ទើបគួរ
អត់ធន់ក្នុងពាក្យរបស់ជនទាំងពួង ។

បណ្តាបទទាំងនោះ បទថា **ចតុមដ្ឋរូបំ** "ដែលមានសភាព
នៃឥរិយាបថ ៤ បិទបាំង" បានដល់ មានសភាពដែលបិទបាំងទុក
ដោយឥរិយាបថ ៤ ។ បទថា **វិរូបរូបេន** "ដោយសភាវៈដែល
គួរខ្ពើម" សេចក្តីថា សប្បុរសទាំងឡាយអ្នកមានគុណដ៏ខ្ពង់ខ្ពស់
រមែងត្រាច់ទៅដោយរូបដែលគួរខ្ពើម គឺ លាមកបាន ។ ក៏ក្នុង
សេចក្តីនេះគួរសម្តែងរឿងរបស់ព្រះមជ្ឈន្តិកថេរៈ ។

សក្កទេវរាជទ្រង់ស្តាប់ដូច្នោះហើយ ក៏អស់សេចក្តីសង្ស័យ
អារាធនាថា "បពិត្រឥសីដ៏ចម្រើន សូមលោកសម្តែងអានិសង្ស
នៃសេចក្តីអត់ធន់នេះដល់ពួកខ្ញុំចុះ" ។ លំដាប់នោះ ព្រះមហាសត្វ

ទើបពោលគាថាដល់សក្កទេវរាជថា

[៥៩១] ន ហេតមត្ថំ មហតីបិ សេនា
សរាជិកា យុជ្ឈមានា លភេថ
យំ ខន្តិមា សប្បុរិសោ លភេថ
ខន្តិពលស្សូបសមន្តិ វេរា ។

សប្បុរសអ្នកមានសេចក្តីអត់ធន់ គប្បីបានផល គឺ ការមិនខ្វាំងខ្ញប់ ទាំងព្រោះការស្ងប់រម្ងាប់នូវពៀរ សេនាសូម្បីច្រើនព្រមទាំងព្រះរាជា កាលច្បាំងហើយ នឹងគប្បីបានផលនោះក៏មិនមែន ពៀរទាំងឡាយរមែងរម្ងាប់ដោយកម្លាំងខន្តិ ។

បណ្តាបទទាំងនោះ បទថា ឯតមត្ថំ[១] "ផលនោះ" បានដល់ផល ពោលគឺ ការមិនខ្វាំងខ្ញប់ ទាំងព្រោះញ៉ាំងពៀរឲ្យស្ងប់ ។

កាលព្រះមហាសត្វពោលដល់គុណនៃខន្តិដូច្នេះហើយ ព្រះ

---

បិដក. ១. ន ហេតមត្ថំ ។

រាជាទាំងនោះត្រិះរិះថា "សក្កទេវរាជត្រាស់សួរតែបញ្ហារបស់ខ្លួន នឹងមិនឲ្យឱកាសសួរដល់ពួកយើង" ។ លំដាប់នោះ សក្កទេវរាជ ទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះរាជាទាំងនោះ ទើបវៀរបញ្ហាដែលព្រះអង្គត្រៀមមក ៤ ប្រការចេញ កាលនឹងត្រាស់សួរការសង្ស័យរបស់ព្រះរាជាទាំងនោះ ទើបត្រាស់គាថាថា

[៥៩២] សុភាសិតន្តេ អនុមោទិយាន
អញ្ញន្តំ បុច្ឆាមិ តទិង្ឃ ព្រូហិ
យថា អហូ ទណ្ឌកី នាលិកីរោ
អថជ្ជុនោ កលាពុ ចាបិ រាជា
តេសំ គតឹ ព្រូហិ សុបាបកម្មិនំ
កត្ថូបបន្នា ឥសីនំ វិហេឋកា ។

ខ្ញុំសូមអនុមោទនាពាក្យជាសុភាសិតរបស់លោក តែនឹងសូមសួរបញ្ហាដទៃៗ នឹងលោក សូមលោកពោលដោះស្រាយ

បញ្ហានោះ ដោយមានព្រះរាជា ៤ ព្រះអង្គ គឺ ព្រះទណ្ឌកី ១ ព្រះបាទនាលិកីរៈ ១ ព្រះបាទអជ្ជុនៈ ១ ព្រះបាទកលាពុ ១ សូមលោកមេត្តាប្រាប់នូវគតិរបស់ព្រះរាជាទាំងនោះ អ្នកមានបាបកម្មដ៏ធ្ងន់ ព្រះរាជាទាំង ៤ អង្គនោះ បៀតបៀនឥសីទាំងឡាយ នាំគ្នាកើតក្នុងទីណា ។

បណ្តាបទទាំងនោះ បទថា **អនុមោទយិមានា**[១] "សូមអនុមោទនា" សេចក្តីថា ខ្ញុំអនុមោទនាពាក្យជាសុភាសិតនេះរបស់លោកពោលគឺ ការវិសជ្ជនាបញ្ហា ៣ ប្រការដែលខ្ញុំសួរហើយ ។ បទថា **យថា អហូ** "ដោយមាន... " សេចក្តីថា ព្រះរាជាទាំង ៤ បានមានហើយ (ដោយប្រការណា) ។ បទថា **កលាពុ ច**[២] "ព្រះបាទកលាពុ ១" បានដល់ ព្រះបាទកលាពុ ១ ។ បទថា **អជជ្ជុនោ** "ព្រះបាទអជ្ជុនៈ" បានដល់ ព្រះបាទអជ្ជុនៈ ១ ។

---

បិដក. ១. អនុមោទិយាន ។ ២. កលាពុវីចី ។

លំដាប់នោះ ព្រះមហាសត្វកាលនឹងវិសជ្ជនាបញ្ហារបស់សក្កទេវរាជ បានពោល ៥ គាថាថា

[៥៩៣] កីសំ ហិ វច្ឆំ អវកិរិយ ទណ្ឌកី
ឧច្ឆិន្នមូលោ សជនោ សរដ្ឋោ
កុក្កុលនាមេ និរយម្ហិ បច្ចតិ
តស្ស ផុលិង្គានិ បតន្តិ កាយេ ។

ក៏ព្រះបាទទណ្ឌកីបានធ្វើនូវកំហុសក្នុងកីសវច្ឆតាបសហើយ ជាអ្នកដាច់នូវឫសគល់ ព្រមទាំងអាណាប្រជារាស្ត្រ ទាំងរដ្ឋមណ្ឌល ទៅឆេះនៅក្នុងនរកឈ្មោះកុក្កុលៈ ជាផ្កាភ្លើងដែលប្រាសចាកអណ្តាតធ្លាក់ត្រូវកាយព្រះរាជានោះ ។

យោ សញ្ញតេ បព្វជិតេ អហេឋយិ
ធម្មំ ភណន្តេ សមណេ អទូសកេ
តំ នាលិកីរំ សុនខា បរត្ថ

សង្គម្ម ខាទន្តិ វិផន្ទមានំ ។

ព្រះបាទនាលិកីរៈអង្គណា បានបៀតបៀនបព្វជិតទាំងឡាយ អ្នកសង្រួមហើយ អ្នកពោលធម៌ អ្នកស្ងប់រម្ងាប់ មិនប្រទូស នឹងនរណា សុនខទាំងឡាយក្នុងលោកខាងមុខមកចោមខាំស៊ី ព្រះបាទនាលិកីរៈនោះដែលអន្ទះអន្ទែងហើយ ។

អថជ្ជុនោ និរយេ សត្តិសូលេ

អវំសិរោ បតិតោ ឧទ្ធបាទោ

អង្គីរសំ គោតមំ ហេឋយិត្វា

ខន្តឹ តបស្សឹ ចិរព្រហ្មចារឹ ។

មួយទៀត ព្រះបាទអជ្ជុនៈជាអ្នកមានព្រះសីសៈដាំចុះក្រោម មានព្រះបាទឡើងខាងលើ ធ្លាក់ចុះក្នុងសត្តិសូលនរក ព្រោះ បៀតបៀនអង្គីរសឥសីជាគោតម អ្នកមានសេចក្តីអត់ធន់ មាន តបៈ ប្រព្រឹត្តព្រហ្មចរិយៈអស់កាលយូរ ។

យោ ខណ្ឌសោ បព្វជិតំ អឆេទយិ
ខន្តឹ វទន្តំ សមណំ អទូសកំ
កលាពុវីចឹ ឧបបជ្ជ បច្ចតិ
មហាបតាបំ កដុកំ ភយានកំ ។

ព្រះរាជាទ្រង់ព្រះនាមថា កលាពុអង្គណា បានកាត់នូវព្រះឥសីឈ្មោះខន្តិវាទី អ្នកស្ងប់រម្ងាប់ មិនប្រទូសរ៉ាយ ធ្វើឲ្យជាកំណាត់ៗ ព្រះរាជាព្រះនាមថាកលាពុអង្គនោះ បានទៅកើតឆេះក្នុងអវិចីនរកដែលជាទីក្តៅខ្លាំង មានវេទនាក្រហល់ក្រហាយគួរខ្លាច ។

ឯតានិ សុត្វា និរយានិ បណ្ឌិតោ
អញ្ញានិ បាបិដ្ឋតរានិ ចេត្ថ
ធម្មញ្ចរេ សមណព្រាហ្មណេសុ
ឯវង្ករោ សគ្គមុបេតិ ឋានំ ។

បុគ្គលណាបានស្តាប់រឿង (នរក) ទាំងនេះ និងនរកដទៃ ដែលអាក្រក់ជាងនេះក្នុងទីនេះហើយ ជាអ្នកឈ្លាស គួរប្រព្រឹត្តធម៌ ក្នុងសមណព្រាហ្មណ៍ទាំងឡាយ អ្នកធ្វើយ៉ាងនេះរមែងចូលដល់ដែនសួគ៌ ។

បណ្តាបទទាំងនោះ បទថា **កីសំ “តាបសឈ្មោះកីសៈ”** គឺសរីសៈរបស់តាបសឈ្មោះ កីសៈ ព្រោះជាអ្នកមានសាច់ និងឈាមតិច ។ បទថា **អវក្រីយ “បានធ្វើកំហុស”** សេចក្តីថា ព្រះបាទទណ្ឌកីធ្វើខុស គឺ ធ្វើកំហុសក្នុងសរីរៈរបស់កីសតាបសដោយការស្តោះទឹកមាត់ និងបោះឈើស្ទន់ទៅលើ ។ បទថា **ឧច្ឆិន្នមូលោ “ជាអ្នកដាច់នូវឫសគល់”** បានដល់ ជាក្សត្រផ្តាច់បង់ឫសគល់ ។ បទថា **សជនោ “ព្រមទាំងអាណាប្រជារាស្ត្រ”** បានដល់ ព្រមដោយបរិស័ទ ។ បទថា **កុក្កុលនាមេ**[១] **និរយម្ហិ “ក្នុងនរកឈ្មោះកុក្កុលៈ”**

---

បិដក. ១. កុក្កូលនាមេ ។

សេចក្តីថា ឆេះហើយក្នុងនរកផេះក្តៅ ដែលតាំងនៅក្នុងទីប្រមាណ ៣០០ យោជន៍រហូតអស់នៃកប្ប ។

បទថា ផុល្លិង្គា "ភ្នក់ភ្លើងដែលប្រាសចាកអណ្តាត" បានដល់ ភ្នក់ភ្លើងដែលប្រាសចាកអណ្តាត បានឮថា កាលព្រះបាទទណ្ឌកី លិចចុះក្នុងកុក្កុលនរកដ៏ក្តៅនោះ ផេះក្តៅរមែងចូលទៅតាមទ្វារទាំង ៩ ផេះភ្លើងដុំធំៗ ធ្លាក់ចុះលើសីសៈ ក្នុងកាលផេះភ្លើងធ្លាក់ចុះលើ សីសៈរបស់ព្រះរាជានោះ សរីរៈទាំងអស់ក៏ឆេះឡើងដូចដើមឈើ ឆេះភ្លើងដូច្នោះ ទុក្ខវេទនាដ៏មានកម្លាំងរមែងប្រព្រឹត្តទៅ ព្រះរាជា នោះកាលមិនអាចនឹងអត់ទ្រាំបានក៏ស្រែកទ្រហោឡើង ។ សរភង្គ-តាបសជាសាស្តាបើកផែនដីចេញ សម្តែងឲ្យឃើញព្រះរាជាដែល កំពុងឆេះនៅក្នុងកុក្កុលនរកនោះ មហាជនក៏ដល់នូវសេចក្តីតក់ស្លុត ភ័យខ្លាច ។ ទើបបណ្តាលឲ្យនរកនោះអន្តរធានទៅ ។

បទថា ធម្មំ ភណន្តេ "អ្នកពោលធម៌" សេចក្តីថា អ្នកពោល

ធម៌ គឺ កុសលកម្មបថ ១០ ។ បទថា **សមណោ** “**អ្នកស្ងប់រម្ងាប់**” បានដល់ លោកអ្នកបណ្តេតបាបហើយ ។ បទថា **អទូសកេ** “**មិនប្រទូសនឹងនរណា**” បានដល់ អ្នកគ្មានកំហុស ។ បទថា **នាលិកីរំ** “**ព្រះបាទនាលិកីរៈ**” បានដល់ ព្រះរាជាដែលមានព្រះនាមដូច្នេះ ។ បទថា **បរត្ថ** “**ក្នុងលោកខាងមុខ**” សេចក្តីថា អ្នកកើតហើយក្នុងបរលោក គឺ នរក ។ បទថា **សង្គម្ម** “**មក**” សេចក្តីថា សុនខទាំងឡាយធំៗ មកអំពីផ្លូវនោះផ្លូវនេះ ប្រជុំគ្នាខាំស៊ីព្រះបាទនាលិកីរៈនោះ ។

បានឮថា កាលព្រះរាជានាលិកីររាជសោយរាជ្យសម្បត្តិក្នុងទន្តបុរនគរ ក្នុងកាលិង្គរដ្ឋនោះ មហាតាបសមួយអង្គហែហមដោយតាបស ៥០០ នាក់មកអំពីព្រៃហិមពាន្ត បានមកស្នាក់នៅក្នុងព្រះរាជឧទ្យាន សម្តែងធម៌ដល់មហាជន ។ ពួកអាមាត្យក្រាបទូលព្រះរាជាថា “តាបសអ្នកមានធម៌នៅក្នុងព្រះរាជឧទ្យាន” ឯព្រះរាជាជា

ជាអ្នកមិនតាំងនៅក្នុងធម៌ គ្រងរាជ្យដោយអធម៌ ។ កាលអាមាត្យទាំងឡាយនាំគ្នាសរសើរតាបស ស្តេចទ្រង់ទើបត្រិះរិះថា “សូម្បីយើងក៏នឹងស្តាប់ធម៌” ហើយស្តេចទៅកាន់ព្រះរាជឧទ្យាន ទ្រង់សំពះតាបសហើយប្រថាប់អង្គុយ ។ តាបសកាលធ្វើបដិសណ្ឋារៈជាមួយព្រះរាជា ទើបក្រាបទូលថា “សូមថ្វាយព្រះពរមហាបពិត្រ ព្រះអង្គទ្រង់គ្រងរាជ្យដោយធម៌ឬ ទ្រង់មិនបៀនបៀនមហាជនទេឬ?” ព្រះរាជាទ្រង់ក្រោធនឹងពាក្យរបស់តាបស ទ្រង់ត្រិះរិះថា “អស់កាលមានប្រមាណប៉ុណ្ណេះ ប្រហែលជដិលកោងនេះនឹងពោលទោសរបស់យើងប៉ុណ្ណោះក្នុងសម្នាក់ពួកអ្នកនគរ ណ្ហើយចុះ យើងនឹងធ្វើឲ្យសមគួរ” ហើយត្រាស់និមន្តថា “ស្អែកនេះ និមន្តពួកលោកទៅកាន់ទ្វាររាំងរបស់ខ្ញុំ” ។ ក្នុងថ្ងៃស្អែកឡើង ទើបត្រាស់ឲ្យយកលាមកចាស់ៗ ដាក់ក្នុងពាងរហូតពេញ កាលពួកតាបសមកហើយ ត្រាស់ឲ្យយកលាមកដាក់ជាភិក្ខាក្នុងភាជនៈរបស់តាបសទាំងនោះ រហូត

ពេញ ឲ្យបិទទ្វារវាំង ហើយត្រាស់ឲ្យមនុស្សក្រាន់អង្រែ និងដំបង ដែកវាយសីសៈរបស់ឥសីទាំងឡាយ ឲ្យចាប់ផ្ទួងសក់អូសមកឲ្យ សុនខខាំស៊ី ទើបចូលទៅកាន់ផែនដីដែលបើកចន្លោះក្នុងទីនោះ ទៅ កើតក្នុងសុនខមហានរកមួយរំពេច ។ សរីរៈព្រះរាជាក្នុងនរកនោះ មានទំហំ ៣ គាវុត ។ លំដាប់នោះ សុនខទាំងឡាយធំៗ ប៉ុនដំរី ដែលធំ មានពណ៌ ៥ ប្រការ ដេញតាមខាំព្រះរាជានោះ សង្កត់ ឲ្យដួលចុះត្រង់ផែនដីដែកដែលឆេះភ្លើងប្រវែង ៩ យោជន៍ ហើយ ត្របាក់យកៗ របូតពេញមាត់ ខាំស៊ីព្រះរាជាដែលកំពុងរើបម្រះ ។ ព្រះមហាសត្វបើកផែនដីចេញជាពីរភាគ ហើយសម្តែងឲ្យបានឃើញ នរកនោះ ដឹងថា មហាជនភ័យខ្លាចហើយ ទើបបណ្តាលឲ្យអន្តរធាន ទៅ ។

បទថា **អថជ្ជុនោ** “មួយទៀត ព្រះបាទអជ្ជុនៈ” បានដល់ ព្រះរាជាទ្រង់ព្រះនាមថា សហស្សពាហុ ។ បទថា **អង្គីរសំ** “ឥសី

ឈ្មោះអង្គីរស” បានដល់ អង្គីរសតាបស ដែលមានឈ្មោះយ៉ាងនេះ ព្រោះមានរស្មីចេញចាកអវយវៈទាំងឡាយ ។ បទថា ហេឋយិត្វា “ព្រោះបៀតបៀន” សេចក្តីថា ព្រះរាជាអជ្ជុនៈបៀតបៀនអង្គីរសតាបស គឺ យកកៅទណ្ឌដែលលាបដោយថ្នាំពិសបាញ់ឲ្យដល់នូវសេចក្តីស្លាប់ ។ បានឮថា ព្រះបាទអជ្ជុនៈនោះ កាលសោយរាជ្យក្នុងកេកករាជធានី ខេតមហិសករដ្ឋ ស្តេចទៅបរបាញ់ម្រឹគ គ្រាសម្លាប់ម្រឹគបានហើយ ក៏ប្រាថ្នាសោយសាច់ឆ្អិន ។ ថ្ងៃមួយ ព្រះអង្គធ្វើអន្ទាក់ដាក់ក្នុងទីដែលម្រឹគមក ប្រថាប់ឈរមើលម្រឹគទាំងឡាយ ។ គ្រានោះ អង្គីរសតាបសឡើងទៅលើដើមឈើមួយដើមនៅត្រង់ទីជិតព្រះរាជា កំពុងបេះផ្លែឈើ ក៏លែងមែកដែលបេះផ្លែហើយចុះមក ព្រោះសំឡេងមែកឈើដែលលោកទម្លាក់ ហ្វូងម្រឹគដែលមកកាន់ទីនោះ ក៏ផ្អើលរត់ទៅ ។ ព្រះរាជាទ្រង់ក្រោធ យកកូនសរដែលមានថ្នាំពិសបាញ់តាបស តាបសក៏ធ្លាក់ចុះមក សីសៈបែកដល់

លលាដ៏ បានធ្វើកាលកិរិយាដោយកូនសរដែលមានចុងដ៏មុតនោះឯង ។ រំពេចនោះ ព្រះរាជាក៏ធ្លាក់ចូលទៅក្នុងផែនដីដែលបើកនូវចន្លោះជាពីរ កើតក្នុងសត្តិសូលនរក ។ សរីរៈមានប្រមាណ ៣ គាវុត ។ នាយនិរយបាលក្នុងនរកនោះ វាយដោយអាវុធដែលឆេះដោយភ្លើង បន្ទាប់ឲ្យឡើងភ្នំដែកដែលឆេះដោយភ្លើង ។ ក្នុងវេលាដែលព្រះរាជានោះស្ថិតនៅលើកំពូលបព៌ត ខ្យល់ក៏ប្រហារ ។ ព្រះរាជាក៏ធ្លាក់ចុះមកព្រោះខ្យល់ ។ ខណៈនោះលំពែងដែកដែលឆេះភ្លើង ប៉ុនៗ ដើមត្នោតផុសឡើងអំពីខាងក្រោម ផែនដីដែកដែលឆេះដោយភ្លើងប្រមាណ ៩ យោជន៍ ។ ព្រះរាជានោះយកសីសៈបុកនឹងចុងលំពែងនោះឯង ហើយត្រូវដោតទុក ។ ក្នុងខណៈនោះផែនដីក៏ឆេះជាភ្លើងឡើង សរីរៈរបស់ព្រះរាជានោះក៏ឆេះទៅដែរ ព្រះរាជាស្រែករើបម្រះត្រូវភ្លើងឆេះនៅក្នុងនរកនោះ ។ ព្រះមហាសត្វបណ្តាលឲ្យផែនដីញែកចេញជាពីរភាគ ហើយបង្ហាញឲ្យឃើញនរក

នោះ ដឹងថា មហាជនតក់ស្លុតហើយ ទើបបណ្តាលឲ្យអន្តរធានវិញ ទៅ ។

បទថា **ខណ្ឌសោ** “**ធ្វើឲ្យជាកំណាត់ៗ**” សេចក្តីថា ព្រះបាទកលាពុ បានឲ្យកាត់ដៃកាត់ជើងទាំង ៤ ត្រចៀក និងច្រមុះរបស់ខន្តិវាទីតាបស ធ្វើឲ្យទៅជាកំណាត់តូចធំ ។ បទថា **អទូសកំ** “**មិនប្រទូស្ត**” បានដល់ អ្នករកកំហុសមិនបាន ។ ព្រះបាទកលាពុគ្រាឲ្យកាត់យ៉ាងនេះហើយ ត្រាស់ឲ្យវាយដោយផ្តៅដែលវេញសម្រាប់ប្រហារ ១.០០០ ដង ឲ្យចាប់ជដាតាបសទាញមកឲ្យក្រាបហើយយកជើងជាន់ត្រង់ខ្នង ធ្វើឲ្យដល់នូវទុក្ខវេទនាដ៏ធំ ។ បទថា **កលាពុវីចី** “**ព្រះរាជាទ្រង់ព្រះនាមថាកលាពុ... អវិចីនរក**” សេចក្តីថា ព្រះបាទកលាពុនោះក៏ចូលដល់អវិចីនរក ។ បទថា **កដុកំ** “**មានវេទនាដ៏ក្តៅ**” សេចក្តីថា ចូលដល់នរកដែលមានវេទនាក៏ខ្លាំងបែបនេះ ត្រូវភ្លើងឆេះហើយក្នុងចន្លោះនៃអណ្តាតភ្លើងទាំង ៦ ។

ម្យ៉ាងទៀត រឿងរបស់ព្រះបាទកលាពុដោយពិស្តារ ខ្ញុំបានពោលហើយក្នុងខន្តិវាទីតាបសជាតកនោះឯង ។

បទថា **អញ្ញានិ បាបិដ្ឋតរានិ** "ពួកដទៃដែលអាក្រក់ជាងនេះក្នុងទីនេះ" សេចក្តីថា កុលបុត្តអ្នកជាបណ្ឌិតស្តាប់រឿង (នរកទាំងនោះ) និងនរកដទៃដែលអាក្រក់ជាងនរកទាំងនេះ ។ បទថា **ធម្មំ ចរេ** "ប្រព្រឹត្តធម៌" សេចក្តីថា ស្តេចសក្កទេវរាជ កុលបុត្តដែលជាបណ្ឌិតដឹងច្បាស់ថា "នរកទាំង ៤ នេះ និងព្រះរាជាទាំង ៤ អង្គនេះ កើតក្នុងនរកទាំងអស់ប៉ុណ្ណេះក៏មិនមែន ដែលពិតសូម្បីនរកដទៃ និងព្រះរាជាសូម្បីដទៃ ក៏កើតហើយក្នុងនរកដូចគ្នា" ដូច្នេះគប្បីប្រព្រឹត្តធម៌ក្នុងសមណព្រាហ្មណ៍ គឺ ថ្វាយចតុប្បច្ច័យ ចាត់-ចែងការរក្សាដោយត្រូវធម៌ ។

កាលព្រះមហាសត្វសម្តែងស្ថានទីកើតរបស់ព្រះរាជាទាំង ៤ យ៉ាងនេះហើយ ព្រះរាជាទាំង ៣ អង្គ ក៏អស់សេចក្តីសង្ស័យ ។

តអំពីនោះ សក្កទេវរាជកាលនឹងត្រាស់សួរបញ្ហាដ៏សេស ៤ ប្រការ ទៀត ទើបត្រាស់គាថាថា

៥៩៤] សុភាសិតន្តេ អនុមោទិយាន

អញ្ញន្តំ បុច្ឆាមិ តទិង្ឃ ព្រូហិ

ខ្ញុំសូមអនុមោទនានូវពាក្យជាសុភាសិតរបស់លោក សូមសួរបញ្ហាប្រការដទៃនឹងលោក សូមអញ្ជើញលោកចូរពោលដោះស្រាយបញ្ហានោះផង ។

កថំវិធំ សីលវន្តំ វទន្តិ

កថំវិធំ បញ្ញវន្តំ វទន្តិ

កថំវិធំ សប្បុរិសំ វទន្តិ

កថំវិធំ នោ សិរី នោ ជហាតិ ។

បណ្ឌិតហៅបុគ្គលដូចម្ដេចថាជាអ្នកមានសីល ហៅបុគ្គលដូចម្ដេចថាជាអ្នកមានបញ្ញា ហៅបុគ្គលដូចម្ដេចថាជាសប្បុរស

សិរីមិនលះបុគ្គលដូចម្តេចហ្ន៎ ។

បណ្តាបទទាំងនោះ បទថា កថំវិធំ នោ សិរិ នោ ជហាតិ "សិរីមិនលះបុគ្គលដូចម្តេចហ្ន៎" សេចក្តីថា សិរីដែលបុគ្គលបានហើយ រមែងមិនលះបុគ្គលដូចម្តេច ។ លំដាប់នោះ ព្រះមហាសត្វកាលនឹងវិសជ្ជនាបញ្ហារបស់សក្កទេវរាជ បានពោល ៤ គាថាថា

[៥៩៥] កាយេន វាចាយ ច យោធ សញ្ញតោ
មនសា ច កិញ្ចិ ន ករោតិ បាបំ
ន អត្តហេតុ អលិកំ ភណាតិ
តថាវិធំ សីលវន្តំ វទន្តិ ។

បុគ្គលណាក្នុងលោកនេះ ជាអ្នកសង្រួមដោយកាយ វាចា និងចិត្ត មិនធ្វើបាបកម្មអ្វីៗ មិននិយាយឡេះឡោះ ព្រោះហេតុនៃខ្លួន បណ្ឌិតហៅបុគ្គលដូច្នោះថា ជាអ្នកមានសីល ។

គម្ភីរបញ្ញំ មនសាភិចិន្តយំ

នច្ចាហិតំ កម្មករោតិ លុទ្ទំ
កាលាគតំ អត្ថបទំ ន រិញ្ចតិ
តថាវិធំ បញ្ញវន្តំ វទន្តិ ។

បុគ្គលណាគិតបញ្ហាដែលជ្រាលជ្រៅបានដោយចិត្ត មិនធ្វើកម្មអាក្រក់ដែលរកប្រយោជន៍មិនបាន មិនបិទផ្លូវនៃប្រយោជន៍ដែលមកដល់តាមកាល បណ្ឌិតហៅបុគ្គលដូច្នោះថាមានបញ្ញា ។

យោ វេ កតញ្ញូ កតវេទី ធីរោ
កល្យាណមិត្តោ ទឡ្ហភត្តិ ច ហោតិ
ទុក្ខិតស្ស សក្កច្ច ករោតិ កិច្ចំ
តថាវិធំ សប្បុរិសំ វទន្តិ ។

បុគ្គលណាជាអ្នកមានកតញ្ញូកតវេទី មានបញ្ញា មានទូវកល្យាណមិត្ត និងមានភក្តីភាពមុតមាំ ជួយធ្វើកិច្ចរបស់មិត្ត

អ្នកក្រលំបាកដោយពេញចិត្ត បណ្ឌិតហៅបុគ្គលដូច្នោះថាជាសប្បុរស ។

ឯតេហិ សព្វេហិ គុណេហុបេតោ

សទ្ធោ មុទូ សំវិភាគី វទញ្ញូ

សង្គាហកំ សខិលំ សណ្ហវាចំ

តថាវិធំ នោ សិរិ នោ ជហាតិ ។

បុគ្គលណាប្រកបដោយគុណសម្បត្តិទាំងពួងនេះ គឺ ជាអ្នកមានសទ្ធា ទន់ភ្លន់ ចែកទានដោយល្អ ដឹងសេចក្ដីបំណងសិរីមិនលះបុគ្គលដូច្នោះជាអ្នកសង្គ្រោះ មានវាចាពីរោះផ្អែមល្ហែម ។

បណ្ដាបទទាំងនោះ បទថា កាយេន "ដោយកាយ" ជាដើមលោកពោលទុកដោយអំណាចនៃសុចរិតតាមត្រៃទ្វារ ។ បទថា ន អត្តហេតុ "មិន... ព្រោះហេតុនៃខ្លួន" នេះ ជាមាតិកានៃទេសនានោះ

ប៉ុណ្ណោះ ។ អធិប្បាយថា មិននិយាយឡេះឡោះ ព្រោះហេតុនៃខ្លួន ព្រោះហេតុនៃអ្នកដទៃ ព្រោះហេតុនៃទ្រព្យ ព្រោះហេតុនៃយសព្រោះហេតុនៃលាភ ឬព្រោះហេតុនៃអាមិស ។ សូម្បីសេចក្តីនេះនឹងសម្រេចដោយពាក្យនេះថា "សង្រួមដោយវាចា" ដូច្នេះក៏ពិតតែដើម្បីសម្តែងខ្លឹមសារឲ្យធ្ងន់ចុះ គួរជ្រាបថា "លោកពោលយ៉ាងនេះទៀតថា ក៏សេចក្តីអាក្រក់ដែលនឹងឈ្មោះថា បុគ្គលច្រើននិយាយកុហកមិនធ្វើមិនមាន" (បុគ្គលមុសាវាទពេញចិត្តធ្វើបាប) ។

បទថា **គម្ភីរបញ្ហំ "បញ្ហាដែលជ្រាលជ្រៅ"** សេចក្តីថា (ជនណាគិត) បញ្ហាដ៏ជ្រាលជ្រៅកំបាំង ប្របូកប្របល់ទាំងអត្ថ និងបាលីដូចគ្នានឹងបញ្ហាដែលមកក្នុងសត្តុភស្តជាតក សម្ភវជាតក និងឧម្មង្គជាតក ។ បទថា **មនសា វិចិន្តយំ**[១] **"គិត... ដោយចិត្ត"** គឺបុគ្គលណា គិតពិចារណាដោយចិត្ត ចាក់ធ្លុះអត្ថ អាចដើម្បីពោល

---

បិដក. ១. មនសាភិចិន្តយំ ។

ដោះស្រាយ ធ្វើឲ្យប្រាកដដូចញ៉ាំងព្រះចន្ទព្រះអាទិត្យឲ្យតាំងឡើង ១.០០០ ដួង ។ បទថា **នច្ចាហិតំ “ដែលរកប្រយោជន៍មិនបាន”** សេចក្តីថា និងបុគ្គលណាមិនធ្វើកម្មដែលមិនជាប្រយោជន៍ គឺ កន្ទង់នូវប្រយោជន៍ គ្រោតគ្រាត ក្តៅក្រហាយ ធ្ងន់ ។ មួយទៀត ដើម្បីនឹងញ៉ាំងសេចក្តីនេះឲ្យជាក់ច្បាស់ គួរពោលកូរិបញ្ហាថា

បណ្ឌិតទាំងឡាយរមែងមិនសាងបាបកម្ម ព្រោះហេតុនៃសេចក្តីសុខរបស់ខ្លួន សប្បុរសទាំងឡាយសូម្បីទុក្ខពាល់ត្រូវ ធ្លាក់ត្រូវ រមែងមិនលះធម៌ព្រោះសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ ។

បទថា **កាលគតំ “ដែលមកដល់តាមកាល”** សេចក្តីថា ជនណាកាលញ៉ាំងទានជាដើមទាំងនេះឲ្យដល់ព្រម ដោយគិតថា កាលនេះគួរឲ្យទាន គួររក្សាសីល គួរចាំឧបោសថ ជាកាលតាំងនៅក្នុងសរណៈ ជាកាលធ្វើបព្វជ្ជា ជាកាលធ្វើសមណធម៌ ជាភារៈដែល

គួរបំពេញវិបស្សនា ឈ្មោះថា រមែងមិនក្តៅក្រហាយ គឺ មិនញុំាង ផ្លូវនៃប្រយោជន៍ដែលមកដល់ឲ្យវិនាស ។ បទថា **តថាវិធំ** “បុគ្គល ដូច្នោះ” សេចក្តីថា ម្នាលសក្កទេវរាជ ព្រះសព្វញ្ញុពុទ្ធក្តី ព្រះប-ច្ចេកពុទ្ធក្តី ព្រះមហាសត្វក្តី កាលនឹងពោលដល់បុគ្គលអ្នកមានបញ្ញា រមែងពោលដល់បុគ្គលបែបនេះ ។

ក្នុងបទថា **យោ វេ** “បុគ្គលណា” នោះ មានអធិប្បាយថា បុគ្គលណាដឹងគុណដែលបុគ្គលដទៃធ្វើហើយដល់ខ្លួន ឈ្មោះថា ជាអ្នកកតញ្ញូ មួយទៀត លុះដឹងយ៉ាងនេះហើយ ក៏ធ្វើការតបគុណរបស់គេដែលបានធ្វើគុណទុកដល់ខ្លួន ឈ្មោះថា ជាអ្នកកតវេទី ។ បទថា **ទុក្ខិតស្ស** “អ្នកក្រលំបាក” សេចក្តីថា បុគ្គលណាលើកនូវសេចក្តីទុក្ខសម្លាញ់របស់ខ្លួន ដែលដល់នូវសេចក្តីទុក្ខមកខ្លួន ជួយធ្វើកិច្ចដែលកើតឡើងដល់សម្លាញ់នោះ ដោយដៃរបស់ខ្លួនដោយគោរព ព្រះពុទ្ធជាដើមរមែងហៅបុគ្គលនោះបែបនេះថា ជាសប្បុរស

ម្យ៉ាងទៀត ធម្មតាសប្បុរសទាំងឡាយរមែងជាអ្នកមានកតញ្ញូកត-វេទី ព្រោះដូច្នោះ គប្បីពោលដល់ជាតក ដូចជា សត្បុតជាតក ចុ-ល្លហំសជាតក និងមហាហំសជាតកជាដើម ។

បទថា **ឯតេហិ សព្វេហិ “ទាំងពួងនេះ”** សេចក្តីថា ម្នាល សក្កទេវរាជ បុគ្គលណាចូលដល់ដោយគុណសម្បត្តិ មានសីលជាដើម ដូចដែលពោលហើយខាងក្រោយទាំងអស់ ។ បទថា **សទ្ធោ “អ្នកមានសទ្ធា”** សេចក្តីថា ប្រកបដោយឱកប្បនសទ្ធា (សទ្ធា គឺ ការជឿមាំ) ។ បទថា **មុទុ “ទន់ភ្លន់”** បានដល់ ជាអ្នកមានប្រក្រតីនិយាយគួរស្រឡាញ់ ។ បទថា **សំវិភាគី “ចែកទានដោយល្អ”** សេចក្តីថា ឈ្មោះថា ជាអ្នកចែកទានដោយល្អ ព្រោះជាអ្នកត្រេកអរក្រៃលែងក្នុងការចែកចំណែកសីល ចំណែកទាន ។ បទថា **វទញ្ញូ “ដឹងនូវបំណង”** អ្នកដឹងនូវពាក្យ ព្រោះអាចដឹងនូវពាក្យរបស់យាចកហើយទើបឲ្យ ។ បទថា **សង្គាហកំ “អ្នកសង្គ្រោះ”** សេចក្តីថា

ឈ្មោះថា អ្នកសង្គ្រោះ ព្រោះសង្គ្រោះជននោះៗ ដោយសង្គហវត្ថុ ៤ ឈ្មោះថា សខិលំ "មានវាចាពីរោះ" ព្រោះពោលពាក្យពីរោះ ឈ្មោះថា សណ្ហវាចំ "ផ្អែមល្ហែម" ព្រោះមានវាចាហ្មត់ចត់ ។ បទថា តថាវិធំ នោ "មិន... បុគ្គលដូច្នោះ" សេចក្តីថា សិរី ពោល គឺ យស និងលាភដ៏ប្រសើរដែលបានហើយ រមែងមិនលះបុគ្គលដូច្នោះ គឺ សិរីរបស់បុគ្គលនោះរមែងមិនវិនាស ។

ព្រះមហាសត្វវិសជ្ជនាបញ្ហា ៤ ប្រការ ដូចញុាំងព្រះចន្ទដែលពេញវង់ឲ្យតាំងឡើងក្នុងផ្ទៃមេឃដូច្នោះ ដោយប្រការដូច្នេះ បន្ទាប់អំពីនោះទៅ ជាការបុច្ឆា និងវិសជ្ជនាបញ្ហាដ៏សេស សក្កទេវរាជត្រាស់គាថាថា

[៩៩៦] សុភាសិតន្តេ អនុមោទិយាន

អញ្ញន្តំ បុច្ឆាមិ តទិង្ឃ ព្រូហិ

សីលំ សិរិញ្ចាបិ សតញ្ច ធម្មំ

បញ្ញញ្ច កំ សេដ្ឋតរំ វទន្តិ ។

ខ្ញុំសូមអនុមោទនានូវពាក្យជាសុភាសិតរបស់លោក សូមសួរបញ្ហាប្រការដទៃនឹងលោក សូមលោកពោលដោះស្រាយបញ្ហានោះផង អ្នកប្រាជ្ញរមែងពោលសីល សិរី ធម៌របស់សប្បុរស និងបញ្ញា ថាប្រការណាប្រសើរជាងគ្នា ។

ព្រះមហាសត្វទូលថា

[៥៩៧] បញ្ញា ហិ សេដ្ឋា កុសលា វទន្តិ

នក្ខត្តរាជារិវ តារកានំ

សីលំ សិរី ចាបិ សតញ្ច ធម្មោ

អន្វាយិកា បញ្ញវតោ ភវន្តិ ។

ការពិត លោកអ្នកប្រាជ្ញទាំងឡាយរមែងពោលថា បញ្ញានោះឯងប្រសើរបំផុត ដូចព្រះចន្ទប្រសើរជាងដួងតារាទាំងឡាយ ដូច្នោះ សីល សិរី និងធម្មរបស់សប្បុរស រមែងប្រព្រឹត្តទៅ

តាមបុគ្គលអ្នកមានបញ្ញា ។

សក្កទេវរាជត្រាស់សួរថា

[៥៩៨] សុភាសិតន្តេ អនុមោទិយាន
អញ្ញន្តំ បុច្ឆាមិ តទិង្ឃ ព្រូហិ
កថង្ករោ កិន្តិករោ កិមាចរំ
កឹ សេវមានោ លភតីធ បញ្ញំ
បញ្ញាយទានិប្បដិបទំ វទេហិ
កថង្ករោ បញ្ញវា ហោតិ មច្ចោ ។

ខ្ញុំសូមអនុមោទនានូវពាក្យជាសុភាសិតរបស់លោក សូមសួរបញ្ហាប្រការដទៃទៀតលោក សូមលោកពោលដោះស្រាយបញ្ហានោះ បុគ្គលក្នុងលោកនេះ ធ្វើយ៉ាងណា ធ្វើដោយឧបាយយ៉ាងណា ប្រព្រឹត្តអ្វី សេពអ្វី ទើបនឹងបាននូវបញ្ញា សូមលោកមេត្តាប្រាប់បដិបទានៃបញ្ញាក្នុងពេលនេះថា នរជនធ្វើ

យ៉ាងណា ទើបជាអ្នកមានបញ្ញា ។

[៥៩៩] សេវេថ វុទ្ធេ និបុណេ ពហុស្សុតេ
ឧគ្គាហកោ ចប្បរិបុច្ឆកោ សិយា
សុណេយ្យ សក្កច្ច សុភាសិតានិ
ឯវង្ករោ បញ្ញវា ហោតិ មច្ចោ ។

បុគ្គលគួរគប់រកលោកអ្នកប្រាជ្ញទាំងឡាយ ហ្មត់ចត់ ជាពហូសូត គួរជាអ្នករៀនសូត្រ អ្នកសាកសួរ គប្បីតាំងចិត្តស្តាប់ពាក្យសុភាសិតដោយគោរព នរជនធ្វើយ៉ាងនេះ ទើបជាអ្នកមានបញ្ញា ។

ស បញ្ញវា កាមគុណេ អវេក្ខតិ
អនិច្ចតោ ទុក្ខតោ រោគតោ ច
ឯវំ វិបស្សី បជហាតិ ឆន្ទំ
ទុក្ខេសុ កាមេសុ មហព្ភយេសុ ។

បុគ្គលអ្នកមានបញ្ញានោះ រមែងពិចារណាឃើញកាមគុណទាំងឡាយ ដោយភាពជារបស់មិនទៀង ដោយភាពជាទុក្ខ និង ដោយភាពជារោគ បុគ្គលឃើញច្បាស់យ៉ាងនេះ រមែងលះសេចក្តីពេញចិត្តក្នុងកាមទាំងឡាយដែលជាទុក្ខ ដែលជាភ័យធំចេញបាន ។

ស វីតរាគោ ស វិនេយ្យ ទោសំ
មេត្តចិត្តំ ភាវេយ្យ អប្បមាណំ
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អនិន្ទិតោ ព្រហ្មមុបេតិ ឋានំ ។

បុគ្គលនោះប្រាសចាករាគៈហើយ កម្ចាត់ទោសៈបាន គប្បីចម្រើនមេត្តាចិត្តដែលរកប្រមាណមិនបាន វៀរអាជ្ញាក្នុងសត្វគ្រប់ជំពូក មិនត្រូវនិន្ទា រមែងចូលដល់ព្រហ្មស្ថាន ។

បណ្តាបទទាំងនោះ បទថា សីលំ "សីល" បានដល់ អា-

ចារសីល ។ បទថា **សិរិ** “សិរី” បានដល់ ឥស្សរិយយស ។ បទថា **សតញ្ច ធម្មំ** “ធម៌របស់សប្បុរស” បានដល់ សប្បុរិសធម៌ ។ បទថា **បញ្ញំ** “បញ្ញា” សេចក្តីថា ស្តេចទេវរាជត្រាស់សួរថា “លោកអ្នកប្រាជ្ញទាំងឡាយរមែងពោលដល់បណ្តាធម៌ ៤ ប្រការទាំងនេះយ៉ាងនេះថា ណាប្រសើរជាងគ្នា” ។

បទថា **បញ្ញា ហិ** “បញ្ញានោះឯង” សេចក្តីថា ព្រះមហាសត្វទូលថា “ម្នាលសក្កៈ ក្នុងធម៌ ៤ យ៉ាងទាំងនេះ ឈ្មោះថាបញ្ញានេះ បណ្ឌិតទាំងឡាយដូចជាព្រះពុទ្ធជាដើមត្រាស់ថា ប្រសើរបំផុត ដូចដួងតារាហែហមព្រះចន្ទ ព្រះចន្ទនោះឯងឧត្តមជាងដួងតារាទាំងនោះ យ៉ាងណា ធម៌សូម្បីទាំង ៣ នេះ គឺ សីល សិរីនិងធម៌របស់សប្បុរសទាំងឡាយ ក៏យ៉ាងនោះ” ។ បទថា **អន្វាយកា បញ្ញវតោ**[១] “រមែងប្រព្រឹត្តទៅតាមបុគ្គលអ្នកមានបញ្ញា” គឺ

---

បិដក. ១. អន្វាយិកា បញ្ញវតោ ។

រមែងប្រព្រឹត្តទៅតាមបុគ្គលអ្នកមានបញ្ញាប៉ុណ្ណោះ គឺ ជាបរិវារ របស់បញ្ញានោះឯង ។

បទថា **ធ្វើយ៉ាងណា** ជាដើម ជាវេវចនៈនឹងគ្នាប៉ុណ្ណោះ ។ បទថា **កថំករោ "ធ្វើយ៉ាងណា"** សេចក្តីថា សក្កទេវរាជត្រាស់សួរថា "បុគ្គលធ្វើនូវកម្មអ្វី ប្រព្រឹត្តអ្វី សេព គឺ គប់រកនូវកម្មអ្វីហ្ន៎ រមែងបាននូវបញ្ញាក្នុងលោកនេះ សូមលោកប្រោសប្រាប់នូវបដិបទា នៃបញ្ញានោះ ខ្ញុំប្រាថ្នានឹងដឹង សត្វត្រូវស្ទាប់ជាធម្មតា ធ្វើយ៉ាងណា ទើបជាអ្នកឈ្មោះថា មានបញ្ញា" ។

បទថា **វុឡេ**[1] **"អ្នកប្រាជ្ញទាំងឡាយ"** បានដល់ បណ្ឌិត អ្នកដល់នូវសេចក្តីចម្រើនដោយបញ្ញា ។ បទថា **និបុណោ "ល្អិតល្អន់"** សេចក្តីថា អ្នកអាចដឹងហេតុការណ៍ដ៏សុខុម ។ បទថា **ឯវំករោ "ធ្វើយ៉ាងនេះ"** សេចក្តីថា សរភង្គតាបសជាសាស្តាតបថា

---

បិដក. ១. ពុទ្ធេ ។

"បុគ្គលណាអាចគប់រក អន្តុយជិតបុគ្គលអ្នកមានប្រការដូចពោល មកហើយយ៉ាងនេះ រមែងរៀនបាលី សាកសួរអត្ថាធិប្បាយរឿយៗ ផ្ទៀងសោតៈស្តាប់ពាក្យសុភាសិតដោយគោរព ដូចបុគ្គលចារឹកចុះលើផែនថ្ម ឬដូចយកពាងមាសដាក់ខ្លាញ់របស់រាជសីហ៍ដូច្នោះ ជនអ្នកធ្វើយ៉ាងនេះ រមែងជាអ្នកមានបញ្ញា" ព្រះមហាសត្វពោលនូវបដិបទានៃបញ្ញាយ៉ាងនេះ ប្រៀបដូចជាញុំាងព្រះអាទិត្យឲ្យឧទ័យឡើងអំពីបស្ចិមលោកធាតុ កាលនឹងពោលគុណរបស់បញ្ញានោះក្នុងពេលនេះ ទើបពោលពាក្យជាដើមថា "បុគ្គលដែលមានបញ្ញានោះ" ។

បណ្តាបទទាំងនោះ បទថា **កាមគុណេ "កាមគុណទាំងឡាយ"** សេចក្តីថា បុគ្គលអ្នកមានបញ្ញានោះរមែងឃើញ គឺ ពិចារណានូវចំណែកនៃកាមទាំងឡាយថាជារបស់មិនទៀង ព្រោះអត្ថថា មានហើយដូចមិនមាន ថាជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំងក្នុងបច្ចុប្បន្ន

និងក្នុងសម្បរាយិកភព ថាជារោគ ព្រោះមានព្រមដោយរោគ គឺ ទុក្ខ ៩៨ ប្រការអាស្រ័យកាមកើតឡើង ។ បទថា **សោ ឯវំ វិ-បស្សំ** “**នោះ... ឃើញច្បាស់យ៉ាងនេះ**” សេចក្តីថា កាលបុគ្គល សម្លឹងឃើញការមិនទៀងជាដើមរបស់កាមទាំងឡាយ ដោយហេតុ ទាំងនេះ ដឹងច្បាស់ថា “ទីបំផុតនៃទុក្ខដែលអាស្រ័យកាមកើតឡើង មិនមាន ការលះកាមតែម្យ៉ាងប៉ុណ្ណោះជាសុខ” ហើយរមែងលះបង់ បាននូវសេចក្តីពេញចិត្តក្នុងកាមដែលជាទុក្ខ ជាភ័យធំ ។

បទថា **ស វីតរាគោ** “**បុគ្គលនោះប្រាសចាករាគៈហើយ**” សេចក្តីថា ម្នាលសក្កៈ បុគ្គលនោះប្រាសចាករាគៈយ៉ាងនេះ កម្ចាត់ នូវទោសដែលកើតឡើងដោយអំណាចអាឃាតវត្ថុ ៩ ប្រការហើយ គប្បីចម្រើនមេត្តាចិត្ត គ្រាចម្រើនមេត្តាចិត្ត ឈ្មោះថាមិនមានប្រ-មាណ ព្រោះមានសត្វរកប្រមាណមិនបានជាអារម្មណ៍ ជាអ្នកមាន ឈានមិនវិនាស នរណាៗ នឹងតិះដៀលមិនបាន រមែងទៅកើតក្នុង

ព្រហ្មលោក ។

កាលព្រះមហាសត្វពោលទោសរបស់កាមទាំងឡាយ យ៉ាង

នេះហើយ ព្រះរាជាសូម្បីទាំង ៣ ព្រះអង្គព្រមទាំងពលនិកាយ ក៏

លះបង់សេចក្តីត្រេកអរក្នុងបញ្ចកាមគុណបានដោយតទង្គប្បហាន ។

ព្រះមហាសត្វដឹងដូច្នោះហើយ ទើបពោលគាថាដោយអំណាចនៃ

សេចក្តីរីករាយរបស់ជនទាំងនោះថា

[៦០០] មហិទ្ធិយំ[១] អាគមនំ អហោសិ

តវមដ្ឋក ភីមរថស្ស ចាបិ

កាលិង្គរាជស្ស ច ឧគ្គតស្ស

សព្វេស វោ កាមរាគោ បហីនោ ។

ការដែលស្តេចមករបស់មហាបពិត្រ ទ្រង់មានព្រះនាមថា

អដ្ឋកៈ ភីមរថៈ និងកាលិង្គរាជ អ្នកមានតេជានុភាពល្បី-

---

១.ម. មហត្ថិយំ ។

ល្បាញ ជាការមកយ៉ាងមហិទ្ធិឫទ្ធិ គ្រប់ៗ ព្រះអង្គទ្រង់លះ

កាមរាគៈបានហើយ ។

បណ្ដាបទទាំងនោះ បទថា **មហិទ្ធិយំ** “ទ្រង់មានព្រះតេជានុភាពល្បីល្បាញទៅ” សេចក្ដីថា ការមានមហិទ្ធិឫទ្ធិ គឺ ធំទូលាយរុងរឿងធំ ។ បទថា **តវមដ្ឋកា**[១] កាត់បទជា **តវ អដ្ឋកា** ។ បទថា **បហីនោ** “ទ្រង់លះ” សេចក្ដីថា កាមរាគៈដែលគ្រប់ព្រះអង្គទ្រង់លះបានហើយដោយតទង្គប្បហាន ។

ព្រះរាជាទាំងឡាយទ្រង់ស្ដាប់ពាក្យនោះហើយ កាលនឹងទ្រង់សរសើរព្រះមហាសត្វ ទើបនាំគ្នាត្រាស់គាថាថា

[៦០១] ឯវមេតំ បរចិត្តវេទិ

សព្វេស នោ កាមរាគោ បហីនោ

ករោហិ ឱកាសមនុគ្គហាយ

បិដក. ១. តវមដ្ឋក ។

យថា គតិន្តេ អភិសម្ភវេម ។

លោកជាអ្នកដឹងចិត្តអ្នកដទៃ ប្រការនោះក៏ជាការពិតដូច្នោះ ឯង ខ្ញុំគ្រប់គ្នាលះបង់កាមរាគៈបានហើយ សូមលោកចូរឲ្យ ឱកាស ដើម្បីសេចក្តីអនុគ្រោះ តាមដែលខ្ញុំទាំងឡាយនឹងដឹង ដល់គតិរបស់លោកបាន ។

បណ្តាបទទាំងនោះ បទថា អនុគ្គហាយ "ដើម្បីអនុគ្រោះ" សេចក្តីថា ព្រះរាជាទាំងឡាយនាំគ្នាត្រាស់ថា "សូមលោកធ្វើនូវ ឱកាសដើម្បីប្រយោជន៍ដល់ការបព្វជ្ជារបស់ពួកខ្ញុំ ដែលពួកខ្ញុំបួស ហើយនឹងគប្បីត្រាស់ដឹង គឺ លុះសេចក្តីសម្រេចតាមគតិរបស់លោក បានដល់ គប្បីចាក់ធ្លុះបាននូវគុណដែលលោកចាក់ធ្លុះហើយ ។

លំដាប់នោះ ព្រះមហាសត្វកាលនឹងធ្វើឱកាសដល់ព្រះរាជា ទាំងនោះ ទើបពោលគាថាតទៅថា

[៦០២] ករោមិ ឱកាសសមនុគ្គហាយ

*តថា ហិ វោ កាមរាគោ បហីនោ*

*ផរាថ កាយំ វិបុលាយ បីតិយា*

*យថា គតឹ មេ អភិសម្ភវេថ ។*

អាត្មាឲ្យឱកាសដើម្បីសេចក្តីអនុគ្រោះ ព្រោះមហាបពិត្រទាំងឡាយលះកាមរាគៈបានយ៉ាងនោះហើយ ចូរញុំាងកាយឲ្យជ្រួតជ្រាបដោយបីតិដ៏ធំទូលាយ តាមដែលមហាបពិត្រទាំងឡាយនឹងទ្រង់ជ្រាបដល់គតិរបស់អាត្មា ។

បណ្តាបទទាំងនោះ បទថា ផរាថ កាយំ "ចូរញុំាងកាយឲ្យជ្រួតជ្រាប" សេចក្តីថា ញុំាងនូវកាយឲ្យជ្រួតជ្រាបដោយបីតិដែលដែលកើតអំពីឈានដ៏ទូលាយ ។

ព្រះរាជាទាំងនោះទ្រង់ស្តាប់ដូច្នោះ កាលនឹងទ្រង់ទទួល ទើបត្រាស់គាថាថា

[៦០៣] *សព្វំ ករិស្សាម តវានុសាសនឹ*

*យំ យំ តុវំ រក្ខសិ ភូរិបញ្ញ*

*ផរាម កាយំ វិបុលាយ បីតិយា*

*យថា គតិន្តេ អភិសម្ភវេម ។*

បពិត្រលោកអ្នកមានប្រាជ្ញាដូចផែនដី ខ្ញុំទាំងឡាយនឹងធ្វើតាមពាក្យទូន្មានដែលលោកពោលគ្រប់យ៉ាង ខ្ញុំទាំងឡាយនឹងញ៉ាំងកាយឲ្យជ្រួតជ្រាបដោយបីតិដ៏ទូលាយ តាមដែលខ្ញុំទាំងឡាយនឹងដឹងដល់គតិរបស់លោក ។

លំដាប់នោះ ព្រះមហាសត្វទើបឲ្យបញ្ជាដល់ព្រះរាជាទាំងនោះ ព្រមទាំងពលនិកាយ កាលនឹងបញ្ជូនពួកឥសីទៅ ទើបពោលគាថាថា

[៦០៤] *កតាយ វច្ឆស្ស កិសស្ស បូជា*

*គច្ឆន្តុ ភោន្តោ ឥសយោ សាធុរូបា*

*ឈានេ រតា ហោថ សទា សមាហិតា*

ឯសា រតី បព្វជិតស្ស សេដ្ឋា ។

លោកដ៏ចម្រើនទាំងឡាយ ឥសីទាំងឡាយអ្នកមានគុណ សេចក្តីល្អ ធ្វើការបូជានេះដល់កីសវច្ឆតាបសហើយ ចូរនាំគ្នាទៅកាន់ទីនៅរៀងៗ ខ្លួនចុះ លោកទាំងឡាយចូរជាអ្នកត្រេកអរក្នុងឈាន ចូរមានចិត្តតាំងមាំគ្រប់កាលចុះ សេចក្តីត្រេកអរនេះជាគុណជាតិប្រសើរបំផុតរបស់បព្វជិត ។

បណ្តាបទទាំងនោះ បទថា គច្ឆន្តុ "ចូរនាំគ្នាទៅ" សេចក្តីថា ព្រះមហាសត្វពោលថា "លោកទាំងឡាយចូរទៅកាន់ស្ថានទីនៅជាដើមរៀងៗ ខ្លួនចុះ" ។

ឥសីទាំងឡាយទទួលពាក្យរបស់ព្រះមហាសត្វហើយ ក៏បាននមស្ការលា ហោះឡើងទៅក្នុងអាកាស ត្រឡប់ទៅកាន់ទីនៅរៀងៗ ខ្លួន ។ ចំណែកសក្កទេវរាជស្តេចក្រោកឡើងពីអាសនៈ ធ្វើការសរសើរព្រះមហាសត្វ ផ្គងអញ្ជលីនមស្ការព្រះមហាសត្វដូចបង្អោន

ដល់ព្រះអាទិត្យ ព្រមទាំងទេវបរិស័ទស្តេចចេញទៅ ។ ព្រះសាស្តា ទ្រង់ជ្រាបខ្លឹមសារនោះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

[៦០៥] សុត្វាន គាថា បរមត្ថសញ្ហិតា
សុភាសិតា ឥសិនា បណ្ឌិតេន
តេ វេទជាតា អនុមោទមានា
បក្កាមុ ទេវា ទេវបុរំ យសស្សិនោ ។

ជនទាំងនោះបានស្តាប់គាថាដែលប្រកបដោយប្រយោជន៍ដ៏ក្រៃលែង ដែលឥសីជាបណ្ឌិតពោលល្អហើយ កើតបីតិសោមនស្ស នាំគ្នាអនុមោទនាហើយ ទេវតាទាំងឡាយអ្នកមានយស ក៏នាំគ្នាត្រឡប់ទៅកាន់ទេវបុរី ។

គាថា ឥមា អត្ថវតី សុព្យញ្ជនា
សុភាសិតា ឥសិនា បណ្ឌិតេន
យោ កោចិមា អដ្ឋិកត្វា សុណេយ្យ

លភេថ បុញ្ញាបរិយំ វិសេសំ
លទ្ធាន បុញ្ញាបរិយំ វិសេសំ
អទស្សនំ មច្ចុរាជស្ស គច្ឆេ ។

គាថាទាំងនេះមានអត្ថព្យញ្ជនៈល្អ ដែលឥសីជាបណ្ឌិត ពោលល្អហើយ បុគ្គលណាមួយស្តាប់គាថាទាំងនេះ ឲ្យមានប្រយោជន៍ គប្បីបានគុណវិសេសទាំងខាងដើម និងខាងចុង គ្រាបានគុណវិសេសទាំងខាងដើម និងខាងចុងហើយ គប្បីសម្រេចដល់ស្ថានទីដែលមច្ចុរាជមើលមិនឃើញ ។

បណ្តាបទទាំងនោះ បទថា បរមត្ថសណ្ហិតា "ដែលប្រកបដោយប្រយោជន៍ដ៏ក្រៃលែង" សេចក្តីថា គាថាទាំងនេះ ឈ្មោះថា អាស្រ័យព្រះនិព្វាន ព្រោះសម្តែងដល់សេចក្តីមិនទៀងជាដើម ។ ព្រះសាស្តាកាលទ្រង់សរសើរពាក្យសុភាសិត ដែលឲ្យដល់នូវព្រះនិព្វាន របស់សរភង្គជាសាស្តា ទើបត្រាស់ពាក្យជាដើមថា គាថា

ទាំងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្ថវតី** **"មានអត្ថ"** សេចក្តីថា គាថាទាំងនេះ ឈ្មោះថា អាស្រ័យប្រយោជន៍ដ៏ក្រៃលែង ព្រោះអត្ថថា ឲ្យដល់ព្រះនិព្វាន ។ បទថា **សុព្យញ្ជនា** **"ព្យញ្ជនៈល្អ"** បានដល់ មានព្យញ្ជនៈបរិសុទ្ធ ។ បទថា **សុភាសិតា** **"ពោលល្អហើយ"** សេចក្តីថា ដែលឥសីជាបណ្ឌិតពោលធ្វើឲ្យគួរស្តាប់ដោយល្អ គឺ ពោលទុកល្អហើយ ។ បទថា **អដ្ឋិកត្វា** **"ឲ្យមានប្រយោជន៍"** សេចក្តីថា បុគ្គលណាជាអ្នកមានសេចក្តីត្រូវការ ព្រោះធ្វើនូវប្រយោជន៍ឲ្យដល់ខ្លួន គប្បីស្តាប់ដោយគោរព ។ បទថា **បុព្វាបរិយំ** **"ទាំងខាងដើម និងខាងចុង"** សេចក្តីថា បឋមជ្ឈានជាគុណវិសេសខាងដើម ទុតិយជ្ឈានជាគុណវិសេសខាងចុង នឹងគប្បីបាននូវគុណវិសេសដែលតាំងនៅដោយសភាពជាខាងចុង ដោយអំណាចនៃសមាបត្តិ ៨ ដោយអំណាចនៃមគ្គ ៤ យ៉ាងនេះ ។ បទថា **អទស្សនំ**

"ស្ថានទី... មើលមិនឃើញ" សេចក្តីថា ចូរគប្បីបានព្រះអរហត្តផល ដែលជាគុណវិសេសខាងចុង ហើយសម្រេចព្រះនិព្វានក្នុងទីបំផុត ព្រោះថា បុគ្គលអ្នកសម្រេចព្រះនិព្វានហើយ រមែងជាអ្នកឈ្មោះ ថា ទៅកាន់ស្ថានទីដែលមច្ចុរាជមើលមិនឃើញ ។

ព្រះសាស្តា គ្រាទ្រង់កាន់យកកំពូលនៃទេសនាដោយអរហត្ត-ផលយ៉ាងនេះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែន តែក្នុងជាតិនេះប៉ុណ្ណោះទេ សូម្បីក្នុងជាតិមុនភ្លៀងផ្កាក៏ធ្លាក់ចុះក្នុង ទីស្មសានជាទីដុតសពព្រះមហាមោគ្គល្លានដែរ" ដូច្នេះហើយ ទ្រង់ ក៏ប្រកាសអរិយសច្ចៈកាលនឹងទ្រង់ប្រជុំជាតក ទើបត្រាស់គាថាថា

[៦០៦] សាលិស្សរោ សារីបុត្តោ មេណ្ឌិស្សរោ ច កស្សបោ

បព្វតោ អនុរុទ្ធោ ច កច្ចាយនោ ច ទេវិលោ

អនុសិស្សោ ច អានន្ទោ កិសវច្ឆោ ច កោលិតោ

(នារទោ ឧទាយី ថេរោ បរិសា ពុទ្ធបរិសា)

*សរភង្គោ ពោធិសត្តោ[១] ឯវំ ធារេថ ជាតកន្តិ ។*

*សាលិស្សរតាបសក្នុងគ្រានោះ បានមកជាព្រះសារីបុត្តក្នុងគ្រានេះ មេណ្ឌិស្សរតាបស បានមកជាព្រះកស្សបៈ បព្វតតាបស បានមកជាព្រះអនុរុទ្ធៈ ទេវិលតាបស បានមកជាព្រះកច្ចាយនៈ អនុសិស្សតាបស បានមកជាព្រះអានន្ទ កីសវច្ឆតាបស បានមកជាព្រះកោលិតៈ គឺ ព្រះមោគ្គល្លាន នារទតាបស បានមកជាព្រះឧទាយី[២] បរិស័ទដ៏សេសក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងគ្រានេះ សរភង្គតាបស ពោធិសត្វ គឺ តថាគត អ្នកទាំងឡាយចូរចងចាំជាតកនេះទុកយ៉ាងនេះ ។*

ចប់អដ្ឋកថា សរភង្គជាតកទី ២

*១.ម. លោកនាថោ ។ ២ អដ្ឋកថាសីហឡ: ជាព្រះបុណ្ណមន្តាណីបុត្ត ។*

# អដ្ឋកថា អលម្ពុសាជាតកទី ៣

## (រឿងឥសិសិង្គតាបសត្រូវឧម្មាយតបះ)

*ព្រះសាស្តាកាលប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធការប្រលោមរបស់នាងបុរាណទុតិយិកា ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **អថាព្រវិ “គ្រានោះ... ត្រាស់បង្គាប់”** ដូច្នេះ រឿងបច្ចុប្បន្ន ខ្ញុំពោលទុកពិស្តារហើយក្នុងឥន្ទ្រិយជាតកនោះឯង ។*

*ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា “ម្នាលភិក្ខុ ដំណឹងថា អ្នកអផ្សុកចង់សឹកពិតឬ?” កាលភិក្ខុនោះក្រាបទូលទទួលជាពាក្យសច្ចះហើយ ទើបត្រាស់សួរថា “នរណាធ្វើឲ្យអ្នកអផ្សុក” កាលភិក្ខុនោះក្រាបទូលថា “នាងបុរាណទុតិយិកា” ទើបត្រាស់ថា “ភិក្ខុ ស្រីនេះបានធ្វើសេចក្តីវិនាសដល់អ្នក អ្នកអាស្រ័យស្រីនេះ ញុំាងឈានឲ្យវិនាស ជាអ្នកវង្វេងជ្រប់ដេកហើយអស់ ៣ ឆ្នាំ រហូតរលឹកដឹង*

បាន ទើបកើតបរិវេទនាដ៏ធំ” ហើយទ្រង់នាំអតីតនិទានមកសម្ដែង ដូចតទៅនេះ ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជ្យសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងដែនកាសិករដ្ឋ ចម្រើនវ័យហើយក៏សម្រេចក្នុងសព្វសិល្បសាស្ត្រ ក៏បួសជាឥសី មានផ្លែឈើក្នុងព្រៃជាអាហារ បានញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងព្រៃធំ ។ គ្រានោះ មេម្រឹគមួយក្បាលមកស៊ីស្មៅដែលលាយដោយទឹកបស្សាវៈ ក្នុងទីបស្សាវៈរបស់តាបសនោះហើយផឹកទឹក ដោយហេតុត្រឹមតែប៉ុណ្ណេះឯង វាក៏មានចិត្តប្រតិព័ទ្ធចំពោះតាបសរហូតតាំងគភ៌ តាំងអំពីនោះមកក៏មិនព្រមទៅណា ត្រាច់ទៅក្នុងទីជិតៗ អាស្រមនោះឯង ។ ព្រះមហាសត្វកំណត់មើលក៏ដឹងហេតុនោះ ។ តមកមេម្រឹគក៏កើតកូនជាមនុស្ស ។ ព្រះមហាសត្វទើបចិញ្ចឹមទារកនោះទុកដោយសេចក្ដីស្រឡាញ់ថាជាបុត្ត បានតាំង

ឈ្មោះថា "ឥសិសិង្គកុមារ" ក្នុងវេលាតមក ព្រះមហាសត្វទើបឲ្យ ឥសិសិង្គកុមារអ្នកដឹងសេចក្តីហើយបួស ក្នុងវេលាខ្លួនជរាបាននាំ តាបសកុមារនោះទៅកាន់នារីវ័ន បានពោលទូន្មានថា "កូនសម្លាញ់ ដែលឈ្មោះថា ស្រី ដូចផ្កាឈើទាំងនេះ មានហើយក្នុងព្រៃហិម-ពាន្តនេះ ស្រីទាំងនោះរមែងញុំាងជនអ្នកធ្លាក់នៅក្នុងអំណាចខ្លួនឲ្យ ដល់នូវសេចក្តីវិនាសដ៏ធំបាន មិនគួរកូននឹងទៅកាន់អំណាចរបស់ ស្រីទាំងនោះឡើយ" ដូច្នេះ ក្នុងវេលាតមក ក៏បានធ្វើកាលៈទៅកាន់ ព្រហ្មលោក ។ ចំណែកឥសិសិង្គតាបស កាលលេងឈានកីឡា ក៏ស្នាក់នៅក្នុងហិមវន្តប្បទេសនោះ បានជាអ្នកមានតបៈដ៏ក្លៀវ-ក្លា ជាអ្នកមានឥន្ទ្រិយជម្រះហើយយ៉ាងល្អ ។ គ្រានោះ ពិភពនៃ ស្តេចសក្កៈក៏កម្រើកដោយតេជះនៃសីលរបស់តាបស ។ សក្កទេវ-រាជទ្រង់ពិចារណាមើលក៏ជ្រាបហេតុនោះ ទ្រង់ព្រះតម្រិះថា "តាបស នេះ គប្បីញុំាងយើងឲ្យឃ្លាតចាកភាពជាស្តេចទេវរាជ យើងនឹង

ត្រូវបញ្ជូននាងទេពអប្សរម្នាក់ឲ្យទៅទម្លាយសីលរបស់លោក” ដូច្នេះ ទើបទ្រង់ពិចារណាក្នុងទេវលោកទាំងអស់ ក្នុងចំណោមទេវបរិចា-រិកា ២ កោដិកន្លះរបស់ព្រះអង្គ ទ្រង់មិនបានឃើញនរណាដទៃដែលអាចនឹងទម្លាយសីលព្រះឥសិសិង្គតាបសបាន ក្រៅអំពីទេពអប្សរឈ្មោះ អលម្ពុសា តែម្នាក់ ទើបត្រាស់ឲ្យនាងមកគាល់ ហើយទ្រង់បញ្ជាឲ្យទៅទម្លាយសីលរបស់ឥសិសិង្គតាបសនោះ ។

ព្រះសាស្តាកាលនឹងទ្រង់ធ្វើសេចក្តីនោះឲ្យជាក់ច្បាស់ ទើបត្រាស់ព្រះគាថាទី ១ ថា

[៦០៧] អថាព្រវិ ព្រហា ឥន្ទោ វត្រភូ ជយតំ បិតា
ទេវកញ្ញំ បរាភេត្វា សុធម្មាយំ អលម្ពុសំ ។

គ្រានោះ ព្រះឥន្ទដែលជាធំ ទ្រង់បង្ក្រាបនូវវត្រៈអសុរ ជាព្រះបិតានៃទេវបុត្តអ្នកឈ្នះ ប្រថាប់គង់នៅក្នុងសុធម្មាទេវសភា ត្រាស់បង្គាប់ឲ្យហៅនាងអលម្ពុសាទេពកញ្ញាមកគាល់ ។

បណ្ដាបទទាំងនោះ បទថា **ព្រហា** “**អ្នកជាធំ**” បានដល់ អ្នកជាធំក្រៃលែង ។ បទថា **វត្រភូ** “**ទ្រង់បង្ក្រាបវត្រអសុរ**” សេចក្ដីថា ទ្រង់គ្របសង្កត់អសុរឈ្មោះវត្រៈ ។ បទថា **ជយតំ បិតា** “**ជាព្រះបិតានៃទេវបុត្តអ្នកឈ្នះ**” សេចក្ដីថា ជាព្រះបិតានៃទេវបុត្តដ៏សេស ៣៣ អង្គ ដែលឈ្នះ គឺ ដល់នូវជ័យជំនះដោយញុំាងកិច្ចនៃបិតាឲ្យសម្រេច ។ បទថា **បរាភេត្វា** “**មកគាល់**” សេចក្ដីថា ទ្រង់ពិចារណាដោយចិត្តទើបដឹងថា “នាងអលម្ពុសានេះ មានកម្លាំងតទល់បាន” ។ បទថា **សុធម្មាយំ** “**សុធម្មទេវសភា**” សេចក្ដីថា ប្រថាប់គង់លើបណ្ឌុកម្ពលសិលាសនៈ ក្នុងសុធម្មាទេវសភា ត្រាស់ឲ្យហៅនាងអលម្ពុសានោះមកគាល់ ហើយត្រាស់គាថានេះថា

[៦០៨] មិស្សេ ទេវា តំ យាចន្តិ តាវតឹសា សឥន្ទកា
ឥសិបលោភិកេ គច្ឆ ឥសិសិង្គំ អលម្ពុសេ ។

នាងអាលម្ពុសាមិសសាទេវកញ្ញា អាចទឹងលួងលោមឥសី

បាន ទេវតាជាន់តាវត្តិង្សព្រមទាំងព្រះឥន្ទសូមអង្វរនាង នាង ចូរទៅរកឥសិសិង្គតាបសចុះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូចតទៅនេះ ស្តេចសក្កៈក៏ត្រាស់នឹងនាងអលម្ពុសាទេវកញ្ញានោះថា **មិស្សេ “មិសសា”** និងពាក្យនេះ ជាឈ្មោះរបស់នាងទេពកញ្ញានោះ ។ ក៏ស្រីគ្រប់ជំពូកលោកហៅថា **មិសសា** ព្រោះប្របូកប្របល់ទៅដោយកិលេសក្នុងបុរស ។ កាលស្តេចសក្កទេវរាជទ្រង់ពក់ទាក់ដោយគុណនាម ជាសាធារណៈនោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **ឥសិបលោភិកេ “លួងលោមឥសីបាន”** សេចក្តីថា នាងអាចនឹងលួងលោមឥសី ។ បទថា **ឥសិសិង្គំ “ឥសិសិង្គតាបស”** សេចក្តីថា បានឮថា ដុកពីរដែលកើតលើសីសៈរបស់ឥសិសិង្គតាបសនោះ ដោយអាការដូចជាស្នែងម្រឹគ ព្រោះហេតុនោះ គេទើបហៅតាមគ្នាយ៉ាងនេះ ។

ដោយប្រការដូច្នេះ ស្តេចសក្កៈទើបត្រាស់បញ្ជានាងអល-

ម្តុសាថា "ម្នាលនាងចូរទៅ ចូរចូលទៅរកឥសិសិង្គតាបស នាំមកក្នុងអំណាចរបស់ខ្លួន ហើយទម្លាយសីលរបស់លោកចុះ" ដូច្នេះ ហើយត្រាស់ពាក្យជាគាថានេះថា

[៦០៩] បុរាយំ អម្ពោ នាចេតិ វតវា ព្រហ្មចរិយវា
និព្វានាភិរតោ ពុទ្ធោ តស្ស មគ្គានិ អាវរ ។

តាបសអង្គនេះជាអ្នកមានវត្ត ប្រព្រឹត្តព្រហ្មចរិយៈ ត្រេកអរក្រៃលែងក្នុងនិព្វាន ជាអ្នកចម្រើនដោយគុណធម៌ កុំបានកន្លងពួកយើងទៅមុនឡើយ នាងចូររាំងផ្លូវទៅកាន់ទេវលោករបស់លោកចុះ ។

បណ្តាបទទាំងនោះ បទថា បុរាយំ "តាបសអង្គនោះ" ន័យថា តាបសនេះជាអ្នកសម្បូរដោយវត្ត និងប្រព្រឹត្តនូវព្រហ្មចរិយៈមួយទៀត តាបសនោះ ត្រេកអរក្រៃលែងក្នុងមគ្គ គឺ ព្រះនិព្វាន និងចម្រើនហើយដោយគុណវុឌ្ឍិ ព្រោះជាអ្នកមានអាយុវែង ព្រោះ

ដូច្នោះ តាបសនេះនឹងគ្រប់សង្កត់ពួកយើងមិនបាន គឺ មិនគួរគ្រប់សង្កត់ ធ្វើឲ្យពួកយើងឃ្លាតចាកទីបានត្រឹមណា នាងចូរទៅរារាំងផ្លូវដែលនឹងទៅកាន់ទេវលោករបស់លោកចេញត្រឹមនោះ អធិប្បាយថា នាងចូរធ្វើក្នុងប្រការដែលតាបសនោះមកកាន់ទីនេះមិនបាន ។

នាងអលម្ពុសាទេវកញ្ញាបានស្តាប់ដូច្នោះ ទើបពោល ២ គាថាថា

[៦១០] ទេវរាជ កិមេវ ត្វំ មមេវ តុវំ សិក្ខសិ
ឥសិបលោភិកេ គច្ឆ សន្តិ អញ្ញាបិ អច្ឆរា ។

បពិត្រព្រះទេវរាជ ព្រះអង្គទ្រង់ធ្វើអ្វី ទ្រង់បំណងចំពោះនាងខ្ញុំម្ចាស់ប៉ុណ្ណោះ ត្រាស់ថា នែនាងអ្នកអាចលួងលោមឥសីបាន នាងចូរទៅចុះ ដូច្នេះ ឯនាងទេពអប្សរសួម្បីដទៃៗក៏មានហើយ ។

មាទិសិយោ បវរា ចេវ អសោកេ នន្ទនេ វនេ

*តាសំបិ ហោតុ បរិយាយោ តាបិ យន្តុ បលោភិកា ។*

នាងទេពអប្សរដែលស្រស់ស្អាតដូចខ្ញុំម្ចាស់ ឬប្រសើរជាងខ្ញុំម្ចាស់នោះ ក៏មានហើយក្នុងនន្ទនវ័ន ដែលរកសេចក្ដីសោកមិនបាន សូមវារៈ គឺ ការទៅចូរមានដល់នាងទេពអប្សរទាំងនោះផងចុះ សូមឲ្យនាងទេពអប្សរទាំងនោះ ចូរទៅប្រលោមលួងលោមចុះ ។

ក្នុងបណ្ដាបទទាំងនោះ បទថា **កិមេវ ត្វំ** "ព្រះអង្គទ្រង់ធ្វើអ្វី" នេះ នាងអលម្ពុសាទេពអប្សរសម្ដែងថា "ព្រះអង្គទ្រង់ធ្វើវត្តនេះឈ្មោះថាអ្វី" ។ ដោយបទថា **មមេវ តុវំ សិក្ខសិ** "ទ្រង់សំដៅតែខ្ញុំម្ចាស់ប៉ុណ្ណោះ" នាងអលម្ពុសាទេពអប្សរពោលដោយបំណងថា "ក្នុងទេវលោកទាំងអស់នេះ ហេតុអ្វីព្រះអង្គជ្រើសរើសចំពោះតែខ្ញុំម្ចាស់ម្នាក់ ទ្រង់មិនមើលអ្នកដទៃខ្វះ" ។ ក៏ **ស** អក្សរក្នុងគាថានេះ ធ្វើការភ្ជាប់ព្យញ្ជនៈ ។ អធិប្បាយថា ព្រោះហេតុអ្វីទើបត្រាស់

ដូច្នេះថា "នែនាងអ្នកអាចលួងលោមឥសីបាន នាងចូរទៅចុះ" ។ បទថា **បរា ចេវ** "ប្រសើរជាង" សេចក្តីថា នាងទេពធីតាដែលក្រៃលែងជាងខ្ញុំម្ចាស់មានហើយ ។ បទថា **អសោកេ** "ដែលរកសេចក្តីសោកមិនបាន" បានដល់ ដែលមិនមានសេចក្តីសោក ។ បទថា **នន្ទនេ** "ក្នុងនន្ទនវ័ន" បានដល់ ក្នុងឧទ្យានដែលជាទីកើតសេចក្តីរីករាយ ។ បទថា **បរិយាយោ** "វារៈ គឺ ការទៅ" បានដល់ វារៈ គឺ ការទៅ ។ លំដាប់នោះ សក្កទេវរាជបានពោល ៣ គាថាថា

[៦១១] អទ្ធា ហិ សច្ចំ ភណសិ សន្តិ អញ្ញាបិ អច្ឆរា
តាទិសិយោ បរា ចេវ អសោកេ នន្ទនេ វនេ ។

នាងនិយាយពិតហើយ នាងទេពអប្សរដទៃៗ ដែលស្មើនឹងនាង និងក្រៃលែងជាងនាងមានហើយក្នុងនន្ទនវ័ន ដែលរកសេចក្តីសោកមិនបាន ។

ន តា ឯវំ បជានន្តិ បារិចរិយំ បុមំ គតា
យាទិសំ ត្វំ បជានាសិ នារិ សព្វង្គសោភនេ ។

នាងអ្នកមានអវយវៈល្អគ្រប់ចំណែក ប៉ុន្តែថា នាងទេព-អប្សរទាំងនោះទៅដល់ប្រុសហើយ រមែងមិនដឹងការបម្រើដូចដែលនាងដឹងឡើយ ។

ត្វមេវ គច្ឆ កល្យាណិ ឥត្ថីនំ បវរា ចសិ
តវេវ វណ្ណរូបេន វសមានា បយិស្សសិ ។

ម្នាលនាងកល្យាណី ចូរទៅចុះ ព្រោះថា នាងជាអ្នកដ៏ប្រសើរជាងស្រីទាំងឡាយ នាងនឹងប្រើរូបរាង ពណ៌សម្បុររបស់នាងនាំតាបសឲ្យមកកាន់ក្នុងអំណាចបាន ។

បណ្តាបទទាំងនោះ បទថា បុមំ គតា "ទៅដល់ប្រុសហើយ" សេចក្តីថា ស្រីទាំងនោះកាលចូលទៅរកប្រុស ក៏មិនចេះដឹងក្នុងការបម្រើ គឺ ការលួងលោមបុរស ។ បទថា វណ្ណរូបេន "រូបរាងនិង

ពណ្ណសម្បរ" សេចក្តីថា ដោយវណ្ណៈនៃសរីរៈ និងរូបសម្បត្តិ ។ បទថា វសមានាបយិស្សសិ[១] "មកកាន់អំណាចបាន" សេចក្តីថា នាងនឹងនាំតាបសនោះមកកាន់អំណាចរបស់ខ្លួន ។

នាងអលម្ពុសាទេពកញ្ញាបានស្តាប់ដូច្នោះ បានពោល ២ គាថាថា

[៦១២] នវាហំ ន គមិស្សាមិ ទេវរាជេន បេសិតា
វិភេមិ ចេតំ អាសាទុំ ឧគ្គតេជោ ហិ ព្រាហ្មណោ ។

ខ្ញុំម្ចាស់ត្រូវស្តេចទេវរាជទ្រង់ប្រើ នឹងមិនទៅមិនបាន តែខ្ញុំម្ចាស់ខ្លាចកាលនឹងប្រលោមតាបសនោះឲ្យត្រេកអរ ព្រោះលោកជាព្រាហ្មណ៍មានតេជៈខ្ពង់ខ្ពស់ ។

អនេកេ និរយំ បត្តា ឥសិមាសាទិយា ជនា
អាបន្នា មោហសំសារំ តស្មា លោមានិ ហំសយេ ។

---

បិដក. ១. វសមានា បយិស្សសិ ។

ជនទាំងឡាយមិនមែនតិច ប្រលោមឥសីឲ្យត្រេកអរហើយ ត្រូវធ្លាក់នរក ដល់សង្សារវដ្តព្រោះសេចក្តីវង្វេង ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបព្រឺរោម ។

បណ្តាបទទាំងនោះ បទថា **នវាហំ** "ខ្ញុំម្ចាស់... មិនបាន" កាត់បទជា **នវេ អហំ** ។ បទថា **វិភេមិ** "ខ្លាច" សេចក្តីថា ខ្ញុំម្ចាស់ខ្លាចក្រែង ។ បទថា **អាសាទុំ** "ដែល... ត្រេកអរ" បានដល់ ធ្វើឲ្យសៅហ្មង ។ លោកពោលអធិប្បាយសេចក្តីទុកថា "បពិត្រទេវៈ ព្រះអង្គទ្រង់ប្រើខ្ញុំម្ចាស់ហើយ មិនទៅក៏មិនបាន ប៉ុន្តែថា ខ្ញុំម្ចាស់ខ្លាចធ្វើឲ្យឥសិសិង្គតាបសនោះត្រេកអរ ហើយទម្លាយសីល ព្រោះលោកជាអ្នកមានតេជះខ្ពង់ខ្ពស់" ។ បទថា **អាសាទិយា** "ប្រលោម" សេចក្តីថា ប្រលោមឥសី ។ បទថា **មោហសំសារំ** "ដល់នូវសង្សារវដ្តព្រោះសេចក្តីវង្វេង" សេចក្តីថា សត្វទាំងឡាយមិនមែនតិចប្រលោមហើយ ឥសីក៏ដល់សង្សារវដ្តព្រោះសេចក្តីវង្វេង ការ

ប្រលោមឥសីព្រោះសេចក្ដីវង្វេង ហើយដល់សង្សារវដ្តតាំងនៅក្នុងវដ្តទុក្ខរាប់មិនអស់ ។ បទថា តស្មា "ព្រោះហេតុនោះ" សេចក្ដីថា ព្រោះហេតុនោះខ្ញុំម្ចាស់ ។ បទថា លោមានិ ហំសយេ "ទើបត្រូវព្រឺរោម" សេចក្ដីថា ខ្ញុំម្ចាស់ទើបព្រឺរោម ។ នាងអលម្ពុសាទេពកញ្ញាទូលថា "កាលខ្ញុំម្ចាស់គិតថា យើងនឹងត្រូវទម្លាយសីលរបស់តាបស" ដូច្នេះ លោមជាតិក៏បះឡើង ។

ព្រះសាស្ដាទ្រង់ត្រាស់អភិសម្ពុទ្ធគាថាទាំងនេះថា

[៦១៣] ឥទំ វត្វាន បក្កាមិ អច្ឆរា កាមវណ្ណិនី
មិស្សា មិស្សេតុមិច្ឆន្តី ឥសិសិង្គំ អលម្ពុសា ។

នាងអលម្ពុសាមិសសាទេពអប្សរ ដែលមានវណ្ណៈគួរឲ្យស្រឡាញ់ ប្រាថ្នានឹងញ៉ាំងឥសិសិង្គតាបសឲ្យច្របូកច្របល់ដោយកិលេស គ្រាក្រាបទូលយ៉ាងនេះហើយ ក៏ចេញទៅ ។

សា ច តំ វនមោគ្គយ្ហ ឥសិសិង្គេន រក្ខិតំ

ពិម្ពិជាលកសញ្ឆន្នំ សមន្តា អឌ្ឍយោជនំ ។

ក៏នាងអលម្ពុសាទេពអប្សរនោះ ចូលទៅកាន់ព្រៃដែលឥសិសិង្គតាបសរក្សា ដែលដេរដាសទៅដោយវល្លិបាសក្រហមជុំវិញប្រមាណកន្លះយោជន៍ ។

បាតោវ បាតកាសម្ហិ ឧទយសមយំ បតិ
អគ្គិដ្ឋំ បរិមជ្ជន្តំ ឥសិសិង្គំ ឧបាគមិ ។

នាងបានចូលទៅរកឥសិសិង្គតាបស ដែលកំពុងបោសរោងភ្លើងអំពីព្រឹក ជិតវេលាព្រះអាទិត្យឧទ័យមុនវេលាអាហារព្រឹក ។

បណ្តាបទទាំងនោះ បទថា បក្កាមិ "ក៏ចេញទៅ" សេចក្តីថា នាងអលម្ពុសាទេពកញ្ញានោះទូលថា "បពិត្រព្រះទេវរាជ បើដូច្នោះព្រះអង្គប្រោសរលឹកដល់ខ្ញុំម្ចាស់" ហើយចូលកាន់បន្ទប់ដេករបស់ខ្លួន ប្រដាប់តាក់តែងខ្លួនបំណងនឹងញ៉ាំងឥសិសិង្គតាបសឲ្យវង្វេង

ដោយកិលេស ទើបគេចចេញទៅ ម្នាលភិក្ខុទាំងឡាយ នាងអប្សរទៅកាន់អាស្រមរបស់ឥសិសិង្គតាបសហើយ ។ បទថា **ពិម្ពជាលរត្តសញ្ឆន្នំ**[១] “ដេរដាសទៅដោយវល្លិបាសក្រហម” ន័យថា ដែលដេរដាសទៅដោយវល្លិបាសក្រហម ។ បទថា **បាតោវ បាតរាសម្ហិ** “អំពីព្រឹក... មុនវេលាអាហារព្រឹក” សេចក្តីថា អំពីព្រឹក គឺ មុនវេលាអាហារព្រឹកនោះឯង ។ មុនត្រឹមណា ពេលណា? **ឧទយុសមយំ**[២] **បតិ** “ជិតវេលាព្រះអាទិត្យរះ” សេចក្តីថា ក្នុងវេលាជិតព្រះអាទិត្យរះឡើងនោះឯង ។ បទថា **អគ្គិដ្ឋំ** “រោងភ្លើង” បានដល់រោងភ្លើង ។ អធិប្បាយថា នាងអលម្ពុសាទេពអប្សរនោះចូលទៅរកឥសិសិង្គតាបសនោះ ដែលប្រកបសេចក្តីព្យាយាមក្នុងវេលាយប់ហើយ ស្រង់ទឹកអំពីព្រឹក ធ្វើឧទកកិច្ចស្រេចហើយ សោយសុខក្នុងឈានក្នុងបណ្ណសាលាបន្តិច ទើបចេញមកបោសរោងភ្លើង ឯនាងក៏មកឈរសម្តែងសេចក្តីស្រស់ស្អាតរបស់ស្រីនៅខាងមុខរបស់

---

បិដក. ១. ពិម្ពជាលកសញ្ឆន្នំ ។ ២. ឧទយសមយំ បតិ ។

ព្រះឥសិសិង្គតាបសនោះ ។

លំដាប់នោះ តាបសកាលនឹងសួរនាងទើបពោលថា

[៦១៤] កា នុ វិជ្ជុរិវាភាសិ ឱសធី វិយ តារកា
វិចិត្តហត្ថាភរណា អាមុត្តមណិកុណ្ឌលា ។

នាងជានរណា មានរស្មីភ្លឺថ្លាដូចផ្លេកបន្ទោរ ដូចជាផ្កាយព្រឹក មានគ្រឿងប្រដាប់ដៃល្អវិចិត្រ ពាក់ដោយកុណ្ឌលកែវ-មណី ។

អាទិច្ចវណ្ណសង្កាសា ហេមចន្ទនគន្ធិនី
សញ្ញតូរុ មហាមាយា កុមារី ចារុទស្សនា ។

ថែងចាំងដូចពន្លឺព្រះអាទិត្យ មានក្លិនចន្ទន៍លឿង មានភ្លៅមូលក្លំស្អាតល្អ មានមាយាច្រើន កំពុងពេញវ័យ គួរឲ្យស្រឡាញ់ ។

វិលាកា មុទុកា សុទ្ធា បាទា តេ សុប្បតិដ្ឋិតា

គមនា កាមនីយា តេ ហរន្តិយេវ មេ មនោ ។

ដើររបស់នាងមិនខ្ពង់កណ្តាល ទន់ល្មើយសែនស្អាត តាំង
ចុះរាបល្អ ដំណើរកែក្រោយរបស់នាងគួរស្រឡាញ់ ទាញចិត្ត
របស់យើងឲ្យស្រើបស្រាល ។

អនុបុព្វា ច តេ ឩរូ នាគនាសសមូបមា
វិមដ្ឋា តុយ្ហំ សុស្សោណី អក្ខស្ស ផលកំ យថា ។

មួយទៀត ភ្លៅរបស់នាងរៀវស្អាត ប្រៀបដូចប្រមោយ
ដំរី ត្រគាករបស់នាងសាយ រលើបរលោងដូចបន្ទះក្តារ ។

ឧប្បលស្សេវ កិញ្ជក្ខា នាភិ តេ សាធុសណ្ឋិតា
បុរា កណ្ហញ្ជនស្សេវ ទូរតោ បដិទិស្សតិ ។

នាភីរបស់នាងតាំងនៅរៀបរយល្អ ដូចបណ្តូលផ្កាឧប្បល
រមែងប្រាកដអំពីចម្ងាយ ស្រដៀងកេសរផ្កាអញ្ជ័នខៀវ ។

ទុវិធា ជាតា ឧរជា អវណ្តា សាធុបច្ចុទា

បយោធរា អបារ្ចតីតា អឡ្ឋឡាពុសមា ថនា ។

ដោះទាំងគូកើតត្រង់ទ្រូងរកអាក្រក់មិនបាន ប្រាកដដោយល្អ តាំងទុកនូវទីវរសមិនធ្លាក់យារ តឹងណែនទាំងសងខាង ស្មើដោយផ្លែឃ្លោកពាក់កណ្តាល ។

ទីឃា កម្ពុតលាកាសា គីវា ឯណេយ្យកា យថា

បណ្ឌរាវរណា វគ្គុ ចតុត្ថមនសន្និកា ។

ករបស់នាងវែងដូច.កម្រឹតទ្រាយ ល្អដូចជំពារមាស បបូរមាត់របស់នាងមានពណ៌ជម្ពូ ល្អភ្លឺផ្លេករួមទាំងពណ៌អណ្តាត ។

ឧទ្ធគ្គា ច អធគ្គា ច ទុមគ្គបរិមជ្ជិតា

ទុវិជា នេលសម្ភូតា ទន្តា តវ សុទស្សនា ។

ធ្មេញរបស់នាងទាំងខាងលើខាងក្រោម ជម្រះល្អដោយឈើស្ទន់ ដុះស្មើស្និទ្ធទាំងលើ និងក្រោម គួរមិលមើល ។

អបណ្ឌរា លោហិតន្តា ជិញ្ជុកផលសន្និភា

អាយតា ច វិសាលា ច នេត្តា តវ សុទស្សនា ។

កែវភ្នែកទាំងសងខាងរបស់នាងខ្មៅក្រិប តាមជុំវិញមាន ពណ៌ក្រហមដូចផ្លែទំពាំងបាយជូ ទាំងវែងទាំងធំទូលាយ ស្អាត ណាស់ ។

នាតិទីឃា សុសមដ្ឋា កនកព្យា សមោចិតា
ឧត្តមង្គរុហា តុយ្ហំ កេសា ចន្ទនគន្ធិកា ។

សរសៃសក់ដែលដុះលើសីសៈរបស់នាង មិនវែងពេក រលើបរលោងល្អ សិតដោយក្រាសមាស មានក្លិនក្រអូបដូច ក្លិនចន្ទន៍ ។

យាវតា កសិគោរក្ខា វាណិជានញ្ច យា គតិ
ឥសីនញ្ច បរក្កន្តំ សញ្ញតានំ តបស្សិនំ ។

វិធីជីវិតរបស់អ្នកស្រែ អ្នកចម្ការ អ្នកចិញ្ចឹមគោ និង របស់ឈ្មួញ និងសេចក្តីព្យាយាមរបស់ឥសីទាំងឡាយដែល

សង្រួមល្អ មានតបៈមានប្រមាណប៉ុនណា ។

ន តេ សមសមំ បស្សេ អស្មឹ បឋវិមណ្ឌលេ
កោ វា ត្វំ កស្ស វា បុត្តោ កថំ ជានេមុ តំ មយំ ។

យើងមិនឃើញបុគ្គលមានប្រមាណប៉ុណ្ណោះ ក្នុងប្រឹថពី-មណ្ឌលនេះសូម្បីតែម្នាក់ ដែលស្មើដូចនាង នាងជានរណា ឬជាបុត្តនរណា យើងនឹងស្គាល់បានដូចម្ដេច ។

បណ្ដាបទទាំងនោះ បទថា **វិចិត្តហត្ថាភរណា** "គ្រឿងប្រដាប់ដៃវិចិត្រល្អ" សេចក្ដីថា ដល់ព្រមដោយហត្ថាភរណៈដ៏វិចត្រ ។ បទថា **ហេមចន្ទនគន្ធិនី** "មានក្លិនចន្ទន៍លឿង" សេចក្ដីថា លាបដោយក្លិនចន្ទន៍លឿងមានពណ៌ខ្លួនដូចមាស ។ បទថា **សញ្ញតូរុ** "មានភ្លៅមូលល្អ" សេចក្ដីថា ភ្លៅមូលល្អ គឺ មានលក្ខណៈភ្លៅដែលបរិបូណ៌ ។ បទថា **វិលាកា** "មិនខ្ពង់" បានដល់ (បាតជើងរបស់នាង) មិនខ្ពង់ត្រង់កណ្ដាល ។ បទថា **មុទុកា** "ទន់ល្មើយ"

សេចក្ដីថា ទន់ល្មើយដោយសុខុមាលជាតិ ។ បទថា **សុទ្ធា** “ដ៏ស្អាត” បានដល់ ប្រាសចាកមន្ទិល ។ បទថា **សុប្បតិដ្ឋិតា** “តាំងចុះស្មើល្អ” សេចក្ដីថា កាលជាន់លើផែនដី ក៏រាបស្មើប្រតិស្ឋានស៊ប់ដោយល្អ ។

បទថា **គមនា** “ដំណើរកែក្រាយ” បានដល់ កាលឈានដើរទៅ ។ បទថា **កាមនីយា** “គួរស្រឡាញ់” សេចក្ដីថា កាលឈានដើរគួរឲ្យស្រឡាញ់ ។ បទថា **ហរន្តិយេវ នេ**[១] **មនោ** “ទាញចិត្តរបស់យើងឲ្យស្រើបស្រាល” សេចក្ដីថា ជើងទាំងពីររបស់នាងដែលឈានដើរទៅ ដោយលីលាដែលស្អាតសង្ហារបស់ស្រីជាន់ខ្ពស់បែបនេះ រមែងតឿនចិត្តរបស់យើងនោះឯង ។

បទថា **វិមដ្ឋា** “រលើបរលោង” បានដល់ ល្អស្អាត ។ បទថា **សុសោណ្ណិ**[២] “ត្រគាករបស់នាងមូលសាយ” បានដល់ មាន

---

បិដក. ១. ហរន្តិយេវ មេ មនោ ។ ២. សុសោណី ។

ត្រគាកស្វាយល្អ ។ បទថា **អក្ខស្ស** “**បន្ទះក្តារ**” សេចក្តីថា ត្រគាករបស់នាងស្វាយស្អាតល្អដូចជាបន្ទះក្តារមាស ។

បទថា **ឧប្បលស្សេវ កិញ្ជក្ខា** “**ដូចបណ្តូលផ្កាឧប្បល**” គឺដូចជាបណ្តូលនៃនីលឧប្បល ។ បទថា **កញ្ញញានស្សេវ** “**ដូចជាកេសរផ្កាអញ្ចានខៀវ**” សេចក្តីថា តាបសពោលយ៉ាងនេះ ព្រោះនាងទេពអប្សរនោះជាអ្នកមានរោមជាតិខ្មៅល្អិតដ៏វិចិត្រ ។ តាបសកាលសរសើរដោះទាំងពីរនោះ ទើបពោលគាថាថា **ទុវិធា** “**ទាំងគូ**” ជាដើម ។ ពិតហើយ ដោះដែលកើតត្រង់ទ្រូងទាំងគូនោះ ឈ្មោះថា **អវណ្តា** “**រកអាក្រក់មិនបាន**” ព្រោះមិនអាក្រក់ ជារបស់ជាប់នៅត្រង់ទ្រូងតែម្យ៉ាង ឈ្មោះថា **សាធុបច្ចទា**[1] “**ប្រាកដដោយល្អ**” ព្រោះដុះចេញមកដោយល្អ ឈ្មោះថា **បិយោធរា** “**តាំងទុកនូវខីរ-រស**” ព្រោះតាំងទុកនូវរសនៃទឹកដោះ ។

បទថា **អប្បតីតា** “**មិនយារ**” សេចក្តីថា មិនធ្លាក់យារ គឺ

---

[1] បិដក. សាធុបច្ចុទា ។

ឈ្មោះថា **តឹងណែន** “**អប្បតីតា**” ព្រោះមិនធ្លាក់យារ ឬព្រោះមិនផុតចុះ ។ ដោះទាំងគូដណ្ដប់ហើយស្មុគ្រតែមាសតាំងទុកខាងលើផ្ទៃពោះ ឈ្មោះថា **អឌ្ឍលាពុសមា** “**ស្មើដោយឃ្លោកពាក់កណ្ដាល**” ព្រោះផ្ទឹមគ្នានឹងផ្លែឃ្លោកមូលពាក់កណ្ដាល ។

បទថា **ឯណេយ្យកា យថា** “**ដូចក.ម្រឹគទ្រាយ**” សេចក្ដីថា ក.នៃម្រឹគទ្រាយទាំងវែងទាំងមូលស្អាតយ៉ាងណា ក.របស់នាងវែងបន្ដិចហើយស្អាត ដូច្នោះ ។ បទថា **កម្ពុតលាភាសា** “**ស្រស់ល្អដោយដំបារមាស**” សេចក្ដីថា ក.របស់នាង រាបស្អាតដូចផ្ទៃសុវណ្ណភេរី ។ បទថា **បណ្ឌរាវរណា** “**បបូរមាត់របស់នាងមានពណ៌ជម្ពូ**” បានដល់ មានធ្មេញស្រស់ស្អាត ។ បទថា **ចតុត្ថមនសន្និភា** “**ដូចគ្នានឹងពណ៌នៃអណ្ដាត**” សេចក្ដីថា អណ្ដាតដែលជាទីតាំងនៃមនៈទី ៤ លោកហៅថា **ចតុត្ថមនៈ** តាបសពោលថា “បបូរមាត់របស់នាងក៏ដូចគ្នានឹងអណ្ដាត ព្រោះក្រហមស្រស់គួរស្រឡាញ់” ។

បទថា ឧទ្ធគ្គា "ខាងលើ" បានដល់ ធ្មេញខាងលើ ។ បទថា អធគ្គា "ខាងក្រោម" បានដល់ ធ្មេញក្រោម ។ បទថា ទុមគ្គបរិមជ្ជិតា "ជម្រះស្អាតដោយឈើស្ទន់" សេចក្តីថា (ធ្មេញទាំងខាងលើខាងក្រោម) ជម្រះហើយដោយឈើស្ទន់ រហូតស្អាតបរិសុទ្ធ ។ បទថា ទុវិជា "ក្រោម... លើ" បានដល់ កើតទាំងពីរខាង ។ បទថា នេលសម្ភូតា "ជិតស្និទ្ធដោយអញ្ចាញខាងក្រោម និងខាងលើដ៏ស្អាត" សេចក្តីថា ធ្មេញដែលដុះចេញទាំងពីរខាងក្នុងទីបំផុតនៃសាច់អញ្ចាញដែលរកទោសមិនបាន ។

បទថា អបណ្ណក "ខ្ទៅក្រិប" មានន័យថា ខ្ទៅ ។ បទថា លោហិតន្តា "ជុំវិញគ្រាប់ភ្នែកពណ៌ក្រហម" បានដល់ មានជុំវិញក្រហម ។ បទថា ជិញ្ជុកផលសន្និភា "ពណ៌ក្រហមដូចផ្លែទំពាំងបាយជូ" សេចក្តីថា ក្នុងទីដែលគួរក្រហមដូចគ្នានឹងផ្លែទំពាំងបាយជូ បទថា សុទស្សនា "មើលស្អាតណាស់" សេចក្តីថា ប្រកបដោយ

បសាទទាំង ៥ គួររមិលមើលមិនចេះឆ្អែត ។

បទថា **នាតិទីឃា** “**មិនវែងពេក**” សេចក្ដីថា ខ្នាតសមល្មមល្អ ។ បទថា **សុសមដ្ឋា** “**រលើបរលោងល្អ**” សេចក្ដីថា រលើបរលោងល្អ ។ បទថា **កនកព្យា សមោចិតា** “**សិតដោយក្រាសមាស មានក្លិនក្រអូបដូចក្លិនចន្ទន៍**” សេចក្ដីថា ក្រាស់មាស លោកហៅថា កនកព្យា យកក្រាសមាសនោះជ្រលក់នឹងប្រេងក្រអូបតាក់តែងឲ្យស្អាត ។ តាបសសម្ដែងសត្វដែលមានជីវិតរស់នៅ ក៏ព្រោះអាស្រ័យកសិកម្ម និងគោរក្ខកម្ម ដោយបទនេះថា **កសិគោរក្ខា** “**អ្នកស្រែ អ្នកចម្ការ អ្នកចិញ្ចឹមគោ**” ។

បទថា **យា គតិ** “**វិធីជីវិត... ប៉ុនណា**” សេចក្ដីថា សេចក្ដីសម្រេចមានប្រមាណប៉ុនណា ។ បទថា **បរក្កន្តំ** “**សេចក្ដីព្យាយាម**” សេចក្ដីថា សេចក្ដីព្យាយាមរបស់ឥសីមានប្រមាណប៉ុនណា ។ អធិប្បាយថា ឥសីទាំងឡាយប្រឹងប្រែងហើយនៅក្នុងហិមវន្តប្បទេស

នេះ មានប្រមាណប៉ុនណា ។

បទថា **ន តេ សមសមំ** “មិន... ស្មើដូចនាង” សេចក្តីថា ក្នុងជនទាំងឡាយនោះ យើងមិនឃើញសូម្បីតែម្នាក់ ដែលស្មើនឹងនាងបានដោយរូបរាង និងស្រស់ស្អាតដោយដំណើរលីលាជាដើម កាលតាបសដឹងថា នាងនោះជាស្ត្រី ទើបសួរដោយអំណាចវោហាររបស់បុរសដូច្នេះថា **កោ វា ត្វំ** “នាងជានរណា” ជាដើម ។

កាលតាបសពោលសរសើរខ្លួន តាំងអំពីជើងរហូតដល់សក់យ៉ាងនេះ នាងអលម្ពុសាទេពកញ្ញានោះក៏នៅស្ងៀម កាលបន្តអនុសន្ធិតាមលំដាប់របស់ពាក្យនោះ នាងអលម្ពុសាទេពកញ្ញាក៏ដឹងថា តាបសនោះជាអ្នកវង្វេងហើយ ទើបពោលគាថាថា

[៦១៥] ន បញ្ហកាលោ ភទ្ទន្តេ  កស្សបេវំ គតេ សតិ

ឯហិ សម្ម រមិស្សាម  ឧភោ អស្មាកមស្សមេ

ឯហិ តំ ឧបគុយ្ហិស្សំ  រតីនំ កុសលោ ភវ ។

លោកកស្សបៈដ៏ចម្រើន កាលចិត្តរបស់លោកជាយ៉ាងនេះហើយ ក៏មិនមែនជាកាលនៃបញ្ញាឡើយ មកចុះលោកជាទីស្រឡាញ់ យើងទាំងពីរនឹងអភិរម្យគ្នាក្នុងអាស្រមរបស់យើង មកចុះលោក ខ្ញុំនឹងឱបរឹតលោក ចូរលោកជាអ្នកឈ្លាសក្នុងក្បួននៃសេចក្តីត្រេកអរដោយកាមគុណ ។

បណ្តាបទទាំងនោះ បទថា កស្សបេវំ គតេ សតិ "ម្នាលលោកកស្សបៈ... កាលចិត្តរបស់លោកជាយ៉ាងនេះហើយ" សេចក្តីថា លោកជាកស្សបគោត្រ កាលចិត្តរបស់លោកប្រព្រឹត្តទៅយ៉ាងនេះហើយ ក៏មិនគួរជាបញ្ញា ។ បទថា សម្ម "ដ៏ចម្រើន" នេះ ជាពាក្យអញ្ជើញដោយពាក្យគួរស្រឡាញ់ ។ បទថា រតីនំ "សេចក្តីត្រេកអរ" សេចក្តីថា លោកចូរជាអ្នកឈ្លាសក្នុងក្បួននៃសេចក្តីត្រេកអរក្នុងបញ្ចកាមគុណ ។

នាងអលម្ពុសាទេពកញ្ញាពោលយ៉ាងនេះហើយ គិតថា បើ

យើងឈរព្រៃនើយដូច្នេះ តាបសនេះក៏មិនព្រមចូលមកចាប់ដៃយើង យើងនឹងដើរធ្វើដូចជាចាកចេញទៅ ។ នាងទើបដើរទៅរកតាបស ព្រោះខ្លួនជាអ្នកឈ្លាសក្នុងមាយាស្រី ទើបដើរបែរមុខទៅតាមផ្លូវដែលខ្លួនមកហើយ ។

កាលនឹងប្រកាសសេចក្ដីនោះ ព្រះសាស្ដាទើបត្រាស់ថា

[៦១៦] ឥទំ វត្វាន បក្កាមិ អច្ឆរា កាមវណ្ណិនី

មិសិ្សា មិស្សេត្តុមិច្ឆន្តី ឥសិសិង្គំ អលម្ពុសា ។

នាងអលម្ពុសាមិសសាទេពកញ្ញា អ្នកមានពណ៌សម្បុរគួរស្រឡាញ់ ប្រាថ្នានឹងឲ្យឥសិសិង្គតាបសស្និទ្ធស្នាលទៅដោយកិលេស គ្រាពោលយ៉ាងនេះហើយក៏គេចទៅ ។

លំដាប់នោះ តាបសឃើញនាងកំពុងដើរទៅ គិតថា នាងនឹងចេញទៅទើបលះសេចក្ដីខ្ជិលរបស់ខ្លួន ស្ទុះទៅដោយរហ័សយកដៃស្ទាបអង្អែលត្រង់ផ្នួងសក់ ។

ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបទ្រង់ត្រាស់ព្រះគាថាថា

[៦១៧] សោ ច វេគេន និក្ខម្ម ឆេត្វា ទន្ធបរក្កមំ

តមុត្តមាសុ វេណីសុ អជ្ឈប្បត្តោ បរាមសិ ។

ចំណែកឥសិសិង្គតាបសនោះ ប្រញាប់ដើរចេញទៅដោយរហ័ស លះនូវសេចក្តីខ្ជិលចេញ ទៅទាន់ក៏ស្ទាបអង្អែលផ្នួងសក់លើសីសៈរបស់នាង ។

តមុទាវត្ត កល្យាណី បលិស្សជ្ជិ សុសោភនី

ចវិ តម្ហា ព្រហ្មចរិយា យថា តំ អថ តោសិតា ។

នាងទេពអប្សរលម្អដោយរូបឆោម ក៏បង្វិលខ្លួនត្រឡប់មកឱបក.តាបសនោះ នាងទេពអប្សរក៏មានចិត្តត្រេកអរថា ឥ-សិសិង្គតាបសឃ្លាតចាកព្រហ្មចរិយៈ តាមដែលសក្កទេវរាជទ្រង់ប្រាថ្នា ។

មនសា អគមា ឥន្ទំ វសន្តំ នន្ទនេ វនេ
តស្សា សង្កប្បមញ្ញាយ មឃវា ទេវកុញ្ជរោ
បល្លង្កំ បាហិនិ ខិប្បំ សោវណ្ណំ សោបវាហនំ ។

នាងរលឹកដល់ព្រះឥន្ទ្រដែលប្រថាប់នៅក្នុងនន្ទនវ័ន ស្តេចមឃវានទេវកុញ្ជរទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់នាងហើយ ទ្រង់ក៏បញ្ជូនបល្ល័ង្កមាស ព្រមទាំងគ្រឿងបរិក្ខារមកដោយរហ័ស ។

សឧរច្ឆទបញ្ញាសំ(១) សហស្សបដិយត្ថតំ
តមេនំ តត្ថ ធារេសិ ឧរេ កត្វាន សោកនា ។

ទាំងគ្រឿងថាប់ទ្រូង ៥០, កម្រាល ១.០០០(២) ផ្ទាំង នាងអលម្ពុសាទេពអប្សរ ឱបព្រះតាបសទុកត្រង់ទ្រូង ។

យថា ឯកមុហុត្តំវ តីណិ វស្សានិ ធារយិ
វិមទោ តីហិ វស្សេហិ បពុជ្ឈិត្វាន ព្រាហ្មណោ ។

---

១.ឱ. ម. សឧត្តរច្ឆទបញ្ញាសំ ។ ២. បិដក ១០០ ។

នាងផ្តេកតាបសទុកអស់ ៣ ឆ្នាំលើបល័ង្កនោះ ហាក់ដូច ជាមួយស្របក់ប៉ុណ្ណោះ ព្រាហ្មណ៍តាបសស្មានស្រវឹងហើយ ដឹងខ្លួនបានដោយវេលាកន្លងទៅ ៣ ឆ្នាំ ។

អទ្ទសាសិ ហរីតរុក្ខេ សមន្តា អគ្គិយាយនំ
នវបត្តវនំ ផុល្លំ កោកិលគណឃោសិតំ ។

បានឃើញព្រៃឈើពណ៌ខៀវជុះដោយជុំវិញផ្ទះភ្លើង លាស់ សន្លឹកថ្មី មានផ្ការីក គឹកកងទៅដោយសំឡេងសត្វតាវ៉ៅ ។

សមន្តា បវិលោកេត្វា រុទំ អស្សូនិ វត្តយិ
ន ជុហេ ន ជបេ មន្តេ អគ្គិហុត្តំ បហាបិតំ ។

លោកត្រួតមើលដោយជុំវិញហើយ ក៏យំសម្រក់ទឹកភ្នែក បរិទេវនាការថា យើងមិនបានបូជាភ្លើង មិនរាយមន្ត អ្វី បណ្តាលឲ្យការបូជាភ្លើងត្រូវវិនាស ។

កោ នុ មេ បារិចរិយាយ បុព្វេ ចិត្តំ បលោភយិ

អរញ្ញេ មេ វិហរតោ  យោ មេ តេជាហសម្ភុតំ
នានារត្នបរិបូរំ  នាវំ គណ្ហិ អណ្ណវេ ។

អ្នកណាហ្ន៎ មកប្រលោមចិត្តរបស់យើងដោយការបម្រើ ក្នុងកាលមុន ញុំាំងឈានដែលកើតព្រមនឹងតេជៈរបស់យើង អ្នកនៅក្នុងព្រៃឲ្យវិនាស ដូចបុគ្គលទាញទូកដែលពេញទៅដោយរតនៈផ្សេងៗ ក្នុងលំហសមុទ្រដូច្នោះ ។

បណ្តាបទទាំងនោះ បទថា អជ្ឈប្បត្តោ "ទៅមិនយូរ" ន័យថា តាបសនោះទៅដោយរហ័ស ។

បទថា តមុទាវត្ត កល្យាណី "នាងទេពអប្សរ... បង្វិលខ្លួនត្រឡប់" សេចក្តីថា នាងអលម្ពុសាទេពកញ្ញាដ៏ស្រស់ស្អាតសម្បូរស្នេហ៍ ងាកខ្លួនត្រឡប់មកឱបព្រះឥសីនោះដែលឈរស្ទាបអង្អែលសក់ ។ បទថា បលិស្សជិ[១] "ឱបរឹត" បានដល់ ឱបរឹត ។ បទ

បិដក. ១. បលិស្សជ្ជិ ។

ថា ចរិ តម្ហិ[១] ព្រហ្មចរិយា យថា តំ អថ តោសិតា "នាងទេព អប្សរក៏មានចិត្តត្រេកអរថា ឥសិសិង្គតាបសឃ្លាតចាកព្រហ្មចរិយៈ តាមស្តេចទេវរាជទ្រង់ប្រាថ្នា" ន័យថា ម្នាលភិក្ខុទាំងឡាយ រំពេចនោះឯង ឈានរបស់ឥសីនោះក៏អន្តរធានទៅ កាលលោកឃ្លាតចាកឈានព្រហ្មចរិយៈនោះហើយ បានប្រព្រឹត្តទៅដូចប្រការដែលស្តេចសក្កទេវរាជទ្រង់ប្រាថ្នានោះឯង លំដាប់នោះ នាងទេពកញ្ញាដែលស្តេចទេវរាជទ្រង់បញ្ជូនមកនោះ ដឹងថា សេចក្តីប្រាថ្នារបស់ស្តេចសក្កទេវរាជសម្រេចហើយ ក៏កើតបីតិបាមោជ្ជៈដោយការញ៉ាំងនូវព្រហ្មចរិយៈរបស់តាបសនោះឲ្យវិនាស ។

បទថា មនសា អគមា "រលឹកដល់" សេចក្តីថា នាងឈរឱបតាបសនោះ ចិត្តបានរលឹកដល់ព្រះឥន្ទយ៉ាងនេះថា "ឱ ស្តេចសក្កៈគួរបញ្ជូនបល្ល័ង្កមក" ។ បទថា នន្ទនេ "ក្នុងនន្ទនវ័ន" សេចក្តីថា សក្កទេវរាជដែលប្រថាប់នៅក្នុងតាវត្តិង្សព្រិកព ពោលគឺ ត្រង់

---

បិដក. ១. ចរិ តម្ហា ។

ទីឈ្មោះថា នន្ទនវ័ន ព្រោះអាចឲ្យកើតសេចក្ដីរីករាយ ។ បទថា **ទេវកុញ្ជរេ** “ទេវកុញ្ជរ” បានដល់ ទេវរាជដ៏ប្រសើរ ។

បទថា **បាហិណិ**[១] “ទើបទ្រង់បញ្ជូន” បានដល់ ទើបបញ្ជូនទៅ ។ បាឋៈថា **បហិណិ** ដូច្នេះក៏មាន ។ បទថា **សោវណ្ណហានំ** “ព្រមទាំងគ្រឿងបរិក្ខារ” បានដល់ សុវណ្ណបល្ល័ង្កព្រមទាំងបរិក្ខារ ។ បទថា **សឱរច្ឆទបញ្ញាសំ** “ទាំងគ្រឿងប្រដាប់ទ្រង់ ៥០” បានដល់ គ្រឿងសំពត់ស្ទៀកដណ្ដប់ព្រមដោយសំពត់ប្រដាប់ទ្រង់ ៥០ ផ្ទាំង ។ បទថា **សហស្សប្បដិយត្ថតំ** “គ្រឿងក្រាល ១.០០០ ផ្ទាំង” បានដល់ កម្រាល គឺ កម្រាលសំពត់ដែលជាទិព្វ ១.០០០ ។ បទថា **តមេនំ តត្ថ** “តាបសនោះ... លើបល្ល័ង្កនោះ” សេចក្ដីថា នាងក៏អង្គុយលើបល្ល័ង្កទិព្វនោះ ផ្ដេកឱបតាបសផ្ទប់នឹងទ្រូង ។

បទថា **តីណិ វស្សានិ** “៣ ឆ្នាំ” សេចក្ដីថា នាងឱបឥសិ-

---

បិដក. ១. បាហិនិ ។

សិង្គតាបសផ្ដេកផ្ដួបនឹងទ្រូង អង្គុយឱបនៅលើបល្ល័ង្កនោះអស់វេលា ៣ ឆ្នាំ ដោយរាប់វេលានៃ មនុស្សដូចជាវេលាមួយស្របក់ ។ បទថា **វិមនោ** **"ស្វាងស្រវឹង"** សេចក្ដីថា តាបសនោះស្វាងស្រវឹង គឺកាលជាអ្នកប្រាសចាកការសន្ទប់ ។ ព្រោះតាបសដេកសន្ទប់រហូតអស់ ៣ ឆ្នាំ លុះត្រឡប់បាននូវស្មារតីភ្ញាក់ឡើង ។ កាលតាបសភ្ញាក់ឡើង នាងអលម្ពុសា ឃើញអាការកម្រើកដៃជាដើមហើយដឹងថា "តាបសភ្ញាក់ឡើងហើយ ទើបបណ្ដាលឲ្យបល្ល័ង្កអន្តរធានទៅ សូម្បីខ្លួនឯងក៏អន្តរធានទៅដូចគ្នា ។

បទថា **អទ្ទសាសិ** **"បានឃើញ"** សេចក្ដីថា តាបសនោះក៏ត្រួតមើលអាស្រមហើយគិតថា "នរណាហ្ន៎ ធ្វើឲ្យយើងដល់នូវការវិបត្តិសីល" ហើយបរិទេវនាការដោយសំឡេងដ៏ខ្លាំង បានសម្ដីងមើលហើយ ។ បទថា **ហរិតរុក្ខេ** **"គុម្ពឈើពណ៌ខៀវដុះ"** សេចក្ដីថា បានឃើញដើមឈើមានស្លឹកខៀវខ្ចីដុះឡើងព័ទ្ធជុំវិញរោងភ្លើង

ពោលគឺ គំនរភ្លើង ដោយជុំវិញ ។ បទថា **នវបត្តវនំ** “លាស់ស្លឹកថ្មី” សេចក្ដីថា គុម្ពឈើដេរដាសទៅដោយស្លឹកឈើខ្ចីៗ ។

បទថា **រុទំ** **“ស្រែកយំ”** បានដល់ បរិទេវនាការ ។ គាថាបរិទេវនាការរបស់តាបសនោះយ៉ាងនេះថា “យើងមិនបានបូជាភ្លើងមិនបានបរិកម្មមន្ត” ។ បទថា **បហាបិតំ** **“ត្រូវវិនាស”** សេចក្ដីថា អ្វីបណ្ដាលឲ្យការបូជាភ្លើងត្រូវវិនាស ។ **ប** អក្សរ ជាឧបសគ្គ ។

បទថា **បារិចរិយាយ** **“ដោយការបម្រើ”** សេចក្ដីថា តាបសបរិទេវនាការថា “អំពីមុននេះ នរណាហ្ន៎ ប្រលោមចិត្តរបស់យើងដោយការបម្រើក្នុងកិលេស ។ **ហ** អក្សរ ក្នុងបទថា **យោ មេ តេជាហសំភូតំ** នេះ ជានិបាត ។ សេចក្ដីក៏ន័យថា ឥសិសិង្គតាបសបរិទេវនាការថា អ្នកណាចាប់ គឺ ញ៉ាំងឈានគុណដែលជាតេជះនៃសមណៈរបស់យើងឲ្យវិនាស ដូចញ៉ាំងទូកក្នុងមហាសមុទ្រដែលពេញទៅដោយរតនៈផ្សេងៗ ឲ្យវិនាសដូច្នោះ អ្នកនោះ គឺ នរណា

ហ្ន៎” អលម្ពុសាទេពកញ្ញាបានឮដូច្នោះ ក៏គិតថា “បើយើងមិនប្រាប់តាបសនេះនឹងផ្ដាសាយើង ណ្ហើយចុះ យើងនឹងប្រាប់ឲ្យលោកជ្រាប” ទើបឈរប្រាកដកាយពោលគាថាថា

[៦១៨] អហាន្តេ បារិចរិយាយ ទេវរាជេន បេសិតា

អវធិ ចិត្តំ ចិត្តេន បមាទា ត្វំ នពុជ្ឈសិ ។

ខ្ញុំដែលស្ដេចទេវរាជប្រើមកដើម្បីបម្រើលោក ទើបបានគ្របសង្កត់ចិត្តលោកដោយចិត្តរបស់ខ្ញុំ លោកមិនដឹងខ្លួនព្រោះសេចក្ដីប្រមាទ ។

ឥសិសិង្គតាបសបានស្ដាប់ពាក្យរបស់នាងហើយ រលឹកដល់ឱវាទដែលបិតាប្រាប់ ក៏បរិទេវនាការថា “ព្រោះយើងមិនបានធ្វើតាមពាក្យរបស់បិតា ទើបដល់នូវសេចក្ដីវិនាសដ៏ធំ” ដូច្នេះហើយ ទើបបានពោល ៤ គាថាថា

[៦១៩] ឥមានិ កិរ មំ តាតោ កស្សបោ អនុសាសតិ

កមលាសរិសិត្ថិយោ   តាយោ ពុជ្ឈសិ មាណវ ។

ដើមដំបូង លោកកស្សបៈអ្នកជាបិតា បានប្រៀនប្រដៅយើងដល់វត្ថុទាំងនេះថា មាណព ស្ត្រីប្រៀបបាននឹងនារីផល[1] កូនចូរស្គាល់ស្ត្រីទាំងនោះ ។

ឱរេ គណ្ឌាយោ ពុជ្ឈសិ   តាយោ ពុជ្ឈសិមាណវ

ឥច្ចានុសាសិមំ តាតោ   យថា មំ អនុកម្បកោ ។

បិតាយើងអាណិតអាសូរយើង ទូន្មានយើងដោយពាក្យនេះថា មាណពអើយ កូនចូរស្គាល់នារីផលអ្នកមានដោះត្រង់ទ្រូង កូនចូរស្គាល់ស្ត្រីទាំងនេះ ។

តស្សាហំ វចនំ នាកំ   បិតុ ពុទ្ធស្ស សាសនំ

អរញ្ញេ និម្មនុស្សម្ហិ   ស្វជ្ជ ឈាយាមិ ឯកកោ ។

យើងមិនបានធ្វើតាមពាក្យទូន្មានរបស់បិតា ជាអ្នក

១.វចនានុក្រម. ជាផ្លែឈើម្យ៉ាងដុះនៅព្រៃហិមពាន្ត ជាទីពេញចិត្តរបស់ពួកវិជាធរ ។

ប្រាជ្ញនោះ ថ្ងៃនេះយើងសោកសៅហើយតែម្នាក់ឯងក្នុងព្រៃដែលរកមនុស្សមិនបាន ។

សោហំ តថា ករិស្សាមិ ធិរត្ថុ ជីវិតេន មេ
បុន វា តាទិសោ ហេស្សំ មរណំ មេ ភវិស្សតិ ។

ថ្វីយ គួរតិះដៀលពិតហ្ន៎ជីវិតរបស់យើង យើងនោះនឹងធ្វើប្រការដែលយើងធ្លាប់ធ្វើដូចដើមទៀត ឬមិនដូច្នោះយើងក៏នឹងស្លាប់ ។

បណ្តាបទទាំងនោះ បទថា ឥមានិ "វត្ថុទាំងនេះ" បានដល់ពាក្យទាំងនេះ ។ បទថា កមលាសរិសិត្ថិយោ "ស្ត្រីប្រៀបដូចជានារីផល" សេចក្តីថា នារីផលទាំងឡាយលោកហៅថា កមលា ស្ត្រីទាំងឡាយក៏ដូចជាផ្កានៃនារីផលទាំងនោះ ។ បទថា តាយោ ពុជ្ឈសិ ចូរស្គាល់ស្ត្រីទាំងឡាយ" សេចក្តីថា គ្រានោះ បិតាទូន្មានពាក្យបែបនេះនឹងយើងថា "មាណពអើយ កូនគួរស្គាល់ស្រីទាំងនោះ

លុះដឹងហើយកុំទៅកាន់ផ្លូវដែលគួរមើល គួរគេចចេញ ន័យថា នារីផលទាំងនោះ គឺ ស្រីទាំងនោះ ។

បទថា **ឱរេ គណ្ឌាយោ** "**អ្នកមានដោះត្រង់ទ្រូង**" សេចក្ដីថា កូនចូរស្គាល់នារីផលដែលប្រកបហើយដោយដោះទាំងពីរនៅខាងមុខទ្រូង ។ បទថា **តាយោ ពុជ្ឈសេ**[១] "**ចូរស្គាល់ស្ត្រីទាំងនេះ**" សេចក្ដីថា មាណពកូន គប្បីដឹងថា "ស្រីទាំងនោះរមែងញ៉ាំងអ្នកដែលនៅក្នុងអំណាចខ្លួនឲ្យវិនាស ។

បទថា **នាកំ** "**មិនបានធ្វើ**" សេចក្ដីថា យើងមិនបានធ្វើតាមពាក្យរបស់លោក ។ បទថា **ឈាយានិ** "**សោកសៅ**" សេចក្ដីថា យើងទើបត្រូវសោកសៅ គឺ បរិទេវនាការហើយ ។

បទថា **ធិរត្ថុ ជីវិតេន មេ** "**ថ្វីយ គួរតិះដៀលពិតហ្ន៎ជីវិតរបស់យើង**" សេចក្ដីថា ជីវិតរបស់យើងគួរតិះដៀល ប្រយោជន៍

---

បិដក. ១. តាយោ ពុជ្ឈសិ ។

អ្វីដោយការដែលយើងមានជីវិតរស់នៅ ។ បទថា បុន វា "ឬមិនដូច្នោះ..." សេចក្តីថា យើងនឹងជាដូច្នោះទៀត គឺ នឹងញុំាងឈានដែលវិនាសហើយឲ្យកើតឡើង ជាអ្នកប្រាសចាករាគៈដោយប្រការណានឹងធ្វើដោយប្រការនោះ ឬថា យើងនឹងស្លាប់ ។

ឥសិសិង្គតាបសនោះលះបង់កាមរាគៈហើយ ញុំាងឈានឲ្យកើតបានទៀត ។ លំដាប់នោះ នាងអលម្ពុសាទេពកញ្ញា ឃើញតេជៈនៃសមណៈរបស់តាបសនោះផង និងដឹងថា លោកបំពេញឈានឲ្យកើតឡើងបានហើយផង ក៏តក់ស្លុត ទើបសូមលោកឲ្យអត់នូវទោសដល់ខ្លួន ។

ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ បានត្រាស់ ២ ព្រះគាថាថា

[៦២០] តស្ស តេជំ វីរិយញ្ច ធិតឹ ញត្វា អវដ្ឋិតំ

សិរសា អគ្គហី បាទេ ឥសិសិង្គំ អលម្ពុសា ។

នាងអលម្ពុសាទេពកញ្ញា គ្រាដឹងតេជះសេចក្ដីព្យាយាម និងបញ្ញាដ៏មុតមាំរបស់ឥសិសិង្គតាបសនោះហើយ ក៏ឱនសីសៈ ចុះត្រង់ជើងរបស់ព្រះឥសិសិង្គតាបស ពោលថា

មា មេ កុជ្ឈ មហាវីរ មា មេ កុជ្ឈ មហាឥសេ
មហា អត្ថោ មយា ចិណ្ណោ តិទសានំ យសស្សិនំ
តយា សង្កម្បិតំ អាសិ សព្វំ ទេវបុរំ តទា ។

បពិត្រលោកមហាវីរៈ សូមលោកកុំក្រោធនឹងខ្ញុំឡើយ បពិត្រលោកអ្នកស្វែងរកគុណដ៏ធំ សូមលោកកុំក្រោធនឹងខ្ញុំឡើយ ខ្ញុំបានបង្កប្រយោជន៍ដ៏ធំហើយ ដើម្បីទេវតាជាន់ត្រៃ-ទស ព្រោះថា ទេវបុរីទាំងអស់ដែលលោកបានធ្វើឲ្យញាប់ញ័រហើយក្នុងគ្រានេះ ។

*លំដាប់នោះ ឥសិសិង្គតាបសតបថា "នាងដ៏ចម្រើន យើងអត់ទោសឲ្យនាង នាងចូរទៅតាមសប្បាយចុះ" កាលនឹងលែងនាង*

ទៅ ទើបពោលគាថាថា

[៦២១] តាវត្តឹសា ច យេ ទេវា តិទសានញ្ច វាសវោ

ត្វញ្ច ភទ្ទេ សុខី ហោហិ គច្ឆ កញ្ញេ យថាសុខំ ។

នាងដ៏ចម្រើន សូមពួកទេវតាជាន់តាវត្តិង្ស ស្តេចវាសវៈ កំពូលនៃត្រៃទស និងនាងចូរមានសេចក្តីសុខចុះ នាងទេព-កញ្ញាសូមនាងទៅតាមសប្បាយចុះ ។

នាងអលម្ពុសាទេពកញ្ញាសំពះតាបសហើយ ក៏ត្រឡប់ទៅកាន់ទេវបុរីព្រមទាំងបល្ល័ង្កមាសនោះឯង ។

ព្រះសាស្តាកាលនឹងទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់ ៣ ព្រះគាថា សេចក្តីថា

[៦២២] តស្ស បាទេ គហេត្វាន កត្វា ច នំ បទក្ខិណំ

អញ្ជលឹ បគ្គហេត្វាន តម្ហា ឋានា អបក្កមិ ។

នាងអលម្ពុសាទេពកញ្ញា ឱនសីសៈចុះទៀបជើងរបស់

ឥសិសិង្គតាបស និងធ្វើប្រទក្សិណហើយ ផ្គងអញ្ជលីចេញ
ចាកទីនោះឯង ។

យោ តស្សា អាសិបល្លង្កោ សោវណ្ណោ សោបវាហនោ
សឧរច្ឆទបញ្ញាសោ សហស្សប្បជិយត្ថតោ
តមេវ បល្លង្កមារុយ្ហ អគា ទេវាន សន្តិកេ ។

នាងឡើងកាន់បល្ល័ង្កមាស ព្រមដោយគ្រឿងបរិក្ខារ ព្រម
ទាំងសំពត់ប្រថាប់ទ្រូង ៥០ និងកម្រាល ១.០០០ ផ្ទាំង
ហើយត្រឡប់ទៅកាន់សម្នាក់នៃទេវតាទាំងឡាយ ។

តមោក្កមិវ អាយន្តឹ ជលន្តឹ វិជ្ជុតំ យថា
បតីតោ សុមនោ វិត្តោ ទេវិន្ទោ អទទា វរំ ។

ស្តេចសក្កៈកំពូលនៃទេវតាទ្រង់បិតិសោមនស្ស រីករាយ
ព្រះទ័យ បានព្រះរាជទានពរដល់នាងទេពកញ្ញានោះ ដែល
កំពុងមក ប្រៀបដូចជាដួងប្រទីបដ៏រុងរឿង ប្រៀបដូចជាផ្លេ-
កបន្ទោរ ដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **ឱក្កមិវ** “ប្រៀបដូចជាដួងប្រទីប” សេចក្ដីថា ដូចប្រទីប ។ ដោយបទមានជាអាទិថា **បតិតោ**(១) “រីករាយ” លោកសម្ដែងដល់អាការស្ដេចសក្កទេវរាជទ្រង់ត្រេកអរ ។ បទថា **អទទា វរំ** “បានព្រះរាជទានពរ” សេចក្ដីថា សក្កទេវរាជទ្រង់ត្រេកអរ បានប្រទានពរឲ្យដល់នាងអលម្ពុសាទេពកញ្ញាដែលមកថ្វាយបង្គំ ឈរហើយនោះ ។

នាងអលម្ពុសាទេពកញ្ញា កាលទឹងទទួលពរក្នុងសម្នាក់របស់ស្ដេចសក្កទេវរាជ ទើបពោលគាថាចុងក្រោយថា

[៦២៣] **វរញ្ចេ មេ អទោ សក្ក សព្វភូតានមិស្សរ**
**ន ឥសិបលោភិកា គច្ឆេ ឯតំ សក្ក វរំ វរេតិ ។**

បពិត្រស្ដេចសក្កៈជាធំជាងភូតទាំងឡាយ បើព្រះអង្គទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់សោត សូមកុំឲ្យខ្ញុំម្ចាស់ត្រូវទៅប្រលោមឥសីទៀតឡើយ បពិត្រស្ដេចសក្កៈ ខ្ញុំម្ចាស់សូមនូវពរប្រការ

បិដក. ១. បតីតោ ។

នេះ ។

គាថានោះ មានអត្ថាធិប្បាយដូច្នេះ បពិត្រស្តេចសក្កទេវរាជ ប្រសិនបើព្រះអង្គទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ហើយ ខ្ញុំម្ចាស់សូមពរប្រការនេះ គឺ កុំឲ្យខ្ញុំម្ចាស់ត្រូវទៅប្រលោមឥសីទៀត គឺ ព្រះអង្គទ្រង់កុំប្រើខ្ញុំម្ចាស់ដើម្បីប្រយោជន៍ប្រការនេះ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងដល់ភិក្ខុនោះហើយ ទ្រង់ប្រកាសសច្ចធម៌ទាំងឡាយ ហើយទ្រង់ប្រជុំជាតកក្នុងទីបំផុតនៃសច្ចៈ ភិក្ខុនោះក៏បានតាំងនៅក្នុងសោតាបត្តិផល ។ នាងអលម្ពុសាក្នុងកាលនោះ បានមកជានាងបុរាណទុតិយិកានេះឯង ឥសិសិង្គតាបសក្នុងកាលនោះ ក៏បានមកជាភិក្ខុអ្នកអផ្សុកនេះ រីឯមហាឥសីជាបិតាក្នុងកាលនោះ គឺ **តថាគត** នេះឯង ។

ចប់អដ្ឋកថា អលម្ពុសាជាតកទី ៣

# អដ្ឋកថា សង្ខបាលជាតកទី ៤

## (រឿងសង្ខបាលនាគរាជបំពេញតបៈ)

*ព្រះសាស្តាកាលប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធឧបោសថកម្ម ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អរិយាវកាសោសិ “លោកជាអ្នកមានរូបរាងស្អាត”** ដូច្នេះ ។*

*សេចក្តីពិស្តារថា គ្រានោះ ព្រះសាស្តាទ្រង់ញុំាងឧបាសកទាំងឡាយដែលរក្សាឧបោសថឲ្យរីករាយ ហើយត្រាស់ថា “បុរាណបណ្ឌិតទាំងឡាយលះបង់នាគសម្បត្តិដ៏ធំហើយ ចូលចាំឧបោសថដូចគ្នា” ឧបាសកទាំងឡាយទូលអារាធនាហើយ ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះ ។*

*ក្នុងអតីតកាល ព្រះចៅផែនដីមគធៈ សោយរាជ្យសម្បត្តិក្នុងព្រះនគររាជគ្រឹះ ។ គ្រានោះ ព្រះពោធិសត្វទ្រង់កើតក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីរបស់ព្រះរាជានោះ ។ ព្រះជនកព្រះជននីទ្រង់*

ថ្វាយព្រះនាមថា “ទុយ្យោធនកុមារ” ។ លោកចម្រើនវ័យហើយ បានសិក្សាសព្វសិល្បសាស្ត្រក្នុងក្រុងតក្កសិលា ត្រឡប់មកសម្តែងសិល្បៈថ្វាយព្រះរាជបិតា តមកព្រះរាជបិតាទើបអភិសេកព្រះកុមារទុកក្នុងរាជ្យសម្បត្តិ ហើយបួសជាឥសីនៅក្នុងព្រះរាជឧទ្យាន ។ ព្រះពោធិសត្វស្តេចបានទៅកាន់សម្នាក់ព្រះរាជបិតាមួយថ្ងៃ ៣ ដង ។ លាភសក្ការៈដ៏ធំបានកើតឡើង (ដល់ព្រះឥសី) ។ ព្រះរាជឥសីមិនអាចធ្វើសូម្បីត្រឹមតែកសិណបរិកម្មបាន ព្រោះកង្វល់នោះ ទើបទ្រង់ត្រិះរិះថា “លាភសក្ការៈរបស់យើងច្រើនណាស់ យើងនៅទីនេះមិនអាចនឹងកាត់នូវព្រៃ គឺ កិលេសនេះបានទេ យើងនឹងទៅប្រាប់លាព្រះឱរសចេញទៅកាន់ទីដទៃ” ព្រះរាជឥសីមិនប្រាប់ឲ្យអ្នកណាៗ ដឹង ស្តេចចេញចាកឧទ្យានទៅកាន់មគធរដ្ឋ បានចូលទៅអាស្រ័យចន្ទកបព៌ត ធ្វើបណ្ណសាលាសៅនៅក្នុងទីនោះ ក្នុងទីល្មមនឹងទៅមកបានអំពីស្ទឹងកណ្ណវេណាឃា ដែលហូរមកអំពីក្បាលទឹក

ឈ្មោះសង្ខបាលៈ ខេត្តមហិសករដ្ឋ ធ្វើកសិណបរិកម្ម ធ្វើឈាន និងអភិញ្ញាឲ្យកើតហើយ ចិញ្ចឹមជីវិតដោយការត្រាច់ភិក្ខាចារ ។ នាគរាជឈ្មោះសង្ខបាលៈ ចេញចាកកណ្ណវេណាឈានទី ព្រមទាំងបរិវារដ៏ច្រើន ចូលទៅ (រកព្រះរាជឥសីនោះ) ជាគ្រាៗ ។ ព្រះរាជឥសីក៏សម្តែងធម៌ដល់សង្ខបាលនាគរាជនោះ ។ តមក ព្រះរាជឱរសរបស់ព្រះរាជឥសីនោះប្រាថ្នានឹងជួបព្រះជនក តែមិនបានដឹងស្ថានទីដែលស្តេចនៅ ទើបប្រោសឲ្យត្រាច់ជាប់តាម ទ្រង់ជ្រាបថា “ប្រថាប់នៅត្រង់ស្ថានទីឈ្មោះឯណោះ” ស្តេចក៏ទៅទីនោះព្រមទាំងបរិវារដ៏ច្រើន ដើម្បីទ្រង់សួរសុខទុក្ខព្រះរាជឥសី ត្រាស់បង្គាប់ឲ្យតាំងបន្ទាយក្នុងទីមួយ ព្រមជាមួយអាមាត្យ២-៣ នាក់ ស្តេចយាងទៅកាន់អាស្រមដ្ឋាន ។ ខណៈនោះ សង្ខបាលនាគរាជកំពុងអង្គុយស្តាប់ធម៌ជាមួយបរិវារដ៏ច្រើន ។ លោកក្រឡេកឃើញព្រះរាជាស្តេចមក ទើបសំពះឥសីក្រោកឡើងចាកអាសនៈគេចចេញទៅ ។

ព្រះរាជាថ្វាយបង្គំព្រះបិតា ទ្រង់ធ្វើបដិសណ្ឋារៈ ហើយប្រថាប់គង់ទូលសួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន នុ៎ះព្រះរាជាអង្គណាស្ដេចមកកាន់សម្នាក់របស់លោកម្ចាស់” ស្ដេចតបថា “កូនសំឡាញ់ នុ៎ះគឺ សង្ខបាលនាគរាជ” ព្រះរាជឱរសក៏កើតសេចក្ដីលោភក្នុងនាគ-ពិភព ព្រោះអាស្រ័យសម្បត្តិរបស់ស្ដេចនាគនោះ ប្រថាប់នៅពីរ-បីថ្ងៃ ទ្រង់ឲ្យចាត់កិច្ចាហារថ្វាយព្រះរាជបិតាជាប្រចាំ ហើយស្ដេចត្រឡប់មកកាន់ព្រះនគរព្រះអង្គវិញ ប្រោសឲ្យសាងរោងទានទុកក្នុងទិសទាំង ៤ ញុំាងសកលជម្ពូទ្វីបឲ្យល្បីល្បាញ ទ្រង់បរិច្ចាគទានរក្សាសីល ធ្វើការរក្សាឧបោសថកម្ម ប្រាថ្នានាគពិភព ក្នុងទីបំផុតនៃព្រះជន្មាយុ ក៏បានទៅកើតជាស្ដេចនាគសង្ខបាលៈក្នុងពិភពនាគនោះឯង ។ ក្នុងកាលកន្លងមក លោកក៏កើតសេចក្ដីក្ដៅក្រហាយក្នុងសម្បត្តិនោះ តាំងអំពីនោះមក ក៏ប្រាថ្នាកំណើតមនុស្ស ហើយរក្សាឧបោសថកម្ម ។ កាលសង្ខបាលនាគរាជនៅក្នុងនាគពិភព គ្រា

នោះ ការរក្សាឧបោសថមិនសម្រេច សីលរមែងវិនាស ។ តាំងអំពីនោះមក ស្តេចទើបចេញចាកនាគពិភពទៅឆ្ងាយរន្ធេលត្រង់ដំបូកមួយក្នុងចន្លោះផ្លូវធំ និងផ្លូវដើរចំពោះមនុស្សម្នាក់ៗ មិនឆ្ងាយអំពីស្ទឹងកណ្ណវេណាឈានទី អធិដ្ឋានឧបោសថ ជាអ្នកមានសីលដែលសមាទានហើយ លះបង់ខ្លួនឲ្យដល់កំពូលថា "ជនទាំងឡាយដែលមានសេចក្តីត្រូវការដោយស្បែក និងសាច់ជាដើមរបស់យើង ក៏ចូរនាំយកស្បែក និងសាច់ជាដើមទៅចុះ" ហើយដេកនៅលើដំបូក បំពេញសមណធម៌ រក្សាឧបោសថក្នុងថ្ងៃ ១៤-១៥ កើត ហើយទៅកាន់នាគពិភពក្នុងថ្ងៃបាដិបទ ។

ថ្ងៃមួយ កាលស្តេចនាគកំពុងសមាទានសីលដេកហើយយ៉ាងនេះ មានអ្នកបច្ចន្តគ្រាម ១៦ នាក់ គិតគ្នាថា "ពួកយើងនឹងទៅរកសាច់មក" មានអាវុធគ្រប់ដៃត្រាច់ទៅក្នុងព្រៃ កាលមិនបានអ្វីក៏ត្រឡប់ ឃើញស្តេចនាគរាជនោះដេកនៅលើដំបូក ក៏គិតគ្នាថា

"ថ្ងៃនេះ ពួកយើងមិនបានសូម្បីតែកូនទន្សោង ពួកយើងនឹងសម្លាប់ស្ដេចនាគរាជបរិភោគ" ហើយគិតទៀតថា "នាគរាជនេះធំណាស់ កាលត្រូវចាប់គង់នឹងគេចចេញ ត្រូវយកលំពែងចាក់ត្រង់គុម្ពកន្ទុយទាំងដែលកំពុងដេក ធ្វើឲ្យអស់កម្លាំងក៏គង់នឹងចាប់បាន" ជនទាំងនោះកាន់លំពែងជាដើមចូលទៅជិត រាងកាយព្រះពោធិសត្វដែលមានទំហំប៉ុនទូកកម្រោល ដូចគ្នានឹងកម្រងផ្កាម្លិះដែលបុគ្គលតម្កល់ទុក នាគរាជនោះប្រកបដោយភ្នែកដូចជាគ្រាប់មក្លាំ សីសៈដូចជាផ្កាជ័យព្រឹក្ស និងផ្កាម្លិះ ស្អាតរកអ្វីប្រៀបមិនបាន ។ ដោយសំឡេងជើងរបស់ជនទាំង ១៦ នាក់ ស្ដេចនាគទើបងើបសីសៈចេញអំពីវង់កន្ទុយ បើកភ្នែកពណ៌ក្រហមសម្លឹងមើលជនទាំងនោះ ដែលមានដៃកាន់លំពែងដើរចូលទៅ ដោយគិតថា "ថ្ងៃនេះ មនោរថរបស់យើងនឹងដល់ទីបំផុតហើយ យើងនឹងប្រគល់ខ្លួនឲ្យជាកំពូលនៃទានហើយទើបដេកអធិដ្ឋានសេចក្ដីព្យាយាម យើងនឹងមិនបើកភ្នែកមើល

ជនទាំងនេះយកលំពែងចាក់សរីរៈរបស់យើង ធ្វើឲ្យជាចន្លោះតូចធំ ដោយអំណាចសេចក្ដីក្រោធឡើយ” ព្រោះខ្លាចសីលរបស់ខ្លួននឹងបែកធ្លាយទើបអធិដ្ឋានឲ្យមុតមាំ ស៊កសីសៈចូលទៅក្នុងរន្ធេលកន្ទុយហើយដេកដូចដើម ។ គ្រាជនទាំងនោះចូលមកជិតហើយ ក៏ចាប់កន្ទុយស្ដេចនាគ ទាញទម្លាក់អំពីជំបូកយកលំពែងដ៏មុតចាក់ត្រង់គុម្ពកន្ទុយ ៨ កន្លែង ស៊កផ្ដៅដែលមានបន្លាចូលទៅតាមចន្លោះដែលចាក់ក្នុងទីទាំង ៨ កន្លែង ហើយនាំគ្នាដើរត្រឡប់មកកាន់ផ្លូវធំ ។ ព្រះមហាសត្វតាំងអំពីត្រូវចាក់ដោយលំពែង ក៏មិនបានបើកភ្នែកមើលជនទាំងនោះ ដោយអំណាចសេចក្ដីក្រោធសូម្បីតែមួយដង ។ កាលត្រូវគេយកឈើស្នែងទាំង ៨ សែងទៅ សីសៈក៏សំយុងចុះខ្ទប់នឹងផែនដី ។ លំដាប់នោះ ជនទាំងនោះនិយាយគ្នាថា “សីសៈរបស់ស្ដេចនាគសំយុង” ទើបដាក់ឲ្យដេកត្រង់ផ្លូវធំ យកលំពែងដែកចាក់ត្រង់រន្ធច្រមុះ ហើយយកខ្សែចង លើកសីសៈពាក់ត្រង់ចុង

ឈើស្នែងនាំគ្នាលើកឡើង ធ្វើដំណើរតទៅទៀត ។

ខណៈនោះ កុដុម្ពិកៈឈ្មោះអាឡារៈ អ្នកក្រុងមិថិលា ដែនវិទេហរដ្ឋ អង្គុយលើយានយ៉ាងសប្បាយ នាំរទេះ ៥០០ ធ្វើដំណើរបញ្ច្រាសគ្នាទៅ ឃើញពួកអ្នកបច្ចន្តគ្រាមកំពុងសែងព្រះពោធិសត្វដើរទៅដូច្នោះ ទើបឲ្យមាសកៈមាសម្នាក់មួយកំបង់ ជាមួយនឹងគោពាហនៈ ១៦ ក្បាល ដល់ជនទាំង ១៦ នាក់នោះ និងឲ្យសំពត់ស្លៀកដណ្តប់ដល់ជនទាំងនោះគ្រប់គ្នា ទាំងឲ្យសំពត់សាច់ល្អិត និងគ្រឿងប្រដាប់ សូម្បីដល់ករិយាជនទាំងនោះ សូមអង្វរឲ្យលែងស្តេចនាគទៅ ។ ស្តេចនាគទៅកាន់នាគពិភព មិនបានធ្វើឲ្យយឺតយូរនៅក្នុងពិភពនាគឡើយ ក៏ចេញទៅរកអាឡារកុដុម្ពិកៈ ព្រមទាំងបរិវារដ៏ច្រើន ពោលគុណរបស់នាគពិភព ហើយអញ្ជើញកុដុម្ពិកៈនោះទៅកាន់ពិភពនាគ ប្រទានយសដ៏ធំព្រមទាំងនាងនាគកញ្ញា ៣០០ ដល់កុដុម្ពិកៈនោះ ឲ្យស្កប់ស្កល់ដោយកាមគុណជាទិព្វ ។ អាឡារកុដុម្ពិកៈ

នៅបរិភោគកាមដែលជាទិព្វក្នុងនាគពិភពអស់វេលាប្រមាណមួយឆ្នាំ ហើយប្រាប់ស្តេចនាគថា "សម្លាញ់ យើងប្រាថ្នានឹងបួស" បានទទួលយកបរិក្ខារបព្វជិត ហើយចេញចាកពិភពនាគ បួសនៅក្នុងហិមវន្តប្បទេសអស់កាលយូរ តមក ទើបត្រាច់ចារិកទៅរហូតដល់ក្រុងពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន ស្អែកឡើងចូលទៅកាន់ព្រះនគរដើម្បីភិក្ខាចារ បានទៅកាន់ទ្វារព្រះរាជវាំង ។ គ្រានោះព្រះបាទពារាណសីទតព្រះនេត្រឃើញអាឡារតាបសនោះហើយ ក៏ឲ្យធាន់ភោជនដែលមានរសដ៏ប្រណីតផ្សេងៗហើយប្រថាប់គង់លើអាសនៈតំណែងមួយ ទ្រង់នមស្ការកាលនឹងទ្រង់ប្រាស្រ័យជាមួយតាបសនោះ បានត្រាស់គាថាទី ១ ថា

[៦២៤] *អរិយាវកាសោសិ*[១] *បសន្នេនេត្តោ*

*មញ្ញេ ភវំ បព្វជិតោ កុលម្ហា*

---

១.ម. សរីរាវកាសោសិ ។

កថំ នុ វិត្តានិ បហាយ ភោគេ
បព្វជិ និក្ខម ឃរា សបញ្ញោ ។

លោកជាអ្នកមានរូបរាងស្អាតល្អ មានកែវភ្នែកភ្លឺថ្លា ខ្ញុំសម្គាល់ថាលោកដ៏ចម្រើនគង់បួសចាកត្រកូល ដូចម្តេច លោកអ្នកមានបញ្ញាទើបលះបង់ទ្រព្យ និងភោគសម្បត្តិចេញបួសជាបព្វជិតហ្ន៎ ។

បណ្តាបទទាំងនោះ បទថា **អភិយាវកាសោសិ** “ជាអ្នកមានរូបរាងល្អស្អាត” សេចក្តីថា ព្រះបាទពារាណសីបានត្រាស់សួរថា “លោកជាអ្នកមានឱកាស គឺ សរីរៈស្អាតល្អរកទោសមិនបាន បានដល់ ជាអ្នកមានរូបរាងស្អាតក្រៃលែង” ។ បទថា **បសន្ននេត្តោ** “មានភ្នែកភ្លឺថ្លា” សេចក្តីថា មានភ្នែកប្រកបដោយបសាទទាំង ៥ ។ បទថា **កុលម្ហា** “ចាកត្រកូល” សេចក្តីថា ខ្ញុំសម្គាល់ថា “លោកប្រាកដជាអ្នកបួសចាកត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ឬត្រកូល

សេដ្ឋី" ។ បទថា កថំ នុ "ដូចម្តេចហ្ន៎" សេចក្តីថា ព្រោះហេតុអ្វី ឬលោកជាបណ្ឌិត ធ្វើអ្វីជាអារម្មណ៍ទើបបានលះបង់ទ្រព្យ និងភោគសម្បត្តិចេញចាកផ្ទះមកបួស ។ បទថា សបញ្ញោ "ជាអ្នកមានបញ្ញា" បានដល់ បុរសជាបណ្ឌិត ។

តអំពីនោះ គួរជ្រាបរឿងទាក់ទងជាមួយគាថា ដោយទំនងនឹងពាក្យសួរឆ្លើយរវាងតាបស និងព្រះរាជាដូចតទៅនេះ ។

អាឡារតាបសទូលថា

[៦២៥] សយំ វិមានំ នរទេវ ទិស្វា
មហានុភាវស្ស មហោរគស្ស
ទិស្វាន បុញ្ញាន មហាវិបាកំ
សទ្ធាយហំ បព្វជិតោម្ហិ រាជ ។

មហាបពិត្រទ្រង់ជាធំលើនរជន អាត្មាភាពបានឃើញវិមានរបស់សង្ខបាលនាគរាជអ្នកមានអានុភាពច្រើនដោយខ្លួនឯង លុះ

ឃើញហើយ ទើបចេញបួសដោយជឿដល់មហាវិបាករបស់បុណ្យទាំងឡាយ ។

ព្រះរាជាត្រាស់ថា

[៦២៦] ន កាមកាមា ន ភយា ន ទោសា

វាចំ មុសា បព្វជិតា ភណន្តិ

អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ

សុត្វា មេ ជាយិហិតិប្បសាទោ ។

បព្វជិតទាំងឡាយមិនពោលពាក្យកុហក ព្រោះសេចក្តីស្រឡាញ់ ព្រោះសេចក្តីខ្លាច ព្រោះសេចក្តីស្អប់ ខ្ញុំសួរលោកហើយ សូមលោកមេត្តាប្រាប់សេចក្តីនោះដល់ខ្ញុំ ព្រោះខ្ញុំបានស្តាប់ហើយនឹងកើតសេចក្តីជ្រះថ្លា ។

អាឡារតាបសទូលថា

[៦២៧] វាណិជ្ជ រដ្ឋាធិប គច្ឆមានោ

បថេ អទ្ទសាសិម្ហិ ភោជបុត្តេ
បវឌ្ឍកាយំ ឧរគំ មហន្តំ
អាទាយ គច្ឆន្តេ បមោទមានេ ។

មហាបពិត្រទ្រង់ជាអធិបតីក្នុងរដ្ឋមណ្ឌល អាត្មាភាពធ្វើដំណើរទៅជួញ បានឃើញបុត្តនាយព្រានទាំងឡាយកាន់សែងនាគមានរាងកាយដ៏ធំ ដើរយ៉ាងរីករាយទៅតាមផ្លូវ ។

សោហំ សមាគម្ម ជនិន្ទ តេហិ
បហដ្ឋលោមោ(១) អវចម្ហិ ភីតោ
កុហិំ អយំ នីយតិ ភីមកាយោ
នាគេន កឹ កាហថ ភោជបុត្តា ។

បពិត្រព្រះអង្គជាកំពូលលើប្រជានិករ អាត្មាភាពបានជួបជាមួយបុត្តនាយព្រានទាំងនោះ ក៏ខ្លាចរហូតព្រឺរោម បានសួរ

---

១.ឱ. សំហដ្ឋលោមោ ។

គេថា នែបុត្តព្រានទាំងឡាយ អ្នកទាំងឡាយនឹងនាំពស់ដែលមានរាងកាយដ៏គួរឲ្យខ្លាចទៅណា អ្នកទាំងឡាយនឹងធ្វើអ្វីដល់ពស់នេះ ។

ពួកគេនាំគ្នាតបថា

នាគោ អយំ នីយតិ ភោជនត្ថំ
បវឌ្ឍកាយោ ឧរគោ មហន្តោ
សាទុញ្ច ថូលញ្ច មុទុញ្ច មំសំ
ន ត្វំ រសញ្ញាសិ វិទេហបុត្ត ។

ពស់ធំមានកាយដែលចម្រើន ពួកយើងនាំទៅដើម្បីនឹងស៊ី សាច់របស់វាមានរសឆ្ងាញ់ ក្រាស់ និងទន់ លោកជាបុត្តអ្នកដែនវិទេហ លោកមិនធ្លាប់លិទ្ធរសទេ ។

ឥតោ មយំ គន្ត្វា សកំ និកេតំ
អាទាយ សត្ថានិ វិកោបយិត្វា

មំសានិ ភក្ខាម បមោទមានា

មយំ ហិ វោ សត្តវោ បន្នគានំ ។

យើងទាំងឡាយទៅអំពីទីនេះ ដល់ស្រុករបស់ខ្លួនហើយ នឹងយកកាំបិតកាប់ចិញ្ច្រាំស៊ីសាច់ឲ្យសប្បាយ ព្រោះថា យើងទាំងឡាយជាសត្រូវនឹងពួកពស់ ។

អាត្មាភាពទើបនិយាយថា

សចេ អយំ នីយតិ ភោជនត្ថំ

បវឌ្ឍកាយោ ឧរគោ មហន្តោ

ទទាមិ វោ ពលិពទ្ទានិ សោឡស

នាគំ ឥមំ មុញ្ចថ ពន្ធនស្មា ។

បើអ្នកទាំងឡាយ នាំពស់ដ៏ធំមានកាយដែលចម្រើននេះ ទៅដើម្បីស៊ី យើងនឹងឲ្យគោ ១៦ ក្បាលដល់អ្នកទាំងឡាយ សូមឲ្យលែងពស់នេះចេញអំពីចំណងចុះ ។

ពួកគេតបថា

អទ្ធា ហិ នោ ភក្ខោ អយំ មនាបោ
ពហូ ច នោ ឱរគា ភុត្តបុព្វា
ករោម តេ តំ វចនំ អឡារ
មិត្តញ្ច នោ ហោហិ វិទេហបុត្ត ។

ពិតហើយ ពស់នេះជាអាហារដ៏ពេញចិត្តរបស់យើងទាំងឡាយដោយពិត និងយើងទាំងឡាយក៏ធ្លាប់ស៊ីពស់មកច្រើនហើយ ម្នាលអាឡារៈបុត្តអ្នកដែនវិទេហរដ្ឋ យើងទាំងឡាយនឹងធ្វើតាមពាក្យរបស់លោក លោកជាបុត្តនៃអ្នកដែនវិទេហៈ តែថា លោកចូរជាមិត្តរបស់យើងទាំងឡាយ ។

តទស្សុ តេ ពន្ធនា មោចយឹសុ
យំ នត្ថុតោ បដិមោក្ខស្ស បាសេ
មុត្តោ ច សោ ពន្ធនា នាគរាជា

បក្កាមិ បាចីនមុខោ មុហុត្តំ ។

ជនទាំងនោះស្រាយនាគរាជចេញអំពីចំណង នាគរាជបាន
រួចអំពីចំណង ដែលគេដោតត្រង់ច្រមុះ និងឈើវែកនោះហើយ
ក៏បែរមុខឆ្ពោះត្រង់ទិសបស្ចិម លូនចេញទៅមួយរំពេច ។

គន្ត្វាន បាចីនមុខោ មុហុត្តំ
បុណ្ណេហិ នេត្តេហិ បលោកយី មំ
តទស្សហំ បិដ្ឋិតោ អន្វគច្ឆឹ
ទសង្គុលី អញ្ជលឹ បគ្គហេត្វា ។
គច្ឆេវ ខោ ត្វំ តរមានរូបោ
មា តំ អមិត្តា បុនរគ្គហេសុំ
ទុក្ខោ ហិ លុទ្ទេហិ បុនា សមាគមោ
អទស្សនំ ភោជបុត្តាន គច្ឆ ។

គ្រាបែរមុខឆ្ពោះទិសបស្ចិមបានបន្តិច មានភ្នែកពេញទៅ

ដោយទឹកភ្នែក ក្រឡេកមកមើលអាត្មាភាព អាត្មាភាពបានតាមទៅអំពីក្រោយនាគរាជក្នុងគ្រានោះ ផ្គងអញ្ជលីទាំង ១០ ប្រមាមជាស់តឿនថា លោកចូរប្រញាប់ទៅឲ្យរហ័ស សូមពួកសត្រូវកុំចាប់បានទៀតឡើយ ព្រោះថា ការសមាគមជាមួយពួកព្រានរឿយៗ ជាទុក្ខ លោកចូរទៅស្ថានទីដែលពួកបុត្តរបស់ព្រានមិនឃើញ ។

អគមាសិ សោ រហទំ វិប្បសន្នំ

នីលោភាសំ រមណីយំ សុតិត្ថំ

សមោនតំ ជម្ពុហិ វេទិសាហិ[១]

បាវេក្ខិ និត្តិណ្ណភយោ បតីតោ ។

នាគរាជនោះបានទៅកាន់អន្លង់ទឹកថ្លា មានពណ៌ខៀវគួរមនោរម្យ មានកំពង់រាបស្មើ គ្របដណ្តប់ទៅដោយជម្ពូព្រឹក្ស

១.ឱ. វេគសាហិ ។

និងដើមអសោក ជាសត្វផុតភ័យមានបីតិ ចូលកាន់នាគពិ-
ភព ។

សោ តំ បវិស្ស ន ចិរស្ស នាគោ
ទិព្វេន មេ បាតុរហុ ជនិន្ទ
ឧបដ្ឋហី មំ បិតរំវ បុត្តោ
ហទយង្គមំ កណ្ណសុខំ ភណន្តោ ។
ត្វំ មេសិ មាតា ច បិតា អឡារ
អព្ភន្តរោ បាណទទោ សហាយោ
សកញ្ច ឥទ្ធឹ បដិលាភកោស្មិ
អឡារ បស្ស មេ និវេសនានិ
បហូតភក្ខំ ពហុអន្នបានំ
មសក្កសារំ វិយ វាសវស្ស ។

បពិត្រព្រះអង្គជាធំលើប្រជានិករ នាគរាជនោះ គ្រាចូល

ទៅកាន់នាគពិភពហើយ មិនយូរក៏មានបរិវារជាទិព្វមកប្រាកដ ដល់អាត្មាភាព ទំនុកបម្រុងអាត្មាភាពដូចជាបុត្តទំនុកបម្រុង បិតាដូច្នោះ បានពោលពាក្យដ៏ពីរោះគួរចាប់ចិត្តថា បពិត្រ អាឡារៈ លោកដូចជាមាតាបិតារបស់ខ្ញុំ ជាដួងជីវិត ជាអ្នក ឲ្យនូវជីវិត ជាសំឡាញ់ ខ្ញុំទើបត្រឡប់បានឥទ្ធិឫទ្ធិរបស់ខ្លួន បពិត្រអាឡារៈ សូមអញ្ជើញលោកទៅលេងនាគពិភពរបស់ យើង ដែលមានកក្ខាហារច្រើន មានបាយ និងទឹកច្រើន ដូច ទេពនគររបស់ស្តេចវាសវៈដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **វិមានំ** **"វិមាន"** សេចក្តីថា (អាត្មា ឃើញ) វិមានកព្វានមណី បរិបូណ៌ដោយនាជកិត្តិសម្បត្តិ (ស្រី របាំ) ដោយវិសេសរបស់សន្ធបាលនាគរាជ ។ បទថា **បុញ្ញានំ**(១) **"របស់បុណ្យទាំងឡាយ"** សេចក្តីថា លុះឃើញមហាវិបាកនៃបុណ្យ

---

បិដក. ១. បុញ្ញាន ។

របស់នាគរាជនោះមក ខ្ញុំទើបចេញបួសដោយសទ្ធា ព្រោះជឿកម្ម ជឿផលនៃកម្ម និងជឿបរលោក ។

បទថា **ន កាមកាមា** “**មិន... ព្រោះសេចក្តីស្រឡាញ់**” គឺ ព្រះរាជាត្រាស់ថា “បព្វជិតទាំងឡាយមិននិយាយកុហក ព្រោះវត្ថុ-កាមខ្លះ ព្រោះខ្លាចខ្លះ ព្រោះទោសៈខ្លះ ។ បទថា **ជាយិហីតិ** “**ទើបកើត**” សេចក្តីថា បពិត្រលោកដ៏ចម្រើន សេចក្តីសោមនស្សជ្រះថ្លាទើបកើតដល់ខ្ញុំ ព្រោះបានស្តាប់ពាក្យរបស់លោក ។

បទថា **វាណិជ្ជំ**(១) “**ឈ្នួញ**” សេចក្តីថា តាបសទូលថា “កាលអាត្មាភាពធ្វើដំណើរទៅដោយគិតថា នឹងធ្វើជំនួញ” ។ បទថា **បថេ អទ្ទសាសិម្ហិ** “**បានឃើញ... ត្រង់ផ្លូវ**” សេចក្តីថា អាត្មាអង្គុយលើយានតូចខាងមុខរទេះ ៥០០ បានឃើញមនុស្សអ្នកជនបទត្រង់ផ្លូវធំ ។ បទថា **បវឌ្ឍកាយំ** “**មានរាងកាយធំ**” សេចក្តីថា មានរាង

---

បិដក. ១. វាណិជ្ជ ។

កាយធាត់ធំ ។ បទថា **អាទាយ** “**សែង**” សេចក្តីថា សែងទៅដោយឈើស្នែង ៨ ។

បទថា **អវចស្មិ**[១] “**បានសួរ**” បានដល់ បានពោលហើយ ។ បទថា **ភីមកាយោ** “**មានរាងកាយគួរខ្លាច**” បានដល់ ដែលមានរាងកាយគួរខ្លាច ។ បទថា **ភោជបុត្តា** “**ពួកបុត្តនាយព្រាន**” ន័យថា អាឡារកុដុម្ពិកៈស្រែកហៅបុត្តនាយព្រានដោយពាក្យដែលគួរស្រឡាញ់ ។ បទថា **វិទេហបុត្ត** “**លោកជាបុត្តអ្នកដែនវិទេហរដ្ឋ**” សេចក្តីថា ពួកបុត្តព្រាននាំគ្នាពោលតបនឹងអាឡារកុដុម្ពិកៈ ព្រោះអាឡារកុដុម្ពិកៈនៅក្នុងវិទេហរដ្ឋ ។

បទថា **វិភោជយិត្វា**[២] “**ចិញ្ច្រាំ**” បានដល់ ចិញ្ច្រាំ (ឬកាប់) ។ បទថា **មយម្ហិ**[៣] **ភោ សត្តវោ** “**យើងទាំងឡាយជាសត្រូវនឹងពួកពស់**” សេចក្តីថា ក៏ពួកយើងជាសត្រូវនឹងនាគទាំងឡាយ ។ បទ

---

បិដក. ១. អវចម្ហិ ។ ២. វិភោបយិត្វា ។ ៣. មយំ ហិ ភោ សត្តវោ ។

ថា ភោជនត្ថំ "ដើម្បីស៊ី" សេចក្តីថា ដើម្បីនឹងបរិភោគ ។ បទថា មិត្តញ្ច នោ ហោហិ "លោកចូរជាមិត្តរបស់យើងទាំងឡាយ" គឺ សូមលោកចូរជាមិត្តរបស់ពួកយើង ដឹងនូវគុណដែលពួកយើងធ្វើ ហើយ ។ បទថា តទស្សុ តេ "ជនទាំងនោះ" សេចក្តីថា មហា-រាជ គ្រាបុត្តនាយព្រានទាំងនោះពោលយ៉ាងនេះហើយ អាត្មាភាព បានឲ្យគោមានកម្លាំង ១៦ ក្បាល គ្រឿងស្លៀកដណ្តប់ ទ្រព្យម្នាក់ៗ ១០០ មាសត្តោរមួយមាសកៈដល់បុត្តនាយព្រានទាំងនោះ ទាំងសំពត់ និងគ្រឿងប្រដាប់ដល់កិរិយាទាំងឡាយរបស់បុត្តព្រានទាំងនោះ ។

លំដាប់នោះ បុត្តព្រានទាំងនោះឲ្យស្តេចនាគសង្ខបាលៈដេក លើផែនដី ព្រោះសភាពរឹងនៃខ្លួន នាំគ្នាស្រាយនូវចំណងផ្តៅដែល ប្រកបដោយបន្ទាចេញ ហើយចាប់ទាញចុងកន្ទុយ គ្រានោះអាត្មា ឃើញនាគរាជលំបាក កាលនឹងមិនឲ្យលំបាក ទើបយកកាំបិតកាត់ វល្លិទាំងនោះបន្តិចម្តងៗ យកចេញមិនឲ្យលំបាក ដោយទំនងដែល

ក្មេងៗ ស្រាយសំពត់ដែលស្លៀកក្នុងវេលានោះ បុត្តព្រានទាំងនោះសិកចំណងត្រង់ប្រហោងច្រមុះ ហើយចងភ្ជាប់នឹងឈើវែក ព្រោះដូច្នោះ ទើបនាំគ្នាស្រាយស្តេចនាគអំពីចំណងនោះ ។ តាបសបានសម្តែងថា "បុត្តនាយព្រានទាំងនោះ គ្រាលែងនាគរាជដូច្នេះហើយដើរទៅបានបន្តិច ក៏នាំគ្នាឈប់ដោយគិតថា "នាគនេះទុព្វលកាព (អស់កម្លាំង) ក្នុងវេលានោះស្លាប់ហើយ យើងនឹងវែកយកទៅ" ។

បទថា **បុណ្ណូហិ** "ពេញ" សេចក្តីថា ចំណែកនាគរាជបែរមុខឆ្ពោះទៅកាន់ទិសបស្ចិមទៅបានបន្តិច មានភ្នែកពេញទៅដោយទឹកភ្នែក សម្លឹងមើលអាត្មាភាព ។ បទថា **តទស្សាហំ**[១] កាត់បទជា **តទា អស្ស អហំ** សេចក្តីថា គ្រានោះ អាត្មាភាពក៏ទៅតាមក្រោយនាគរាជនោះ ។

បទថា **គច្ឆេវ** "ចូរប្រញាប់ទៅ" សេចក្តីថា អាឡារតាបស

---

បិដក. ១. តទស្សហំ ។

ពោលថា "អាត្មាបានពោលយ៉ាងនេះនឹងស្តេចនាគនោះ" ។ បទថា **រហទំ** "អន្លង់ទឹក" សេចក្តីថា នាគរាជនោះបានទៅកាន់អន្លង់ទឹកកណ្តាលវេណាឈានទី ។ បទថា **សម្មោទតំ**(១) "គ្របដណ្តប់" ន័យថា ដែលទោរទន់ទៅដោយដើមជម្ពូ និងដើមអសោកត្រង់ប្រាំងទាំងពីរ ។ បទថា **និត្តិណ្ណភយោ បតីតោ** "ជាអ្នកផុតភ័យមានបីតិ" សេចក្តីថា បានឮថា នាគរាជនោះមើលអន្លង់ទឹកនោះហើយ បានសម្តែងសេចក្តីគោរពដល់អាឡារកុដុម្ពិកៈ ហើយផុសឡើងមកទាំងកន្ទុយ ។ ស្ថានទីដែលស្តេចនាគមុជទៅក្នុងទឹកនោះឯង ជាទីផុតភ័យ ។ ព្រោះហេតុនោះ នាគរាជនោះទើបបានរួចផុតភ័យ បាននូវសេចក្តីរីករាយ ។

បទថា **បាវិស្ស** "ចូលទៅហើយ" សេចក្តីថា លុះចូលទៅហើយ ។ បទថា **ទិព្វេន មេ** "បរិវារទិព្វ... ដល់អាត្មាភាព" ន័យ

---

បិដក. ១. សមោទតំ ។

ថា មិនបានដល់នូវសេចក្ដីប្រមាទក្នុងនាគពិភព កាលអាត្មាមិនទាន់ទៅដល់ប្រាំងកណ្ណវេណាឈានទី ស្ដេចនាគក៏បានមកប្រាកដចំពោះមុខអាត្មាព្រមទាំងទិព្វបរិវារ ។ បទថា **ឧបដ្ឋហិ**[១] "**ប្រាកដ**" គឺចូលមកជិត ។

បទថា **អព្ភុន្តរោ** "**ជាដួងជីវិត**" សេចក្ដីថា លោកដូចជាបេះ-ដូង លោកមានឧបការៈដល់ខ្ញុំដ៏ច្រើន ខ្ញុំនឹងធ្វើសក្ការៈដល់លោក បទថា **បស្ស មេ និវេសនានិ** "**អញ្ជើញលោកទៅមើលនាគពិភពរបស់ខ្ញុំ**" សេចក្ដីថា អញ្ជើញលោកទៅរីករាយក្នុងនាគពិភពរបស់ខ្ញុំ ។ បទថា **មសក្កសារំ វិយ** "**ដូចទេវនគររបស់ស្ដេចវាសវៈដូច្នោះ**" សេចក្ដីថា រណ្ដៅភ្នំសិនេរុបព៌ត លោកហៅថា សក្កសារៈព្រោះ មានបាតជាថ្មដា ដោយមិនមានការស្រុតចុះបាន នាគរាជសំដៅយកតាវត្តិង្សពិភព ដែលខ្លួនសាងទុកក្នុងនាគពិភពនោះឯង

---

បិដក. ១. ឧបដ្ឋិហី ។

ទើបពោលដូច្នេះ ។

បពិត្រមហារាជ នាគរាជនោះគ្រាពោលយ៉ាងនេះហើយ កាល នឹងពណ៌នានាគពិភពរបស់ខ្លួនឲ្យក្រៃលែងឡើងទៅ ទើបពោល ២ គាថាថា

[៦២៨] តំ ភូមិភាគេហិ ឧបេតរូបំ
អសក្ខរា ចេវ មុទូ សុភា ច
នីចាតិណា អប្បរជា ច ភូមិ
បាសាទិកា យត្ថ ជហន្តិ សោកំ ។

នាគពិភពនោះសម្បូរដោយភូមិភាគ ផែនដីមិនគ្រួស ទន់ ស្រស់ស្អាត មានស្មៅទាបៗ មិនមានធូលី នាំមកនូវសេចក្តី ជ្រះថ្លា រម្ងាប់សេចក្តីសោករបស់អ្នកដែលចូលទៅ ។

អនាវកុលា វេឡុរិយូបនីលា
ចតុទ្ទិសំ អម្ពវនំ សុរម្មំ

បក្កា ច បេសី ច ផលា សុផល្លា

និច្ចោតុកា ធារយន្តិ ផលានិ ។

ក្នុងនាគពិភពនោះ មានស្រះបោក្ខរណីដែលមិនអាក្រក់ មានពណ៌ខៀវដូចកែវពិទូរ្យ មានដើមស្វាយគួរមនោរម្យទាំង ៤ ទិស មានផ្លែទុំពាក់កណ្តាល ខ្ចីពាក់កណ្តាល បញ្ចេញផ្លែជានិច្ច ។

បណ្តាបទទាំងនោះ បទថា អសក្ខរា "មិនមានក្រួស" ន័យថា ភូមិភាគក្នុងនាគពិភពនោះ ប្រាសចាកថ្ម និងក្រួស ភូមិភាគនោះទន់ ល្អស្អាត សុទ្ធតែមាសប្រាក់ និងកែវមណី ដេរដាសទៅដោយខ្សាច់ គឺ រតនៈ ៧ ប្រការ ។ បទថា នីចតិណា[១] "ស្មៅទាបៗ" សេចក្តីថា ប្រកបទៅដោយស្មៅដែលទាប មានពណ៌ដូចពណ៌នៃខ្នងសត្វអណ្តើកមាស ។ បទថា អប្បរជា "មិនមានល្អង

---

បិដក. ១. នីចាតិណា ។

ធូលី" សេចក្តីថា ប្រាសចាកនូវផង់ធូលី ។ បទថា **យត្ថ ជហន្តិ សោកំ "រម្ងាប់សេចក្តីសោក"** សេចក្តីថា មានភូមិភាគដែលចូលទៅដល់វិនាសសេចក្តីសោក ។

បទថា **អនាវកុលា "ដែលមិនអាក្រក់"** ន័យថា មិនអាក្រក់ គឺ មិនមានជង្គត់ ។ ន័យមួយទៀតថា ផ្ទែកខាងលើរាបស្មើ ប្រាស-ចាកភាពរដិបរដុប ។ បទថា **វេឡុរិយូបនីលា "ខៀវស្រស់ដូចជាកែវពិទូរ្យ"** សេចក្តីថា ខៀវខ្ចីដូចកែវពិទូរ្យ ។ អធិប្បាយថា ក្នុងនាគពិភពនោះ មានស្រះបោក្ខរណីសុទ្ធហើយដោយកែវពិទូរ្យ ប-រិបូណ៌ដោយទឹកមានពណ៌ខៀវ ដេរដាសដោយផ្កាឈូក និងឧប្បលពណ៌ផ្សេងៗ ។ បទថា **ចតុទ្ទិសំ "ទាំង ៤ ទិស"** បានដល់ ក្នុងទិសទាំងបួននៃស្រះបោក្ខរណី ។ បទថា **បក្កា ច "ទុំ"** សេចក្តីថា ក្នុងចម្ការអម្ពវ័ននោះ មានដើមស្វាយដែលមានផ្លែទុំហើយខ្លះចាស់ខ្លះ មានផ្លែខ្ចីខ្លះ ផ្លែជាចង្កោមៗ ។ បទថា **និច្ចោតុកា "ចេញ

ផ្លែជានិច្ច" សេចក្តីថា ប្រកបទៅដោយផ្កា និងផ្លែដែលសមគួរដល់
រដូវទាំង ៦ ។

អាឡារតាបសទូលព្រះបាទពារាណសីទៀតថា

[៦២៩] តេសំ វនានំ នរទេវ មជ្ឈេ
និវេសនំ កស្សរសន្និកាសំ
រជតគ្គឡំ សោវណ្ណមយំ ឧឡារំ
ឱភាសតិ វិជ្ជុរិវន្តលិក្ខេ ។

មហាបពិត្រដ៏ប្រសើរជាងនរជន ក្នុងកណ្តាលចម្ការនោះ មាននិវេសន៍គឺផ្ទះសម្រេចហើយដោយមាស មានទ្វារប្រកបដោយប្រាក់ ស្អាតរុងរឿងក្រៃលែង ដូចជាផ្លេកបន្ទោររុងរឿងក្នុងកណ្តាលវេហាដូច្នោះ ។

មណិមយា សោវណ្ណមយា ឧឡារា
អនេកចិត្តា សតតំ សុនិម្មិតា

បរិបូរា កញ្ញាហិ អលង្កតាហិ

សុវណ្ណកាយូរធរាហិ រាជ ។

សូមថ្វាយព្រះពរ ក្នុងកណ្តាលចម្ការនោះ ផ្ទះកំពូល និង បន្ទប់សុទ្ធតែកែវមណី និងដោយមាសយ៉ាងឱឡារវិចិត្រច្រើន អនេកប្បការ និម្មិតដោយល្អជាប់តគ្នា ពេញទៅដោយនាង នាគកញ្ញាទាំងឡាយ ដែលប្រដាប់ហើយនូវបណ្តាញមាស ។

សោ សង្ខបាលោ តរមានរូបោ

បាសាទមារុយ្ហ អនោមវណ្ណោ

សហស្សថម្ភំ អតុលានុភាវំ

យត្ថស្ស ភរិយា មហេសី អហោសិ ។

សង្ខបាលនាគរាជនោះមានពណ៌សម្បុរមិនថោកថយ ឡើង កាន់ប្រាសាទមានសសរប្រមាណមួយពាន់ មានអានុភាពរាប់ មិនបាន ជាទីនៅនៃមហេសីរបស់សង្ខបាលនាគរាជនោះ ។

ឯកា ច នារី តរមានរូបា
អាទាយ វេឡុរិយមយំ មហគ្ឃំ
សុភំ មណឹ ជាតិមន្តូបបន្នំ
អចោទិតា អាសនមព្ភិហាសិ ។

នារីម្នាក់វាសវរវៃមិនចាំបាច់តឿន លើកអាសនៈសម្រេចដោយកែវពិទូរ្យល្អស្អាតមានតម្លៃច្រើន សម្បូរដោយកែវមានជាតិដូចកែវមណីមកក្រាល ។

តតោ មំ ហត្ថេ ឧរគោ គហេត្វា
និសីទយី បាមុខអាសនស្មឹ
ឥទមាសនំ អត្រ ភវំ និសីទតុ
ភវញ្ហិ មេ អញ្ញតរោ គរូនំ វា
អញ្ញា ច នារី តរមានរូបា
អាទាយ វារឹ ឧបសង្កមិត្វា

បាទានិ បក្ខាលយិ មេ ជនិន្ទ

ភរិយាវ ភត្តុ បតិនោ បិយស្ស ។

លំដាប់នោះ នាគរាជដឹកដៃអាត្មាភាពឲ្យអង្គុយលើអាសនៈ ដែលជាធំពោលថា នេះអាសនៈ សូមលោកអង្គុយលើអាសនៈ នេះ ព្រោះថា លោកជាបុគ្គលម្នាក់ជាទីគោរពរបស់ខ្ញុំ ក្នុង ចំណោមអ្នកដែលជាទីគោរពទាំងឡាយ ។

បពិត្រព្រះអង្គទ្រង់កំពូលលើប្រជានិករ នារីម្នាក់ទៀតក៏ រវាសរវៃ ដងទឹកមកលាងជើងរបស់អាត្មាភាព ដូចភរិយា លាងជើងឲ្យស្វាមីជាទីស្រឡាញ់ដូច្នោះ ។

អបរា ច នារី តរមានរូបា

បគ្គយ្ហ សោវណ្ណមយាយ បាតិយា

អនេកសូបំ វិវិធំ វិយញ្ជនំ

ឧបនាមយី ភត្ត មនុញ្ញរូបំ ។

មាននារីម្នាក់ទៀតវាសរវៃ ផ្គងភាជនៈមាស ពេញទៅដោយកត្តាហារគួរបរិភោគ មានសូបៈច្រើនយ៉ាង មានព្យញ្ជនៈផ្សេងៗ នាំមកឲ្យអាត្មាភាព ។

តុរិយេហិ មំ ភារត កុត្តវន្តំ
ឧបដ្ឋហុំ កត្ថុ មនោ វិទិត្វា
តត្ថុត្តរិំ មំ និបតី មហន្តំ
ទិព្វេហិ កាមេហិ អនប្បកេហិ ។

សូមថ្វាយព្រះពរ នារីទាំងនោះជាអ្នកដឹងចិត្តស្វាមីនាំគ្នាទំនុកបម្រុងអាត្មាភាពអ្នកបរិភោគហើយ ដោយតន្ត្រីទាំងឡាយ នាគរាជនោះក៏ចូលមករកអាត្មាភាព ព្រមដោយកាមគុណដែលជាទិព្វមិនមែនតិច ធំក្រៃលែងជាងរបាំនោះ ។

បណ្ដាបទទាំងនោះ បទថា និវេសនំ “និវេសន៍” បានដល់បាសាទ ។ បទថា ភស្សរសន្និកាសំ “រស្មីភ្លឺផ្លេក” គឺ មើលទៅ

ក្ដីផ្ទេក ។ បទថា វេឡុរិយគ្គឡំ “ទ្វារសម្រេចដោយប្រាក់” សេចក្ដីថា មានទ្វារបង្អួចជាប្រាក់ ។

បទថា មណិមយា “សម្រេចហើយដោយកែវមណី” សេចក្ដីថា ផ្ទះកំពូល និងបន្ទប់មានសភាពបែបនេះក្នុងប្រាសាទនោះ ។ បទថា បរិបូរា “ពេញ” បានដល់ បរិបូណ៌ ។

បទថា សោ សង្ខបាលោ “សង្ខបាលនាគរាជនោះ” ន័យថា អាឡារតាបសបញ្ជាក់ថា មហារាជ កាលនាគរាជនោះសរសើរនាគពិភពហើយយ៉ាងនេះ អាត្មាភាពប្រាថ្នានឹងមើលពិភពនាគនោះលំដាប់នោះ សង្ខបាលនាគរាជទើបនាំអាត្មាភាពទៅកាន់ទីនោះ ចាប់ដៃជាប្រញាប់ឡើងកាន់ប្រាសាទមានសសរមួយពាន់សុទ្ធតែសសរកែវពិទូរ្យ នាំទៅកាន់ស្ថានទីដែលមហេសីរបស់ស្ដេចនាគនៅ ។

បទថា ឯកា ច “នារីម្នាក់” សេចក្ដីថា កាលអាត្មាភាពឡើងកាន់ប្រាសាទហើយ ស្ត្រីម្នាក់នាំអាសនៈកែវពិទូរ្យដ៏ស្អាតចូលដល់

ជាតិកែវមណីសូម្បីដទៃៗ មកក្រោល ដោយនាគរាជនោះមិនបាន ប្រាប់ឡើយ ។ បទថា **អត្ថិហាសិ** “លើក” បានដល់ នាំមក អ-ធិប្បាយថា ក្រោលហើយ ។

បទថា **បមុខអាសនស្មឹ**[១] “**លើអាសនៈដែលជាធំ**” បានដល់ លើអាសនៈដែលជាប្រមុខ ។ អធិប្បាយថា អញ្ជើញឲ្យអង្គុយលើ អាសនៈដ៏ខ្ពង់ខ្ពស់ ។ បទថា **គរូនំ** “**គោរព**” សេចក្តីថា នាគរាជ នោះ ពោលអញ្ជើញឲ្យអង្គុយយ៉ាងនេះថា លោកដូចជាមាតាបិតា របស់យើងម្នាក់ ។

បទថា **វិវិធំ វិយញ្ជនំ** “**មានព្យញ្ជនៈផ្សេងៗ**” បានដល់ ជាមួយបាយមានប្រការផ្សេងៗ ។ បទថា **កត្តមនុញ្ញរូបំ** “**កត្តា-ហារគួរបរិភោគ**” បានដល់ កត្តាហារដែលគួរបរិភោគ អាឡារតាបស ហៅព្រះរាជាថា “ភារតៈ” ។ បទថា **កុត្តវន្តំ** “**អ្នកបរិភោគហើយ**”

---

បិដក. ១. បាមុខអាសនស្មឹ ។

បានដល់ បរិភោគស្រេចហើយ ។ បទថា **ឧបដ្ឋហុំ** “ទំនុកបម្រុង” សេចក្ដីថា នារីទាំងឡាយធ្វើការរាំច្រៀង ទំនុកបម្រុងអាត្មាភាព ដែលបរិភោគស្រេចហើយ ដោយតន្ត្រីយសេស ។ បទថា **ភត្តុ មនោ វិទិត្វា** “ដឹងចិត្តស្វាមី” សេចក្ដីថា នារីទាំងឡាយដែលដឹងចិត្តកស្ដារបស់ខ្លួន ។ បទថា **តតុត្តរី** “ជាក្រៃលែង” សេចក្ដីថា ក្រៃលែងជាងរបាំនោះ ។ បទថា **មំ និបតិ**[១] “ចូលមករកអាត្មា” សេចក្ដីថា នាគរាជនោះ ចូលមករកអាត្មាភាព ។ បទថា **មហន្តំ ទិព្វេហិ** “ជាទិព្វមិនមែនតិច” សេចក្ដីថា ដោយកាមដែលជាទិព្វដ៏មហោឡារ ។ បទថា **កាមេហិ** “កាមគុណ” សេចក្ដីថា ដោយកាមដែលជាទិព្វទាំងនោះមិនមែនតិច គឺ មិនមែនតិចតួច ។

ក៏គ្រានាគរាជនោះចូលមករកហើយ ក៏ពោលគាថាថា

[៦៣០] **ភរិយា មមេតា តិសតា អឡារ**

---

បិដក. ១. មំ និបតី ។

សព្វត្តមង្គា   បទុមុត្តរាភា

អឡារ ឯតាសុ តេ កាមការា

ទទាមិ តេ តា បរិចារយស្សុ ។

បពិត្រអាឡារៈ ភរិយារបស់ខ្ញុំទាំង ៣០០ នេះ សុទ្ធតែមានចង្កេះរាងរៀវ មានរស្មីរុងរឿងដូចត្របកបទុម នាងទាំងនេះនឹងជាអ្នកបម្រើលោក ខ្ញុំសូមលើកនាងទាំងនេះឲ្យលោក លោកចូរឲ្យនាងទាំងនេះបម្រើចុះ ។

បណ្ដាបទទាំងនោះ បទថា សព្វត្តមង្គា "សុទ្ធតែមានចង្កេះរៀវ" សេចក្ដីថា ភរិយារបស់ខ្ញុំទាំងអស់សុទ្ធតែមានចង្កេះរៀវតូច អធិប្បាយថា ចង្កេះមូលក្លំ វាស់បានដោយបាតដៃ តែបាលីក្នុងអដ្ឋកថាថា "សុមង្គា" ។ បទថា បទុមុត្តរាភា[១] "មានរស្មីរុងរឿងដូចត្របកបទុម" បានដល់ មានសម្បុរផ្ទូរផង់ដូចពណ៌នៃផ្កាបទុម ។

បិដក. ១. បទុមុត្តរាភា ។

អធិប្បាយថា មានឆវីវណ្ណដូចត្របកបទុម ។ បទថា **បរិចារយស្សុ** "បម្រើ" សេចក្តីថា នាគរាជនោះពោលថា "លោកចូរធ្វើនាងទាំងនោះឲ្យជាបាទបរិចារិការបស់ខ្លួន" ហើយប្រគល់មហាសម្បត្តិព្រមទាំងស្ត្រី ៣០០ ជាបាទបរិចារិកាដល់អាត្មាភាព ។

អាឡារតាបសនោះទូលតទៅទៀតថា

[៦៣១] សំវច្ឆរំ ទិព្វរសានុភុត្វា

តទាស្សុហំ ឧត្តរិ បច្ចភាសឹ

នាគស្សិទំ កិន្តិ កថញ្ច លទ្ធំ

កថជ្ឈគមាសិ វិមានសេដ្ឋំ ។

អាត្មាភាពបានសោយរសដែលជាទិព្វអស់មួយឆ្នាំ គ្រានោះអាត្មាភាពបានសួរដល់សម្បត្តិដ៏ក្រៃលែងថា ម្នាលស្តេចនាគ លោកបានសម្បត្តិដូច្នេះដោយឧបាយដូចម្តេច បាននូវវិមានដ៏ប្រសើរដូចម្តេច ។

អធិច្ច លទ្ធំ បរិណាមជន្តេ
សយំ កតំ ឧទាហុ ទេវេហិ ទិន្នំ
បុច្ឆាមិ តំ នាគរាជេតមត្ថំ
កថជ្ឈគមាសិ វិមានសេដ្ឋំ ។

បានដោយមិនមានហេតុ ឬកើតព្រោះនរណាបង្អោនមកឲ្យដល់លោក លោកធ្វើខ្លួនឯង ឬថាទេវតាឲ្យ ម្នាលស្តេចនាគ ខ្ញុំសូមសួរសេចក្តីនោះនឹងលោក លោកបានវិមានដ៏ប្រសើរដូចម្តេច ។

បណ្តាបទទាំងនោះ បទថា ទិព្វរសានុភុត្វា "បានសោយនូវរសដែលជាទិព្វ" សេចក្តីថា អាត្មាភាពសោយនូវរសនៃកាមគុណដែលជាទិព្វហើយ ។ បទថា តទាស្សុហំ កាត់បទជា តទា អស្សុ អហំ ។ បទថា នាគស្សិទំ "ម្នាលស្តេចនាគ... នេះ" សេចក្តីថា ខ្ញុំបានសួរនាគរាជនោះដូច្នេះថា "សម្បត្តិដែលកើតហើយនេះរបស់

លោកអ្នកមានវង្សត្រកូលដ៏ចម្រើន លោកធ្វើកម្មអ្វីទើបបាន លោកបានគ្រប់គ្រងវិមានដ៏ប្រសើរនេះដូចម្ដេចហ្ន៎" ។

បទថា **អធិច្ច លទ្ធំ** "បានដោយមិនមានហេតុ" សេចក្ដីថា លោកបានដោយរកហេតុមិនបាន ។ បទថា **បរិណាមជន្តេ** "កើតព្រោះនរណាបង្អោនឲ្យ" សេចក្ដីថា ឬឈ្មោះថា កើតហើយដោយការបង្អោនមក ព្រោះជារបស់ដែលនរណាៗ បង្អោនមកដើម្បីប្រយោជន៍ដល់លោក ។ បទថា **សយំ កតំ** "ធ្វើខ្លួនឯង" សេចក្ដីថា បន្ទាប់ឲ្យហៅជាងមកហើយប្រគល់រតនៈឲ្យធ្វើ ។

លំដាប់តទៅជាគាថាពោលសួរឆ្លើយរវាងជនទាំងពីរ គប្បីជ្រាបដូចតទៅនេះ ។

[៦៣២] នាធិច្ច លទ្ធំ ន បរិណាមជំ មេ
ន សយំ កតំ នាបិ ទេវេហិ ទិន្នំ
សកេហិ កម្មេហិ អបាបកេហិ

បុញ្ញេហិ មេ លទ្ធមិទំ វិមានំ ។

សង្ខបាលនាគរាជតបថា

ខ្ញុំបានវិមាននេះ មិនមែនមិនមានហេតុទេ និងមិនមែនកើតព្រោះនរណាបង្គោនឲ្យខ្ញុំ ខ្ញុំមិនបានធ្វើខ្លួនឯង សូម្បីទេវតាក៏មិនបានឲ្យ ខ្ញុំបានវិមាននេះដោយបុញ្ញកម្មដែលមិនមែនជាបាបរបស់ខ្លួន ។

អាត្មាភាពសួរថា

[៦៣៣] កិន្តេ វតំ កី បន ព្រហ្មចរិយំ

កិស្ស សុចិណ្ណស្ស អយំ វិបាកោ

អក្ខាហិ មេ នាគរាជេតមត្ថំ

កថំ នុ តេ លទ្ធមិទំ វិមានំ ។

វត្តរបស់លោកដូចម្តេច និងព្រហ្មចរិយៈរបស់លោកដូចម្តេច នេះជាវិបាកនៃកម្មអ្វីដែលលោកប្រព្រឹត្តល្អហើយ ម្នាល

ស្តេចនាគ សូមលោកចូរប្រាប់សេចក្តីនេះដល់ខ្ញុំ លោកបានវិមាននេះមកដូចម្តេចហ្ន៎ ។

នាគរាជតបថា

[៦៣៤] រាជា អហោសឹ មគធានមិស្សរោ
ទុយ្យោធនោ នាម មហានុភាវោ
សោ ឥត្តរំ ជីវិតំ សំវិទិត្វា
អសស្សតំ វិបរិណាមធម្មំ ។

ខ្ញុំបានជាព្រះរាជាដែលធំជាងជនដែនមគធៈ មាននាមថា ទុយ្យោធនៈ មានអានុភាពច្រើន បានឃើញច្បាស់ថា ជីវិតជារបស់តិចតួច មិនទៀង មានការប្រែប្រួលទៅជាធម្មតា ។

អន្នញ្ច បានញ្ច បសន្នចិត្តោ
សក្កច្ច ទានំ វិបុលំ អទាសឹ
ឱបានភូតំ មេ ឃរំ តទាសិ

សន្តប្បិតា សមណព្រាហ្មណា ច ។

ទើបជាអ្នកមានចិត្តជ្រះថ្លា បានឲ្យបាយ និងទឹកជាទានដ៏ធំដោយគោរព វាំងរបស់ខ្ញុំក្នុងគ្រានោះ ដូចជាអណ្តូងទឹក សមណព្រាហ្មណ៍ទាំងឡាយក៏ឆ្អែតស្កប់ស្កល់ក្នុងទីនោះ ។

មាលញ្ច គន្ធញ្ច វិលេបនញ្ច

បទីបយំ យានមុបស្សយញ្ច

អច្ឆាទនំ សេយ្យមថន្នបានំ

សក្កច្ច ទានានិ អទម្ហ តត្ថ ។

ខ្ញុំបានឲ្យផ្កាឈើ គ្រឿងក្រអូប គ្រឿងលាប ប្រទីប យានទីស្នាក់ សំពត់ស្លៀកដណ្តប់ ទីដេក និងបាយទឹក ជាទានដោយគោរពក្នុងទីនោះ ។

តំ មេ វតំ តំ បន ព្រហ្មចរិយំ

តស្ស សុចិណ្ណស្ស អយំ វិបាកោ

តេនេវ មេ លទ្ធមិទំ វិមានំ

បហូតភក្ខំ ពហុអន្នបានំ ។

នោះជាវត្ត និងជាព្រហ្មចរិយៈរបស់ខ្ញុំ នេះជាវិបាកនៃកម្ម នោះ ដែលខ្ញុំប្រព្រឹត្តល្អហើយ ខ្ញុំបានវិមានដែលមានភក្សាហារបរិបូណ៌ មានបាយទឹកច្រើន ព្រោះវត្ត និងព្រហ្មចរិយៈនោះឯង ។

[៦៣៥] នច្ចហិ គីតេហិ ចុបេតរូបំ

ចិរដ្ឋិតិកំ ន ច សស្សតាយំ

អប្បានុភាវា តំ មហានុភាវំ

តេជស្សិនំ ហន្តិ អតេជវន្តោ

កិមេវ ទាឋាវុធ កឹ បដិច្ច

ហត្ថត្ថមាគច្ឆិ វនិព្វកានំ ។

ភយំ នុ តេ អន្វគតំ មហន្តំ

តេជោ នុ តេ នាន្វគតំ ទន្តមូលំ
កិមេវ ទាឋាវុធ កឹ បដិច្ច
កិលេសមាបជ្ជិ វនិព្វកានំ ។

វិមាននេះបរិបូណ៌ដោយរបាំរាំច្រៀងតាំងនៅអស់កាលយូរ តែជារបស់មិនទៀង អាត្មាភាពទើបសួរថា បុត្តនាយព្រានទាំងឡាយដែលមានអានុភាពតិច មិនមានតេជះ ហេតុអ្វីទើបបៀតបៀនលោកដែលមានអានុភាពច្រើន មានតេជះច្រើន លោកមានចង្កូមជាអាវុធ ព្រោះអាស្រ័យអ្វីឬ លោកទើបដល់នូវសេចក្តីសៅហ្មងក្នុងសម្នាក់របស់បុត្តព្រានទាំងឡាយ សេចក្តីភ័យធំតាមដល់លោក ឬថា ពិសរបស់លោកមិនស៊ុះទៅកាន់គល់ចង្កូម លោកអ្នកមានចង្កូមជាអាវុធ ព្រោះអាស្រ័យអ្វីឬ លោកទើបដល់នូវសេចក្តីសោក ក្នុងសម្នាក់របស់បុត្តនាយព្រានទាំងឡាយ ។

សង្ខបាលនាគរាជតបថា

[៦៣៦] ន មេ ភយំ អន្វគតំ មហន្តំ
តេជោ ន សក្កា មម តេភិ ហន្តុំ
សតញ្ច ធម្មានិ សុកិត្តិតានិ
សមុទ្ទវេលាវ ទុរច្ចយានិ ។

មហន្តភ័យមិនបានតាមដល់ខ្ញុំឡើយ ជនពួកនោះមិនអាចទម្លាយតេជះរបស់ខ្ញុំបាន តែថា ធម៌របស់សប្បុរសទាំងឡាយលោកប្រកាសទុកល្អហើយ លំបាកនឹងកន្លងបាន ដូចដែននៃសមុទ្ទដូច្នោះ ។

ចាតុទ្ទសឹ បញ្ចទសឹ អឡារ
ឧបោសថំ និច្ចមុបាវសាមិ
អថាគមុំ សោឡស ភោជបុត្តា
រជ្ជុំ គហេត្វាន ទឡ្ហញ្ច បាសំ ។

បពិត្រអាឡារៈ ខ្ញុំបានចូលទៅចាំឧបោសថក្នុងថ្ងៃចាតុទ្ទសី បណ្ណរសីជានិច្ច តមកពួកបុត្តនាយព្រាន ១៦ នាក់ជាមនុស្ស អាក្រក់ កាន់យកខ្សែ និងអន្ទាក់ដ៏មាំមក ។

ភេត្វាន នាសំ អតិកស្ស រជ្ជុំ
នយឹសុ មំ សម្បរិគយ្ហ លុទ្ទា
ឯតាទិសំ ទុក្ខមហំ តិតិក្ខំ
ឧបោសថំ អប្បដិកោបយន្តោ ។

ព្រានទាំងនោះនាំគ្នាចាក់ច្រមុះ យកខ្សែដោត ហើយសែង ខ្ញុំទៅ ខ្ញុំអត់ទ្រាំដល់សេចក្តីទុក្ខនោះ មិនធ្វើឧបោសថឲ្យកម្រើក ឡើយ ។

អាត្មាភាពសួរថា

[៦៣៧] ឯកាយនេ តំ បថេ អទ្ទសំសុ
ពលេន វណ្ណេន ចុបេតរូបំ

*សិរិយា បញ្ញាយ ច ភាវិតោសិ*

*កិមត្ថិយំ[១] នាគ តបោ ករោសិ ។*

បុត្តនាយព្រានទាំងនោះ បានជួបលោកដែលសម្បូរដោយកម្លាំង និងពណ៌សម្បុរ ត្រង់ផ្លូវមនុស្សដើរតែម្នាក់ ម្នាលនាគរាជ លោកជាអ្នកចម្រើនដោយសិរី និងបញ្ញា នឹងបំពេញតបៈដើម្បីប្រយោជន៍អ្វីទៀតហ្ន៎ ។

សង្ខបាលនាគរាជតបថា

[៦៣៨] *ន បុត្តហេតុ ន ធនស្ស ហេតុ*

*ន អាយុនោ ចាបិ អឡារ ហេតុ*

*មនុស្សយោនឹ អភិបត្ថយានោ*

*តស្មា បរក្កម្ម តបោ ករោមិ ។*

បពិត្រអាឡារៈ ខ្ញុំបំពេញតបៈមិនមែនព្រោះហេតុនៃបុត្ត

---

១. ម. កឹ បត្ថយំ ។

មិនមែនព្រោះហេតុនៃទ្រព្យ និងមិនមែនព្រោះហេតុនៃអាយុ ខ្ញុំប្រាថ្នាកំណើតមនុស្ស ព្រោះដូច្នោះ ទើបព្យាយាមបំពេញតបៈ ។

អាត្មាភាពសួរថា

[៦៣៩] ត្វំ លោហិតក្ខោ វិហតន្តរំសោ
អលង្កតោ កប្បិតកេសមស្សុ
សុរោសិតោ លោហិតចន្ទនេន
គន្ធព្វរាជាវ ទិសា បភាសសិ ។

លោកជាអ្នកមានភ្នែកក្រហម មានស្មើរុងរឿង ប្រដាប់តាក់តែងហើយ កោរសក់ និងពុកមាត់ លាបដោយលម្អិតចន្ទន៍ក្រហម ស្វាងស្វែទៅគ្រប់ទិសដូចគន្ធព្វរាជាដូច្នោះ ។

ទេវិទ្ធិបត្តោសិ មហានុភាវោ
សព្វេហិ កាមេហិ សមង្គិភូតោ

បុច្ឆាមិ តំ នាគរាជេតមត្ថំ

សេយ្យោ ឥតោ កេន មនុស្សលោកោ ។

លោកជាអ្នកដល់ហើយនូវទេវឫទ្ធិ មានអានុភាពច្រើន សម្បូរទៅដោយកាមារម្មណ៍ទាំងពួង ម្នាលស្តេចនាគ ខ្ញុំសូមសួរសេចក្តីនេះនឹងលោក ហេតុអ្វីមនុស្សលោកទើបប្រសើរជាងពិភពនាគនេះ ។

សង្ខបាលនាគរាជតបថា

[៦៤០] អទ្ធា រ នាញ្ញត្រ មនុស្សលោកា

សុទ្ធី វ សំវិជ្ជតិ សំយមោ វា

អហញ្ច លទ្ធាន មនុស្សយោនឹ

កាហាមិ ជាតិមរណស្ស អន្តំ ។

បពិត្រអាឡារៈ ក្រៅអំពីមនុស្សលោក សេចក្តីបរិសុទ្ធ ឬសេចក្តីសង្រួមរមែងមិនមាន បើខ្ញុំបាននូវកំណើតមនុស្ស

ហើយ នឹងធ្វើទីបំផុតនៃជាតិ និងមរណៈ ។

អាត្មាភាពពោលថា

[៦៤១] សំវច្ឆរោ មេ វសតោ តវន្តិកេ

អន្នេន បានេន ឧបដ្ឋិតោស្មិ

អាមន្តយិត្វាន បលេមិ នាគ

ចិរប្បវុដ្ឋោស្មិ អហំ ជនិន្ទ ។

ខ្ញុំនៅក្នុងសម្នាក់របស់លោកមួយឆ្នាំហើយ ជាអ្នកដែលលោកទំនុកបម្រុងដោយបាយ និងទឹក ខ្ញុំសូមលាលោកសិនហើយ បពិត្រលោកជាកំពូលនៃនាគ ខ្ញុំចេញចាកមនុស្ស-លោកមកយូរហើយ ។

សន្ធបាលនាគរាជតបថា

[៦៤២] បុត្តា ច ទារា អនុជីវិនោ ច

និច្ចានុសិដ្ឋា ឧបតិដ្ឋតេ តំ

កច្ចិនុ តេ នាភិសំសិត្ថ កោចិ

បិយញ្ហិ មេ ទស្សនំ តុយ្ហ អឡារ ។

បពិត្រអាឡារៈ បុត្ត ភរិយា និងបរិវារជន ខ្ញុំទូន្នានជា-និច្ចឲ្យទំនុកបម្រុងលោក នរណាមិនបានជេរប្រទេចលោកទេឬ ព្រោះថា ការដែលបានជួបលោកក៏រាប់ថា ជាទីពេញចិត្តពេញចិត្តរបស់ខ្ញុំ ។

អាត្មាភាពឆ្លើយថា

[៦៨៣] យថាបិ មាតុ ច បិតុ អគារេ

បុត្តោ បិយោ បដិវិហិតោ វសេយ្យ

តតោបិ មយ្ហំ ឥធមេវ សេយ្យោ

ចិត្តញ្ហិ តេ នាគ មយិ បសន្នំ ។

បពិត្រស្តេចនាគ បុត្តជាទីស្រឡាញ់បដិបត្តិទំនុកបម្រុងមាតាបិតាក្នុងផ្ទះ ជាអ្នកប្រសើរសូម្បីដោយប្រការណា លោក

ទំនុកបម្រុងខ្ញុំនៅក្នុងទីនេះ ជាអ្នកប្រសើរជាងការប្រការនោះ ព្រោះថា ចិត្តរបស់លោកជ្រះថ្លានឹងខ្ញុំ ។

សង្ខបាលនាគរាជពោលថា

[៦៤៤] មណិ មមំ វិជ្ជតិ លោហិតង្គោ
ធនាហរោ មណិរតនំ ឧឡារំ
អាទាយ ត្វំ គច្ឆ សកំ និកេតំ
លទ្ធា ធនន្តំ មណិមោស្សជស្សុ ។

កែវមណីមានពណ៌ក្រហម ដែលនឹងនាំទ្រព្យមកបានតាមបំណងរបស់ខ្ញុំមានហើយ លោកចូរកាន់យកមណីរតន៍ដែលឧឡារនោះទៅកាន់ទីនៅរបស់ខ្លួនចុះ បានទ្រព្យហើយចូររក្សាកែវមណីនោះទុក ។

បណ្តាបទទាំងនោះ បទថា កិន្តេ វតំ "វត្តរបស់លោកដូចម្តេច" សេចក្តីថា អាត្មាភាពសួរថា "អ្វីជាវត្តសមាទានរបស់លោក

ហ្ន៎” ។ បទថា ព្រហ្មចរិយំ “ព្រហ្មចរិយៈ” សេចក្ដីថា អ្វីជាចរិយា ដ៏ប្រសើររបស់លោក ។

បទថា ឱបានភូតំ “ដូចជាអណ្ដូងទឹក” សេចក្ដីថា (នាគរាជតបថា) គ្រានោះផ្ទះរបស់ខ្ញុំដូចជាស្រះបោក្ខរណី ដែលជីកទុកក្នុងផ្លូវធំបែកជា ៤ មានសម្បត្តិដែលសមណព្រាហ្មណ៍អ្នកតាំងនៅក្នុងធម៌ គប្បីបរិភោគបានតាមសប្បាយ ។

បទថា ន ច សស្សតាយំ “តែជារបស់មិនទៀង” សេចក្ដីថា នាគរាជនោះពោលនឹងអាត្មាភាពថា “ការពិត វិមាននេះសូម្បីជារបស់តាំងនៅបានយូរ ក៏មិនមែនជារបស់ទៀងសម្រាប់ខ្ញុំដែរ” ។ អាឡារតាបសពោលសំដៅដល់បុត្តនាយព្រានព្រៃថា អ្នកមានអានុភាពតិច ។ បទថា ហន្តិ “បៀតបៀន” សេចក្ដីថា (អាឡារកុដុម្ពិកៈសួរថា) ព្រោះហេតុអ្វី បុត្តព្រានព្រៃទើបយកលំពែងចាក់លោកក្នុងទីទាំង ៨ កន្លែង ។ បទថា កឹ បដិច្ច “ព្រោះអាស្រ័យ

*អ្វី*" សេចក្តីថា លោករមែងមកកាន់កណ្តាប់ដៃ គឺ ចូលដល់អំណាចរបស់ពួកវណិពកៈក្នុងគ្រានោះ ព្រោះបំណងអ្វី ។ បទថា **វណិព្វកានំ** "*របស់បុត្រនាយព្រានទាំងឡាយ*" សេចក្តីថា បុត្រព្រានព្រៃទាំងឡាយ លោកហៅថា វណិព្វកៈក្នុងទីនេះ ។

បទថា **តេជោ នុ តេ អន្វគតំ**[១] **ទន្តមូលំ** "*ឬថា ពិសរបស់លោកមិនស្ទុះទៅកាន់គល់នៃចង្កូម*" សេចក្តីថា តេជៈរបស់លោកដូចម្តេច ព្រោះឃើញពួកបុត្តព្រានព្រៃក្នុងគ្រានោះ ភ័យធំក៏ទៅតាមលោក ឬថា ពិសដែលមានក្នុងចង្កូមជាមូលមិនទៅតាមលោក ។ បទថា **កិលេសំ**[២] "*សេចក្តីសៅហ្មង*" បានដល់ ទុក្ខ ។ បទថា **វណិព្វកានំ** "*របស់បុត្តនាយព្រានទាំងឡាយ*" សេចក្តីថា ព្រោះអាស្រ័យអ្វី លោកទើបដល់នូវសេចក្តីទុក្ខក្នុងសម្នាក់របស់បុត្តនាយព្រានទាំងឡាយ គឺ ព្រោះអាស្រ័យពួកបុត្តនាយព្រាន ។

---

បិដក. ១. នាន្វាគតំ ទន្តមូលំ ។ ២. កិលេសមាបជ្ជិ ។

បទថា **តេជោ ន សក្កា មម តេភិ ហន្តុំ** “ជនពួកនោះមិនអាចទម្លាយតេជះរបស់ខ្ញុំបាន” សេចក្ដីថា នាគរាជតបថា “តេជះ គឺ ពិសរបស់យើងមិនអាចបៀតបៀនដោយតេជះរបស់អ្នកដទៃ គឺ ជនពួកដទៃបានទេ” ។ បទថា **សតំ** “**របស់សប្បុរសទាំងឡាយ**” បានដល់ សប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម ។ បទថា **ធម្មានិ** “**ធម៌**” បានដល់ ធម៌ ពោលគឺ សីល សមាធិ បញ្ញា ខន្តិ ករុណា និងមេត្តាភាវនា ។ បទថា **សុកិត្តិតានិ** “**លោកប្រកាសទុកល្អហើយ**” សេចក្ដីថា លោកពណ៌នាទុកល្អហើយ គឺ ពោលទុកល្អហើយ ។ បទថា **កឹ** “**អ្វី**” សេចក្ដីថា លោកធ្វើយ៉ាងណា? ។

បទថា **សមុទ្ទវេលាវ ទុរច្ចយានិ** “**ប្រាជ្ញានឹងកន្លងបាន ដូចដែននៃសមុទ្រដូច្នោះ**” សេចក្ដីថា សង្ខបាលនាគរាជពោលថា “សប្បុរសទាំងនោះពណ៌នាទុកថា បុគ្គលកន្លងបានលំបាកសូម្បីដើម្បីជីវិត ដូចជាត្រើយមហាសមុទ្រដែលកន្លងបានលំបាកដូច្នោះ ព្រោះ

ហេតុនោះ ខ្ញុំទើបជាអ្នកប្រកបដោយខន្តិ និងមេត្តា ព្រោះខ្លាចដាច់សីល កាលខ្ញុំក្រោធ ក៏មិនបានឲ្យកន្ទងនូវខេត្តនៃសីល" ។ ដោយធម្មទេសនារបស់សង្ខបាលនាគរាជនេះ រមែងបាននូវបារមីគ្រប់ទាំង ១០ គឺ

១. ការដែលព្រះមហាសត្វលះបង់សរីរៈក្នុងគ្រានោះ ចាត់ជាទានបារមី ។

២. ការដែលមិនទម្លាយសីលដោយតេជះ គឺ ពិសបែបនោះ ចាត់ជាសីលបារមី ។

៣. ការចេញចាកនាគពិភពបំពេញសមណធម៌ ចាត់ជានេក្ខម្មបារមី ។

៤. ការចាត់ចែងថា គួរធ្វើវត្ថុនេះៗ ចាត់ជាបញ្ញាបារមី ។

៥. សេចក្តីព្យាយាមដោយអំណាចនៃការអត់ធន់ ចាត់ជាវីរិយបារមី ។

៦. សេចក្តីអត់ធន់ដោយអំណាចនៃសេចក្តីអត់ធន់ ចាត់ជាខន្តិបារមី ។

៧. ការសមាទានសច្ចៈ ចាត់ជាសច្ចបារមី ។

៨. ការអធិដ្ឋានក្នុងចិត្តថា យើងនឹងមិនទម្លាយសីលរបស់យើង ចាត់ជាអធិដ្ឋានបារមី ។

៩. ភាពជាអ្នកមានការអាណិតអាសូរ ចាត់ជាមេត្តាបារមី ។

១០. ភាពជាអ្នកដាក់ខ្លួនជាកណ្តាលក្នុងវេទនា ចាត់ជាឧបេក្ខាបារមី ។

បទថា **អថាគមុំ** "**តមក... មក**" សេចក្តីថា ម្នាលអាឡារៈ ថ្ងៃមួយ បុត្តព្រានព្រៃ ១៦ នាក់ ឃើញខ្ញុំដេកនៅលើដំបូក ក៏នាំគ្នាកាន់ខ្សែដ៏រឹង អន្ទាក់ដ៏មាំ និងលំពែង មកកាន់សម្នាក់របស់ខ្ញុំ ។

បទថា **ភេត្វាន** "**ចាក់**" សេចក្តីថា គេទាំងនោះចាក់សរីរៈរបស់ខ្ញុំក្នុងទីទាំងប្រាំបី ហើយស៊កផ្តៅដែលមានបន្លាចូលទៅ ។

បទថា **នាសំ អតិកស្ស រជ្ជុំ** “យកខ្សែដោតច្រមុះ” សេចក្តីថា ដើរទៅបានបន្តិចឃើញសីសៈរបស់ខ្ញុំធ្លាក់ចុះ ទើបបានឲ្យដេកត្រង់ផ្លូវធំ ហើយចាក់ច្រមុះខ្ញុំទៀត ដោយខ្សែចងព្យួរត្រង់ចុងឈើស្នែង ហើយសែងនាំខ្ញុំទៅ ។

បទថា **អទ្ទសំសុ** “បានជួប” សេចក្តីថា អាត្មាភាពនិយាយថា “សន្ធបាលៈសម្លាញ់ បុត្តនាយព្រានទាំងនោះ ឃើញលោកសម្បូរដោយកម្លាំង និងពណ៌សម្បុរក្នុងចន្លោះផ្លូវដែលដើរទៅមកតែម្នាក់ឯងបាន តែលោកចម្រើនដោយសិរី គឺ ឥស្សរិយយស និងសភាពស្អាតល្អ និងចម្រើនដោយបញ្ញា លោកជាអ្នក (រុងរឿង) បែបនេះ បំពេញតបៈដើម្បីអ្វី លោកប្រាថ្នាអ្វីទើបចាំឧបោសថ គឺរក្សាសីល” ។ បាឋៈថា **អទ្ទសាសិំ** ប្រែថា ខ្ញុំបានឃើញហើយដូច្នេះក៏មាន ។ អធិប្បាយថា ខ្ញុំបានឃើញលោកក្នុងផ្លូវធំដែលទៅមកបាននៃមនុស្សច្រើន ។

បទថា **អភិបត្ថយមានោ**[១] "ប្រាថ្នា" បានដល់ បានប្រាថ្នាហើយ ។ បទថា **តស្មា** "ព្រោះដូច្នោះ" សេចក្តីថា នាគរាជតបថា ខ្ញុំប្រាថ្នាកំណើតមនុស្ស ព្រោះដូច្នោះទើបប្រឹងប្រែងធ្វើតបកម្មដោយសេចក្តីព្យាយាម ។

បទថា **សុភាសិតោ** "ដ៏ល្អមទា" សេចក្តីថា លោកជាអ្នកលាបលនហើយដោយល្អ ។ បទថា **ឥតោ** "នេះ" ន័យថា មនុស្សលោកនឹងមានអ្វីក្រៃលែងជាងនាគពិភពនេះ ។

បទថា **សុទ្ធិ**[២] "សេចក្តីបរិសុទ្ធ" បានដល់ វិសុទ្ធិ ពោលគឺមគ្គផល និងព្រះនិព្វាន ។ បទថា **សំយមោ** "សេចក្តីសង្រួម" បានដល់ សីល ។ ស្តេចនាគរាជនោះ សំដៅយកការកើតឡើងនៃព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធទាំងឡាយក្នុងមនុស្សលោកប៉ុណ្ណោះ ទើបពោលពាក្យនេះ ។

---

បិដក. ១. អភិបត្ថយានោ ។ ២. សុទ្ធី ។

បទថា **កាហាមិ** "**នឹងធ្វើ**" សេចក្តីថា ស្តេចនាគពោលតទៅថា "កាលខ្ញុំធ្វើនូវសេចក្តីមិនមាននៃបដិសន្ធិរបស់ខ្លួន នឹងធ្វើនៅទីបំផុតនៃជាតិ ជរា និងមរណៈបាន មហារាជ សន្ធបាលនាគរាជនោះសរសើរមនុស្សលោកយ៉ាងនេះ" ។

បទថា **សំវច្ឆរោ មេ** "**ខ្ញុំ... មួយឆ្នាំ**" សេចក្តីថា សូមថ្វាយព្រះពរ កាលនាគរាជនោះសរសើរមនុស្សលោកយ៉ាងនេះ អាត្មាធ្វើសេចក្តីពេញចិត្តក្នុងបព្វជ្ជាទើបពោលពាក្យនេះ ។

បណ្តាបទទាំងនោះ បទថា **ឧបដ្ឋិតោស្មិ** "**ជាអ្នកដែលលោកទំនុកបម្រុង**" សេចក្តីថា ខ្ញុំជាអ្នកដែលលោកប្រណិប័តន៍ ឬក្រោកទទួលហើយដោយបាយ និងទឹក និងកាមគុណដែលជាទិព្វ ។ បទថា **បលេមិ** "**សូមលា**" សេចក្តីថា នៅរលឹកដល់ ។ (តែ) នឹងត្រូវចាកចេញទៅ ។ បទថា **ចិរប្បវុដ្ឋោស្មិ** "**ចាកមនុស្សលោកមកយូរ**" សេចក្តីថា ខ្ញុំមកអំពីមនុស្សលោកយូរហើយ ។

បទថា **នាភិសំសិត្ថ** “មិនបានជេរប្រទេច” សេចក្តីថា ស្តេចនាគរាជសួរថា “ក្នុងបុត្តជាដើមរបស់ខ្ញុំ នរណាៗ មិនបានជេរ មិនបានបរិភាសលោកទេឬ?” បាឋៈថា **នាភិសជ្ជេថ** ប្រែថា មិនបានថែទាំ ដូច្នេះក៏មាន ។ អធិប្បាយថា មិនបានធ្វើឲ្យថ្នាំងថ្នាក់ ។ បទថា **បដិវិហិតោ** “ទំនុកបម្រុង” បានដល់ ទំនុកបម្រុងហើយ ។

បទថា **មណិ មមំ** “កែវមណី... របស់ខ្ញុំ” សេចក្តីថា ស្តេចនាគរាជពោលថា “អាឡារៈសម្លាញ់ បើលោកនឹងទៅឲ្យបានដូច្នេះ កែវមណីពណ៌ក្រហមរមែងនាំទ្រព្យមកឲ្យ ឲ្យនូវសម្បត្តិដែលគួរប្រាថ្នាទាំងពួងរបស់ខ្ញុំមានហើយ ម្នាលអាឡារៈ លោកចូរកាន់យកមណីរតន៍ទៅកាន់ផ្ទះចុះ លោកនឹងបានទ្រព្យតាមប្រាថ្នាដោយអានុភាពនៃមណីរតន៍នេះ ចូររក្សាមណីរតន៍ក្នុងផ្ទះនោះ កាលនឹងរក្សាកុំរក្សាទុកក្នុងទីដទៃ គួររក្សាទុកក្នុងក្អមទឹករបស់ខ្លួន” គ្រានាគរាជពោលដូច្នេះហើយ ក៏បង្អោនមណីរតន៍មកឲ្យអាត្មា ។

គ្រាអាឡារតាបសពោលយ៉ាងនេះហើយ ទើបពោលតទៅថា "សូមថ្វាយព្រះពរមហាបពិត្រ គ្រានោះ អាត្មាភាពបានពោលពាក្យនេះនឹងស្តេចនាគរាជថា "ម្នាលសម្លាញ់ យើងមិនបានត្រូវការដោយទ្រព្យ តែយើងប្រាថ្នានឹងបួស ដូច្នេះហើយ ក៏សូមបរិក្ខារនៃបព្វជិត ចេញចាកនាគពិភពព្រមជាមួយស្តេចនាគនោះ និងអញ្ជើញស្តេចនាគឲ្យត្រឡប់ហើយ ទើបចូលកាន់ហិមវន្តប្បទេសបព្វជ្ជា" ដូច្នេះ កាលនឹងពោលធម្មកថាថ្វាយព្រះរាជា ទើបពោល ២ គាថាថា

[៦៤៥] ទិដ្ឋា មយា មានុសកាបិ កាមា

អសស្សតា វិបរណាមធម្មា

អាទីនវំ កាមគុណេសុ ទិស្វា

សទ្ធាយហំ បព្វជិតោម្ហិ រាជ ។

សូមថ្វាយព្រះពរ សូម្បីកាមគុណជារបស់មនុស្ស អាត្មា

បានឃើញហើយ ជារបស់មិនទៀង មានសេចក្តីប្រែប្រួល ជាធម្មតា អាត្មាឃើញទោសក្នុងកាមគុណទាំងឡាយ ទើបចេញបួសដោយសទ្ធា ។

ទុមប្ផលានេវ បតន្តិ មាណវា
ទហរា ច វុឌ្ឍា ច សរីរភេទា
ឯតំបិ ទិស្វា បព្វជិតោម្ហិ រាជ
អបណ្ណកំ សាមញ្ញមេវ សេយ្យោ ។

សូមថ្វាយព្រះពរ ទាំងមនុស្សក្មេង មនុស្សចាស់ រមែងមានសរីរៈបែកធ្លាយ ធ្លាក់ចុះទៅ ប្រៀបដូចផ្លែឈើដូច្នោះ អាត្មាឃើញគុណប្រការនេះថា សាមញ្ញផលជាវត្តបដិបត្តិមិនខុស ប្រសើរ ទើបចេញបួស ។

បណ្តាបទទាំងនោះ បទថា សទ្ធាយ "ដោយសទ្ធា" សេចក្តីថា អាត្មាបួសព្រោះជឿកម្ម ជឿផលនៃកម្ម និងជឿព្រះនិព្វាន ។

បទថា **ទុមប្ផលានេវ** “ដូចផ្លែឈើ” សេចក្តីថា ផ្លែឈើទាំងឡាយ ទុំហើយក្តី មិនទាន់ទុំក្តី រមែងជ្រុះទៅយ៉ាងណា មនុស្សទាំងឡាយ ទាំងក្មេងទាំងចាស់ រមែងជ្រុះទៅដូចគ្នា ។ បទថា **អបណ្ណកំ** “វត្ត-បដិបត្តិដែលមិនខុស” បានដល់ សាមញ្ញផលដែលមិនខុស គឺ ជានិយ្យានិកធម៌ ។ បទថា **សាមញ្ញមេវ សេយ្យោ** “សាមញ្ញផល... ប្រសើរ” សេចក្តីថា មហារាជ អាត្មាភាពឃើញគុណនៃបព្វជ្ជាថា “បព្វជ្ជានោះឯងជារបស់ខ្ពង់ខ្ពស់” ទើបបានបួស ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់គាថាតទៅថា

[៦៤៦] *អទ្ធា ហវេ សេវិតព្វា សបញ្ញា*

*ពហុស្សុតា យេ ពហុឋានចិន្តិនោ*

*នាគញ្ច សុត្វាន តុវញ្ចព្រហ្មេ*

*កាហាមិ បុញ្ញានិ អនប្បកានិ ។*

ជនពួកណាជាពហូសូត រិះគិតហេតុផលបានច្រើន ជន

ពួកនោះជាអ្នកមានបញ្ញា បុគ្គលគួរស្វែងរកដោយពិតនោះឯង បពិត្រអាឡារៈ ខ្ញុំបានស្តាប់ពាក្យរបស់នាគរាជ និងពាក្យរបស់លោកហើយ នឹងធ្វើបុណ្យឲ្យច្រើន ។

បណ្តាបទទាំងនោះ បទថា យេ ពហុឋានចិន្តិនោ "បុគ្គលពួកណា... រិះគិតហេតុផលបានច្រើន" សេចក្តីថា ជនពួកណាដឹងហេតុការណ៍បានច្រើន ។ បទថា នាគញ្ច "នាគរាជ" សេចក្តីថា ព្រោះបានស្តាប់ពាក្យស្តេចនាគ និងរបស់លោកដែលមានប្រក្រតីនៅដោយសេចក្តីមិនប្រមាទយ៉ាងនោះ (ខ្ញុំនឹងសាងបុណ្យកុសលឲ្យច្រើន) ។

លំដាប់នោះ កាលតាបសញុំាងនូវឧស្សាហៈឲ្យកើតចំពោះព្រះរាជាហើយ ទើបពោលគាថាចុងក្រោយថា

[៦៤៧] អទ្ធា ហវេ សេវិតព្វា សបញ្ញា
ពហុស្សុតា យេ ពហុឋានចិន្តិនោ

នាគញ្ច សុត្វាន មមញ្ច រាជ

ករោហិ បុញ្ញានិ អនប្បកានីតិ ។

សូមថ្វាយព្រះពរ ជនទាំងឡាយជាពហូសូត វិះគិតហេតុផលបានច្រើន ជនពួកនោះជាអ្នកមានបញ្ញា បុគ្គលគួរគប់រកដោយពិត មហារាជ ព្រោះទ្រង់ស្តាប់រឿងរ៉ាវរបស់នាគរាជ និងរបស់អាត្មាភាពហើយ សូមព្រះអង្គប្រោសទ្រង់បំពេញនូវកុសលឲ្យច្រើន ។

តាបសនោះ សម្តែងធម៌ថ្វាយព្រះរាជាយ៉ាងនេះហើយ នៅក្នុងព្រះរាជឧទ្យាននោះអស់វេលា ៤ ខែក្នុងរដូវភ្លៀង ហើយត្រឡប់ទៅកាន់ហិមវន្តប្បទេសវិញ ចម្រើនព្រហ្មវិហារ ៤ ដរាបអស់ជីវិត បានជាអ្នកចូលដល់ព្រហ្មលោកហើយ ។ ចំណែកសន្ធបាលនាគរាជក៏រក្សាឧបោសថរហូតអស់ជីវិត ចំណែកព្រះបាទពារាណសីក៏ទ្រង់បំពេញបុណ្យមានទានជាដើម ហើយក៏ទៅតាមកម្មរបស់ខ្លួន

ដែលធ្វើទុកល្អហើយ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ថា "បុរាណកបណ្ឌិតទាំងឡាយបានលះបង់នាគសម្បត្តិ ហើយរក្សាឧបោសថកម្មយ៉ាងនេះ" ហើយទ្រង់បានប្រជុំជាតកថា "តាបសជាព្រះរាជបិតាក្នុងកាលនោះ បានមកជាព្រះអានន្ទ អាឡារតាបសក្នុងកាលនោះ បានមកជាព្រះសារីបុត្ត ចំណែកសង្ខបាលនាគរាជក្នុងកាលនោះ គឺ **តថាគតជាអរហន្តសម្មាសម្ពុទ្ធ**" ។

ចប់អដ្ឋកថា សង្ខបាលជាតកទី ៤

# អដ្ឋកថា ចុល្លសុតសោមជាតកទី ៥

## (រឿងព្រះបាទចុល្លសុតសោមចេញបួស)

ព្រះសាស្តាកាលប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធនេក្ខម្មបារមី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អមន្តយាមិ និគមំ** “**យើងសូមប្រាប់អ្នកនិគម**” ដូច្នេះ ។

បច្ចុប្បន្ននិទាន ដូចគ្នាក្នុងមហានារទកស្សបជាតក (ចំណែកអតីតនិទាន មានដូចតទៅនេះ) ។

ក៏ក្នុងអតីតកាល ព្រះនគរពារាណសីមានឈ្មោះថា “សុទស្សននគរ” ព្រះរាជាទ្រង់ព្រះនាមថា **ព្រហ្មទត្ត** ស្តេចប្រថាប់នៅក្នុងព្រះនគរនោះ ។ ព្រះពោធិសត្វទ្រង់បដិសន្ធិក្នុងព្រះគភ៌ព្រះអគ្គមហេសីរបស់ព្រះរាជានោះ កន្លងបាន ១០ ខែក៏ប្រសូតចាកព្រះគភ៌របស់ព្រះមាតា ។ ក៏ព្រះកក្រ្តរបស់ព្រះកុមារនោះមានសិរី ដូចជាព្រះចន្ទពេញវង់ ។ ព្រោះហេតុនោះ ព្រះជនកព្រះជននីទ្រង់ទើប

ថ្វាយព្រះនាមថា *"សោមកុមារ"* រាជកុមារនោះគ្រាដឹងក្តីហើយជាអ្នកពេញចិត្តក្នុងសុតៈ មានការស្តាប់ជាប្រក្រតី ព្រោះហេតុនោះអ្នកដែនទើបថ្វាយព្រះនាមទៀតថា *"សុតសោម"* ។ លុះចម្រើនវ័យហើយ ព្រះកុមារស្តេចទៅរៀនសិល្បសាស្ត្រក្នុងក្រុងតក្កសិលា ស្តេចត្រឡប់វិញ ទ្រង់បានស្វេតឆត្ររបស់ព្រះជនក សោយរាជ្យ-សម្បត្តិដោយធម៌ ទ្រង់មានព្រះឥស្សរិយយសដ៏ធំ ។ ព្រះអង្គមានស្រីស្នំចំនួន ១៦.០០០ នាក់ មាន **ព្រះនាងចន្ទាទេវី** ជាប្រធាន ។ ក្នុងវេលាតមកស្តេចក៏ចម្រើនដោយព្រះឱរសព្រះធីតា រហូតទ្រង់មិនត្រេកអរក្នុងឃរាវាសវិស័យ ក៏មានព្រះបំណងនឹងទៅកាន់ព្រៃហើយទ្រង់បួស ។ ថ្ងៃមួយ ព្រះអង្គត្រាស់ហៅនាយកូសាមាលាមកត្រាស់ថា "ម្នាលសម្លាញ់ កាលណាអ្នកឃើញសក់របស់យើងស្កូវហើយ អ្នកគប្បីប្រាប់យើង" កាលនោះ នាយកូសាមាលាក៏ទទួលព្រះរាជតម្រាស់របស់ស្តេច វេលាតមក ក៏ឃើញព្រះកេសា

ស្កូវទើបក្រាបទូលឲ្យទ្រង់ជ្រាប កាលព្រះរាជាត្រាស់ថា "នែកូសាមាលា បើដូច្នោះអ្នកចូរដកសក់នោះ មកដាក់នឹងបាតដៃយើង ទើបយកតម្បៀតមាសដកព្រះកេសាមកដាក់លើបាតព្រះហត្ថ" ព្រះមហាសត្វទតព្រះនេត្រមើលព្រះកេសាស្កូវនោះ ទ្រង់ស្ងុតព្រះទ័យថា "សរីរៈរបស់យើងត្រូវជរាគ្របសង្កត់ហើយ ទើបទ្រង់កាន់សរសៃព្រះកេសាស្កូវនោះស្តេចយាងចុះចាកប្រាសាទ ប្រថាប់គង់លើរាជបល្ល័ង្កដែលតាក់តែងទុកត្រង់ទីគាល់របស់មហាជន ហើយត្រាស់ឲ្យហៅអាមាត្យប្រមាណ ១៨.០០០ នាក់ មានសេនាបតីជាប្រធាន និងព្រាហ្មណ៍ ៦០.០០០ នាក់ បុរោហិតជាប្រធាន និងអ្នកដែនអ្នកនិគមជាដើមដទៃៗ មកគាល់ជាចំនួនច្រើន ហើយទ្រង់ត្រាស់ថា "កេសាស្កូវកើតត្រង់សីសៈរបស់យើងហើយ យើងជាមនុស្សចាស់ហើយ អ្នកទាំងឡាយចូរទទួលដឹងថា យើងនឹងចេញបព្វជ្ជា" ដូច្នេះ ទើបត្រាស់គាថាទី ១ ថា

[៦៤៨] អាមន្តយាមិ និគមំ មិត្តាមច្ចេ បារិសជ្ជេ ច
សិរស្មឹ បលិតំ ជាតំ បព្វជ្ជំ ទានិ រោចយំ ។

យើងសូមប្រាប់អ្នកនិគម មិត្ត អាមាត្យ និងខ្ញុំរាជបរិវារ សក់ត្រង់សីសៈរបស់យើងស្កូវហើយ ឥឡូវនេះ យើងពេញ-ចិត្តក្នុងបព្វជ្ជាភេទ ។

បណ្តាបទទាំងនោះ បទថា អាមន្តយាមិ "សូមប្រាប់" គឺ យើងសូមប្រកាសឲ្យលោកទាំងឡាយបានដឹង ។ បទថា រោចយំ "យើងពេញចិត្ត" សេចក្តីថា យើងពេញចិត្ត លោកដ៏ចម្រើនទាំងឡាយ លោកទាំងឡាយចូរដឹងថា យើងនេះនឹងបួស ។

បណ្តាជនទាំងឡាយ ដែលបានស្តាប់ព្រះតម្រាស់ព្រះរាជានោះ អាមាត្យម្នាក់ជាអ្នកអង់អាចក្លាហាន ក្រាបទូលគាថាថា

[៦៤៩] អកុំ មេ កថំ នុ ភណសិ
សល្លំ មេ ទេវ ឧរសិ កប្បេសិ

សត្តសតា តេ ភរិយា
កថំ នុ តេ តា ភវិស្សន្តិ ។

យ៉ាងណាហ្ន៎ ព្រះអង្គទើបត្រាស់សេចក្តីមិនចម្រើនដល់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គជាសម្មតិទេព ព្រះអង្គទ្រង់ថ្វាយព្រះសែងសរត្រង់ទ្រូងរបស់ខ្ញុំព្រះអង្គហើយ ព្រះជាយារបស់ព្រះអង្គមានដល់ ៧០០ នាក់ ព្រះនាងទាំងនោះរបស់ព្រះអង្គនឹងរស់នៅដូចម្តេច ។

បណ្តាបទទាំងនោះ បទថា អកុំ "មិនចម្រើន" បានដល់វត្ថុដែលមិនមានសេចក្តីចម្រើន ។ បទថា ឧរសិ កប្បេសិ "ថ្វាយ (ព្រះសែងសរ) ត្រង់ទ្រូង" សេចក្តីថា ព្រះអង្គទ្រង់ញុំាងព្រះសស្ត្រាដែលសំលៀងហើយដោយល្អឲ្យមុតចូលទ្រូងរបស់ខ្ញុំព្រះអង្គ ។ បទថា សត្តសតា "៧០០ នាក់" នេះ អាមាត្យនោះពោលសំដៅដល់ខត្តិយកញ្ញាអ្នកមានជាតិស្មើគ្នា ។ បទថា កថំ នុ តេ តា

ករិយា "ព្រះនាងទាំងនោះរបស់ព្រះអង្គនឹងរស់នៅដូចម្ដេចហ្ន៎" គឺព្រះរាជជាយារបស់ព្រះអង្គទាំងនោះ កាលព្រះអង្គទ្រង់ផ្នួសហើយ នឹងជាអនាថា មិនមានទីពឹង នឹងរស់នៅបានយ៉ាងណា ការដែលព្រះអង្គទ្រង់ធ្វើនាងទាំងនោះឲ្យមិនមានទីពឹង ហើយទ្រង់ផ្នួសនេះ មិនសមគួរឡើយ ព្រះអង្គ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់គាថាទី ៣ ថា

[៦៥០] បញ្ញាយិហិន្តិ ឯតា ទហរា
អញ្ញំបិ តា គមិស្សន្តិ
សគ្គញ្ច បត្ថយានោ
តេនាហំ បព្វជិស្សាមិ ។

នាងទាំងនោះនៅក្មេង នឹងប្រាកដតាមកម្មរបស់ខ្លួនឯង នាងទាំងនោះនឹងទៅពឹងពាក់ព្រះរាជាអង្គដទៃក៏បាន ចំណែកយើងប្រាថ្នាសួគ៌ ព្រោះហេតុនោះ យើងទើបបួស ។

បណ្តាបទទាំងនោះ បទថា **បញ្ញាយន្តិ**[១] "នឹងប្រាកដ" គឺ នារីទាំងនោះនឹងប្រាកដដោយកម្មវៀងៗ ខ្លួន យើងជាអ្វីរបស់នាងទាំងនេះ នាងទាំងនេះសុទ្ធតែនៅក្មេង ព្រះរាជាដទៃៗ ក៏នៅមាន នារីទាំងនេះនឹងទៅពឹងព្រះរាជាដទៃៗ នោះបាន ។

អាមាត្យជាដើម កាលមិនអាចនឹងទូលឃាត់ព្រះពោធិសត្វបាន ទើបនាំគ្នាទៅកាន់សម្នាក់របស់ព្រះមាតាព្រះពោធិសត្វ ក្រាបទូលសេចក្តីនោះថ្វាយទ្រង់ជ្រាប ។ ព្រះរាជជននីស្តេចមកដោយប្រញាប់ត្រាស់ថា "កូនសម្លាញ់ ដំណឹងថា កូនបំណងនឹងបួសពិតឬ?" ដូច្នេះហើយ បានត្រាស់ ២ គាថាថា

[៦៥១] ទុល្លទ្ធំ មេ អាសិ សុតសោម
យស្ស តេ ហោមហំ មាតា
យំ មេ វិលបន្តិយា

---

បិដក. ១. បញ្ញាយិហិន្តិ ។

អនបេក្ខោ បព្វជសិ ទេវ ។

បាសុតសោមដ៏ប្រសើរ ម៉ែជាមាតារបស់កូនដែលម៉ែបាន មកដោយសេចក្តីលំបាក ព្រោះកាលម៉ែពោលដដែលៗ ហើយ កូនក៏មិនអាល័យ នឹងបួសឲ្យបាន ។

ទុល្លទ្ធំ មេ អាសិ សុតសោម
យំ តំ អហំ វិជាយិស្សំ
យំ មេ វិលបន្តិយា
អនបេក្ខោ បព្វជសិ ទេវ ។

បាសុតសោមដ៏ប្រសើរ ម៉ែប្រសូតកូនជាអ្នកដែលម៉ែបាន មកដោយលំបាក ហេតុអ្វីកាលម៉ែពោលដដែលៗ ហើយ កូន នៅមិនអាល័យ ប្រាថ្នានឹងបួសឲ្យបាន ។

បណ្តាបទទាំងនោះ បទថា ទុល្លទ្ធំ “បានមកដោយលំបាក” សេចក្តីថា កូនឈ្មោះថា ជាអ្នកដែលបានមកដោយលំបាក ព្រោះ

កាលម៉ែនឹងបាន ក៏ត្រូវប្រសព្វសេចក្ដីលំបាក ទើបបានកូនជាបុត្ត មក ៗ បទថា **យំ មេ** “**អ្នកដែលម៉ែ**” សេចក្ដីថា កាលម៉ែពោល អង្វរហើយដោយប្រការផ្សេងៗ កូននៅប្រាថ្នានឹងបួសឲ្យបានដោយ ហេតុណា ហេតុនោះការបានបុត្តដូចជាកូន ទើបឈ្មោះថា បានមក ដោយសេចក្ដីលំបាក ៗ

ព្រះពោធិសត្វមិនបានត្រាស់អ្វីជាមួយព្រះមាតា ដែលទ្រង់ បរិទេវនាការយ៉ាងនេះឡើយ ៗ ព្រះរាជជននីទ្រង់ព្រះកន្សែង ទ្រង់ ប្រថាប់ឈរនៅក្នុងទីម្ខាងមួយព្រះអង្គឯង ៗ លំដាប់នោះ ប្រជា- ជនទើបនាំគ្នាទៅក្រាបទូលដល់ព្រះរាជបិតារបស់ព្រះពោធិសត្វ ព្រះ រាជបិតាស្ដេចមកហើយ ត្រាស់គាថាយ៉ាងនេះដូចគ្នាថា

[៦៥២] *កោ នាមេសោ ធម្មោ សុតសោម*

*កា ច នាម បព្វជ្ជា*

*យំ នោ អម្ហេ ជិណ្ណេ បហាយ*

*អនបេក្ខោ បព្វជសិ ទេវ ។*

*បាសុតសោមដ៏ប្រសើរ ធម៌នោះឈ្មោះអ្វី និងអ្វីឈ្មោះថា ការបព្វជ្ជា ព្រោះថា កូននឹងលះបង់យើងទាំងពីរនាក់ជាមនុស្សចាស់ហើយ មិនអាល័យ នឹងបួសតែម្យ៉ាង ។*

*បណ្ដាបទទាំងនោះ បទថា យំ នោ អម្ហេ "យើងទាំងពីរ" មានអធិប្បាយថា "កូនជាបុត្តរបស់មាតាបិតា ហេតុអ្វីមិនបដិបត្តិមាតាបិតាដែលចាស់ជរាក្នុងវេលាដែលគួរបដិបត្តិ បែរជាលះបង់ទៅបួសដោយមិនអាល័យ ដូចជាញ៉ាំងនូវដុំសិលាឲ្យធ្លាក់ក្នុងជ្រោះដូច្នោះ ព្រោះហេតុនោះ បិតាសូមសួរកូន ធម៌របស់កូននេះឈ្មោះអ្វី?" ។*

*ព្រះមហាសត្វទ្រង់ស្ដាប់ដូច្នោះហើយក៏នៅស្ងៀម លំដាប់នោះព្រះរាជបិតាទើបត្រាស់នឹងព្រះមហាសត្វថា "សុតសោមកូនសម្លាញ់ប្រសិនបើកូនមិនមានសេចក្ដីស្នេហា អាល័យក្នុងមាតាបិតា និង*

បុត្តធីតារបស់កូនក៏នៅតូចៗ មានច្រើន មិនអាចនឹងព្រាត់ប្រាស កូនបាន ក្នុងវេលាក្មេងទាំងនោះចម្រើនវ័យហើយ កូនសឹមបួស ចុះ" ហើយត្រាស់គាថាទី ៧ ថា

[៦៥៣] បុត្តាបិ តុយ្ហំ ពហវោ
ទហរា អប្បត្តយោព្វនា
មញ្ជូ តេបិ តំ អបស្សន្តា
មញ្ញេ ទុក្ខំ និគច្ឆន្តិ ។

សូម្បីបុត្ត និងធីតាទាំងឡាយរបស់កូនក៏មានច្រើន នៅតូចណាស់ នៅមិនទាន់កំលោះក្រមុំ កំពុងនិយាយគួរឲ្យស្រឡាញ់ កាលមិនឃើញកូន នឹងលំបាកទៅតាមគ្នា ។

បណ្ដាបទទាំងនោះ បទថា មញ្ជូ "និយាយគួរឲ្យស្រឡាញ់" សេចក្ដីថា បាសម្គាល់ថា "គេទាំងនោះ នឹងនាំគ្នាដល់នូវសេចក្ដីលំបាក គឺ ត្រឡប់បាននូវទុក្ខទាំងផ្លូវកាយ និងផ្លូវចិត្ត" ។

ព្រះមហាសត្វទ្រង់ស្តាប់ព្រះតម្រាស់នោះហើយ ក៏ត្រាស់ព្រះ

គាថាថា

[៦៥៥] បុត្តេហិ ច មេ ឯតេហិ

ទហរេហិ អប្បត្តយោព្វនេហិ

មញ្ជូហិ សព្វេហិបិ តុម្ហេហិ

ចិរំបិ បត្វា វិនាភាវោ ។

ការនៅរួមគ្នាសូម្បីយូរ ហើយព្រាត់ប្រាសចាកគ្នា ចាក

ឱរសធីតាទាំងនេះរបស់ខ្ញុំព្រះអង្គ ដែលកំពុងនៅក្មេង មិន

ទាន់ចម្រើនវ័យ កំពុងនិយាយពីរោះក្តី ចាកព្រះអង្គទាំងពីរ

ព្រះអង្គ និងវត្ថុទាំងពួងទៅក្តី ជារបស់ទៀងពិត ។

បណ្តាបទទាំងនោះ បទថា សព្វេហិបិ តុម្ហេហិ "ចាកព្រះ

អង្គទាំងពីរអង្គ និងវត្ថុទាំងពួងទៅក្តី" សេចក្តីថា បពិត្រព្រះបិតា

ដែលថា ខ្ញុំព្រះអង្គនឹងចាកឱរសធីតាប៉ុណ្ណោះក៏មិនមែន ដែលពិត

សូម្បីព្រះអង្គទាំងពីរ សូម្បីសព្វសន្ធារដទៃៗ ដែលតាំងនៅបាន អស់កាលយូរ ក៏នឹងព្រាត់ប្រាសចាកគ្នា គឺ មានសភាពផ្សេងៗ គ្នា ព្រោះក្នុងលោកសន្និវាសទាំងអស់ សន្ធារសូម្បីតែមួយដែល ឈ្មោះថា ជារបស់ទៀងមិនមានឡើយ ។

ព្រះមហាសត្វសម្ដែងធម្មកថាចំពោះព្រះរាជបិតាយ៉ាងនេះ ។ ព្រះរាជបិតាបានស្ដាប់ធម្មកថារបស់ព្រះមហាសត្វហើយ ក៏ទ្រង់នៅ ដោយតុណ្ហីភាព ។ លំដាប់នោះ អាមាត្យទាំងឡាយទើបទៅប្រាប់ ដល់ព្រះជាយាទាំង ៧០០ អង្គរបស់ព្រះមហាសត្វ ។ ព្រះជាយា ទាំងនោះទើបចុះចាកមហាប្រាសាទទៅកាន់សម្នាក់របស់ព្រះមហា-សត្វ ខ្វះក៏ក្រាបចុះទៀបព្រះបាទបរិទេវនាការ ពោលគាថាថា

[៦៥៥] ឆិន្នំ នុ តុយ្ហំ ហទយំ

អាទូ ករុណា ច នត្ថិ អម្ហេសុ

យំ នោ វិកន្ទន្តិយោ

អនបេក្ខោ បព្វជសិ ទេវ ។

ព្រះទ័យរបស់ព្រះអង្គនឹងកាត់ដាច់ហើយឬ ឬទ្រង់មិនព្រះករុណាខ្ញុំម្ចាស់ទាំងឡាយ ហេតុអ្វីព្រះអង្គទើបមិនអាល័យខ្ញុំម្ចាស់ទាំងឡាយដែលខ្សឹកខ្សួល ស្តេចនឹងចេញបួសឲ្យបានតែម្យ៉ាងឬ ។

គាថានោះ មានអត្ថាធិប្បាយដូច្នេះ បពិត្រព្រះសុតសោមជាព្រះស្វាមី ព្រះហឫទ័យរបស់ព្រះអង្គកាត់ដាច់ហើយ ដែលធ្វើឲ្យព្រះអង្គបំណងស្តេចទៅបួសដោយដាច់ខាត ព្រោះមិនមានសេចក្តីស្នេហាសូម្បីតែតិចតួច ឬឈ្មោះថា សេចក្តីករុណារបស់ព្រះអង្គមិនមានក្នុងពួកខ្ញុំម្ចាស់ ព្រោះមិនមានព្រះករុណា ព្រះអង្គទើបលះបង់ទាំងពួកខ្ញុំម្ចាស់ដែលកំពុងខ្សឹកខ្សួលយ៉ាងនេះទៅបព្វជ្ជា ។

ព្រះមហាសត្វទ្រង់ស្តាប់សំឡេងបរិទេវនាការរបស់ពួកបាទ-បចារិកាទាំងនោះ ដែលកន្ទក់កន្ទេញហើយទៀបបាទមូល ទ្រង់ក៏

ត្រាស់គាថាជាលំដាប់តទៅថា

[៦៥៦] ន ច មយ្ហំ ធិន្នំ ហទយំ

អត្ថិ ករុណាបិ មយ្ហំ តុម្ហេសុ

សគ្គញ្ច បត្ថយមានោ

តេនាហំ បព្វជិស្សាមិ ។

ចិត្តរបស់យើងមិនបានដាច់ខាត និងយើងក៏មានសេចក្តីករុណាក្នុងអ្នកទាំងឡាយ តែយើងប្រាថ្នាសួគ៌ ព្រោះដូច្នោះទើបយើងចេញបួស ។

បណ្តាបទទាំងនោះ បទថា សគ្គញ្ច "សួគ៌" សេចក្តីថា ព្រះមហាសត្វទ្រង់លួងលោមចិត្តព្រះជាយាទាំងនោះថា "យើងប្រាថ្នាសួគ៌ មួយទៀត ដែលឈ្មោះថា បព្វជ្ជានេះ ពុទ្ធាទិបណ្ឌិតសរសើរហើយ ព្រោះហេតុនោះ យើងទើបបួស អ្នកទាំងឡាយកុំខូចចិត្តឡើយ" ។

លំដាប់នោះ អាមាត្យទាំងឡាយទើបក្រាបទូលព្រះអគ្គមហេសីរបស់ព្រះពោធិសត្វឲ្យទ្រង់ជ្រាប ។ ក៏ព្រះអគ្គមហេសីនោះទ្រង់តតេងតតាង ទ្រង់គភ៌ជិតកាលប្រសូត ស្តេចថ្វាយបង្គំព្រះមហាសត្វ ប្រថាប់ឈរត្រង់ទីម្ខាង បានពោល ៣ គាថាថា

[៦៥៧] ទុល្លទ្ធំ មេ អាសិ សុតសោម

យស្ស តេ អហំ ភរិយា

យំ មេ វិលបន្តិយា

អនបេក្ខា បព្វជសិ ទេវ ។

បពិត្រព្រះសុតសោមដ៏ប្រសើរ ខ្ញុំម្ចាស់ជាអគ្គមហេសីរបស់ព្រះអង្គ បានព្រះអង្គមកដោយលំបាក ហេតុអ្វីកាលខ្ញុំព្រះម្ចាស់យំសោកហើយ ទ្រង់ទើបមិនបានអាល័យ ទ្រង់នឹងបួស ។

ទុល្លទ្ធំ មេ អាសិ សុតសោម

យស្ស តេ អហំ ភរិយា

យំ មេ កុច្ឆិបដិសន្ធិ

អនបេក្ខោ បព្វជសិ ទេវ ។

បពិត្រព្រះសុតសោមដ៏ចម្រើន ខ្ញុំម្ចាស់ជាអគ្គមហេសីរបស់ព្រះអង្គ បានព្រះអង្គមកដោយលំបាក ហេតុអ្វីព្រះអង្គទើបទ្រង់មិនអាល័យព្រះឱរស ដែលបដិសន្ធិក្នុងគភ៌របស់ខ្ញុំម្ចាស់ ទ្រង់នឹងផ្នួស ។

បរិបក្កោ មេ គព្ភោ កុច្ឆិគតោ

យាវ នំ វិជាយាមិ

មាហំ ឯកា វិធវា

បច្ឆា ទុក្ខានិ អទ្ទក្ខិំ ។

គភ៌របស់ខ្ញុំម្ចាស់គ្រប់ហើយ សូមព្រះអង្គទ្រង់រង់ចាំខ្ញុំម្ចាស់ប្រសូតសិន កុំឲ្យខ្ញុំម្ចាស់នៅតែម្នាក់ឯង ត្រូវបានទទួល

ទុក្ខជាខាងក្រោយឡើយ ។

បណ្ដាបទទាំងនោះ បទថា *យំ មេ* “ខ្ញុំម្ចាស់” សេចក្ដីថា ព្រោះហេតុអ្វី កាលខ្ញុំម្ចាស់កំពុងសោក ព្រះអង្គមិនបានអាល័យ ប្រាថ្នានឹងបួស តាំំណែងអគ្គមហេសីដែលខ្ញុំម្ចាស់បានអំពីសម្នាក់នៃព្រះអង្គនោះ ខ្ញុំម្ចាស់បានមកដោយលំបាក ។ ក្នុងគាថាទីពីរមានអធិប្បាយថា ព្រោះហេតុអ្វី ព្រះអង្គទ្រង់លះបង់ខ្ញុំម្ចាស់ដែលកំពុងមានគភ៌ចាស់ មិនបានអាល័យ ចេញបួស សភាពជាអគ្គមហេសីរបស់ខ្ញុំម្ចាស់ដែលបានមកនោះ ខ្ញុំម្ចាស់បានមកដោយលំបាក ។ បទថា *យាវ នំ* “រហូតនឹង... ប្រសូត” សេចក្ដីថា សូមព្រះអង្គទ្រង់រង់ចាំរហូតខ្ញុំម្ចាស់នឹងប្រសូតសិនចុះ” ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ព្រះគាថាថា

[៦៥៨] *បរិបក្កោ តេ គព្ភោ កុច្ឆិគតោ*

*ឥង្ឃ ត្វំ វិជាយស្សុ*

បុត្តំ អនោមវណ្ណំ

តំ ហិត្វា បព្វជិស្សាមិ ។

គភ៌របស់នាងចាស់ហើយ ចូរប្រសូតព្រះឱរសដែលមានពណ៌សម្បុរមិនថោកថយចុះ ខ្ញុំនឹងលះបង់ឱរសព្រមទាំងនាងបួសឲ្យបាន ។

បណ្ដាបទទាំងនោះ បទថា បុត្តំ "ឱរស" សេចក្ដីថា នាងដ៏ចម្រើន យើងដឹងថា នាងមានគភ៌ចាស់ តែកាលនាងប្រសូតនឹងប្រសូត្រព្រះឱរស មិនមែនជាធីតា សូមនាងចូរប្រសូតឱរសដោយសួស្ដីចុះ ចំណែកយើងនឹងលះបង់បុត្តព្រមទាំងខ្លួននាង បួសឲ្យបាននោះឯង ។

ព្រះនាងទេវីស្ដាប់ព្រះរាជតម្រាស់របស់ព្រះរាជស្វាមីហើយមិនអាចអត់ទ្រាំនឹងសេចក្ដីសោកបាន ទើបទូលថា "បពិត្រព្រះសម្មតិទេព គ្រានេះ រាប់តាំងអំពីថ្ងៃនេះទៅ ឈ្មោះថា ជីវិតរបស់

ខ្ញុំម្ចាស់មិនមានឡើយ” ហើយយកព្រះហត្ថទាំងពីរគក់ព្រះហឫទ័យ បន្ធូរព្រះអស្សុជលបរិទេវនាការដោយព្រះសូរសៀងដ៏ខ្លាំង ។ តពីនោះ ព្រះមហាសត្វកាលនឹងទ្រង់លួងលោមព្រះនាង ទើបត្រាស់ព្រះគាថាថា

[៦៥៩] មា ត្វំ ចន្ទេ រុទិ មា សោចិ

វនតិមិរមត្តក្ខិ

អារោហ វរបាសាទំ

អនបេក្ខោ អហំ គមិស្សាមិ ។

ម្នាលនាងចន្ទា នាងកុំយំឡើយ នាងដែលមានកែវភ្នែកស្មើដោយផ្កាអញ្ចាន់ នាងកុំសោកសៅឡើយ ចូរឡើងកាន់ប្រាសាទដ៏ប្រសើរចុះ យើងមិនអាល័យទេ នឹងទៅបួស ។

បណ្តាបទទាំងនោះ បទថា មា ត្វំ ចន្ទេ រុទិ “ម្នាលនាងចន្ទា នាងកុំយំឡើយ” សេចក្តីថា ព្រះនាងអូនចន្ទាទេវីដ៏ចម្រើន

នាងកុំយំសោកឡើយ ។ បទថា **វនតិមិរមត្តក្ខិ** **“មានកែវភ្នែកស្មើដោយផ្កាអញ្ចាន”** សេចក្តីថា ដែលមានដួងព្រះនេត្រស្មើដោយផ្កាអញ្ចាន ។ តែក្នុងព្រះបាលីលោកសរសេរទុកថា **“កោវិលារតម្ពក្ខិ”** សេចក្តីថា នេត្រារបស់ព្រះនាងចន្ទាទេវីនោះ ក្រហមដូចផ្កាសិរ-មាន់ ។

ព្រះនាងចន្ទាទេវី ស្តាប់ព្រះរាជតម្រាស់ហើយ មិនអាចនឹងតាំងនៅបាន ស្តេចឡើងកាន់ប្រាសាទប្រថាប់អង្គុយព្រះកន្សែង ។ លំដាប់នោះ ព្រះឱរសច្បងរបស់ព្រះមហាសត្វ ឃើញព្រះមាតាទ្រង់ព្រះកន្សែង ទើបត្រិះរិះថា “ហេតុអ្វីហ្ន៎ ព្រះមាតារបស់យើងទើបប្រថាប់គង់ព្រះកន្សែង” កាលនឹងទូលសួរព្រះមាតា ទើបបានត្រាស់ព្រះគាថាថា

[៦៦០] *កោ តំ អម្ម កោបេសិ*

*កឹ រោទសិ បេក្ខសិ ច មំ ពាឡ្ហំ*

កំ អវជ្ឈំ ឃាតេមិ

ញាតីនំ ឧទិក្ខមានានំ ។

បពិត្រព្រះមាតា នរណាធ្វើឲ្យព្រះមាតាទ្រង់ពិរោធ ហេតុអ្វីព្រះមាតាទ្រង់ទើបព្រះកន្សែង និងសម្លក់សម្លឹងមើលខ្ញុំព្រះអង្គ បណ្តាព្រះញាតិដែលឃើញហើយ ខ្ញុំព្រះអង្គនឹងសម្លាប់នរណាដែលត្រាស់បង្គាប់ឲ្យសម្លាប់ ។

បណ្តាបទទាំងនោះ បទថា **កោបេសិ** “ទ្រង់ពិរោធ” ន័យថា បពិត្រព្រះមាតា នរណាធ្វើឲ្យព្រះមាតាក្រោធខឹង គឺ នរណាបានធ្វើវត្ថុមិនជាទីស្រឡាញ់ដល់ព្រះមាតា ។ បទថា **អបេក្ខសិ ច** “សម្លក់សម្លឹង” មានអធិប្បាយថា កាលព្រះមាតាសម្លក់សម្លឹងខ្ញុំព្រះអង្គ ហេតុអ្វីទើបទ្រង់ព្រះកន្សែង ។ បទថា **កំ អវជ្ឈំ ឃាតេមិ** “នឹងសម្លាប់នរណាដែលត្រាស់បង្គាប់ឲ្យសម្លាប់” សេចក្តីថា ព្រះរាជឱរសទូលសួរថា “ខ្ញុំព្រះអង្គនឹងសម្លាប់នរណាដែលគួរនឹង

សម្លាប់ ចំពោះព្រះញាតិរបស់ព្រះមាតាដែលឃើញហើយទុំះឯង ប្រោសត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់ចុះ" ។

លំដាប់នោះ ព្រះនាងទេវីត្រាស់ព្រះគាថាថា

[៦៦១] នហិ សោ សក្កា ហន្តុំ
វិជិតាវី យោ មំ តាត កោបេសិ
បិតា តេ មំ តាត អវច
អនបេក្ខោ អហំ គមិស្សាមិ ។

កូនសម្លាញ់ បុគ្គលណាទ្រង់ឈ្នះក្នុងផែនដីធ្វើឲ្យម៉ែក្រោធ បុគ្គលនោះមិនអាចនឹងសម្លាប់បានឡើយ ព្រះបិតារបស់កូន បានត្រាស់នឹងម៉ែថា ខ្ញុំមិនមានអាល័យ នឹងទៅបួស ។

បណ្តាបទទាំងនោះ បទថា វិជិតាវី "ទ្រង់ឈ្នះ" សេចក្តីថា កូនសម្លាញ់ បុគ្គលណាជាអ្នកឈ្នះក្នុងផែនដីនេះ ធ្វើឲ្យម៉ែក្រោធ គឺ ញុំាំងសេចក្តីក្រោធ និងសេចក្តីសោកឲ្យចូលទៅក្នុងហឫទ័យ

របស់ម៉ែ ដោយការពោលពាក្យមិនជាទីស្រឡាញ់ បុគ្គលនោះ កូនមិនអាចសម្លាប់បានទេ ព្រោះជាព្រះបិតារបស់កូន ព្រះអង្គទ្រង់ត្រាស់នឹងម៉ែថា "យើងនឹងលះបង់សិរីរាជ្យសម្បត្តិ និងខ្ទួនទាងចូលកាន់ព្រៃហើយបព្វជ្ជា" នេះគឺ ហេតុនៃការកន្ទេងរបស់ម៉ែ ។

ជេដ្ឋឱរសទ្រង់ស្តាប់ព្រះសវនីយ៍ព្រះមាតាហើយ ក៏ទូលថា "បពិត្រព្រះមាតា ព្រះមាតាត្រាស់ពាក្យនេះដូចម្តេច បើដូច្នេះពួកយើងក៏នឹងជាមនុស្សអនាថា រកទីពឹងមិនបានឬ" ដូច្នេះហើយ ទ្រង់ក៏បរិទេវនាការត្រាស់ព្រះគាថាថា

[៦៦២] យោហំ បុព្វេ រថេន យាមិ ឧយ្យានំ
មត្តកុញ្ជរេ ច យោធេមិ
សុតសោមេ បព្វជិតេ
កថំ នុទានិ ករិស្សាមិ ។

កាលមុនយើងធ្លាប់ត្រាច់ទៅឧទ្យានដោយរថ និងសិក្សា

*ការច្បាំងគ្នាជាមួយដំរីចុះប្រេង កាលព្រះរាជបិតាសុតសោម*
*ទ្រង់ផ្នួសហើយ គ្រានេះយើងនឹងធ្វើយ៉ាងណា ។*

គាថានោះ មានអត្ថាធិប្បាយដូច្នេះ កាលមុនយើងធ្លាប់ឡើងរថ ដែលប្រដាប់ហើយដោយគ្រឿងអលង្ការទាំងពួងទឹមដោយសេះអាជានេយ្យ ៤ ក្បាល ទៅព្រះរាជឧទ្យានប្រយុទ្ធនឹងកុញ្ជរជាតិចុះប្រេង ទាំងលេងកីឡាដទៃៗ ដូចជាអស្វកីឡាជាដើម ឥឡូវនេះ កាលព្រះរាជបិតាសុតសោមទ្រង់បួសហើយ យើងនឹងទៅជាយ៉ាងណា ។

លំដាប់នោះ ឱរសប្អូនជាកនិដ្ឋភាតារបស់ជេដ្ឋឱរស មានព្រះជន្មាយុបាន ៧ ព្រះវស្សា ឃើញក្សត្រទាំងពីរទ្រង់ព្រះកន្សែង ទើបចូលទៅគាល់ព្រះមាតាទូលសួរថា "បពិត្រព្រះមាតា ព្រោះហេតុអ្វីព្រះមាតា និងម្ចាស់បងទ្រង់កន្សែង" ទ្រង់ស្តាប់រឿងរ៉ាវនោះហើយក៏ទូលលួងលោមលោកទាំងពីរថា "បើដូច្នោះ សូមព្រះមាតា និង

ម្ចាស់បងទ្រង់កុំព្រះកន្សែងឡើយ ខ្ញុំព្រះអង្គមិនព្រមឲ្យព្រះបិតាបួសឡើយ” ហើយស្ដេចចុះចាកប្រាសាទព្រមដោយពួកកីលៀង ស្ដេចទៅកាន់សម្នាក់ព្រះរាជបិតា ទូលថា “បពិត្រព្រះបិតា ដំណឹងថាព្រះបិតានឹងលះបង់ពួកខ្ញុំព្រះអង្គអ្នកមិនបំណាងឲ្យបួសឬ” ហើយត្រាស់ថា “ខ្ញុំព្រះអង្គមិនព្រមឲ្យព្រះបិតាបួសទេ” ទូលហើយក៏ចូលទៅឱប.កព្រះបិតាយ៉ាងណែន ត្រាស់គាថាថា

[៦៦៣] មាតុ ច មេ រុទន្ត្យា

ជេដ្ឋស្ស ច ភាតុនោ អកាមស្ស

ហត្ថេបិ មេ គហិស្សំ

នហិ គច្ឆសិ សោ អកាមានំ ។

កាលព្រះមាតារបស់ខ្ញុំព្រះអង្គទ្រង់ព្រះកន្សែងហើយ និងកាលព្រះជេដ្ឋភាតាទ្រង់មិនសប្បាយព្រះទ័យ ខ្ញុំព្រះអង្គក៏នឹងចាប់ព្រះហត្ថទាំងពីររបស់ព្រះបិតាទុក កាលខ្ញុំព្រះអង្គទាំង

ឡាយមិនសប្បាយ ព្រះបិតាស្តេចនឹងទៅមិនបាន ។

ព្រះមហាសត្វទ្រង់ព្រះតម្រិះថា "ឱរសរបស់យើងនេះ នឹងធ្វើអន្តរាយដល់យើង ដោយឧបាយយ៉ាងណាហ្ន៎ ទើបយើងធ្វើឲ្យគេចៀសចេញទៅបាន" លំដាប់នោះ ព្រះមហាសត្វទើបក្រឡេកមើលទៅព្រះកិលៀងត្រាស់ថា "នែកីលៀង ម៉ែអញ្ជើញទៅចុះ នេះជាគ្រឿងប្រដាប់ក គឺ កែវមណី ចំណែកនេះជារបស់នាង ម៉ែចូរជួយនាំព្រះឱរសចេញទៅ កុំធ្វើអន្តរាយដល់យើងឡើយ" កាលព្រះអង្គឯងទ្រង់មិនអាចនឹងចាប់ព្រះហត្ថព្រះឱរសចេញទៅបាន ទើបគិតសូកដល់ព្រះកីលៀង ហើយត្រាស់ព្រះគាថាថា

[៦៦៤] ឱរជ្ជេហិ ត្វំ ជាតិ

ឥមំ កុមារំ រមេហិ អញ្ញត្ថ

មា មេ បរិបន្ថមកាសិ

សគ្គំ មម បត្ថយានស្ស

មេនាំអើយ សូមម៉ែក្រោកឡើងចុះ ម៉ែចូរនាំព្រះរាជកុមារនេះទៅលេងឲ្យសប្បាយក្នុងទីដទៃ កាលយើងកំពុងប្រាថ្នាសួគ៌ កុមារនេះកុំធ្វើអន្តរាយដល់យើងឡើយ ។

បណ្ដាបទទាំងនោះ បទថា ឥមំ កុមារំ "កុមារនេះ" សេចក្ដីថា ព្រះរាជាត្រាស់ថា "មេនាំអើយ នាងចូរក្រោកឡើង ជួយនាំព្រះកុមារនេះទៅ ហើយមកទទួលយកកែវមណីនេះ នាំព្រះកុមារឲ្យទៅសប្បាយក្នុងទីដទៃចុះ" ។

ព្រះភីលៀងនោះ បានតម្លៃឈ្នួលហើយ ទើបតៀនព្រះកុមារឲ្យលើកដឹងព្រះអង្គ ហើយនាំទៅក្នុងទីដទៃ ព្រះញាតិបរិទេវនាការពោលជាគាថាថា

[៦៦៥] យន្នូនិមំ ទទេយ្យំ បកន្តំ
កោ នុ មេ ឥមិនា អត្ថោ
សុតសោមេ បព្វជិតេ

កឹ នុ មេនំ ករិស្សាមិ ។

ដូចម្តេចហ្ន៎ យើងគប្បីឲ្យកែវមណីដែលមានពន្លឺចែងចាំង នេះ ប្រយោជន៍អ្វីរបស់យើងដោយកែវមណីនេះ កាលព្រះបាទសុតសោមទ្រង់ផ្នួសហើយ យើងនឹងធ្វើបានជាមួយនឹងកែវមណីនេះ ។

គាថានោះ មានអធិប្បាយដូច្នេះ ព្រះកិលៀងខ្សឹកខ្សួលថា "ហេតុអ្វីហ្ន៎ យើងទើបទទួលយកកែវមណីនេះដើម្បីជាតម្លៃឈ្នួល យើងគប្បីឲ្យកែវមណីនោះ ដែលធ្វើនូវរស្មីចែងចាំងដូចជាផ្កាយ ប្រសិនបើព្រះបាទសុតសោមបរមនរិន្ទ្រទ្រង់ផ្នួសហើយ កែវមណីនេះនឹងមានប្រយោជន៍អ្វីដល់យើង" ។ បទថា កឹ នុ មេនំ ករិស្សាមិ "យើងនឹងធ្វើអ្វីបានជាមួយកែវមណីនេះ" សេចក្តីថា កាលព្រះអង្គទ្រង់ផ្នួសហើយ យើងនឹងមិនបានកែវមណីនេះ សូម្បីនឹងបាន ក៏នឹងធ្វើអ្វីជាមួយកែវមណីនេះ អ្នកទាំងឡាយចូរមើលការធ្វើរបស់

យើងចុះ ។

លំដាប់នោះ អាមាត្យមហាសេនាគុត្តគិតថា "ប្រហែលព្រះរាជានេះទ្រង់ធ្វើសេចក្តីសម្គាល់ថា "រាជទ្រព្យរបស់យើងក្នុងឃ្លាំងមានតិច យើងនឹងទូលនូវព្រះរាជទ្រព្យមានច្រើនចំពោះព្រះអង្គ" គេក៏ក្រោកឡើងថ្វាយបង្គំ ហើយពោលគាថាថា

[៦៦៦] កោសោ ច តុយ្ហំ វិបុលោ
កោដ្ឋាគារញ្ច តុយ្ហំ បរិបូរំ
បថវី ច តុយ្ហំ វិជិតា(១)
រមស្សុ មា បព្វជិ ទេវ ។

ព្រះឃ្លាំងតូចរបស់ព្រះអង្គនៅធំទូលាយ និងព្រះឃ្លាំងព្រះញាតិរបស់ព្រះអង្គក៏បរិបូណ៌ បឋវីមណ្ឌលព្រះអង្គក៏ទ្រង់ឈ្នះហើយ សូមព្រះអង្គទ្រង់ចូរត្រេកអរចុះ ទ្រង់កុំបួសឡើយ

---

១.ម. វិជិតាវិ ។

ព្រះអង្គ ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់ព្រះគាថាថា

[៦៦៧] កោសោ ច មយ្ហំ វិបុលោ
កោដ្ឋាគារញ្ច មយ្ហំ បរិបូរំ
បថវី ច មយ្ហំ វិជិតា
តំ ហិត្វា បព្វជិស្សាមិ ។

ឃ្លាំងតូចរបស់យើងក៏ធំទូលាយ ឃ្លាំងញាតិរបស់យើងក៏បរិបូណ៌ និងបឋវីមណ្ឌលយើងក៏ឈ្នះហើយ តែយើងនឹងលះបង់វត្ថុនោះៗ ចេញបួស ។

កាលមហាសេនាគុត្តអាមាត្យ បានស្តាប់ព្រះតម្រាស់ដូច្នោះ ទើបថយចេញទៅ កុលពន្ធនសេដ្ឋីទើបក្រោកឡើងថ្វាយបង្គំពោលគាថាថា

[៦៦៨] មយ្ហំបិ ធនំ បហូតំ

សង្ខាតុំ នោបិ ទេវ សក្កោមិ

តំ តេ ទទាមិ សព្វម្បិ

រមស្សុ មា បព្វជិ ទេវ ។

បពិត្រមហារាជ ទ្រព្យរបស់ខ្ញុំព្រះអង្គមានច្រើនណាស់ ខ្ញុំព្រះអង្គមិនអាចនឹងរាប់បាន ខ្ញុំព្រះអង្គសូមថ្វាយទ្រព្យទាំងអស់នោះចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ត្រេកអរ ទ្រង់កុំបួសឡើយ ព្រះអង្គ ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះហើយ ទើបត្រាស់គាថាថា

[៦៦៩] ជានាមិ តេ ធនំ បហូតំ

កុលវឌ្ឍន បូជិតោ តយា ចស្មិ

សគ្គញ្ច បត្ថយមានោ

តេនាហំ បព្វជិស្សាមិ ។

ម្នាលកុលវឌ្ឍនសេដ្ឋី យើងដឹងថាទ្រព្យរបស់លោកមាន

ច្រើន និងលោកក៏បូជាយើង តែយើងប្រាថ្នាសួគ៌ ព្រោះដូច្នោះ ទើបយើងត្រូវតែបួស ។

គ្រាកុលពន្ធនសេដ្ឋីបានស្ដាប់ព្រះរាជតម្រាស់ហើយ ក៏ថយចេញទៅ ព្រះមហាសត្វទើបត្រាស់ហៅព្រះអនុជព្រះនាមថា សោ-មទត្តមកប្រាប់ថា "បាសោមទត្ត បងនឿយណាយដូចមាន់ព្រៃត្រូវឃាំងក្នុងទ្រុង សេចក្ដីមិនត្រេកអរក្នុងឃរាវាសគ្របសង្កត់បង បងនឹងបួសក្នុងថ្ងៃនេះឲ្យបាន សូមប្អូនចូរគ្រប់គ្រងរាជ្យសម្បត្តិនេះចុះ" កាលទ្រង់ប្រគល់រាជ្យសម្បត្តិឲ្យហើយ ទើបត្រាស់ព្រះគាថាថា

[៦៧០] ឧក្កណ្ឋិតោស្មិ ពាឡ្ហំ

អរតិ មំ សោមទត្ត អាវិសតិ

ពហុកា ហិ អន្តរាយា

អជ្ជេវាហំ បព្វជិស្សាមិ ។

---

១. កុលវឌ្ឍនសេដ្ឋី និងកុលពន្ធនសេដ្ឋី តាមសេចក្ដីជាមនុស្សតែមួយទេ អ្នកប្រែ ។

បាសោមទត្ត យើងនៅឡើយណាយពេកណាស់ សេចក្តីមិនត្រេកអរ រមែងមកគ្របសង្កត់យើង អន្តរាយមានច្រើន យើងនឹងបួសឲ្យបានក្នុងថ្ងៃនេះឯង ។

សូម្បីសោមទត្តស្តាប់ព្រះរាជតម្រាស់នោះហើយ ក៏មានព្រះបំណងទ្រង់នឹងបួស កាលនឹងសម្តែងព្រះបំណងនោះ ទើបត្រាស់គាថាតទៅថា

[៦៧១] ឥទំ ច តុយ្ហំ រុចិតំ សុតសោម
អជ្ជេវ ទានិ ត្វំ បព្វជ
អហំបិ បព្វជិស្សាមិ
ន ឧស្សហេ តយា វិនា អហំ ឋាតុំ ។

បពិត្រម្ចាស់បងសុតសោម កាលបព្វជ្ជាកិច្ចនេះព្រះអង្គទ្រង់ពេញព្រះទ័យ សូមព្រះអង្គទ្រង់បួសឥឡូវនេះចុះ សូម្បីខ្ញុំព្រះអង្គក៏នឹងបួសក្នុងថ្ងៃនេះដែរ ខ្ញុំព្រះអង្គមិនអាចនៅឆ្ងាយ

ព្រះអង្គបានឡើយ ។

លំដាប់នោះព្រះមហាសត្វទ្រង់ហាមព្រះអនុជ ហើយត្រាស់គាថាថា

[៦៧២] នហិ សក្កា បព្វជិតុំ នគរេ

ន ហិ បច្ចតិ ជនបទេ ច ។

អ្នកនឹងបួសមិនបានទេ ព្រោះថា នរណាៗ ក្នុងព្រះនគរ និងស្រុក និគម ជនបទ នឹងមិននាំគ្នាចម្អិនអាហារស៊ីឡើយ ។

បណ្តាបទទាំងនោះ បទថា ន ហិ បច្ចតិ "មិននាំគ្នាចម្អិននូវអាហារស៊ី" សេចក្តីថា ព្រោះបានជ្រាបបំណងក្នុងការបព្វជ្ជារបស់បងក្នុងវេលានេះ មនុស្សទាំងអស់នោះ នរណាៗ ក្នុងសុទស្សនគរដែលមានអាណាខេត្ត ១២ យោជន៍នេះ និងក្នុងជនបទទាំងអស់នឹងមិននាំគ្នាចម្អិនអាហារ គឺ មិននាំគ្នាបង្កាត់ភ្លើងចម្អិន ប្រសិនបើយើងបួសទាំងពីរនាក់ អ្នកដែននឹងគ្មានទីពឹង ព្រោះហេតុនោះ អ្នក

បួសមិនបាន បងនឹងបួសតែម្នាក់ឯងប៉ុណ្ណោះ ។

មហាជនបានស្ដាប់ព្រះរាជតម្រាស់ហើយ នាំគ្នាក្រាបទៀប ព្រះយុគលបាទរបស់ព្រះមហាសត្វបរិទេវនាការ ទូលថា

[៦៧៣] សុតសោមេ បព្វជិតេ
កថន្នុ ទានិ ករិស្សាម ។

កាលព្រះបាទសុតសោមទ្រង់ផ្នួសហើយ ឥឡូវនេះខ្ញុំព្រះ អង្គទាំងឡាយ នឹងធ្វើយ៉ាងណាហ្ន៎ ព្រះអង្គ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ថា "កុំឡើយអ្នកទាំងឡាយ កុំសោកសៅឡើយ សូម្បីយើងនឹងតាំងនៅបានយូរ ក៏នឹងព្រាត់- ប្រាសចាកអ្នកទាំងឡាយ ព្រោះសង្ខារដែលកើតឡើងហើយឈ្មោះ ថាទៀង មិនមាន" កាលនឹងទ្រង់សម្ដែងធម៌ដល់មហាជន ទើបបាន ត្រាស់ថា

[៦៧៤] ឧបនិយ្យតិទំ មញ្ញេ

បរិត្តំ ឧទកំវ បន្ថរាម្ហិ

ឯវំ សុបរិត្តកេ ជីវិតេ

ន ច បមជ្ជិតុំ កាលោ ។

យើងយល់ថា ជីវិតនេះត្រូវជរានាំចូលទៅ ដូចជាទឹកតិច វេលានេះមិនមែនជាវេលាដែលនឹងប្រមាទឡើយ ។

ឧបនិយ្យតិទំ មញ្ញេ

បរិត្តំ ឧទកំវ បន្ថរាម្ហិ

ឯវំ សុបរិត្តកេ ជីវិតេ

អថ ពាលា បមជ្ជន្តិ ។

យើងយល់ថា ជីវិតនេះត្រូវជរានាំទៅ ដូចជាទឹកតិចតួចក្នុងសំពត់តម្រងក្បុង កាលជីវិតជារបស់តិចតួចយ៉ាងនេះ តែពួកបុគ្គលពាលរមែងនាំគ្នាប្រមាទ ។

តេ វឌ្ឍយន្តិ និរយំ

តិរច្ឆានយោនិញ្ច បិត្តិវិសយញ្ច

តណ្ហាពន្ធនពន្ធា

វឌ្ឍេន្តិ អសុរកាយំ ។

បុគ្គលពាលទាំងនោះដែលគ្រឿងចង គឺ តណ្ហាចងទុក ហើយ រមែងធ្វើនរក កំណើតសត្វតិរច្ឆាន បេតវិស័យ និង អសុរកាយឲ្យចម្រើន ។

បណ្ដាបទទាំងនោះ បទថា ឧបនិយ្យតិទំ មញ្ញេ "យល់ថា ជីវិតនេះត្រូវជរានាំចូលទៅ" សេចក្ដីថា អាណាប្រជារាស្ត្រ យើង យល់ថា "ជីវិតនេះត្រូវជរានាំចូលទៅ" ក្នុងសត្វទាំងឡាយពួកដទៃ ជីវិតនេះដោយសេចក្ដីក៏ត្រូវជរាបៀតបៀន ដោយន័យត្រូវជរានាំ ទៅ តែក្នុងទីនេះ ដោយន័យត្រូវជរាឃុំគ្រង ព្រោះដូច្នោះ ទឹកតិច តួចដែលគេដាក់ចុះក្នុងសំពត់តម្រងក្បួងរបស់ជាងជ្រលក់ រមែង ធាប់ស្ងួតដោយរហ័សយ៉ាងណា សូម្បីជីវិតក៏ដូច្នោះដូចគ្នា កាល

បើជីវិតមានតិចដូច្នេះ ការដែលប្រមាទក្នុងបុញ្ញកិរិយារបស់សត្វទាំងឡាយអ្នកប្រកាន់នូវអាយុសង្ខារដ៏តិចតួចនោះហើយ មិនគួរធ្វើសេចក្តីប្រមាទ ស្រវឹងឡើយ ព្រោះហេតុនោះ ក្នុងសេចក្តីនេះទើបមានការអធិប្បាយត្រឹមប៉ុណ្ណោះ ។

បទថា អថ ពាលា បមជ្ជន្តិ “តែពួកបុគ្គលពាលរមែងនាំគ្នាប្រមាទ” សេចក្តីថា បុគ្គលពាលទាំងឡាយដូចជាមិនចាស់មិនស្លាប់ លិចហើយក្នុងភក់ គឺ កាមគុណ ស្រវឹងប្រមាទហើយ ដូចជ្រូកលិចនៅក្នុងភក់ គឺ លាមកដូច្នោះ ។ បទថា អសុរកាយំ “អសុរកាយ” សេចក្តីថា រមែងទៅកើតបន្ថែមក្នុងកំណើតអសុរកាយឈ្មោះ កាលកញ្ជិកៈ ។

ព្រះមហាសត្វ ទ្រង់សម្តែងធម៌ដល់មហាជនយ៉ាងនេះហើយ ស្តេចឡើងកាន់បុប្ផកប្រាសាទ ប្រថាប់ឈរត្រង់ជាន់ទី ៧ ទ្រង់យកព្រះខាន់កាត់ព្រះមោលី ហើយត្រាស់ថា “យើងមិនមែនជាអ្វីនឹង

អ្នកទាំងឡាយឡើយ អ្នកទាំងឡាយចូរកេព្រះរាជារបស់ខ្លួនចុះ” ហើយបោះព្រះមោលី ទាំងគ្រឿងប្រដាប់ទៅក្នុងចន្លោះនៃមហាជន លួងធូលីដ៏ច្រើនក៏ហុយឡើងក្នុងទីនោះ ។ មហាជនក៏ត្រឡប់មកឈរមើល បានឃើញលួងធូលីនោះអ្នកខ្លះក៏យំរៀបរាប់ថា “ព្រះមោលីទាំងគ្រឿងប្រដាប់ដែលព្រះរាជាទ្រង់កាត់ហើយបោះមកក្នុងចន្លោះនៃមហាជន ដូច្នោះក្រសែនៃលួងធូលី ទើបហុយឡើងក្នុងទីជិតប្រាសាទ” ហើយពោលគាថាថា

[៦៧៥] ឧហញ្ញតេ រជគ្គំ អវិទូរេ

បុប្ផកម្ហិ ច បាសាទេ

មញ្ញេ នោ កេសា ឆិន្នា

យសស្សិនោ ធម្មរាជស្ស ។

គំនរនៃធូលីហុយអណ្តែតឡើងមិនឆ្ងាយអំពីបុប្ផកប្រាសាទ ប្រហែលព្រះរាជាដ៏ទ្រង់យសរបស់ពួកយើង ទ្រង់នឹងកាត់ព្រះ

កេសាហើយ ។

បណ្ដាបទទាំងនោះ បទថា **ឧហញ្ញតេ "ហុយឡើង"** បានដល់ ហុយឡើង ។ បទថា **វជ្ជំ "គំនរធូលី"** បានដល់ គំនរធូលី ។ បទថា **អវិទូរេ "មិនឆ្ងាយ"** សេចក្ដីថា (គំនរធូលីកើតឡើង) មិននៅឆ្ងាយអំពីទីដែលពួកយើងឈរនេះឡើយ ។ បទថា **បុប្ផកម្ហិ "បុប្ផ-កប្រាសាទ"** សេចក្ដីថា ជិតៗ បុប្ផកប្រាសាទ ។ បទថា **មញ្ញេ នោ "ប្រហែល... របស់ពួកយើង"** សេចក្ដីថា ពួកយើងយល់ថា "ព្រះធម្មរាជារបស់ពួកយើងនឹងកាត់ព្រះកេសាចេញហើយ" ។

ចំណែកព្រះមហាសត្វ ទ្រង់ប្រើមហាតួ៌កឲ្យទៅនាំបរិក្ខាររបស់បព្វជិតមក ប្រោសឲ្យនាយភូសាមាលាដាក់ព្រះកេសា និងព្រះមស្សុ ហើយគ្រឿងរាជអលង្ការទុកលើព្រះកម្រាល កាត់ដាយព្រះភូសាក្រហម ទ្រង់ប្រដាប់កាសាវព័ស្ត្រ ទ្រង់ស្ពាយបាត្រដីត្រង់ព្រះអង្សាខាងឆ្វេង ចាប់ធារព្រះទណ្ឌ (ឈើប្រត់) ស្ដេចចង្រ្កមទៅមកត្រង់

ផ្ទៃព្រះរោង ហើយស្ដេចចុះចាកប្រាសាទ ទ្រង់យាងទៅក្នុងលំផ្នែក ផ្លូវ តែមិនមាននរណាស្គាល់ព្រះអង្គដែលស្ដេចយាងទៅឡើយ ។ លំដាប់នោះ ខត្តិយកញ្ញា ៧០០ នាក់របស់ព្រះមហាសត្វនោះ នាំគ្នាឡើងទៅកាន់ប្រាសាទ មិនឃើញព្រះមហាសត្វ ឃើញតែគ្រឿងអាភរណៈក៏ត្រឡប់ចុះវិញ ហើយផ្ដោះទៅកាន់សម្នាក់របស់ស្រីស្នំ ១៦.០០០ នាក់ដ៏សេស ស្ដាប់ដំណឹងថា ព្រះសុតសោមមទិសៈអង្គបិយរាជស្វាមីពួកនាងទ្រង់បួសហើយ ខ្លះក៏បរិទេវនាការដោយសំឡេងខ្លាំងៗ ហើយចេញទៅខាងក្រៅ ។ ខណៈនោះ មហាជនបានជ្រាបថា ព្រះរាជាទ្រង់បួសហើយ អ្នកព្រះនគរទាំងអស់ក៏ជួបប្រជុំគ្នាត្រង់ទ្វារព្រះរាជវាំងថា "ដំណឹងថា ព្រះរាជារបស់ពួកយើងទ្រង់បួសហើយ" មហាជនពួកខ្លះក៏នាំគ្នាទៅកាន់ស្ថានទីដែលធ្លាប់ស្ដេចប្រថាប់ ដូចជាទីប្រាសាទជាដើម ដោយគិតថា ព្រះរាជាព្រះអង្គស្ដេចគង់ក្នុងទីនេះ និងស្ដេចប្រថាប់ត្រង់ទីនេះ តែមិនបានជួប

ព្រះរាជា ទើបនាំគ្នាត្រាច់បរិទេវនាការដោយគាថាទាំងនេះថា

[៦៧៦] អយមស្ស បាសាទោ
សោវណ្ណបុប្ផមាល្យវីតិកិណ្ណោ
យ[១]ហិមនុវិចរិ រាជា
បរិកិណ្ណោ ឥត្ថាគារេហិ ។

ព្រះរាជាទ្រង់ហែហមដោយស្រីស្នំ ស្តេចទៅកាន់ប្រាសាទណា នេះគឺប្រាសាទនោះរបស់ព្រះអង្គដែលដេរដាសទៅដោយសុវណ្ណបុប្ផាមាល័យ ។

អយមស្ស បាសាទោ
សោវណ្ណបុប្ផមាល្យវីតិកិណ្ណោ
យហិមនុវិចរិ រាជា
បរិកិណ្ណោ ញាតិសង្ឃេន ។

---

១.ឱ. យម្ហិ ។

ព្រះរាជាទ្រង់ហែហមដោយពួកព្រះញាតិ ស្តេចទៅកាន់ប្រាសាទណា នេះគឺប្រាសាទនោះរបស់ព្រះអង្គដែលដេរដាសទៅដោយសុវណ្ណបុប្ផាមាល័យ ។

ឥទមស្ស  កូដាគារំ
សោវណ្ណបុប្ផមាល្យវីតិកិណ្ណំ
យហិមនុវិចរិ  រាជា
បរិកិណ្ណោ ឥត្ថាគារេហិ ។

ព្រះរាជាទ្រង់ហែហមទៅដោយពួកស្រីស្នំ ស្តេចទៅកាន់កូដាគារណា នេះគឺកូដាគារនោះរបស់ព្រះអង្គដែលដេរដាសទៅដោយសុវណ្ណបុប្ផាមាល័យ ។

ឥទមស្ស  កូដាគារំ
សោវណ្ណបុប្ផមាល្យវីតិកិណ្ណំ
យហិមនុវិចរិ  រាជា

បរិកិណ្ណា ញាតិសង្ឃេន ។

ព្រះរាជាទ្រង់ហែហមដោយពួកព្រះញាតិ ស្តេចទៅកាន់កូដាគារណា នេះគឺកូដាគារនោះរបស់ព្រះអង្គដែលដេរដាសទៅដោយសុវណ្ណបុប្ផាមាល័យ ។

អយមស្ស អសោកវនិកា

សុបុប្ផិតា សព្វកាលិកា រម្មា

យហិមនុវិចរិ រាជា

បរិកិណ្ណា ឥត្ថាគារេហិ ។

ព្រះរាជាទ្រង់ហែហមដោយពួកស្រីស្នំ ស្តេចទៅកាន់សួនអសោកវ័នណា នេះគឺសួនអសោកវ័ននោះ របស់ព្រះអង្គដែលមានផ្កាឈើរីកព្រោងព្រាត គួរមនោរម្យអស់កាលទាំងពួង ។

អយមស្ស អសោកវនិកា

សុបុប្ផិតា សព្វកាលិកា រម្មា

យហិមនុវិចរិ រាជា

បរិកិណ្ណោ ញាតិសង្ឃេន ។

ព្រះរាជាទ្រង់ហែហមដោយពួកព្រះញាតិ ស្តេចទៅកាន់សួនអសោកវ័នណា នេះគឺ សួនអសោកវ័ននោះរបស់ព្រះអង្គដែលមានផ្កាឈើរីកព្រោងព្រាត គួរមនោរម្យអស់កាលទាំងពួង ។

ឥទមស្ស ឧយ្យានំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

យហិមនុវិចរិ រាជា

បរិកិណ្ណោ ឥត្ថាគារេហិ ។

ព្រះរាជាទ្រង់ហែហមដោយស្រីស្នំ ស្តេចទៅកាន់ព្រះរាជឧទ្យានណា នេះគឺព្រះឧទ្យាននោះរបស់ព្រះអង្គ ដែលមានផ្កាឈើរីកស្គុសស្គាយ គួរមនោរម្យអស់កាលទាំងពួង ។

ឥទមស្ស ឧយ្យានំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

យហិមនុវិចរិ រាជា

បរិកិណ្ណោ ញាតិសង្ឃេន ។

ព្រះរាជាទ្រង់ហែហមដោយពួកព្រះញាតិ ស្តេចទៅកាន់ព្រះរាជឧទ្យានណា នេះគឺព្រះឧទ្យាននោះរបស់ព្រះអង្គ ដែលមានផ្កាឈើរីកស្គុសស្គាយ គួររីករាយអស់កាលទាំងពួង ។

ឥទមស្ស កណិការវនំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

យហិមនុវិចរិ រាជា

បរិកិណ្ណោ ឥត្ថាគារេហិ ។

ព្រះរាជាទ្រង់ហែហមដោយពួកស្រីស្នំ ស្តេចទៅកាន់សួនកណិការណា នេះគឺសួនកណិការនោះរបស់ព្រះអង្គ ដែលមាន

ផ្ការីកស្គុសស្គាយ គួររីករាយអស់កាលទាំងពួង ។

ឥទមស្ស កណិការវនំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

យហិមនុវិចរិ រាជា

បរិកិណ្ណោ ញាតិសង្ឃេន ។

ព្រះរាជាទ្រង់ហែហមដោយពួកព្រះញាតិ ស្តេចទៅកាន់សួនកណិការណា នេះគឺសួនកណិការនោះរបស់ព្រះអង្គ ដែលមានផ្ការីកស្គុសស្គាយ គួរមនោរម្យអស់កាលទាំងពួង ។

ឥទមស្ស បាដលិវនំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

យហិមនុវិចរិ រាជា

បរិកិណ្ណោ ឥត្ថាគារេហិ ។

ព្រះរាជាទ្រង់ហែហមដោយពួកស្រីស្នំ ស្តេចទៅកាន់សួន

បាដលិវ័នណា នេះគឺសួនបាដលិវ័ននោះរបស់ព្រះអង្គ ដែលមានផ្ការីកស្គុសស្គាយ គួរមនោរម្យអស់កាលទាំងពួង ។

ឥទមស្ស បាដលិវនំ
សុបុប្ផិតំ សព្វកាលិកំ រម្មំ
យហិមនុវិចរិ រាជា
បរិកិណ្ណោ ញាតិសង្ឃេន ។

ព្រះរាជាទ្រង់ហែហមដោយព្រះញាតិ ស្តេចទៅកាន់សួនបាដលិវ័នណា នេះគឺសួនបាដលិវ័ននោះ របស់ព្រះអង្គដែលមានផ្កាអរីកស្គុសស្គាយ គួររីករាយអស់កាលទាំងពួង ។

ឥទមស្ស អម្ពវនំ
សុបុប្ផិតំ សព្វកាលិកំ រម្មំ
យហិមនុវិចរិ រាជា
បរិកិណ្ណោ ឥត្ថាគារេហិ ។

ព្រះរាជាទ្រង់ហែហមដោយពួកស្រីស្នំ ស្តេចទៅកាន់សួនអម្ពវ័នណា នេះគឺសួនអម្ពវ័ននោះរបស់ព្រះអង្គ ដែលមានផ្កាវីកស្គុសស្គាយ គួរវីករាយអស់កាលទាំងពួង ។

ឥទមស្ស អម្ពវនំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

យហិមនុវិចរិ រាជា

បរិកិណ្ណោ ញាតិសង្ឃេន ។

ព្រះរាជាទ្រង់ហែហមទៅដោយពួកព្រះញាតិ ស្តេចទៅកាន់សួនអម្ពវ័នណា នេះគឺសួនអម្ពវ័ននោះរបស់ព្រះអង្គ ដែលមានផ្កាវីកស្គុសស្គាយ គួរវីករាយអស់កាលទាំងពួង ។

អយមស្ស បោក្ខរណី

សញ្ឆន្នា អណ្ឌជេហិ វីតិកិណ្ណា

យហិមនុវិចរិ រាជា

បរិកិណ្ណា ឥត្ថាគារេហិ ។

ព្រះរាជាទ្រង់ហែហមដោយស្រីស្នំ ស្តេចទៅកាន់ស្រះបោក្ខរណីណា នេះគឺស្រះបោក្ខរណីនោះរបស់ព្រះអង្គ ដែលដេរដាសទៅដោយបុប្ផជាតិគ្រប់ប្រភេទ ដេរដាសទៅដោយហ្វូងវិគហជាតិ ។

អយមស្ស បោក្ខរណី

សញ្ឆន្នា អណ្ឌជេហិ វីតិកិណ្ណា

យហិមនុវិចរិ រាជា

បរិកិណ្ណោ ញាតិសង្ឃេន ។

ព្រះរាជាទ្រង់ហែហមដោយព្រះញាតិ ស្តេចទៅកាន់ស្រះបោក្ខរណីណា នេះគឺស្រះបោក្ខរណីនោះរបស់ព្រះអង្គ ដែលដេរដាសទៅដោយបុប្ផជាតិគ្រប់ប្រភេទ ដេរដាសទៅដោយហ្វូងវិគហជាតិ ។

បណ្ដាបទទាំងនោះ បទថា **វីតិកិណ្ណា** *“ដេរដាស”* សេចក្ដីថា ដេរដាសទៅដោយសុវណ្ណបុប្ផា និងនានាមាល័យ ។ បទថា **បរិកិណ្ណា** *“ចោមរោម”* ហែហមជារង្វង់ ។ បទថា **ឥត្ថាគារេហិ** *“ស្រីស្នំ”* សេចក្ដីថា ស្រីទាំងឡាយរាប់អំពីទាសីទៅ ឈ្មោះថា ឥត្ថាគារ គឺ ស្រីស្នំរបស់អាមាត្យទាំងឡាយ ក៏ឈ្មោះថា ញាតិទាំងអស់ ក្នុងបទថា **ញាតិសង្ឃេន** *“ព្រះញាតិ”* នេះ ។ បទថា **កូដាគារំ** *“កូដាគារ”* បានដល់ ទីផ្ចុំ និងបន្ទប់កូដាគារដែលវិចិត្រទៅដោយរតនៈទាំងប្រាំពីរ ។ បទថា **អសោកវនិកា** *“អសោកវ័ន”* បានដល់ ភូមិភាគក្នុងអសោកវ័ន ។ បទថា **សព្វកាលិកា** *“រហូតកាលទាំងពួង”* សេចក្ដីថា ធន់ដល់ការប្រើប្រាស់គ្រប់កាលទាំងពួងជានិច្ច ។

បទថា **ឧយ្យានំ** *“ឧទ្យាន”* បានដល់ ព្រះរាជឧទ្យានដូចគ្នានឹងឧទ្យានចិត្តលតាវ័នក្នុងនន្ទនវ័ន ។ បទថា **សព្វកាលិកំ** *“រហូតអស់កាលទាំងពួង”* សេចក្ដីថា ដេរដាសដោយឈើផ្កា ឈើផ្លែ ដែល

កើតឡើងក្នុងរដូវកាលសូម្បីទាំងប្រាំមួយ ។ បទថា **សព្វកាលិកំ** “**រហូតកាលទាំងពួង**” ក្នុងកណិការវនជាដើម មានសេចក្តីថា ក៏មានផ្ការីកអស់កាលទាំងពួងដូចគ្នា ។ បទថា **សព្ពន្នា** “**ដេរដាស**” សេចក្តីថា ដេរដាសយ៉ាងល្អដោយផ្កាច្រើនទៀង ដែលកើតទាំងក្នុងទឹក និងលើគោកមានច្រើនយ៉ាង ។ បទថា **អណ្ណជេហិ វិតិកិណ្ណា** “**ដេរដាសទៅដោយហ្វូងវិគហៈ**” សេចក្តីថា សម្បូរទៅដោយហ្វូងបក្សី ។

មហាជនបរិទេវនាការក្នុងទីនោះៗ យ៉ាងនេះហើយ ត្រឡប់មកកាន់ព្រះលានហ្លួងទៀត ពោលគាថាថា

[៦៧៧] **រាជា ខោ[១] បព្វជិតោ សុតសោមោ**

**រជ្ជំ ឥមំ បហន្ត្វាន**

**កាសាយវត្ថវសនោ**

១.ម. រាជា វោ ខោ ។

នាគោវ ឯកកោ ចរតិ ។

ព្រះបាទសុតសោមទ្រង់បានលះបង់រាជសម្បត្តិនេះ ហើយស្តេចទ្រង់ផ្នួស ទ្រទ្រង់សំពត់កាសាវពស្ត្រ ត្រាច់ទៅមួយអង្គឯង ដូចដំរីដ៏ប្រសើរដូច្នោះ ។

ដូច្នេះហើយ ខ្ញុះក៏លះបង់សម្បត្តិក្នុងផ្ទះរបស់ខ្លួន ដឹកដៃបុត្តធីតាចេញទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះឯង ។ ព្រះរាជមាតា រាជបិតា ព្រះជាយា ព្រះឱរសព្រះធីតា និងស្រីរបាំ ១៦.០០០ ក៏ទ្រង់បដិបត្តិដូច្នោះដូចគ្នា ។ ព្រះនគរទាំងអស់មើលទៅឃើញដូចជាទទេ ។ ចំណែកអ្នកជនបទ ក៏បានតាមទៅខាងក្រោយជនទាំងនោះ ព្រះពោធិសត្វទ្រង់នាំបរិស័ទប្រមាណ ១២ យោជន៍ ស្តេចឆ្ពោះមុខទៅកាន់ព្រៃហិមពាន្ត ។

លំដាប់នោះ ស្តេចសក្កទេវរាជទ្រង់ជ្រាបថា ព្រះពោធិសត្វស្តេចចេញអភិនេស្ក្រមណ៍ ទើបត្រាស់ហៅវិស្សុកម្មទេវបុត្តមកត្រាស់

ថា "ម្នាលវិស្សុកម្មទេវបុត្ត ព្រះបាទសុតសោមមហារាជស្តេចចេញ អភិនេស្រ្កមណ៍ គួរនឹងបានទីប្រថាប់ ទាំងសមាគមក៏ធំកន្លង អ្នកចូរទៅនិម្មិតអាស្រមបទទទឹង ៣ យោជន៍ បណ្តោយ ៥ យោជន៍ ត្រង់មាត់ទន្លេគង្គាក្នុងហិមវន្តប្បទេសចុះ" ។ វិស្សុកម្មទេវបុត្តក៏បណ្តាលតាមទេវបញ្ជាគ្រប់ប្រការ ចាត់ចែងបព្វជិតបរិក្ខារទុកក្នុងអាស្រមបទនោះ ហើយនិម្មិតផ្លូវដើរបានតែមនុស្សទុកស្រេចហើយ ក៏ត្រឡប់ទៅកាន់ទេវលោកវិញ ព្រះមហាសត្វស្តេចទៅតាមផ្លូវនោះ ស្តេចចូលកាន់អាស្រមបទនោះ ព្រះអង្គទ្រង់បួសខ្លួនឯងមុន ហើយឲ្យប្រជាជនដ៏សេសបួសជាខាងក្រោយ ។ ក្នុងវេលាតមក ជនទាំងឡាយបួសច្រើនឡើងៗ ស្ថានទីក៏ធំរហូតដល់ ៣០ យោជន៍ក៏ពេញបរិបូណ៌ ។ ការកំណត់ដែលស្តេចសក្កទេវរាជប្រើឲ្យវិស្សុកម្មទេ-វបុត្តនិម្មិតអាស្រមក្តី កំណត់ទីដែលប្រជាជនបួសដ៏ច្រើនក្តី កំណត់ទីដែលព្រះពោធិសត្វចាត់ចែងជាអាស្រមបទក្តី គប្បីជ្រាបតាមន័យ

ដែលមកហើយក្នុងហត្ថិបាលជាតកនោះឯង ។ មិច្ឆាវិតក្កៈមានកា-មវិតក្កៈជាដើមកើតឡើងដល់អ្នកណាៗ ព្រះមហាសត្វស្តេចក៏ចូលទៅរកបុគ្គលនោះៗ ត្រង់ទីនោះតាមផ្លូវអាកាស ប្រថាប់ពត់ភ្នែនក្នុងអាកាស កាលនឹងទ្រង់ឲ្យឱវាទ ទើបត្រាស់ ២ ព្រះគាថាថា

[៦៧៨] មាស្សុ បុព្វេ រតិកីឡិតានិ
ហសិតានិ អនុស្សរិត្ថ
មា វោ កាមា ហនឹសុ
សុរម្មញ្ហិ សុទស្សនំ នគរំ ។

អ្នកទាំងឡាយ កុំរលឹកដល់សេចក្តីត្រេកអរក្នុងការលេងនិងការរីករាយក្នុងកាលមុនឡើយ កាមទាំងឡាយកុំទម្លាយអ្នកទាំងឡាយបានឡើយ ពិតហើយ សុទស្សនទនគរគួររីករាយក្រៃលែងណាស់ ។

មេត្តចិត្តញ្ច ភាវេថ

អប្បមាណំ ទិវា ច រត្តោ ច

អថ គច្ឆិត្ថ ទេវបុរំ

អាវាសំ បុញ្ញកម្មិនន្តិ ។

អ្នកទាំងឡាយចូរចម្រើនមេត្តាចិត្ត ដែលរកប្រមាណមិនបាន ទាំងថ្ងៃទាំងយប់ចុះ កាលបើដូច្នេះ អ្នកទាំងឡាយនឹងបានទៅកាន់ទេវបុរីដែលជាទីនៅរបស់លោកអ្នកមានបុណ្យ ។

បណ្តាបទទាំងនោះ បទថា **រតិកីឡិតានិ** “ត្រេកអរក្នុងការលេង” សេចក្តីថា (អ្នកទាំងឡាយកុំរលឹកដល់) សេចក្តីត្រេកអរក្នុងកាម និងការលេងដែលប្រព្រឹត្តទៅដោយអំណាចនៃការលេងផ្លូវកាយ វាចា និងចិត្ត ។ បទថា **មា វោ កាមា ហនឹសុ** “កាមទាំងឡាយកុំទម្លាយអ្នកទាំងឡាយបានឡើយ” ន័យថា វត្ថុកាមនិងកិលេសកាមកុំបៀតបៀនពួកអ្នក ។ បទថា **សុរម្មញ្ហិ** “រីករាយ” សេចក្តីថា សុទស្សនទនគរគួររីករាយត្រេកអរ អ្នកទាំងឡាយកុំរលឹកដល់សុទស្សនទនគរនោះ ។ ក៏ព្រះពោធិសត្វនោះត្រាស់ប្រាប់

ដល់ព្រហ្មវិហារ ៤ ។ បទថា **អប្បមាណំ** **"មិនមានប្រមាណ"** បានដល់ មេត្តាព្រហ្មវិហារដែលមានសត្វរកប្រមាណមិនបានជាអា-រម្មណ៍ ។ បទថា **គច្ឆិត្ថ** **"នឹងបានទៅ"** គឺ នឹងបានទៅហើយ ។ បទថា **ទេវបុរំ** **"ទេវបុរី"** បានដល់ ព្រហ្មលោក ។

សូម្បីពួកឥសីទាំងនោះ តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វហើយ ក៏បានចូលដល់ព្រហ្មលោកដោយប្រការដូច្នេះ ។ រឿងរ៉ាវទាំងអស់គួរពោលដោយន័យដែលមកហើយ ក្នុងហត្ថិបាលជាតកនោះឯង ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងជាតិនេះទេ សូម្បីក្នុងជាតិមុន តថាគតក៏ចេញមហាភិនេស្ក្រមណ៍ដូចគ្នា" ទើបទ្រង់ប្រជុំជាតកថា "ព្រះមាតាព្រះបិតាក្នុងកាលនោះ បានមកជាស-ក្យមហារាជត្រកូលក្នុងគ្រានេះ ព្រះនាងចន្ទាទេវីក្នុងគ្រានោះ បានមកជារាហុលមាតា, ជេដ្ឋឱរសក្នុងកាលនោះ បានមកជាព្រះសារីបុត្ត,

កនិដ្ឋឱរសក្នុងគ្រានោះ បានមកជាព្រះរាហុល, ព្រះភីលៀងក្នុងគ្រានោះ បានមកជានាងខុជ្ជុត្តរា, កុលពន្ធសេដ្ឋីក្នុងគ្រានោះ បានមកជាព្រះមហាកស្សបៈ, មហាសេនាគុត្តៈក្នុងគ្រានោះ បានមកជាព្រះមហាមោគ្គល្លាន, សោមទត្តកុមារក្នុងគ្រានោះ បានមកជាព្រះអានន្ទ, បរិស័ទដ៏សេសក្នុងគ្រានោះ បានមកជាពុទ្ធបរិស័ទក្នុងគ្រានេះ ឯព្រះបាទសុតសោមក្នុងគ្រានោះ គឺ **តថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធ** នេះឯង ។

ចប់អដ្ឋកថា ចុល្លសុតសោមជាតកទី ៥

## ចប់អដ្ឋកថាចត្តាឡីសនិបាត
## ដែលប្រដាប់ដោយជាតក ៥ រឿង

១. តេសកុណជាតក
២. សរភង្គជាតក
៣. អលម្ពុសាជាតក
៤. សង្ខបាលជាតក
៥. ចុល្លសុតសោមជាតក

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

-លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ......... $ 2.000 USA

-ឧបាសក សោម រតនៈ ព្រមទាំងភរិយា បុត្ត និងចៅ ...... $ 500 USA

-ឧបាសក តាំង សុជល ឧបាសិកា ឡុង កេន

ព្រមទាំងបុត្ត និងចៅ ......... $ 200 USA

-កញ្ញា តាំង សុមាវតី ......... $ 50 USA

-ចៅស្រី ប៉ាន់ ឧត្តរា<br>
ប៉ាន់ ប៉ានីឡា<br>
ប៉ាន់ សាហ៊ីយ៉ា ......... $ 50 USA


នត្ថិ សន្តិ បរំ សុខំ
ព្រះរាជាណាចក្រកម្ពុជា